# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍
# វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ
# ២០២៤-២០២៨

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ខែមករា ឆ្នាំ២០២៤

# មាតិកា


**អារម្ភកថា** ........................................................................................ v

**អក្សរបំព្រួញ** ...................................................................................... vii

**ជំពូកទី ១ ÷ សេចក្ដីផ្ដើម**........................................................................ ១

**១.១- ទស្សនាទាន និងសាវតារនៃការរៀបចំផែនការយុទ្ធសាស្ត្រ**................................ ២

**១.២- ការរៀបចំ និងរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រ** ......................................... ៣

**១.៣- ចក្ខុវិស័យ និងបេសកកម្ម** ........................................................................ ៤

**១.៤- គោលបំណង** ........................................................................................ ៥

**១.៥- គោលដៅ** .............................................................................................. ៦

**ជំពូកទី ២ ÷ បរិការណ៍ និងភាពចាំបាច់នៃការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**........................................................ ៩

**២.១- ស្ថានភាពប្រជាសាស្ត្រ និងទីផ្សារការងារកម្ពុជា** ............................................. ៩

២.១.១. ស្ថានភាពប្រជាសាស្ត្រ និងការផ្គត់ផ្គង់កម្លាំងពលកម្ម.................................... ៩

ក. ស្ថានភាពប្រជាសាស្ត្រ.................................................................... ៩

ខ. កម្រិតនៃការទទួលបានការអប់រំរបស់កម្លាំងពលកម្ម.............................. ១៤

២.១.២. ស្ថានភាពសេដ្ឋកិច្ច និងតម្រូវការកម្លាំងពលកម្មបច្ចុប្បន្ន និងអនាគត..............១៥

ក. ស្ថានភាពសេដ្ឋកិច្ច និងតម្រូវការកម្លាំងពលកម្មបច្ចុប្បន្ន........................ ១៥

ខ. ការព្យាករនិន្នាការតម្រូវការទីផ្សារការងារនាពេលអនាគត.........................១៩

២.១.៣. បញ្ហាភាពមិនបន្ស៊ីគ្នានៃជំនាញ និងភាពមានការងារមិនពេញលេញ...............២២

២.១.៤. ស្ថានភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគ្រាស គ្រឹះស្ថានធុន តូច និងមធ្យម..... ២៥

២.១.៥. ស្ថានភាពប្រជាសាស្ត្រ និងនិន្នាការទេសន្តរប្រវេសន៍ការងារនៅក្នុងតំបន់......... ២៦

**២.២-និន្នាការពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ** ..... ២៧

២.២.១. និន្នាការនយោបាយ និងសេដ្ឋកិច្ចសកល..................................................២៧

២.២.២. និន្នាការសេដ្ឋកិច្ច និងតម្រូវការទីផ្សារការងារ ........................................... ២៨

២.២.៣. និន្នាការប្រជាសាស្ត្រ និងការផ្គត់ផ្គង់កម្លាំងពលកម្ម.................................... ២៩

២.២.៤. ការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងនិន្នាការនៃការផ្សារភ្ជាប់ គោលនយោបាយពាណិជ្ជកម្មទៅនឹងការលើកកម្ពស់លក្ខខណ្ឌការងារ............ ៣០

២.២.៥. បច្ចេកវិទ្យាឌីជីថល និងការកើនឡើងនៃប្រភេទការងារទម្រង់ថ្មី.................... ៣១

២.២.៦. និន្នាការសេដ្ឋកិច្ច និងការងារបៃតង ..................................................... ៣១
**២.៣-សមិទ្ធផលនៃការអនុវត្ត ផ.យ.អ.ក.ប ២០១៩-២០២៣**........................... ៣២
២.៣.១. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ......... ៣២
២.៣.២. ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ.............. ៣៦
២.៣.៣. ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុង និងក្រៅប្រទេស .................... ៣៩
២.៣.៤. ការអភិវឌ្ឍរបបសន្តិសុខសង្គម.............................................................. ៤១
២.៣.៥. ការពង្រឹងសេវាគាំទ្រទូទៅ..................................................................... ៤៣
**២.៤-បញ្ហាប្រឈម**............................................................................... ៤៥
**ជំពូកទី ៣ ÷ ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្ដុះបណ្ដាល វិជ្ជាជីវៈ ២០២៤-២០២៨** ............................................................ ៥០
**៣.១-ការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម**........................ ៥១
៣.១.១. ការពង្រឹងការអនុវត្តគោលនយោបាយ និងសិក្សាស្រាវជ្រាវ ដោយឆ្លើយតបនឹង បដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង...... ៥២
៣.១.២. ការពង្រឹងប្រសិទ្ធភាពនៃយន្តការផ្ដល់សេវាស្វែងរកការងារ និងវេទិកាការងារ..... ៥៦
៣.១.៣. ការពង្រឹង និងពង្រីកសេវាប្រឹក្សាយោបល់ និងមគ្គទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ. ៦១
៣.១.៤. ការពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេសតាមរយៈ បច្ចេកវិទ្យាឌីជីថល............................................................................... ៦៤
៣.១.៥. ការពង្រឹងការអនុវត្តគោលនយោបាយជាតិស្ដីពីមុខរបរ និងការងារ និងកម្មវិធី ជំរុញការលើកកម្ពស់ផលិតភាពការងារ ..................................................... ៦៩
**៣.២-ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យឆ្លើយតប នឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង**.. ៧៤
៣.២.១. ការពង្រឹងប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំបណ្ដុះបណ្ដាល បច្ចេកទេស និងវិជ្ជាជីវៈ តាមបច្ចេកវិទ្យាឌីជីថល...................................... ៧៥
៣.២.២. ការពង្រឹងគុណភាពអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយរួមបញ្ចូល នូវជំនាញសម្បទាការងារ, ជំនាញសម្បទាបត់បែន, ជំនាញបច្ចេកវិទ្យាឌីជីថល និងជំនាញបៃតង ......................................................................................... ៨០
៣.២.៣. ការពង្រឹង និងពង្រីកការបណ្ដុះបណ្ដាលកម្លាំងពលកម្មជំនាញ ដើម្បីគាំទ្រ គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ....................................... ៨៥

៣.២.៤. ការពង្រឹងភាពជាដៃគូរវាងរដ្ឋ ឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីធានានិរន្តរភាព
នៃកម្មវិធីបណ្តុះបណ្តាល.......................................................................... ៩០
៣.២.៥. ការជំរុញការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍........................... ៩៤
**៣.៣-ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាពនិងសុខភាពការងារ និងសុខដុមនីយកម្ម
នៃទំនាក់ទំនងវិជ្ជាជីវៈ ស្របតាមការវិវត្ត នៃពិភពការងារ**........................ ៩៩
៣.៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច និងយន្តការអធិការកិច្ចការងារ ដើម្បីលើក
កម្ពស់វប្បធម៌អនុលោមភាពនៃច្បាប់ពាក់ព័ន្ធវិស័យការងារ........................១០០
៣.៣.២. ការលើកកម្ពស់លក្ខខណ្ឌស្តីពីសុវត្ថិភាពនិងសុខភាពការងារ...................... ១០៥
៣.៣.៣. ការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ........... ១១០
៣.៣.៤. ការពង្រឹងសមត្ថភាពស្ថាប័ន និងតួអង្គពាក់ព័ន្ធក្នុងការពិភាក្សា កំណត់ប្រាក់ឈ្នួល
អប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត ............................... ១១៥
៣.៣.៥. ការលើកកម្ពស់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ដើម្បីប្រែក្លាយសហគ្រាស
មួយជាសហគមន៍សុខសាន្តមួយ .......................................................១១៩
**៣.៤-ការពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព
គុណភាព និងប្រសិទ្ធភាព**.............................................................. ១២៤
៣.៤.១. ការពង្រឹង និងពង្រីកទីផ្សារការងារនៅបរទេសដែលមានលក្ខខណ្ឌការងារល្អ..១២៥
៣.៤.២. ការពង្រឹងយន្តការ តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការជ្រើសរើស
ការបណ្តុះបណ្តាល និងការបញ្ជូនពលករទៅធ្វើការនៅបរទេស ................. ១២៩
៣.៤.៣. ការពង្រឹងយន្តការគ្រប់គ្រង និងសេវាគាំពារនៅតាមប្រទេសទទួលដល់ពលករ
ទេសន្តរប្រវេសន៍កម្ពុជា..................................................................១៣៤
៣.៤.៤. ការពង្រឹងយន្តការនៃការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍កម្ពុជា
ដែលធ្វើមាតុភូមិនិវត្តន៍ ...................................................................១៣៨
៣.៤.៥. ការពង្រឹងការគ្រប់គ្រងហត្ថពលកម្មបរទេសនៅកម្ពុជា............................១៤៣
**៣.៥- ការអភិវឌ្ឍរបបសន្តិសុខសង្គមស្របតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច** ១៤៧
៣.៥.១. ការពង្រឹង និងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម ស្របតាម
ការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច.................................................. ១៤៨
៣.៥.២. ការពង្រឹង និងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម.........១៥២
៣.៥.៣. ការលើកកម្ពស់ការយល់ដឹង និងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម... ១៥៥

៣.៥.៤. ការពង្រឹងការគ្រប់គ្រង និងចាត់ចែងមូលនិធិសន្តិសុខសង្គម ដើម្បីបង្កើនប្រយោជន៍បន្ថែមដល់សមាជិក ប.ស.ស. និងវិស័យទំនាក់ទំនងវិជ្ជាជីវៈ .................... ១៥៩
៣.៥.៥. ការអភិវឌ្ឍសមត្ថភាពបេឡាជាតិសន្តិសុខសង្គម.................................... ១៦២
**៣.៦-ការធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រឆ្ពោះទៅតាមបច្ចេកវិទ្យាឌីជីថល**.............................................................. ១៦៦
៣.៦.១. ពង្រឹងការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក ស្របតាមកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ..................................................................... ១៦៧
៣.៦.២. ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.......................................................... ១៧១
៣.៦.៣. អភិវឌ្ឍសមត្ថភាពមន្ត្រី គ្រប់គ្រងចំណេះដឹង គ្រប់គ្រងស្ថិតិ និងកសាងលិខិតបទដ្ឋានគតិយុត្ត.......................................................................... ១៧៥
៣.៦.៤. ពង្រឹងភាពជាម្ចាស់ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ សមភាពយេនឌ័រ និងសេវាសង្គម.......................................................................... ១៧៩
៣.៦.៥. ពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ.......................................................................... ១៨៤
**ជំពូកទី ៤ ÷ ការកៀរគរប្រភពធនធានហិរញ្ញវត្ថុ** ........................................... ១៨៩
**ជំពូកទី ៥ ÷ ការតាមដាន និងវាយតម្លៃ** ................................................... ១៩០
៥.១. ការរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ....................................... ១៩១
៥.២. ដំណាក់កាលការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ....................................... ១៩២
៥.៣. ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រ លទ្ធផល និងសូចនាករ ........................... ១៩៣
៥.៤. ក្របខណ្ឌអនុវត្ត និងយន្តការសម្របសម្រួល ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ.... ១៩៥
**ជំពូកទី ៦ ÷ សេចក្តីសន្និដ្ឋាន** ............................................................ ១៩៧
**ឧបសម្ព័ន្ធ ÷ សូចនាករស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨**.............................................................. ២០០

**អារម្ភកថា**

ការដាក់ចេញនូវនយោបាយ ឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានយកអាយុជីវិតធ្វើជាដើមទុន ត្រូវបានអនុវត្តដោយជោគជ័យទាំងស្រុងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ និងបានធ្វើឱ្យកម្ពុជាទទួលបាននូវសុខសន្តិភាពពេញលេញទូទាំងផ្ទៃប្រទេស ពុំធ្លាប់មានក្នុងរយៈពេលជាង ៥០០ឆ្នាំក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ ក្នុងរយៈពេល ២៥ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង ៤ដំណាក់កាល ព្រមទាំងប្រភពគោលនយោបាយពាក់ព័ន្ធដទៃទៀត ដោយបានធ្វើឱ្យប្រទេសជាតិសម្រេចបានជាបន្តបន្ទាប់នូវសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រជាច្រើនលើគ្រប់វិស័យ ទាំងនយោបាយ សង្គម និងសេដ្ឋកិច្ច។

ដោយសារកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ ព្រមជាមួយការដាក់ចេញនូវកម្មវិធីកំណែទម្រង់មុតស្រួចស៊ីជម្រៅនានាជាប់ជាប្រចាំ បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជា មានកំណើនក្នុងអត្រាខ្ពស់ជាមធ្យមប្រមាណ ៧% សម្រាប់រយៈពេលជាង ២ទសវត្សរ៍ មុនផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការរីករាលដាលជំងឺកូវីដ-១៩ សង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន ភាពស្រុតចុះនៃទំនុកចិត្តវិនិយោគ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចអឺរ៉ុប សហរដ្ឋអាមេរិក និងចិន។ ទន្ទឹមនឹងសមិទ្ធផលនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ដោយបានធ្វើឱ្យកាន់តែប្រសើរឡើងនូវស្ថានភាពទីផ្សារការងារ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លក្ខខណ្ឌការងារ លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ និងរបបសន្តិសុខសង្គម។ លើសពីនេះ អនុសាសន៍ទាំង ១០ចំណុច របស់ **សម្តេចតេជោ** ត្រូវបានអនុវត្តយ៉ាងពេញលេញ និងទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីបងប្អូនកម្មករនិយោជិត។

ឈរលើមូលដ្ឋានបទពិសោធ មរតកប្រវត្តិសាស្ត្រ និងសមិទ្ធផលដ៏ថ្លៃថ្លាទាំងនេះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សម្រាប់ការកសាង និងការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨** និង**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** ដែលជាការគិតគូរអំពីរបៀបវារៈអភិវឌ្ឍសង្គម-សេដ្ឋកិច្ចសម្រាប់ដំណាក់កាលបន្ទាប់ សំដៅបន្តដឹកនាំកម្ពុជាសម្រេចបាននូវសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រជាច្រើនបន្ថែមទៀតលើគ្រប់វិស័យ ដើម្បីលើកកម្ពស់មុខមាត់ថ្មី និងមោទនភាពជាតិរបស់កម្ពុជានៅលើឆាកអន្តរជាតិ ទាំងក្នុងក្របខណ្ឌតំបន់ ទាំងពិភពលោក។

ដោយមានមគ្គទេសក៍ពី**កម្មវិធីនយោបាយ** និង**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល**, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ ដែលជាឯកសារគោល និងជាត្រីវិស័យចង្អុលបង្ហាញនូវយុទ្ធសាស្ត្រគន្លឹះ កម្មវិធីអាទិភាព ចង្កោមសកម្មភាព និងសកម្មភាពការងារ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងអង្គភាព គ្រឹះស្ថានក្រោមឱវាទ និងគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្ត និងសម្រេចឱ្យបានសម្រាប់រយៈពេល ៥ឆ្នាំ ខាងមុខ។ ឯកសារនេះ ត្រូវបានរៀបចំឡើងឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨, ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០, ឯកសារអនុលោមភាពជាមួយស្តង់ដាអន្តរជាតិ, គោលនយោបាយជាតិនិងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។

យើងខ្ញុំទាំងអស់គ្នាពិតជាចងចាំមិនភ្លេចនូវឧបការគុណដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចតេជោ** និងសូមប្តេជ្ញាយ៉ាងមោះមុតចូលរួមការពារឱ្យខាងតែបាននូវមរតកសមិទ្ធផលដ៏ថ្លៃថ្លាជាប្រវត្តិសាស្ត្ររបស់ **សម្តេចតេជោ** ឱ្យស្ថិតស្ថេរគង់វង្សជារៀងដរាប។ ខ្ញុំបាទក៏សូមសម្តែងនូវអំណរគុណ **សម្តេចធិបតី** ដែលបានផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុវត្តនូវការងារចំពោះមុខចំនួន ៦ចំណុច ក្នុងឆ្នាំ២០២៣ និងការងារអាទិភាពចំនួន ៤ចំណុច ផ្សេងទៀតសម្រាប់រយៈពេល ២ឆ្នាំខាងមុខទៀត (ឆ្នាំ២០២៤ និង២០២៥) ព្រមទាំងផ្តល់អនុសាសន៍ ណែនាំជាបន្តបន្ទាប់ សំដៅកសាងមូលធនមនុស្សដែលមានជំនាញ មនសិការ សីលធម៌សង្គម ស្មារតីស្នេហាជាតិ និងផលិតភាពការងារខ្ពស់អាចឆ្លើយតបតាមតម្រូវការនៃការវិវត្តយ៉ាងឆាប់រហ័សនៃមូលដ្ឋានសេដ្ឋកិច្ច ឧស្សាហកម្ម និងបច្ចេកវិទ្យាឌីជីថល ជំរុញសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ប្រកបដោយលក្ខខណ្ឌការងារល្អ សុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ, និងអភិវឌ្ឍរបបសន្តិសុខសង្គមពេញលេញ ដែលនឹងរួមចំណែកបង្កើននូវភាពប្រកួតប្រជែង និងភាពទាក់ទាញរបស់កម្ពុជា ក៏ដូចជាជួយលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ និងសមធម៌សង្គម។

ខ្ញុំក៏សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅប្រកបដោយកតញ្ញូតាធម៌ជូនចំពោះថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់អាណត្តិ ជាពិសេស **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** និង **ឯកឧត្តមបណ្ឌិត ពេជ សោភ័ន** ក្នុងកិច្ចខិតខំយ៉ាងពេញទំហឹងយកអស់កម្លាំងប្រាជ្ញាស្មារតីនាអាណត្តិកន្លងទៅ ក្នុងការអភិវឌ្ឍវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យមានការវិវត្តរីកចម្រើនមកទល់បច្ចុប្បន្ននេះ។

ក្នុងនាមក្រសួង និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ កិច្ចខិតខំរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ដែលបានចូលរួមសហការដោយស្អិតរមួតប្រកបដោយភាពបុរេសកម្ម និងអន្តរសកម្ម ក្នុងការរៀបចំនូវ **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨"** ដ៏មានសារៈសំខាន់នេះ ដែលមានភាពរស់អាចឆ្លើយតបនឹងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យនានា និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជានាពេលខាងមុខផងដែរ។

ខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ អនុវត្តផែនការយុទ្ធសាស្ត្រខាងលើនេះប្រកបដោយភាពវៃឆ្លាត និងទទួលខុសត្រូវខ្ពស់សំដៅសម្រេចឱ្យបាននូវគោលបំណង និងគោលដៅរំពឹងទុករបស់ប្រជាពលរដ្ឋ ជាពិសេសរបស់បងប្អូនកម្មករ និយោជិត និយោជក និងយុវជនជាទីគោរពស្រឡាញ់នៃយើងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

ថ្ងៃ ព្រហស្បតិ៍ ១៥កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

# អក្សរបំព្រួញ

| | | |
|---|---|---|
| ក.ស.ថ.ម. | : | ក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីរៀបចំដាក់ឱ្យដំណើរការរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ |
| គ.ក.ប. | : | គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា |
| គ.ជ.ព. | : | គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ |
| គ.ជ.អ.ប. | : | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| គ.ប.ប.ព.ប. | : | គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស |
| ទ.ជ.ម.ក. | : | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| ន.គ.វ.ស. | : | នាយកដ្ឋានគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម |
| ន.គ.ន.ប. | : | នាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម |
| ន.ត.ល. | : | នាយកដ្ឋានតាវកាលិកសន្តិសុខសង្គម |
| ន.ថ.ហ.គ. | : | នាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ |
| ន.ប.ព. | : | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| ន.ប.ភ. | : | នាយកដ្ឋានបញ្ជិកា និងភាគទាន |
| ន.រ.ធ. | : | នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស |
| ន.ស.ន. | : | នាយកដ្ឋានស្តារនីតិសម្បទា |
| ន.ស.ម.ស. | : | នាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាល |
| ន.ស.អ. | : | នាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ |
| ន.អ.ស. | : | នាយកដ្ឋានអធិការកិច្ចសន្តិសុខសង្គម |
| ប.ស.ស. | : | បេឡាជាតិសន្តិសុខសង្គម |
| ផ.ស.ស. | : | ផលិតផលក្នុងស្រុកសរុប |
| ផ.យ.អ.-ក.ស.ប. | : | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ផ.យ.អ.ជ | : | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ស.ដ.ក. | : | នាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា |
| អ.ក.ជ.ប.អ. | : | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា |
| អ.គ.ក.ប. | : | អគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា |
| អ.គ.ជ.ព. | : | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ |
| អ.ប.វ. | : | អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |



ក្ស

| | | |
|---|---|---|
| ACPECC | : | ASEAN Chartered Professional Engineer Coordinating Committee |
| AFEO | : | ASEAN Federation of Engineering Organizations |
| AOP | : | Annual Operation Plan |
| API | : | Application Programming Interface |
| AQRF | : | ASEAN Qualification Reference Framework |
| BSP | : | Budget Strategy Plan |
| C1 | : | Technical and Vocational Certificate 1 |
| C2 | : | Technical and Vocational Certificate 2 |
| C3 | : | Technical and Vocational Certificate 3 |
| CamDX | : | Cambodia Data Exchange |
| CBT | : | Competency-Based Training |
| CEDAW | : | Convention on the Elimination of All Forms of Discrimination Against Women |
| COE | : | Centre of Excellence |
| CQF | : | Cambodia Qualifications Framework |
| CSIC | : | Cambodia Standard Industrial Classification |
| CTQF | : | Cambodia Trainers Qualification Framework |
| FEIAP | : | The Federation of Engineering Institutions of Asia and the Pacific |
| FMIS | : | Financial Management Information Systems |
| GCM | : | Global Compact for Migration |
| GIZ | : | German Agency for International Cooperation |
| GMAP | : | Gender Mainstreaming Action Plan |
| GMS | : | Greater Mekong Subregion |
| ILO | : | International Labour Organization |
| ILO-BFC | : | International Labour Organization-Better Factories Cambodia |
| ISCO | : | International standard classification of occupation |
| ISIC | : | International Standard Industarial Classification Of All Economic Activities |
| ISO | : | International Standard Organization |
| LAC | : | Labour Advisory Committee |
| LACMS | : | Labour Centralized Management System |

| | | |
|---|---|---|
| MOU | : | Memorandum of Understanding |
| MRA | : | Mutual Recognition Arrangement |
| MRC | : | Migrant Resource Centres |
| MRS | : | Mutual Recognition of Skills |
| MTOSB | : | Manpower Training and Overseas Sending Board |
| NEP | : | National Employment Policy |
| NPFEP | : | National Policy Framwork on Productive Economy |
| NRMIS | : | Non-Tax Revenue Management Information System |
| NTB | : | National Training Board |
| OSH | : | Occupational Safety and Health |
| PAYG | : | Pay As You Go |
| PB | : | Program Budgeting |
| PMRS | : | Patient Management and Registration System |
| PPP | : | Public-Private Partnerships |
| QIPs | : | Qualified Investment Projects |
| RCC | : | Recognition of Current Competencies |
| RIS | : | Return to Industry Scheme |
| RPL | : | Recognition of Prior Learning |
| SARMIS | : | State Asset Register Management Information System |
| SICMS | : | Self-Inspection Cetrailized Mangement System |
| SMEs | : | Small and Medium Enterprises |
| SOP | : | Standard Operating Procedure |
| TCS | : | Teacher Competency Standard |
| TENA | : | Training and Education Needs Assessment |
| TD | : | Travel Document |
| TVET | : | Technical and Vocational Education and Training |
| TVETMIS | : | Technical Vocational Education and Training Management Information System |
| TWG | : | Technical Working Group |
| TWG-TVET | : | Technical Working Group for Technical and Vocational Education and Training |

| | | |
|---|---|---|
| UNFPA | : | United Nations Population Fund |
| WARM | : | Work Adjustment for Recycling and Managing Waste |
| WBL | : | Work-Based Learning |
| WIND | : | Work Improvement in Neighborhood Development |
| WINDY | : | Work Improvement in Neighborhood Development for Youth |
| WISCON | : | Work Improvement at Small Construction Sites |
| WISE | : | Work Improvement in Small Enterprises |
| WISH | : | Work Improvement for Safe Home |

# ជំពូកទី ១
# សេចក្តីផ្តើម

## ១.១- ទស្សនាទាន និងសារៈសំខាន់នៃការរៀបចំផែនការយុទ្ធសាស្ត្រ

មរតកជាប្រវត្តិសាស្ត្រនៃការអនុវត្តដោយជោគជ័យ **នយោបាយឈ្នះ-ឈ្នះ** នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានយកអាយុជីវិតធ្វើជាដើមទុន ដើម្បីនាំមកនូវសុខសន្តិភាពពេញបរិបូរជូនប្រទេសជាតិ គឺជាបុរេលក្ខខណ្ឌ និងបរិការណ៍អំណោយផលបំផុតសម្រាប់កម្ពុជា ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនឱ្យសម្រេចបានកំណើនខ្ពស់ក្នុងអត្រាជាមធ្យមប្រមាណ ៧% សម្រាប់រយៈពេលជាង ២ទសវត្សរ៍ មុនផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការរីករាលដាលជំងឺកូវីដ-១៩ សង្គ្រាមរុស្ស៊ីនិងអ៊ុយក្រែន និងភាពស្រុតចុះនៃទំនុកចិត្តវិនិយោគ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចអឺរ៉ុប សហរដ្ឋអាម៉េរិក និងចិន។ ក្នុងរយៈពេល ២៥ឆ្នាំ ចុងក្រោយនេះ កម្ពុជារក្សាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ ឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដីពេញបរិបូរ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការរីកចម្រើនលូតលាស់ និងអភិវឌ្ឍលើគ្រប់វិស័យ ដែលបានលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនកាន់តែល្អប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ ជាពិសេស ប្រែក្លាយពីប្រទេសក្រីក្រទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ និងបានកំពុងធ្វើដំណើរក្នុងជំហានដ៏ស្វាហាប់ឆ្ពោះទៅសម្រេចឱ្យបានចក្ខុវិស័យ ប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

សមិទ្ធផលនៃកំណើនសេដ្ឋកិច្ចខ្ពស់ជាបន្តបន្ទាប់ក្នុងរយៈពេលកន្លងមក កើតចេញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលគ្រប់អាណត្តិ ដែលបានដាក់ចេញ និងអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់នូវយុទ្ធសាស្ត្រ និងគោលនយោបាយជាបន្តបន្ទាប់ ដូចជា យុទ្ធសាស្ត្រត្រីកោណ, យុទ្ធសាស្ត្រចតុកោណ ទាំង ៤ ដំណាក់កាល, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិស្របតាមអាណត្តិនីមួយៗនៃរាជរដ្ឋាភិបាល និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានាជាច្រើនទៀត។

ទន្ទឹមនឹងសមិទ្ធផលរួមនៃសង្គម-សេដ្ឋកិច្ចកម្ពុជា, វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។ តាមរយៈការខិតខំអនុវត្តដោយជោគជ័យនូវ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៥អាណត្តិបន្តបន្ទាប់កន្លងមកនេះ បានរួមចំណែកធ្វើឱ្យមានភាពទាក់ទាញដល់វិនិយោគទុន និងបង្កើតការងារជូនកម្មករនិយោជិតកាន់តែច្រើនឡើង ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនចំនួនសហគ្រាស គ្រឹះស្ថាន បានកើនពីចំនួន ៦៤ និងមានកម្មករនិយោជិតត្រឹមប្រមាណ ៨ម៉ឺននាក់ នៅឆ្នាំ១៩៩៧ ដល់ចំនួន ៤០ ៩៧៥ និងមានកម្មករនិយោជិតសរុបប្រមាណ១,៧លាននាក់ គិតត្រឹមចុងឆ្នាំ២០២៣ ក្នុងនោះ វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរ និងកាបូបមានចំនួន ១ ៤៩៩ និងមានកម្មករនិយោជិតសរុបចំនួន ៨៨៦ ៣៥៥នាក់ ដោយបានប្រាក់ឈ្នួលប្រចាំឆ្នាំប្រមាណ ២,៧៥ពាន់លានដុល្លារ។ ស្ថានភាពទីផ្សារការងារមានភាពរឹងមាំ ជាមួយនឹងលក្ខខណ្ឌការងារ លក្ខខណ្ឌ

សុវត្ថិភាពនិងសុខភាពការងារ សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ និងរបបសន្តិសុខសង្គមកាន់តែល្អប្រសើរ ព្រមទាំងបន្តពង្រីកទីផ្សារការងារជំនាញនៅប្រទេសអភិវឌ្ឍន៍ ដែលជាជម្រើសបន្ថែមជូនប្រជាជន។ លើសពីនេះ អនុសាសន៍ទាំង ១០ចំណុច របស់ **សម្តេចតេជោ** ត្រូវបានអនុវត្តយ៉ាងពេញលេញ និងជោគជ័យបំផុតដោយទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីបងប្អូនកម្មករនិយោជិត និងនិយោជក។

ទោះជាយ៉ាងនេះក្តី, ជាមួយវឌ្ឍនភាពល្អប្រសើរខាងលើនេះ ស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចសកលក៏បានបន្តជះឥទ្ធិពលអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា ដែលទាមទារជាចាំបាច់នូវការយកចិត្តទុកដាក់ និងគិតគូរបន្ថែម។ តាមការសិក្សាស្រាវជ្រាវ និងការវាយតម្លៃរបស់ស្ថាប័នអន្តរជាតិធំៗ បានបង្ហាញថា ក្នុងរយៈពេលមួយទៅពីរឆ្នាំខាងមុខនេះ សេដ្ឋកិច្ចសកលនឹងមានកំណើនយឺតក្នុងអត្រាទាបជាងធម្មតា ដោយសារការប្រែប្រួលនូវនិន្នាការសកលធំៗ ទាំងនិន្នាការភូមិសាស្ត្រនយោបាយ និងពហុប៉ូលនិយម និន្នាការភូមិសាស្ត្រសេដ្ឋកិច្ច និន្នាការបរិវត្តកម្មឌីជីថល និងទាំងនិន្នាការបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ ក្នុងនោះ ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុនៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ដើម្បីឆ្លើយតបទៅនឹងកម្រិតអតិផរណាខ្ពស់ធៀបនឹងអត្រាគោលដៅ និងផលប៉ះពាល់ពីសង្គ្រាមរុស្ស៊ីនិងអ៊ុយក្រែនមកលើការផ្គត់ផ្គង់ និងថ្លៃថាមពល គឺជាបញ្ហាប្រឈមចម្បងមួយរបស់ពិភពលោក។ ទោះបីជាសេដ្ឋកិច្ចសកលនៅមានភាពមិនប្រាកដប្រជា នៅក្រោយវិបត្តិជំងឺកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញក្នុងទម្រង់ជាអក្សរវី (V) ក្នុងនោះ ស្ថានភាពទីផ្សារការងារនៅកម្ពុជាមានភាពធន់ និងរឹងមាំ ដោយបង្កើតឱកាសការងារបានកាន់តែច្រើនទាំងបរិមាណនិងគុណភាព និងកាន់តែមានលក្ខណៈប្រសើរជាងមុន ព្រមជាមួយការពង្រឹងគុណភាពការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដែលអាចធ្វើឱ្យបងប្អូនអាចបង្កើតមុខរបរ និងរកការងារធ្វើកាន់តែទទួលបានប្រាក់ចំណូលខ្ពស់។ ស្ថានភាពងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាក៏នៅប្រឈមនឹងការប្រែប្រួលរចនាសម្ព័ន្ធ និងនិម្មាបនកម្មសេដ្ឋកិច្ច សង្គម បរិស្ថាន និងនយោបាយសកល។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការគិតគូរអំពីរបៀបវារៈអភិវឌ្ឍសង្គម-សេដ្ឋកិច្ចសម្រាប់ដំណាក់កាលបន្ទាប់ ដោយវាយតម្លៃប្រមើលមើលសម្រាប់រយៈពេល២៥ឆ្នាំទៅមុខ និងសម្លឹងឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ដោយឈរលើមូលដ្ឋានបទពិសោធមរតកប្រវត្តិសាស្ត្រ និងសមិទ្ធផលរយៈពេល ២៥ឆ្នាំកន្លងមក។ ក្នុងក្របខណ្ឌនៃទស្សនវិស័យនេះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** ដើម្បី **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព** និង**ចីរភាព** តាមរយៈការអនុវត្តអភិក្រម “**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**” និងអភិក្រម“**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**”។ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ កំណត់យកអាទិភាពគន្លឹះ៥ ដោយបន្ថែមបច្ចេកវិទ្យា និងបន្តយកមនុស្ស ជាអាទិភាពទី១ ហើយ ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា គឺជាអាទិភាពបន្តបន្ទាប់តាមលំដាប់។ គួររំឭកផងដែរថា កាលពីឆ្នាំ១៩៨៧ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានប្រកាសដាក់ចេញនូវគោលនយោបាយផ្តល់អាទិភាពលើ ទឹក ផ្លូវ ភ្លើង និងមនុស្ស ផ្អែកលើអភិក្រមជាក់ស្តែង ប្រាកដនិយម និងមានទស្សនវិស័យវែងឆ្ងាយសម្រាប់ការស្តារកសាង និងអភិវឌ្ឍសង្គមជាតិ។ គោលនយោបាយអាទិភាពគន្លឹះទាំង៤ នេះ នៅតែមានភាពសមស្រប ប្រសិទ្ធភាព



ញ

និងរឹតតែត្រឹមត្រូវរហូតដល់បច្ចុប្បន្ន ជាពិសេស ក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម ៤.០។ លំដាប់អាទិភាពនេះ ត្រូវបានប្តូរមកជា មនុស្ស ទឹក ផ្លូវ និងភ្លើង វិញ ដោយកំណត់យក "មនុស្ស" ជាអាទិភាពទី១ តែម្តង ចាប់ពីរាជរដ្ឋាភិបាល នីតិកាលទី៣ នៃរដ្ឋសភា ដែលផ្តើមអនុវត្តនៅក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ (២០១៣-២០១៨)។ ការណ៍នេះ បានបង្ហាញយ៉ាងច្បាស់ថា រាជរដ្ឋាភិបាល បានផ្តោតការយកចិត្តទុកដាក់ជាអាទិភាពលើការអភិវឌ្ឍមូលធនមនុស្ស ដែលជាកត្តាចាំបាច់មិនអាចខ្វះបានក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈការជំរុញឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេសជាមួយសមត្ថភាពពិតប្រាកដ ដើម្បីក្លាយខ្លួនជាកម្លាំងពលកម្មជំនាញ អ្នកបច្ចេកទេស ដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ។

ក្នុងន័យនេះ ដើម្បីចូលរួមអនុវត្តឱ្យបានជោគជ័យនូវ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងគោលនយោបាយជាតិនានារបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំនូវ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និង បណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨** សម្រាប់ជាផែនទីចង្អុលផ្លូវជូនដល់អង្គភាពពាក់ព័ន្ធក្រោមឱវាទរបស់ខ្លួនអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់តាមតួនាទីនិងភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ១.២- ការរៀបចំ និងរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រ

ផ្អែកតាម **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** និងសមិទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាអាណត្តិកន្លងមក ក្រសួងបានបន្តរៀបចំនិងដាក់ចេញកាន់តែមុតស្រួច និងប្រកបដោយការប្តេជ្ញាចិត្តខ្ពស់នូវ «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨**» ដើម្បីបន្សាំ និងឆ្លើយតបទៅនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល, យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨, ក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០, ឯកសារអនុលោមភាពជាមួយស្តង់ដាអន្តរជាតិ ព្រមទាំងធានាសង្គតិភាព ភាពប្រទាក់ក្រឡាជាមួយក្របខណ្ឌគោលនយោបាយថ្នាក់ជាតិ និងអនុវិស័យពាក់ព័ន្ធនានា។ គោលនយោបាយពាក់ព័ន្ធជាច្រើនត្រូវបានយកមកធ្វើជាឯកសារពិគ្រោះ និងធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនេះផងដែរ ដូចជា គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ ២០១៥-២០២៥, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១៧-២០២៥, គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់កម្ពុជាឆ្នាំ២០១៩-២០២៣, គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥, យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០,

ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា, ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ឆ្នាំ២០២៣-២០៣៥, ផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជា ឆ្នាំ២០២៣-២០២៧, ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥,គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០, ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ជំនាញឌីជីថលនៅកម្ពុជា ២០២៤-២០៣៥, ផែនការមេដើម្បីអភិវឌ្ឍន៍ខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង,កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ និងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ គឺជាឯកសារគោល និងជាត្រីវិស័យចង្អុលបង្ហាញនូវយុទ្ធសាស្ត្រគន្លឹះ កម្មវិធីអាទិភាព ចង្កោមសកម្មភាព និងសកម្មភាពការងារ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងអង្គភាព និងគ្រឹះស្ថានក្រោមឱវាទទាំងអស់ ត្រូវអនុវត្ត និងសម្រេចឱ្យបាន សម្រាប់រយៈពេល៥ឆ្នាំ ខាងមុខ(២០២៤-២០២៨)។ ការសម្រេចបាននូវផែនការយុទ្ធសាស្ត្រខាងលើនេះនឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រទាំង៥ "**កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព**" របស់រាជរដ្ឋាភិបាល ជាពិសេស ការបង្កើនការងារឱ្យកាន់តែច្រើន ទាំងបរិមាណនិងគុណភាពជូនប្រជាជនកម្ពុជា និងការកាត់បន្ថយភាពក្រីក្រក្នុងអត្រាទាបជាង ១០% និងទម្លាក់អត្រានៃភាពក្រីក្រឱ្យស្ថិតនៅក្នុងកម្រិតអប្បបរមា ព្រមទាំងចូលរួមកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ផែនការយុទ្ធសាស្ត្រនេះ ក៏នឹងដើរតួជាផែនទីចង្អុលផ្លូវសម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការស្វែងរកនូវធនធានបន្ថែមសម្រាប់គាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ ការចូលរួមអនុវត្តនូវផែនការយុទ្ធសាស្ត្រឱ្យបានជោគជ័យ នឹងចូលរួមកាន់តែប្រសើរថែមទៀតដល់ការអភិវឌ្ឍមូលធនមនុស្សដើម្បីចូលរួមក្នុងការបង្កើនល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច និងការធ្វើបរិវត្តកម្មរចនាសម្ព័ន្ធឧស្សាហកម្ម ពីឧស្សាហកម្មអតិពលកម្មទៅជាឧស្សាហកម្មអតិមូលធន ព្រមជាមួយការលើកកម្ពស់ជីវភាពរស់នៅ សេចក្តីថ្លៃថ្នូរ និងការពង្រឹងរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិត និងទេសន្តរប្រវេសន៍ខ្មែរ, ពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងនីតិរដ្ឋ, និងប្តេជ្ញាផលិតមូលធនមនុស្ស និងអភិវឌ្ឍកម្លាំងពលកម្មឱ្យមានជំនាញ ចំណេះដឹង សមត្ថភាព គុណធម៌ សីលធម៌ ចរិយាមារយាទ មនសិការវិជ្ជាជីវៈ ស្មារតីទទួលខុសត្រូវ មានផលិតភាព ការប្រកួតប្រជែងខ្ពស់ មានភាពធន់ បត់បែន អាចឆ្លើយតបតាមតម្រូវការនៃការវិវត្តយ៉ាងឆាប់រហ័សនៃមូលដ្ឋានសេដ្ឋកិច្ច ឧស្សាហកម្ម បច្ចេកវិទ្យាឌីជីថល និងការការពារបាននូវបរិស្ថានប្រកបដោយចីរភាព ស្របតាមការតម្រង់ទិសគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ដោយធានាថា "**ពលរដ្ឋម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត**" និងអនុវត្តតាមអភិក្រមរបស់ **សម្តេចធិបតី "រៀនឱ្យចប់ ឱ្យចេះ ឱ្យមានការងារ"**។

រចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រនេះ មានអារម្ភកថា ខ្លឹមសារជំពូក និងឧបសម្ព័ន្ធ។ ខ្លឹមសារសំខាន់ៗនៃផែនការយុទ្ធសាស្ត្រនេះ ចែកចេញជា ៦ជំពូក ដូចខាងក្រោម÷

ជំពូកទី១ ÷ សេចក្តីផ្តើម

ជំពូកទី២ ÷ បរិការណ៍ និងភាពចាំបាច់នៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលបច្ចេកទេស

ជំពូកទី៣ ÷ ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨

ជំពូកទី៤ ÷ ការកៀរគរប្រភពធនធានហិរញ្ញវត្ថុ

ជំពូកទី៥ ÷ ការតាមដាន និងវាយតម្លៃ

ជំពូកទី៦ ÷ សេចក្តីសន្និដ្ឋាន។

## ១.៣- ចក្ខុវិស័យ និងបេសកកម្ម

ចក្ខុវិស័យ និងបេសកកម្ម របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា គឺរួមចំណែកយ៉ាងសកម្មជាមួយស្ថាប័ន និងដៃគូពាក់ព័ន្ធ ធានាឱ្យបាននូវ (១) ការផ្តល់ព័ត៌មានទីផ្សារការងារនិងមគ្គុទេសក៍គ្រប់គ្រាន់សម្រាប់យុវជន និងការអភិវឌ្ឍមូលធនមនុស្សប្រកបដោយជំនាញសមរម្យ មនសិការ សីលធម៌សង្គម ស្មារតីស្នេហាជាតិ មានផលិតភាពការងារខ្ពស់ មានភាពធន់ ដែលងាយបត់បែនរហ័ស អាចឆ្លើយតបបាននៃការវិវត្តនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច បច្ចេកទេស និងបច្ចេកវិទ្យាឌីជីថល, (២) ភាពសុខសាន្តនៅកន្លែងការងារ ដោយប្រែក្លាយសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ពោលជាកន្លែងដែលមានលក្ខខណ្ឌការងារល្អ មានសុវត្ថិភាពនិងសុខភាពការងារល្អ មានភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ កម្មករនិយោជិត និងនិយោជកចេះគោរពគ្នា អធ្យាស្រ័យគ្នា ប្រកាន់យកគោលការណ៍ឈ្នះ-ឈ្នះជាធំ មិនយកការចាញ់ឈ្នះជាគោលក្នុងការដោះស្រាយវិវាទ ឬបញ្ហា, (៣) យន្តការគាំពារ និងការពារកិត្តិយស សេចក្តីថ្លៃថ្នូរ និងផលប្រយោជន៍របស់បងប្អូនពលករទេសន្តប្រវេសន៍, និង (៤) ការអភិវឌ្ឍរបបសន្តិសុខសង្គមពេញលេញ ដើម្បីបន្តជំរុញការបង្កើត រក្សា និងបង្កើនការងារទាំងបរិមាណ និងគុណភាព សំដៅចូលរួមសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

## ១.៤- គោលបំណង

ផែនការយុទ្ធសាស្ត្រនេះមានគោលបំណងរួមចំណែកបង្កើត រក្សា និងបង្កើនការងារទាំងបរិមាណនិងគុណភាពដល់ប្រជាជនកម្ពុជា, អភិវឌ្ឍមូលធនមនុស្សប្រកបដោយចំណេះដឹង ជំនាញ ឥរិយាបថការងារ សីលធម៌វិជ្ជាជីវៈ ផលិតភាព និងភាពប្រកួតប្រជែងខ្ពស់, លើកកម្ពស់បរិយាកាសការងារល្អប្រសើរទាំងសម្រាប់កម្មករនិយោជិត ទាំងក្នុង និងក្រៅប្រព័ន្ធ និងទាំងសម្រាប់និយោជក, ធានាសុវត្ថិភាពនិងសេចក្តីថ្លៃថ្នូរជូនពលករទេសន្តរប្រវេសន៍, និងពង្រីកការគ្របដណ្តប់នៃរបបសន្តិសុខសង្គមឱ្យកាន់តែទូលំទូលាយ តាមរយៈយុទ្ធសាស្ត្របច្ចេកទេស

ចំនួន ៥ និងយុទ្ធសាស្ត្រគាំទ្រទូទៅចំនួន ១ (៥បូក១) រៀងគ្នា ដូចតទៅ (១) រៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម, (២) ធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង, (៣) អភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ស្របតាមការវិវត្តនៃពិភពការងារ, (៤) ពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព, (៥) អភិវឌ្ឍរបបសន្តិសុខសង្គមស្របតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច, (៦) ធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រទូទៅ តាមបច្ចេកវិទ្យាឌីជីថល។

## ១.៥- គោលដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ បេសកកម្ម និងគោលបំណងខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់នូវគោលដៅចំនួន ៦ ដែលមានភាពប្រទាក់ក្រឡាគ្នាយ៉ាងល្អជាមួយកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងគោលនយោបាយជាតិនានា ដោយបានកំណត់នូវក្របខណ្ឌពេលវេលាជាក់លាក់, សូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់វាស់វែងការអនុវត្តយុទ្ធសាស្ត្រ កម្មវិធី និងចង្កោមសកម្មភាព ដូចដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃផែនការយុទ្ធសាស្ត្រនេះ។

- **ទី១- រៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម** តាមរយៈការដាក់ចេញ និងអនុវត្តនូវកម្មវិធីសំខាន់ចំនួន ៥ រួមមាន **(១)** ការពង្រឹងការអនុវត្តគោលនយោបាយ និងសិក្សាស្រាវជ្រាវ ដោយឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង, **(២)** ការពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាស្វែងរកការងារ និងវេទិកាការងារ, **(៣)** ការពង្រឹង និងពង្រីកសេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ, **(៤)** ការពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេសតាមរយៈបច្ចេកវិទ្យាឌីជីថល និង **(៥)** ការពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងកម្មវិធីជំរុញការលើកកម្ពស់ផលិតភាពការងារ។
- **ទី២- ធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង** ដែលបានដាក់ចេញ និងអនុវត្តនូវកម្មវិធីសំខាន់ចំនួន ៥ រួមមាន **(១)** ការពង្រឹងប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមបច្ចេកវិទ្យាឌីជីថល, **(២)** ការពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយរួមបញ្ចូលនូវជំនាញសម្បទាការងារ, ជំនាញសម្បទាបត់បែន, ជំនាញបច្ចេកវិទ្យាឌីជីថល និងជំនាញបៃតង, **(៣)** ការពង្រឹង និងពង្រីកការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញ ដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម, **(៤)** ការពង្រឹងភាពជាដៃគូរវាងរដ្ឋ ឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីធានានិរន្តរភាពនៃកម្មវិធីបណ្តុះបណ្តាល និង **(៥)** ការជំរុញការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍។



ញ

**ទី៣- អភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាពនិងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈស្របតាមការវិវត្ត នៃពិភពការងារ** តាមរយៈការដាក់ចេញ និងអនុវត្តនូវកម្មវិធីសំខាន់ចំនួន ៥ រួមមាន (១) ការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច និងយន្តការអធិការកិច្ចការងារ ដើម្បីលើកកម្ពស់វប្បធម៌អនុលោមភាពនៃច្បាប់ពាក់ព័ន្ធវិស័យការងារ, (២) ការលើកកម្ពស់លក្ខខណ្ឌស្តីពីសុវត្ថិភាពនិងសុខភាពការងារ, (៣) ការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ, (៤) ការពង្រឹងសមត្ថភាពស្ថាប័ន និងតួអង្គពាក់ព័ន្ធក្នុងការពិភាក្សា កំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត និង (៥) ការលើកកម្ពស់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ដើម្បីប្រែក្លាយសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ។

**ទី៤- ពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព** ដែលបានដាក់ចេញ និងអនុវត្តនូវកម្មវិធីសំខាន់ចំនួន ៥ រួមមាន (១) ការពង្រឹង និងពង្រីកទីផ្សារការងារនៅបរទេសដែលមានលក្ខខណ្ឌការងារល្អ, (២) ការពង្រឹងយន្តការ តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការជ្រើសរើស ការបណ្តុះបណ្តាល និងការបញ្ជូនពលករទៅធ្វើការនៅបរទេស, (៣) ការពង្រឹងយន្តការគ្រប់គ្រង និងសេវាគាំពារនៅតាមប្រទេសទទួល ដល់ពលករទេសន្តរប្រវេសន៍កម្ពុជា, (៤) ការពង្រឹងយន្តការនៃការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ និង (៥) ការពង្រឹងការគ្រប់គ្រងហត្ថពលកម្មបរទេសនៅកម្ពុជា។

**ទី៥- អភិវឌ្ឍរបបសន្តិសុខសង្គមស្របតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច** តាមរយៈការដាក់ចេញ និងអនុវត្តនូវកម្មវិធីសំខាន់ចំនួន ៥ រួមមាន (១) ការពង្រឹង និងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គមស្របតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច, (២) ការពង្រឹង និងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម, (៣) ការលើកកម្ពស់ការយល់ដឹង និងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម, (៤) ការពង្រឹងការគ្រប់គ្រង និងចាត់ចែងមូលនិធិសន្តិសុខសង្គម ដើម្បីបង្កើនប្រយោជន៍បន្ថែមដល់សមាជិក ប.ស.ស. និងវិស័យទំនាក់ទំនងវិជ្ជាជីវៈ និង (៥) ការអភិវឌ្ឍសមត្ថភាពបច្ចេកវិទ្យាលេខ... 

**ទី៦- ធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈនិងសេវាគាំទ្រទូទៅ តាមបច្ចេកវិទ្យាឌីជីថល** តាមរយៈការដាក់ចេញ និងអនុវត្តនូវកម្មវិធីសំខាន់ចំនួន ៥ រួមមាន (១) ពង្រឹងការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក ស្របតាមកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា, (២) ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (៣) អភិវឌ្ឍសមត្ថភាពមន្ត្រី គ្រប់គ្រងចំណេះដឹង គ្រប់គ្រងស្ថិតិ និងកសាងលិខិតបទដ្ឋានគតិយុត្ត, (៤) ពង្រឹងភាពជាម្ចាស់ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ សមភាពយេនឌ័រ និងសេវាសង្គម និង (៥) ពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ។

តាមរយៈគោលដៅ និងផែនការសកម្មភាពទាំងឡាយដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រនេះ ក្រសួងនឹងសម្រេចបាននូវមហិច្ឆតាដូចខាងក្រោម÷

- កាត់បន្ថយបានជាអតិបរមានូវភាពមិនស៊ីសង្វាក់គ្នារវាងតួអង្គអ្នកស្វែងរកការងារ អ្នកផ្តល់ការងារ និងអ្នកផ្តល់ការបណ្តុះបណ្តាល
- យុវជន និងកម្លាំងពលកម្មនឹងក្លាយជាកម្លាំងពលកម្មដែលមានជំនាញ ចំណេះ ជាពិសេសជំនាញសម្បទាការងារ (Employability Skills), ជំនាញសម្បទាបត់បែន (Adaptability Skills) ដោយសារតែការជ្រើសរើសជំនាញបានត្រឹមត្រូវ សមរម្យ សមស្របតាមសមត្ថភាព លទ្ធភាព និងតម្រូវការនៃទីផ្សារការងារ សេដ្ឋកិច្ច និងសង្គម និងដោយសារមានកម្មវិធីបណ្តុះបណ្តាលប្រកបដោយគុណភាព មានភាពបត់បែនស្របតាមស្តង់ដាជាតិ និងតំបន់
- យុវជន សិស្ស និស្សិត កម្មករនិយោជិត ប្រជាពលរដ្ឋមានឱកាសទទួលបានការងារ និងមុខរបរទាំងនៅក្នុង និងក្រៅប្រទេសកាន់តែសមរម្យ និងទទួលបានចំណូលកាន់តែខ្ពស់
- គ្រប់កន្លែងការងារមានលក្ខខណ្ឌការងារល្អ និងភាពសុខសាន្តនៅកន្លែងការងារ
- គ្រប់កម្មករនិយោជិត និងប្រជាពលរដ្ឋមានសុខុមាលភាព និងសន្តិសុខសង្គមពេញលេញទាំងនៅក្នុងអំឡុងពេលមានការងារ និងមុខរបរ រហូតដល់ពេលចូលនិវត្តន៍។

# ជំពូកទី ២
# បរិការណ៍ និងភាពចាំបាច់នៃការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ២.១- ស្ថានភាពប្រជាសាស្ត្រ និងទីផ្សារការងារកម្ពុជា

### ២.១.១. ស្ថានភាពប្រជាសាស្ត្រ និងការផ្គត់ផ្គង់កម្លាំងពលកម្ម

### ក. ស្ថានភាពប្រជាសាស្ត្រ

ប្រជាជនកម្ពុជាសរុបបានកើនពី ១៥,៥លាននាក់ នៅឆ្នាំ២០១៩ ដល់ ១៧,២លាននាក់ នៅឆ្នាំ២០២៣ ឬកើនឡើងជាមធ្យម ២,១% ក្នុងមួយឆ្នាំ។ ក្នុងរយៈពេលដូចគ្នានេះ ប្រជាជនស្ថិតនៅក្នុងវ័យធ្វើការបានកើនឡើងពី ១០,១លាននាក់ ទៅ ១១,១លាននាក់ ជាមួយអត្រាកំណើនផ្សេងៗគ្នាទៅតាមក្រុមអាយុ។ ជាក់ស្តែង ប្រជាជនស្ថិតនៅក្រុមអាយុ ១៥-២៤ឆ្នាំ មានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ២,៣%, អាយុ ២៥-៣៤ឆ្នាំ មានកំណើន ១,៣% និងអាយុ ៣៥-៤៤ឆ្នាំ មានកំណើន ៥,០%។ នៅឆ្នាំ ២០២៣ ប្រជាជនកម្ពុជាស្ថិតនៅក្នុងវ័យធ្វើការអាយុ ១៥-៦៤ឆ្នាំ មានប្រមាណ ៦៤,៥% នៃចំនួនប្រជាជនសរុប និងប្រមាណ ៣០,៤% មានអាយុក្រោម ១៤ឆ្នាំ ដែលនេះបង្ហាញអំពីរចនាសម្ព័ន្ធប្រជាសាស្ត្រនៃប្រជាជនវ័យក្មេងច្រើន។

**តារាងទី១ ÷ ចំនួនប្រជាជនសរុបតាមក្រុមអាយុ ចន្លោះឆ្នាំ២០១៩-២០២៣**

| ក្រុមអាយុ | ចំនួនប្រជាជន (ពាន់នាក់) | | | | បម្រែបម្រួលជាមធ្យមប្រចាំឆ្នាំ | |
|---|---|---|---|---|---|---|
| | ២០១៩ | | ២០២៣ | | ចំនួន (ពាន់នាក់) | អត្រាកំណើន (%) |
| | ចំនួន | ចំណែក (%) | ចំនួន | ចំណែក (%) | | |
| **០-១៤** | ៤,៥៧១ | ២៩,៤% | ៥,២២១ | ៣០,៤% | ១៣០,០ | ២,៨% |
| **១៥-២៤** | ២,៦៦៥ | ១៧,១% | ២,៩៦៧ | ១៧,៣% | ៦០,៥ | ២,៣% |
| **២៥-៣៤** | ២,៧៣៤ | ១៧,៦% | ២,៩០៥ | ១៦,៩% | ៣៤,២ | ១,៣% |
| **៣៥-៤៤** | ២,០៥៩ | ១៣,២% | ២,៥៧១ | ១៥,០% | ១០២,៤ | ៥,០% |
| **៤៥-៥៤** | ១,៥០៤ | ៩,៧% | ១,៤៣៦ | ៨,៤% | -១៣,៧ | -០,៩% |
| **៥៥-៦៤** | ១,១០៦ | ៧,១% | ១,១៩៣ | ៦,៩% | ១៧,២ | ១,៦% |
| **៦៥+** | ៩១២ | ៥,៩% | ៨៧៦ | ៥,១% | -៧,៣ | -០,៨% |
| **សរុប** | **១៥,៥៥** | **១០០,០%** | **១៧,១៦៩** | **១០០,០%** | **៣២៣,៣** | **២,១%** |

ប្រភព÷ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ (ទិន្នន័យឆ្នាំ២០១៨) និងទស្សនវិស័យប្រជាជនពិភពលោកនៃអង្គការសហប្រជាជាតិ ទាញយកថ្ងៃទី២ ខែមករា ឆ្នាំ២០២៤



ញ

រចនាសម្ព័ន្ធប្រជាសាស្ត្រតាមក្រុមអាយុ (រូបភាពទី១ និងទី២ខាងក្រោម) បានបង្ហាញថា កម្ពុជាបច្ចុប្បន្ន កំពុងស្ថិតនៅក្នុងដំណាក់កាលនៃការទាញយកនូវភាគលាភប្រជាសាស្ត្រ (កំណត់សម្គាល់បច្ចេកទេសទី១) រហូតដល់ឆ្នាំ២០៥០ ដែលឆ្លុះបញ្ចាំងតាមរយៈចំណែកនៃប្រជាជនវ័យក្មេងអាយុក្រោម ៣៥ឆ្នាំ មានរហូតដល់ចំនួន ៦៤,៦% នៅឆ្នាំ២០២៣ ហើយនឹងនៅបន្តរហូតដល់ឆ្នាំ២០៣០ខាងមុខ ជាមួយនឹងអត្រាប្រមាណ ៥៧,២% បន្ទាប់មកនឹងថយចុះមកត្រឹម ប្រមាណ៤៩,៥% នៅឆ្នាំ២០៥០។

**រូបភាពទី១÷ រចនាសម្ព័ន្ធប្រជាសាស្ត្រ នៅឆ្នាំ២០២៣ និង២០៣០ (%នៃចំនួនប្រជាជនសរុបតាមភេទ)**




ប្រភព÷ ទស្សនវិស័យប្រជាជនពិភពលោកនៃអង្គការសហប្រជាជាតិ ទាញយកថ្ងៃទី២ ខែមករា ឆ្នាំ២០២៤

ដោយស្ថិតនៅក្នុងដំណាក់កាលដំបូងនៃបាតុភូតអន្តរកម្មប្រជាសាស្ត្រ កម្ពុជាកំពុងទទួលបានផលចំណេញពីភាគលាភប្រជាសាស្ត្រ និងអត្រាទាបនៃអ្នករស់នៅក្នុងបន្ទុក ដែលនឹងបង្កើតកាលានុវត្តភាពសម្រាប់ជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងសម្រេចកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ប្រកបដោយចីរភាពក្នុងរយៈពេលប្រមាណ ៣ ទសវត្សរ៍ខាងមុខ។ ប៉ុន្តែកត្តាទាំងនោះនឹងប្រែក្លាយទៅជាបន្ទុកសម្រាប់សេដ្ឋកិច្ចកម្ពុជាវិញ នៅពេលដែលរចនាសម្ព័ន្ធប្រជាសាស្ត្រតាមអាយុរបស់កម្ពុជាផ្លាស់ប្តូរពីរាងពីរ៉ាមីតដែលមានបាតទូលំទូលាយ (Wide Base Pyramid) ទៅជារាងដប (Bottle Shape) នៅឆ្នាំ២០៥០ (រូបភាពទី២ ខាងក្រោម)។ ការណ៍នេះបង្ហាញថា បន្ទាប់ពីឆ្នាំ២០៥០ ចំនួនប្រជាជនដែលមានអាយុលើសពី ៦៤ឆ្នាំ នឹងមានការកើនឡើងជាបន្តបន្ទាប់ ដែលធ្វើឱ្យកម្ពុជាត្រូវប្រឈមនឹងបញ្ហាពីរក្នុងពេលតែមួយ÷ ទីមួយ គឺត្រូវបំពេញតម្រូវការការងាររបស់យុវជនដែលឈានដល់អាយុចូលធ្វើការថ្មី ដែលទាមទារការងារកាន់តែល្អប្រសើរជាងមុន និងទីពីរ គឺត្រូវអភិវឌ្ឍប្រព័ន្ធគាំពារសង្គមរឹងមាំដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន ជាពិសេសក្រុមមនុស្សចាស់។

**សម្គាល់បច្ចេកទេសទី១÷ តើអ្វីទៅជាភាគលាភប្រជាសាស្ត្រ?**

**ភាគលាភប្រជាសាស្ត្រ÷** គឺជាសក្តានុពលកំណើនសេដ្ឋកិច្ច ដែលបណ្តាលមកពីការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុប្រជាជន ជាពិសេស នៅពេលដែលសមាមាត្រនៃចំនួនប្រជាជនក្នុងអាយុធ្វើការ (អាយុ ១៥-៦៤ ឆ្នាំ) មានទំហំធំជាងចំនួនប្រជាជនដែលមិនស្ថិតក្នុងអាយុធ្វើការ (អាយុក្រោម ១៥ឆ្នាំ និងអាយុ ៦៥ឆ្នាំឡើង)។ សក្តានុពលនៃកំណើនសេដ្ឋកិច្ច ដែលបណ្តាលមកពីភាគលាភប្រជាសាស្ត្រនេះ អាចខ្លាំង ឬតិច អាស្រ័យលើគោលនយោបាយ និងការវិនិយោគលើធនធានមនុស្ស ជាពិសេសក្នុងចំណោមចំនួនប្រជាជនវ័យក្មេង (United Nations Population Fund, UNFPA)។ ភាគលាភប្រជាសាស្ត្រ ចាប់ផ្តើមដំបូងនៅពេលដែលអត្រាមានកូនក្នុងចំណោមស្ត្រី និងអត្រាមរណភាពចាប់ផ្តើមធ្លាក់ចុះ ដែលធ្វើឱ្យមានការប្រែប្រួលនៃរចនាសម្ព័ន្ធអាយុប្រជាជន។ ការធ្លាក់ចុះនៃអត្រាមានកូនក្នុងចំណោមស្ត្រី បានធ្វើឱ្យមានការធ្លាក់ចុះនៃសមាមាត្ររបស់ប្រជាជនអាយុក្រោម ១៥ឆ្នាំ ធៀបទៅនឹងប្រជាជនដែលស្ថិតនៅក្នុងវ័យធ្វើការ ហើយដំណាក់កាលដំបូងនៃភាគលាភប្រជាសាស្ត្រនឹងចាប់ផ្តើមបិទមកវិញ ដោយសារការកើនឡើងអាយុសង្ឃឹមរស់របស់ប្រជាជន ដែលធ្វើឱ្យសមាមាត្រនៃប្រជាជនដែលស្ថិតក្នុងវ័យធ្វើការធៀបនឹងអ្នកដែលមានអាយុវ័យចាប់ពី ៦៥ឆ្នាំ ចាប់ផ្តើមមានការកើនឡើង។ រយៈពេលដំបូងនៃភាគលាភប្រជាសាស្ត្រអាចមានរយៈពេលប្រមាណ ៥ទសវត្សរ៍ ឬរហូតដល់ពេលដែលមានការធ្លាក់ចុះនៃអត្រាមានកូនក្នុងចំណោមស្ត្រី ធ្វើឱ្យមានការធ្លាក់ចុះនៃចំនួនអ្នកដែលស្ថិតនៅក្នុងវ័យធ្វើការ ដែលធ្វើឱ្យសមាមាត្រអ្នកដែលស្ថិតនៅក្នុងវ័យធ្វើការធៀបអ្នកមិនស្ថិតនៅក្នុងវ័យធ្វើការចាប់ផ្តើមថយចុះ។ សម្រាប់ប្រទេសកម្ពុជា ភាគលាភប្រជាសាស្ត្របានចាប់ផ្តើមតាំងពីឆ្នាំ២០១០ ហើយត្រូវបានព្យាករថានឹងបញ្ចប់នៅក្នុងអំឡុងឆ្នាំ២០៥០ ឬមានរយៈពេលប្រមាណ ៤០ឆ្នាំ ខណៈប្រទេសជប៉ុនមានរយៈពេល ៤០ឆ្នាំ (១៩៦៤-២០០៤), ប្រទេសកូរ៉េ ៤០ឆ្នាំ (១៩៨៧-២០២៧), ប្រទេសអ៊ីតាលី ១៨ឆ្នាំ (១៩៨៤-២០០២), ប្រទេសអេស្ប៉ាញ ២៣ឆ្នាំ (១៩៩១-២០១៤), ប្រទេសចិន ៣៧ឆ្នាំ (១៩៩៤-២០៣១), ប្រទេសប្រេស៊ីល ៣២ឆ្នាំ (២០០៦-២០៣៨) ប្រទេសថៃ ៣៤ឆ្នាំ (១៩៩៤-២០០៨) និងប្រទេសបង់ក្លាដែស ៣៤ឆ្នាំ (២០១៨-២០៥២)។

**រយៈពេលនៃភាគលាភប្រជាសាស្ត្ររបស់កម្ពុជា**

**(សមាមាត្រអាយុក្រោម ១៤ឆ្នាំ និងសមាមាត្រអាយុ ៦៥ឆ្នាំឡើង ធៀបនឹងចំនួនប្រជាជនស្ថិតក្នុងវ័យធ្វើការអាយុ ១៥ ទៅ ៦៤ឆ្នាំ)**




ប្រភព÷ ទស្សនវិស័យប្រជាជនពិភពលោកនៃអង្គការសហប្រជាជាតិ ទាញយកថ្ងៃទី២ ខែមករា ឆ្នាំ២០២៤

ដោយឡែក ប្រទេសមួយឈានទៅរកប្រទេសដែលមានប្រជាជនវ័យចាស់ត្រូវបែងចែកជា ៣ដំណាក់កាល (យោងតាមអង្គការសហប្រជាជាតិ) គឺ÷ ដំណាក់កាលទី១-ប្រទេសកំពុងឈានទៅរកប្រជាជនវ័យចាស់ ឬ aging society គឺនៅពេលប្រជាជនដែលមានអាយុចាប់ពី ៦៥ឆ្នាំឡើង មានអត្រាពី ៧% ទៅ ១៣%, ដំណាក់កាលទី២-ប្រទេសមានប្រជាជនវ័យចាស់ ឬ aged society គឺនៅពេលអត្រានេះកើនចន្លោះពី ១៤% ទៅ ២០% និងដំណាក់កាលទី៣-ប្រទេសមានប្រជាជនវ័យចាស់ច្រើន ឬ super-aged society គឺអត្រានេះបានកើនដល់ ២១% ឬខ្ពស់ជាងនេះ។

**រូបភាពទី២÷ រចនាសម្ព័ន្ធប្រជាសាស្ត្រ នៅឆ្នាំ២០៥០ (%នៃចំនួនប្រជាជនសរុបតាមភេទ)**




ប្រភព÷ ទស្សនវិស័យប្រជាជនពិភពលោកនៃអង្គការសហប្រជាជាតិ ទាញយកថ្ងៃទី២ ខែមករា ឆ្នាំ២០២៤

បើទោះបីជារចនាសម្ព័ន្ធប្រជាសាស្ត្ររបស់កម្ពុជាបច្ចុប្បន្ន បានធ្វើឱ្យប្រសើរឡើងនូវការប្រកួតប្រជែងតាមរយៈការផ្គត់ផ្គង់កម្លាំងពលកម្មដ៏ច្រើន ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់អន្តរកាលប្រជាសាស្ត្រ ដែលធ្វើឱ្យកម្ពុជាប្រឈមនូវបញ្ហាចំនួន២÷ ទី១) ការកើនឡើងនៃចំនួនប្រជាជនស្ថិតនៅក្នុងវ័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងទី២) ការកើនឡើងនៃចំនួនអ្នកស្ថិតក្នុងវ័យធ្វើការ (រូបភាពទី៣ និងទី៤ ខាងក្រោម)។ រូបភាពទី៣ បង្ហាញថាចំនួនប្រជាជនស្ថិតនៅក្នុងវ័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អាយុ ១៥ ទៅ ២៤ឆ្នាំសរុប មាននិន្នាការកើនឡើងពី ២,៩លាននាក់ ទៅប្រមាណ ៣,១លាននាក់ ឬកើនឡើងប្រមាណ ៤ម៉ឺននាក់ក្នុងឆ្នាំ ចន្លោះឆ្នាំ ២០២៣-២០២៨។

**រូបភាពទី៣÷ ចំនួនប្រជាជនក្នុងវ័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អាយុពី ១៥ទៅ ២៤ឆ្នាំ (ពាន់នាក់) ពីឆ្នាំ ២០២៣-២០២៨**




ប្រភព÷ ទស្សនវិស័យប្រជាជនពិភពលោកនៃអង្គការសហប្រជាជាតិ ទាញយកថ្ងៃទី២ ខែមករា ឆ្នាំ២០២៤

រូបភាពទី៤ ខាងក្រោមបង្ហាញថា ប្រជាជនស្ថិតនៅក្នុងអាយុធ្វើការសរុប (អាយុ ១៥-៦៤ឆ្នាំ) បន្តកើនឡើងប្រមាណ ១២៤,០ពាន់នាក់/ ឆ្នាំ ចន្លោះឆ្នាំ២០២៣ និង២០២៨ ដែលក្នុងនោះចំនួនអ្នកគ្រប់អាយុឈានចូលធ្វើការថ្មី (ឈានចូលអាយុ ១៥ឆ្នាំ) ប្រមាណ ៣២២,២ពាន់នាក់/ ឆ្នាំ និងចំនួនអ្នកចាកចេញ (ស្លាប់ ឬឈានដល់អាយុ ៦៥ឆ្នាំ) មានប្រមាណ ១៩៨,២ពាន់នាក់/ ឆ្នាំ។ ការណ៍នេះ បង្ហាញអំពីភាពចាំបាច់សម្រាប់កម្ពុជា ក្នុងការបង្កើតការងារថ្មីកាន់តែមានគុណភាពល្អ សម្រាប់កម្លាំងពលកម្មថ្មីដែលឈានដល់អាយុចូលធ្វើការ។

**រូបភាពទី៤÷ ចំនួនប្រជាជនកម្ពុជាស្ថិតក្នុងវ័យធ្វើការ (ពាន់នាក់) ពីឆ្នាំ១៩៨០-២០៥០**




*ចំណាំ÷ ការប្រែប្រួលអ្នកស្ថិតនៅក្នុងវ័យធ្វើការ= ចំនួនអ្នកចូលថ្មី- ចំនួនអ្នកចាកចេញ; ចំនួនអ្នកចូលថ្មីគឺសំដៅលើចំនួនប្រជាជនដែលឈានចូលគ្រប់អាយុ ១៥ឆ្នាំ; ចំនួនអ្នកចាកចេញ= ចំនួនអ្នកដែលស្លាប់+(អ្នកធ្វើទេសន្តរប្រវេសន៍ចេញក្រៅប្រទេស-អ្នកដែលធ្វើទេសន្តរប្រវេសន៍ចូលក្នុងប្រទេស)

ប្រភព÷ ទស្សនវិស័យប្រជាជនពិភពលោកនៃអង្គការសហប្រជាជាតិ ទាញយកថ្ងៃទី២ ខែមករា ឆ្នាំ២០២៤

ជាមួយនឹងការធ្លាក់ចុះនៃអត្រាមានកូននៅក្នុងចំណោមស្ត្រីជាបន្តបន្ទាប់ពីប្រមាណ ៦,១នាក់ ចន្លោះឆ្នាំ ១៩៨០-១៩៨៤ មកប្រមាណជា ២,៣នាក់ នៅចន្លោះឆ្នាំ ២០២០-២០២៤ និងការធ្លាក់ចុះនៃអត្រាមនុស្សស្លាប់ក្នុងចំណោម ១ ០០០នាក់ ពី ៤៩,៩នាក់ ទៅ ១៨,៩នាក់ ក្នុងចន្លោះពេលដូចគ្នា បានធ្វើឱ្យចំនួនប្រជាជនសរុបប្រទេសកម្ពុជានឹងកើនពី ៦,២លាននាក់ នៅឆ្នាំ១៩៨០ ដល់ប្រមាណ ១៧,២លាននាក់ នៅឆ្នាំ២០២៣ ហើយបន្តកើនឡើងដល់ចំនួនខ្ពស់បំផុតប្រមាណជា ២០,៨លាននាក់ នៅក្នុងឆ្នាំ២០៦៧។ ទន្ទឹមនឹងនេះ ភាគលាភប្រជាសាស្ត្រកម្ពុជាបានចាប់ផ្តើមតាំងពីឆ្នាំ២០១០ ហើយត្រូវបានព្យាករថានឹងបញ្ចប់នៅក្នុងអំឡុងឆ្នាំ ២០៥០ ឬមានរយៈពេលប្រមាណ ៤០ឆ្នាំ។ ការណ៍នេះ បានបង្ហាញអំពីសារសំខាន់នៃនិន្នាការប្រជាសាស្ត្រដែលត្រូវយកចិត្តទុកដាក់បំផុត ជាពិសេស ក្នុងការទាញយកប្រយោជន៍ឱ្យបានជាអតិបរមានៃភាគលាភប្រជាសាស្ត្រដែលនៅសល់រយៈពេលប្រមាណជា ២៥ឆ្នាំ តាមរយៈការវិនិយោគទៅលើសុខភាព ការអប់រំ និងបណ្តុះបណ្តាលដល់ប្រជាជន ដើម្បីពន្យាជាសន្សឹមៗនៃរយៈពេលនៃការទាញភាគលាភប្រជាសាស្ត្រឱ្យបានកាន់តែយូរ ខណៈប្រទេសអភិវឌ្ឍន៍ជាច្រើនលើពិភពលោកបានខកខានមិនបានអនុវត្ត តាមរយៈការគាំទ្រដល់ម្តាយ និងទារក

មុននិងក្រោយពេលសម្រាល ការបង្កើតទារកដ្ឋាននិងមត្តេយ្យសហគមន៍គាំទ្រដល់ការចិញ្ចឹមបីបាច់ និងទទួលបានការអប់រំ ការគាំទ្រដល់ការកែសម្រួលលក្ខខណ្ឌទីផ្សារការងារ និងវិធានការផ្សេងៗទៀត សំដៅលើកទឹកចិត្តប្រជាជន និងរក្សាបាននូវអត្រានៃការជំនួស (Replacement Rate) ប្រមាណ ២,១នាក់/ គ្រួសារ។

**ខ. កម្រិតនៃការទទួលបានការអប់រំរបស់កម្លាំងពលកម្ម**

កម្រិតនៃការទទួលបានការអប់រំ និងការបណ្តុះបណ្តាលមានការកើនឡើងជាលំដាប់ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃអត្រាអ្នកដែលទទួលបានកម្រិតការអប់រំខ្ពស់ នៅក្នុងក្រុមអាយុប្រជាជនវ័យក្មេង (អាយុ ១៥-៣៤ឆ្នាំ) ដែលនេះជាសក្តានុពលធនធានមនុស្សវ័យក្មេងរបស់កម្ពុជា។ បើទោះបីជាមានវឌ្ឍនភាពល្អប្រសើរកន្លងមក ប្រជាជនដែលស្ថិតនៅក្នុងវ័យធ្វើការ(អាយុ ១៥-៦៤ឆ្នាំ) ប្រមាណ ៨៥,២% ឬប្រមាណ ៩,៤៣លាននាក់ ទទួលបានការអប់រំទាបជាងមធ្យមសិក្សាបឋមភូមិ។ ជាមួយនឹងការទទួលបានការអប់រំមូលដ្ឋានទាប ប្រជាជនទាំងនោះភាគច្រើនធ្វើការក្នុងប្រភេទមុខរបរដែលមានផលិតភាពទាប ហើយក៏ជារនាំងនៃការទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈផ្លូវការ ព្រមទាំងផ្តល់ផលលំបាកក្នុងការបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ ឬបង្កើនជំនាញ ក្នុងការបង្កើនលទ្ធភាពចាប់យកឱកាសការងារដែលល្អប្រសើរជាងមុន។ ការណ៍នេះ បង្ហាញអំពីភាពចាំបាច់ក្នុងការពង្រឹង និងបង្កើនអត្រាគង់វង្សរបស់សិស្សរហូតបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ ដើម្បីកាត់បន្ថយលំហូរនៃកម្លាំងពលកម្មដែលមានការអប់រំទាបចូលទៅក្នុងទីផ្សារ និងការបង្កើនការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈទៅដល់កម្លាំងពលកម្មដែលនៅក្នុងទីផ្សារ ដើម្បីធ្វើបរិវត្តកម្មនៃរចនាសម្ព័ន្ធកម្លាំងពលកម្មពីគ្មានជំនាញទៅជំនាញកាន់តែខ្ពស់ ប្រកបដោយភាពងាយបត់បែនរហ័សស្របនឹងតម្រូវការទីផ្សារការងារ។

កន្លងមក កម្ពុជាទទួលបានវឌ្ឍនភាពជាច្រើនលើការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជាក់ស្តែង របាយការណ៍រដ្ឋបាលស្តីពីការបូកសរុបលទ្ធផល នៃការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជារបស់ក្រសួង បានបង្ហាញថាប្រជាជនសរុបចំនួនប្រមាណ ១,៦៧លាននាក់ ទទួលបានការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប៉ុន្តែចំនួននេះគឺស្ថិតនៅក្នុងចំនួនមួយតិច (១៧,៧%) ធៀបនឹងក្រុមគោលដៅប្រមាណ ៩,៤៣លាននាក់ ហើយវគ្គបណ្តុះបណ្តាលជំនាញមួយចំនួនក៏ហួសសម័យកាល និងមិនអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ន ដែលទាមទារឱ្យមានការធ្វើបច្ចុប្បន្នភាព និងរៀបចំនូវកញ្ចប់គុណវុឌ្ឍិបណ្តុះបណ្តាលបន្ថែម។ បន្ថែមលើនេះ ក៏មានតម្រូវការចាំបាច់ក្នុងការជំរុញការធ្វើតេស្តទទួលស្គាល់ការសិក្សាដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្ន (Recognition of Prior Learning/ Recognition of Current Competencies-RPL/RCC) ដើម្បីបើកច្រកក្នុងការទទួលស្គាល់ជំនាញដល់កម្លាំងពលកម្មដែលមានជំនាញ និងអាចបើកច្រកកាន់តែទូលំទូលាយសម្រាប់ការទទួលបានការបណ្តុះបណ្តាលពេញមួយជីវិត។

**តារាងទី២ ÷ ការបែងចែកចំនួនប្រជាជនស្ថិតនៅក្នុងវ័យធ្វើការ តាមកម្រិតនៃការអប់រំ ក្នុងឆ្នាំ២០២១**

| ក្រុមអាយុ | គ្មាន ឬ រៀនបាន តិចតួច | មិនបញ្ចប់ ថ្នាក់បឋម សិក្សា | បញ្ចប់ថ្នាក់ បឋមសិក្សា | មធ្យម សិក្សា បឋមភូមិ | ការអប់រំទាបជាងឬ ស្មើមធ្យមសិក្សា បឋមភូមិ | មធ្យម សិក្សា ទុតិយភូមិ | ឧត្តម សិក្សា | សរុប |
|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥=១+២+៣+៤ | ៦ | ៧ | ៨ |
| ១៥-២៤ | ៤,០% | ២៣,០% | ៣៣,៦% | ២២,៣% | ៨២,៩% | ១១,១% | ៦,០% | ១០០% |
| ២៥-៣៤ | ៩,៥% | ២៦,៩% | ២៦,៤% | ១៥,៨% | ៧៨,៧% | ៩,៨% | ១១,៥% | ១០០% |
| ៣៥-៤៤ | ១៦,៥% | ៣៥,៧% | ២៣,៩% | ១២,១% | ៨៨,២% | ៦,៦% | ៥,២% | ១០០% |
| ៤៥-៥៤ | ១៩,៩% | ៤១,៨% | ១៩,៩% | ១០,៩% | ៩២,៥% | ៥,១% | ២,៤% | ១០០% |
| ៥៥-៦៤ | ២២,២% | ៤៩,១% | ១៦,០% | ៨,៤% | ៩៥,៨% | ២,៥% | ១,៧% | ១០០% |
| **សរុប** | **១២,០%** | **៣១,៧%** | **២៦,០%** | **១៥,៥%** | **៨៥,២%** | **៨,២%** | **៦,៦%** | **១០០%** |

ប្រភព÷ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ ២០២១

## ២.១.២. ស្ថានភាពសេដ្ឋកិច្ច និងតម្រូវការកម្លាំងពលកម្មបច្ចុប្បន្ន និងអនាគត

### ក. ស្ថានភាពសេដ្ឋកិច្ច និងតម្រូវការកម្លាំងពលកម្មបច្ចុប្បន្ន

ប្រទេសកម្ពុជាបន្តរក្សាបានសន្តិភាព និងស្ថិរភាព ដែលជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចបន្តមានការរីកចម្រើនគួរជាទីមោទនៈ។ សេដ្ឋកិច្ចកម្ពុជា បានកើនឡើងជាមធ្យមក្នុងអត្រា ៧% ជាង២ទសវត្សរ៍ លើកលែងតែក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដ-១៩ ដែលសេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះក្នុងអត្រា-៣,១% ប៉ុន្តែបានងើបឡើងវិញក្នុងទម្រង់ជាអក្សរវី (V) នៅក្រោយវិបត្តិជំងឺកូវីដ-១៩ ខណៈសេដ្ឋកិច្ចនៃប្រទេសមួយចំនួនកំពុងស្ថិតក្នុងភាពមិនប្រាកដប្រជាខ្ពស់ ជាមួយអត្រាអ្នកអត់ការងារ អតិផរណា និងបញ្ហាបំណុលសាធារណៈ។ ជាលទ្ធផល ចំនួនអ្នកមានការងារធ្វើបានបន្តកើនឡើងជាមួយនឹងអត្រាជាមធ្យមប្រចាំឆ្នាំប្រមាណ ០,៨% ចន្លោះឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ អនុបាតនៃអ្នកមានការងារធ្វើធៀបនឹងប្រជាជន (អាយុ ១៥ឆ្នាំឡើង) ដែលបង្ហាញពីលទ្ធភាពនៃសេដ្ឋកិច្ចក្នុងការបង្កើតការងារជូនប្រជាជន រួមបញ្ចូលទាំងអ្នកដែលឈានចូលទីផ្សារការងារថ្មី និងអ្នកដែលមានបំណងផ្លាស់ប្តូរកន្លែងការងារ គឺស្ថិតក្នុងអត្រាខ្ពស់ក្នុងរង្វង់ ៧៥%។ ប៉ុន្តែអនុបាតនេះមានភាពខុសគ្នារវាងបុរស និងស្ត្រី ដោយបុរសមានអត្រាប្រមាណជាង ៨០% ដែលអត្រានេះខ្ពស់ជាងអត្រារបស់ស្ត្រីដែលមានប្រមាណចន្លោះពី ៦៨,៨% ដល់ ៦៩,៦% ប៉ុណ្ណោះ ចន្លោះឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។

## តារាងទី៣÷ សូចនាករសេដ្ឋកិច្ច និងទីផ្សារការងារសំខាន់ៗ

| បរិយាយ | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| អត្រាកំណើន ផ.ស.ស. (ថ្លៃថេរឆ្នាំ២០០០) | | ៧,១% | -៣,១% | ៣,០% | ៥,២% | ៥,៦% |
| អត្រាកំណើនការងារ | | ២,៥% | -៤,១% | ១,៨% | ១,១% | ២,៧% |
| អត្រាចូលរួមកម្លាំងពលកម្ម (១៥ឆ្នាំឡើង) | សរុប | ៧៦,០% | ៧៥,៣% | ៧៦,០% | ៧៦,០% | ៧៥,៨% |
| | ស្រី | ៦៩,៧% | ៦៩,១% | ៧០,១% | ៦៩,៧% | ៦៩,៥% |
| | ប្រុស | ៨២,៧% | ៨១,៩% | ៨២,៣% | ៨២,៧% | ៨២,៤% |
| អនុបាតអ្នកមានការងារទៅនឹងប្រជាជន (១៥ឆ្នាំឡើង) | សរុប | ៧៥,៩% | ៧៥,១% | ៧៥,៧% | ៧៥,៤% | ៧៥,២% |
| | ស្រី | ៦៩,៦% | ៦៨,៨% | ៦៩,៤% | ៦៩,៣% | ៦៩,១% |
| | ប្រុស | ៨២,៦% | ៨១,៧% | ៨២,០% | ៨១,៩% | ៨១,៧% |
| អត្រាអ្នកគ្មានការងារ (១៥ឆ្នាំឡើង) *(*សម្គាល់បច្ចេកទេសទី២)* | សរុប | ០,១% | ០,២% | ០,៤% | ០,២% | ០,២% |
| | ស្រី | ០,១% | ០,២% | ០,៤% | ០,៣% | ០,២% |
| | ប្រុស | ០,១% | ០,១% | ០,៤% | ០,២% | ០,២% |
| អត្រាអ្នកគ្មានការងារ (១៥-២៤ឆ្នាំ) *(*សម្គាល់បច្ចេកទេសទី២)* | សរុប | ០,៤% | ០,៨% | ០,៩% | ០,៨% | ០,៧% |
| | ស្រី | ០,៥% | ០,៦% | ១,០% | ០,៩% | ០,៨% |
| | ប្រុស | ០,៣% | ០,៥% | ០,៨% | ០,៧% | ០,៦% |

ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (សម្រាប់ទិន្នន័យ ផ.ស.ស.), អង្គការអន្តរជាតិខាងការងារ (សម្រាប់ទិន្នន័យសូចនាករទីផ្សារការងារ)

ទន្ទឹមនេះ អត្រានិកម្មភាពសម្រាប់ប្រជាជនអាយុ ១៥ឆ្នាំឡើង ស្ថិតក្នុងអត្រាមួយទាបក្រោម ១,០% ប៉ុន្តែអត្រានិកម្មភាពសម្រាប់យុវជន (អាយុចន្លោះពី ១៥-២៤ឆ្នាំ) ស្ថិតក្នុងកម្រិតខ្ពស់ជាងអ្នកដែលមានអាយុ ១៥ឆ្នាំឡើង។ ការណ៍នេះបង្ហាញថា ក្រុមយុវជនមានការលំបាកជាងក្រុមអាយុផ្សេងក្នុងការទទួលបានការងារ ដែលទាមទារឱ្យមានការរៀបចំជាកម្មវិធី ឬគោលនយោបាយទីផ្សារការងារសកម្មកាន់តែមុតស្រួច ស៊ីជម្រៅ និងផ្តោតជាសំខាន់ក្នុងការជួយដល់យុវជនដែលឈានចូលទីផ្សារការងារជាលើកដំបូង។

**សម្គាល់បច្ចេកទេសទី២÷ និយមន័យអ្នកមានការងារ ឬអ្នកគ្មានការងារ**

**អ្នកមានការងារធ្វើ÷** ***សំដៅលើ អ្នកមានអាយុ ១៥ឆ្នាំឡើង ដែលក្នុងរយៈពេលមួយសប្តាហ៍ ឬ៧ថ្ងៃចុងក្រោយ បានចូលរួមក្នុងសកម្មភាពផលិតផលិតផល ឬផ្តល់សេវាកម្ម ដើម្បីទទួលបានប្រាក់ឈ្នួល ឬប្រាក់ចំណេញ យ៉ាងតិច ១ម៉ោង*** ដោយគិតបញ្ចូលទាំងអ្នកកំពុងធ្វើការក្នុង និងក្រៅប្រទេស និងអ្នកដែលអវត្តមាននៅកន្លែងធ្វើការ ដោយមូលហេតុនៃការឈប់សម្រាកដោយសារមានជំងឺគ្រោះថ្នាក់ការងារ ការសិក្សា ឬការបណ្តុះបណ្តាល សម្រាកលំហែរមាតុភាព ឬដោយមូលហេតុផ្សេងៗ។ ដោយឡែក **អ្នកគ្មានការងារ** សំដៅលើបុគ្គលទាំងឡាយណាដែលស្ថិតនៅក្នុងអាយុធ្វើការ ដែល**មិនមានការងារ** និង**កំពុងស្វែងរកការងារ** និង**អាចទទួលយកឱកាសការងារ ឬអាចធ្វើការងារបានប្រសិនបើមាន។** ក្នុងន័យនេះ បើមានបុគ្គលមិនមានការងារ ហើយមិនព្រមស្វែងរកការងារ ឬមានឱកាសការងារ ប៉ុន្តែមិនព្រមទទួលយកឱកាសនេះ ក៏មិនត្រូវបានចាត់ទុកជាអ្នកគ្មានការងារដែរ។ ដោយឡែកបុគ្គលទាំងអស់នេះគឺត្រូវបានចាត់ទុកថាស្ថិតនៅក្រៅកម្លាំងពលកម្ម។ ហេតុដូច្នេះហើយនៅក្នុងទីផ្សារការងារ ក្រៅពីអ្នកនៅក្នុងកម្លាំងពលកម្ម (**ចំនួនអ្នកមានការងារ + ចំនួនអ្នកអត់ការងារ**) គឺមានប្រជាជនគ្រប់អាយុធ្វើការមួយចំនួនទៀតស្ថិតនៅក្រៅកម្លាំងពលកម្ម ដែលអ្នកនៅក្រៅកម្លាំងពលកម្មត្រូវបានឱ្យនិយមន័យថា ជាអ្នកក្នុងអាយុធ្វើការទាំងឡាយណាដែលអត់ធ្វើការ ឬមិនធ្វើការក្នុងរយៈពេលជាក់លាក់ណាមួយ ដោយមូលហេតុ **១)** ជាប់រៀននៅតាមគ្រឹះស្ថានសិក្សា (សិស្ស/និស្សិត), **២)** ជាប់ភារកិច្ចគ្រួសារ ថែទាំសមាជិកគ្រួសារ ឬជាមេផ្ទះ, ចូលនិវត្តន៍ ឬចាស់ជរា, ពិការភាព និងមិនអាចបំពេញការងារបាន, **៣)** ជឿថាគ្មានការងារធ្វើ មិនចង់ធ្វើការ ឬមិនចាប់ផ្តើមការងារក្នុងរយៈពេលខ្លីណាមួយ។ ជាការគណនា អត្រាអ្នកគ្មានការងារ គឺជាផលធៀបរវាងចំនួនអ្នកគ្មានការងារ និងចំនួនអ្នកនៅក្នុងកម្លាំងពលកម្ម។

***អត្រាអ្នកគ្មានការងារធ្វើ (%) = (ចំនួនអ្នកគ្មានការងារ/ចំនួនកម្លាំងពលកម្មសរុប) x ១០០***

យោងតាមនិយមន័យខាងលើ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជា ជាទូទៅតែងមានអត្រាអ្នកអត់ការងារធ្វើទាបដោយប្រជាជនភាគច្រើនបំផុតមានការងារធ្វើ ដែលអាចជាការងារក្នុងវិស័យកសិកម្ម ឬការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធជាដើម។ តាមនិយមន័យនេះ ទិន្នន័យដែលបានទាញចេញបានជាសាធារណៈពី ILOSTAT (ilostat.ilo.org/data/) របស់អង្គការ ILO (*ធ្វើការចងក្រងស្ថិតិការងារផ្លូវការពីគ្រប់ប្រទេសដោយស្របទៅនឹងអនុសញ្ញាអន្តរជាតិខាងការងារពាក់ព័ន្ធនឹងនិយមន័យ និងការវាស់វែងស្ថិតិការងារ ព្រមទាំងធ្វើការប៉ាន់ស្មានដោយឈរលើទិន្នន័យនេះ)* បានបង្ហាញថា **ចាប់តាំងពីឆ្នាំ១៩៩១ ប្រទេសកម្ពុជារក្សាបាននូវអត្រាអ្នកគ្មានការងារទាបប្រមាណ ១%** ហើយទាបជាងគេប្រសិនបើប្រៀបធៀបជាមួយនឹងបណ្តាក្រុមប្រទេស ដែលមានសេដ្ឋកិច្ចប្រហាក់ប្រហែលកម្ពុជា និងទាបជាងបណ្តាប្រទេសនៅក្នុងតំបន់ ដូចជាប្រទេសថៃ វៀតណាម និងឡាវជាដើម។

**សូចនាករមួយផ្សេងទៀតដែលវាស់វែងអំពីស្ថានភាពមានការងារ** គឺ **អនុបាតអ្នកមានការងារធៀបនឹងប្រជាជន** (Employment-to-Population Ratio) ដែលជាផលធៀបរវាងចំនួនអ្នកមានការងារ និងចំនួន**អ្នកនៅក្នុងអាយុធ្វើការទាំងនៅក្នុងកម្លាំងពលកម្ម** (ជាអ្នកមានការងារធ្វើ ឬអ្នកគ្មានការងារធ្វើ) និង**អ្នកនៅក្រៅកម្លាំងពលកម្ម។** សូចនាករនេះ បង្ហាញពីលទ្ធភាពនៃសេដ្ឋកិច្ចក្នុងការបង្កើតការងារជូនប្រជាជនរួមបញ្ចូលទាំងអ្នកដែលឈានចូលទីផ្សារការងារថ្មី និងអ្នកដែលមានបំណងផ្លាស់ប្តូរកន្លែងការងារ ដែលអាចគណនាដូចរូបមន្ត÷

**អនុបាតអ្នកមានការងារធ្វើធៀបនឹងប្រជាជន (%) = (ចំនួនអ្នកមានការងារធ្វើ / អ្នកស្ថិតនៅក្នុងអាយុធ្វើការ) x ១០០**

ជារួម ការពិនិត្យលើអត្រាអ្នកគ្មានការងារ ឬអនុបាតអ្នកមានការងារធៀបនឹងប្រជាជន គឺមិនត្រឹមតែពិនិត្យលើតួលេខ ឬត្រឹមភាគរយតែប៉ុណ្ណោះទេ គឺត្រូវពិនិត្យទៅលើស្ថិរភាពនិងនិន្នាការ ព្រមទាំងបូកបញ្ចូលជាមួយនឹងសូចនាករទីផ្សារការងារផ្សេងបន្ថែមទៀតដូចជា អត្រាអ្នកចូលរួមកម្លាំងពលកម្ម, ភាគរយនៃប្រជាជនដែលធ្វើការក្រៅពីវិស័យកសិកម្ម, ភាគរយអ្នកដែលធ្វើការក្នុងស្ថានភាពការងារដែលងាយរងគ្រោះជាដើម ដែលជាសូចនាករបន្ថែមក្នុងការវាស់វែងអំពីកំណើនការងារដែលមានផលិតភាព និងលក្ខខណ្ឌការងារល្អ។

នៅក្នុងឆ្នាំ២០២៣ ជាមួយនឹងការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចប្រមាណជា ៥,៦% ទីផ្សារការងារកម្ពុជាបន្តរក្សាបាននូវស្ថានភាពរឹងមាំគួរឱ្យកត់សម្គាល់ ជាមួយនឹងអត្រាកំណើន ២,៧% ឬអាចបង្កើតការងារបន្ថែមបានចំនួន ២៤,៦ម៉ឺនការងារ។ ប្រសិនបើពិនិត្យទៅតាមវិស័យ ចន្លោះឆ្នាំ២០២២ និងឆ្នាំ២០២៣ ចំនួនអ្នកដែលធ្វើការងារសរុបនៅក្នុងប្រទេសត្រូវបានប៉ាន់ស្មានថា កើនឡើងប្រមាណជា ២,៧% ឬស្មើនឹងប្រមាណ ២៤៦,៦ពាន់នាក់ ដែលធ្វើឱ្យចំនួនអ្នកមានការងារធ្វើសរុបនៅក្នុងប្រទេសកើនដល់ប្រមាណ ៩,៣លាននាក់ ដែលក្នុងនោះមាន៖

- **វិស័យកសិកម្ម៖** បានថយចុះចំនួនការងារប្រមាណ ៦៦,២ពាន់នាក់ ដែលជានិន្នាការនៃដំណើរការនៃការធ្វើឧស្សាហាភាវូបនីយកម្ម តាមរយៈការផ្ទេរកម្លាំងពលកម្មពីវិស័យនេះ ទៅរកការងារក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម ដែលមានផលិតភាពខ្ពស់ជាង
- **វិស័យឧស្សាហកម្ម៖** បានកើនឡើងប្រមាណ ៨៥,៥ពាន់នាក់ ឬស្មើនឹង ៣,២% ដែលភាគច្រើននៃកំណើននេះ ត្រូវបានសង្កេតឃើញនៅក្នុងវិស័យសំណង់ និងវិស័យឧស្សាហកម្មផ្សេងទៀត
- **វិស័យសេវាកម្ម៖** មានកំណើនវិជ្ជមាន ក្នុងអត្រា ៦,៦% ដែលជំរុញដោយការងើបឡើងវិញនៃអនុវិស័យការស្នាក់នៅ និងភោជនីយដ្ឋាន ក្រោយវិបត្តិជំងឺកូវីដ-១៩ វិស័យពាណិជ្ជកម្មលក់ដុំនិងរាយ និងវិស័យសេវាកម្មផ្សេងទៀត។

**តារាងទី៤៖ រចនាសម្ព័ន្ធអ្នកមានការងារធ្វើ (១៥ ទៅ ៦៤ឆ្នាំ) នៅក្នុងប្រទេសតាមវិស័យ ឆ្នាំ២០២២ និង២០២៣**

| បរិយាយ | ២០២២ | | ២០២៣ | | កំណើន | |
|---|---|---|---|---|---|---|
| | ពាន់នាក់ | % | ពាន់នាក់ | % | ពាន់នាក់ | % |
| **កសិកម្ម** | **២ ៩៤១,២** | **៣២,៤** | **២ ៨៧៤,៩** | **៣០,៩** | **-៦៦,២** | **-២,៣** |
| **ឧស្សាហកម្ម** | **២ ៦៧០,៨** | **២៩,៤** | **២ ៧៥៦,៣** | **២៩,៦** | **៨៥,៥** | **៣,២** |
| កាត់ដេរ | ១ ១៤៨,២ | ១២,៧ | ១ ១៦១,៥ | ១២,៥ | ១៣,៣ | ១,២ |
| សំណង់ | ៩១៩,២ | ១០,១ | ៩៥៨,០ | ១០,៣ | ៣៨,៧ | ៤,២ |
| ឧស្សាហកម្មផ្សេងទៀត | ៦០៣,៣ | ៦,៧ | ៦៣៦,៨ | ៦,៨ | ៣៣,៥ | ៥,៦ |
| **សេវាកម្ម** | **៣ ៤៥៧,៣** | **៣៨,១** | **៣ ៦៨៤,៧** | **៣៩,៥** | **២២៧,៤** | **៦,៦** |
| ពាណិជ្ជកម្មលក់ដុំ និងរាយ | ១ ៤១៣,៩ | ១៥,៦ | ១ ៤៦១,៦ | ១៥,៧ | ៤៧,៧ | ៣,៤ |
| ការស្នាក់នៅ និងភោជនីយដ្ឋាន | ៣៨៣,៣ | ៤,២ | ៥២៦,៣ | ៥,៦ | ១៤៣,០ | ៣៧,៣ |
| ការដឹកជញ្ជូន និងគមនាគមន៍ | ៤៤១,៣ | ៤,៩ | ៤៦០,៥ | ៤,៩ | ១៩,២ | ៤,៣ |
| អចលនទ្រព្យ | ៤១៣,១ | ៤,៦ | ៤០៥,៨ | ៤,៤ | -៧,៤ | -១,៨ |
| សេវាកម្មផ្សេងទៀត | ៨០៥,៧ | ៨,៩ | ៨៣០,៦ | ៨,៩ | ២៤,៩ | ៣,១ |
| **ការងារក្នុងប្រទេសសរុប** | **៩ ០៦៩,៣** | **១០០** | **៩ ៣១៥,៩** | **១០០** | **២៤៦,៦** | **២,៧** |

ប្រភព៖ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០២៤*

*ចំណាំបច្ចេកទេស៖ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺផ្អែកលើទិន្នន័យអ្នកមានការងារក្នុងប្រទេសដែលធ្វើការប៉ាន់ស្មានពីអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ចាប់ពី ឆ្នាំ១៩៩៣ ដល់ ២០២១ ជាមួយទៅនឹងលទ្ធផលនៃការព្យាករកំណើនសេដ្ឋកិច្ចតាមវិស័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



ញ

## ២. ការព្យាករនិន្នាការតម្រូវការទីផ្សារការងារនាពេលអនាគត

សម្រាប់ការព្យាកររយៈពេលមធ្យម (ចន្លោះឆ្នាំ២០២៤-២០២៦) កម្ពុជាត្រូវបានព្យាករថានឹងអាចបង្កើតការងារបន្ថែមជូនប្រជាពលរដ្ឋប្រមាណ ២៣,៥ម៉ឺននាក់ ក្នុងមួយឆ្នាំ។ កំណើនការងារជាមធ្យមប្រមាណ ២,៥% ក្នុងមួយឆ្នាំនឹងធ្វើឱ្យចំនួនអ្នកមានការងារសរុបកើនឡើងដល់ប្រមាណ ១០,២លាននាក់ នៅឆ្នាំ២០២៦។ គួរកត់សម្គាល់ផងដែរថា វិស័យឧស្សាហកម្មដែលជាក្បាលម៉ាស៊ីនបង្កើតការងារ ត្រូវបានព្យាករថានឹងបង្កើតការងារប្រមាណ ១៦,៥ម៉ឺននាក់ ក្នុងមួយឆ្នាំ ឬស្មើនឹងអត្រាកំណើនការងារ ៥,៧%។ រីឯវិស័យសេវាកម្មវិញត្រូវបានរំពឹងថានឹងបង្កើតការងារប្រមាណ ១៦,៧ម៉ឺននាក់ ក្នុងមួយឆ្នាំស្មើនឹងអត្រាកំណើនការងារ ៤,៤%។ និន្នាការកំណើនការងារនៅក្នុងវិស័យទាំង ២នេះ គឺដោយសារការកើនឡើងនៃតម្រូវការក្នុងការពង្រីកផលិតកម្ម និងអាជីវកម្ម ព្រមទាំងការផ្លាស់ប្តូរការងារពីវិស័យកសិកម្ម ដែលត្រូវបានព្យាករថាចំនួនការងារនឹងថយចុះប្រមាណ ៩,៨ម៉ឺននាក់ ក្នុងមួយឆ្នាំ ស្មើនឹងអត្រាថយចុះការងារ ៣,៥% ក្នុងមួយឆ្នាំ។

**រូបភាពទី៥÷ ការព្យាករកំណើនការងារជាមធ្យមក្នុងមួយឆ្នាំសម្រាប់ឆ្នាំ ១៩៩៤-២០២៦ តាមវិស័យ**




ប្រភព÷ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០២៤

បើពិនិត្យឱ្យស៊ីជម្រៅតាមអនុវិស័យ (តារាងទី៥)÷

- អនុវិស័យដែលមានអត្រាកំណើនការងារលឿន និងចំនួនការងារបង្កើតបន្ថែមថ្មីច្រើនក្នុងមួយឆ្នាំមាន÷ ការស្នាក់នៅ និងភោជនីយដ្ឋាន (អត្រាកំណើន ១០,១% ស្មើចំនួនការងារបន្ថែម ៥,៨ម៉ឺននាក់), សំណង់ (អត្រាកំណើន ៦,៧% ស្មើចំនួនការងារបន្ថែម ៦,៨ម៉ឺននាក់), និងឧស្សាហកម្មផ្សេងទៀត (អត្រាកំណើន ៦,៤% ស្មើចំនួនការងារបន្ថែម ៤,៣ម៉ឺននាក់)
- អនុវិស័យផ្សេងទៀត ដែលបង្កើតការងារច្រើនជាង ២ម៉ឺននាក់ ក្នុងមួយឆ្នាំ រួមមាន÷ លក់ដុំនិងរាយ (៥,៤ម៉ឺននាក់), កាត់ដេរ (៥,៣ម៉ឺននាក់), ការដឹកជញ្ជូននិងគមនាគមន៍ (២,១ម៉ឺននាក់) និងសេវាកម្មផ្សេងទៀត (២,៤ម៉ឺននាក់)

- អនុវិស័យនៃវិស័យកសិកម្ម ត្រូវរំពឹងថានឹងថយចុះនៃចំនួនអ្នកមានការងារ ដោយអនុវិស័យដាំដុះថយចុះ ៥,៧ម៉ឺននាក់ និងអនុវិស័យកសិកម្មផ្សេងទៀតថយចុះ ៤ម៉ឺននាក់។

**តារាងទី៥÷ ការព្យាករកំណើនការងារជាមធ្យមក្នុងមួយឆ្នាំសម្រាប់ឆ្នាំ ២០២៤-២០២៦ តាមវិស័យ និងអនុវិស័យ**

| វិស័យ/អនុវិស័យ | កំណើនផ.ស.ស.ជាមធ្យម/ឆ្នាំ | អត្រាកំណើនការងារ | ចំនួនការងារ/ឆ្នាំ (នាក់) |
|---|---|---|---|
| **កសិកម្ម** | **១.៣** | **-៣,៥%** | **-៩៧ ៥៣២** |
| **ឧស្សាហកម្ម** | **៩,0** | **៥,៧%** | **១៦៤ ៧៣០** |
| កាត់ដេរ | ៨,៧% | ៤,៤% | ៥៣ ១០១ |
| សំណង់ | ៥,២% | ៦,៧% | ៦៨ ៣១៨ |
| ឧស្សាហកម្មផ្សេងទៀត | ១២,៦% | ៦,៤% | ៤៣ ៣១១ |
| **សេវាកម្ម** | **៦,៩%** | **៤,៤%** | **១៦៧ ៤៤២** |
| ពាណិជ្ជកម្មលក់ដុំ និងរាយ | ៧,១% | ៣,៦% | ៥៤ ៥៥៦ |
| ការស្នាក់នៅ និងភោជនីយដ្ឋាន | ១២,១% | ១០,១% | ៥៨ ០៥១ |
| ការដឹកជញ្ជូន និងគមនាគមន៍ | ៨,១% | ៤,៣% | ២០ ៦១៥ |
| អចលនទ្រព្យ | ៤,៥% | ២,៥% | ១០ ១៨០ |
| សេវាកម្មផ្សេងទៀត | ៦,០% | ២,៨% | ២៤ ០៤០ |
| **ការងារក្នុងប្រទេសសរុប** | **៦,៩%** | **២,៥%** | **២៣៤ ៦៤០** |

ប្រភព÷ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០២៤

ស្របជាមួយនឹងការធ្លាក់ចុះចំនួនការងារនៅក្នុងវិស័យកសិកម្ម មុខរបរនិងការងារជាកសិករ ត្រូវបានព្យាករថានឹងថយចុះប្រមាណ ៨,៤ម៉ឺននាក់ ក្នុងមួយឆ្នាំ (តារាងទី៦)។ មុខរបរនិងការងារ ២ប្រភេទ ដែលរំពឹងថានឹងកើនឡើងលឿន និងបង្កើតការងារថ្មីច្រើនជាងគេជូនប្រជាជនរួមមាន÷ ប្រភេទទី១ សិប្បករ ឬអ្នកជំនាញធ្វើការងារដោយប្រើកម្លាំង (ជាកម្លាំងពលកម្មជំនាញ ដែលទាមទារការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ) ប្រមាណ ១៣,៧ម៉ឺននាក់ ក្នុងមួយឆ្នាំ ស្មើនឹង ២៥,៨% នៃការងារសរុបបង្កើតបន្ថែម ហើយភាគច្រើននៃមុខរបរប្រភេទនេះ ត្រូវបានបង្កើតឡើងក្នុងអនុវិស័យសំណង់, កាត់ដេរ និងឧស្សាហកម្មផ្សេងៗ។ រីឯប្រភេទទី២នោះ គឺអ្នកលក់ ឬអ្នកបម្រើសេវាកម្មប្រមាណជា ១០,៩ម៉ឺននាក់ក្នុងមួយឆ្នាំ ដែលភាគច្រើននឹងត្រូវបង្កើតឡើងក្នុងអនុវិស័យការស្នាក់នៅនិងភោជនីយដ្ឋាន, ការលក់ដុំនិងរាយ និងសេវាកម្មផ្សេងៗ។ ប្រភេទមុខរបរដែលមានកំណើនគួរឱ្យកត់សម្គាល់ផងដែរនោះ រួមមាន÷ អ្នកបញ្ជា ឬផ្គុំគ្រឿងចក្រ ឬឧបករណ៍ ២,១ម៉ឺននាក់ក្នុងមួយឆ្នាំ ដែលភាគច្រើននៃការងារប្រភេទនេះនឹងត្រូវបង្កើតឡើងក្នុងអនុវិស័យការដឹកជញ្ជូន និងគមនាគមន៍ និងឧស្សាហកម្មផ្សេងៗ និងប្រភេទមុខរបរនិងការងារជាជំនួយការរដ្ឋបាល ឬលេខាប្រមាណ ១,២ម៉ឺននាក់ ក្នុងមួយឆ្នាំ ដែលភាគច្រើននឹងបង្កើតឡើងក្នុងអនុវិស័យសេវាកម្មផ្សេងៗ អចលនទ្រព្យ កាត់ដេរ ការដឹកជញ្ជូន និងគមនាគមន៍។

ដោយឡែក ប្រភេទការងារដែលទាមទារជំនាញខ្ពស់ដូចជា អ្នកបច្ចេកទេសកម្រិតមធ្យម និងអ្នកឯកទេសវិជ្ជាជីវៈកម្រិតខ្ពស់ ជារួមត្រូវបានរំពឹងថា នឹងកើនប្រមាណជា ៨ពាន់នាក់ និង ៩ពាន់នាក់ ក្នុងមួយឆ្នាំ រៀងគ្នា។ រីឯអ្នកធ្វើការងារគ្មានជំនាញ ត្រូវបានព្យាករថានឹងកើនឡើងប្រមាណជា ១,៩ម៉ឺននាក់ ក្នុងមួយឆ្នាំ ដែលភាគច្រើននៃការងារទាំងនោះស្ថិតនៅក្នុងអនុវិស័យសំណង់ និងការដឹកជញ្ជូននិងគមនាគមន៍។

**តារាងទី៦÷ ការព្យាករកំណើនការងារជាមធ្យមក្នុងមួយឆ្នាំសម្រាប់ឆ្នាំ ២០២៤-២០២៦ តាមប្រភេទនៃមុខរបរ**

| ប្រភេទមុខរបរ | %នៃការងារសរុបឆ្នាំ២០២៣ | អត្រាកំណើនការងារ | ចំនួនការងារ/ឆ្នាំ (នាក់) |
|---|---|---|---|
| អ្នកគ្រប់គ្រង | ១,១% | ៣,៤% | ៣ ៧៩៦ |
| អ្នកឯកទេសវិជ្ជាជីវៈកម្រិតខ្ពស់ | ៣,៥% | ២,៥% | ៨ ៥៥៤ |
| អ្នកបច្ចេកទេសកម្រិតធម្យម | ២,៣% | ៣,៤% | ៨ ០២៧ |
| ជំនួយការរដ្ឋបាល ឬលេខា | ៣,៦% | ៣,៥% | ១២ ៣៧៥ |
| អ្នកលក់ ឬបម្រើសេវាកម្ម | ២១,៣% | ៥,១% | ១០៩ ៤៦៤ |
| កសិករ | ២៦,៣% | -៣,៦% | -៨៤ ២៣៣ |
| សិប្បករ ឬអ្នកជំនាញធ្វើការងារដោយកម្លាំង | ២៥,៨% | ៥,២% | ១៣៧ ២២៥ |
| អ្នកបញ្ជា ឬផ្គុំគ្រឿងចក្រ ឬឧបករណ៍ | ៤,៧% | ៤,៤% | ២០ ៦៨៦ |
| អ្នកធ្វើការងារគ្មានជំនាញ | ១១,៥% | ១,៧% | ១៨ ៧៤៧ |
| **សរុប** | **១០០,០%** | **២,៥%** | **២៣៤ ៦៤១** |

ប្រភព÷ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០២៤

ស្រដៀងគ្នាទៅនឹងនិន្នាការការងារតាមប្រភេទមុខរបរដែរ (តារាងទី៧) ចំនួនការងារដែលទាមទារកម្រិតអប់រំតិចតួច ឬគ្មាន ត្រូវបានរំពឹងថានឹងថយចុះជាគំហុក ដោយជំនួសមកវិញនូវការងារដែលតម្រូវឱ្យមានកម្រិតមធ្យមសិក្សាទុតិយភូមិ និងមធ្យមសិក្សាបឋមភូមិ ដែលត្រូវបានរំពឹងថានឹងមានការកើនឡើងប្រមាណ ១៣,៧ម៉ឺននាក់ និង ៤,០ម៉ឺននាក់ក្នុងមួយឆ្នាំ រៀងគ្នា ដែលប្រភេទការងាររបស់ក្រុមស្ថិតនៅក្នុងកម្រិតអប់រំទាំងអស់នេះត្រូវការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ជាការចាំបាច់ក្នុងការផ្តល់នូវជំនាញបច្ចេកទេសជាក់លាក់ដែលឆ្លើយតបទៅនឹងកំណើនតម្រូវការតាមវិស័យ និងប្រភេទនៃមុខរបរ។ បន្ថែមពីលើនេះ កម្ពុជាក៏មានតម្រូវការចាំបាច់ក្នុងការផ្តល់នូវជំនាញដល់កម្លាំងពលកម្មដែលគ្មាន ឬមានការអប់រំតិចតួច និងមិនបានបញ្ចប់ថ្នាក់បឋមសិក្សា ប្រមាណ ៧ម៉ឺននាក់ ដែលអ្នកទាំងនោះមានការប្រឈមខ្ពស់ក្នុងការបាត់បង់ការងារ។ ទន្ទឹមនឹងនេះ ចំនួនការងារដែលទាមទារការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ទាំងកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១, ២ និង៣ រួមទាំងសញ្ញាបត្របច្ចេកទេសជាន់ខ្ពស់ ត្រូវបានរំពឹងទុកថានឹងកើនឡើងយ៉ាងរហ័សជាមួយនឹងអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ២៥,៧% និង ៣៨,៥% រៀងគ្នា។ ការកើនឡើងនេះ គឺបណ្តាលមកពីការធ្វើពិពិធកម្មសេដ្ឋកិច្ច ឈានទៅរកវិស័យដែលប្រើប្រាស់ជំនាញកាន់តែខ្ពស់ និងមានតម្លៃបន្ថែមកាន់តែប្រសើរជាងមុន ជាពិសេសនៅក្នុងឧស្សាហកម្មផ្សេងទៀតក្រៅពីកាត់ដេរ។ ជាមួយគ្នានេះ តម្រូវការការងារសម្រាប់

អ្នកបញ្ចប់កម្រិតថ្នាក់ឧត្តមសិក្សា ត្រូវបានព្យាករថានឹងបន្តកើនឡើងប្រមាណ ៧,៥ម៉ឺននាក់ជាមធ្យមក្នុង ១ឆ្នាំ ស្របទៅនឹងនិន្នាការនៃការអភិវឌ្ឍសេដ្ឋកិច្ច។

**តារាងទី៧÷ ការព្យាករកំណើនការងារជាមធ្យមក្នុងមួយឆ្នាំសម្រាប់ឆ្នាំ ២០២៤-២០២៦ តាមកម្រិតអប់រំ**

| កម្រិតនៃការអប់រំ | %នៃការងារសរុបឆ្នាំ២០២៣ | អត្រាកំណើនការងារ | ចំនួនការងារ/ឆ្នាំ (នាក់) |
|---|---|---|---|
| សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១,២ និង៣ | ០,៧% | ២៥,៧% | ២២ ៨៤៣ |
| សញ្ញាបត្របច្ចេកទេសជាន់ខ្ពស់ | ០,៦% | ៣៨,៥% | ២៨ ៧៥៦ |
| បញ្ចប់ថ្នាក់ឧត្តមសិក្សា | ៧,១% | ១០,២% | ៧៥ ១៩៤ |
| បញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ | ៩,០% | ១៤,២% | ១៣៧ ១២៦ |
| បញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ | ១៤,០% | ៣,០% | ៤០ ៣១៦ |
| បញ្ចប់ថ្នាក់បឋមសិក្សា | ២៨,៣% | ០,១% | ១ ៥១៤ |
| មិនទាន់បញ្ចប់ថ្នាក់បឋមសិក្សា | ៣២,០% | -០,៥% | -១៣ ៤២៣ |
| គ្មាន ឬមានការអប់រំតិចតួច | ៨,១% | -៨,០% | -៥៧ ៦៨៧ |
| **សរុប** | **១០០,០%** | **២,៥%** | **២៣៤ ៦៤១** |

ប្រភព÷ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០២៤

### ២.១.៣. បញ្ហាភាពមិនបន្ស៊ីគ្នានៃជំនាញ និងភាពមានការខ្វះមិនពេញលេញ

បើទោះបីជាពុំមានទិន្នន័យគ្រប់គ្រាន់ដើម្បីសិក្សា និងធ្វើការប្រៀបធៀបពីភាពមិនបន្ស៊ីគ្នានៃជំនាញក៏ដោយ តាមរយៈការពិនិត្យ និងការវិភាគទៅលើស្ថានភាពប្រជាសាស្ត្រ ការទទួលបានការអប់រំ និងជំនាញ និងតម្រូវការកម្លាំងពលកម្មនៅផ្នែកខាងលើ បានបង្ហាញថាភាពមិនបន្ស៊ីគ្នានៃជំនាញកំពុងតែមានការកើនឡើងនៅក្នុងទីផ្សារការងារនៃប្រទេសកម្ពុជា ជាពិសេស អ្នកដែលធ្វើការនៅក្នុងជំនាញកម្រិតទាប និងមធ្យម។ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើអង្កេតស្តីពីភាពមិនបន្ស៊ីគ្នានៃជំនាញ និងគុណវុឌ្ឍិ ក្នុងប្រទេសកម្ពុជាឆ្នាំ២០២១[៩] ដែលជាអង្កេតលើកដំបូង និងធំជាងគេទៅលើទស្សនៈរបស់យុវជនអាយុចន្លោះពី ២១ ទៅ ៣៤ឆ្នាំ លើស្ថានភាពការងារ និងតម្រូវការកម្រិតជំនាញ ដែលទាមទារក្នុងការបំពេញការងាររបស់ខ្លួនពេលបច្ចុប្បន្នធៀបទៅនឹងកម្រិតជំនាញដែលខ្លួនមាន។ ជាលទ្ធផល អង្កេតនេះបានបង្ហាញថា យុវជនដែលកំពុងធ្វើការយល់ឃើញថា ទីផ្សារការងារបច្ចុប្បន្នកំពុងប្រឈមទៅនឹងបញ្ហាភាពមិនបន្ស៊ីគ្នានៃជំនាញ ដែលរួមមានទាំងបញ្ហាជំនាញ ដែលខ្លួនមានលើសពីតម្រូវការការងារប្រមាណ ១៨,២% និងបញ្ហាជំនាញដែលខ្លួនមានទាបជាងតម្រូវការការងារប្រមាណ ៨,៦%។ ក្នុងចំណោមអ្នកមានការងារធ្វើជាប្រុស និងស្រី, តាមក្រុមអាយុ, និងតាមអ្នកមានបទពិសោធ ឬគ្មានបទពិសោធការងារ កំពុងប្រឈមបញ្ហាភាពមិនបន្ស៊ីគ្នានៃជំនាញដូចគ្នា (រូបភាពទី៦)។

[9] http://www.nea.gov.kh/bulletin/view.do?condBulletinMngSeq=e46e1a4727b711ea8e118cec4b8e345c

**រូបភាពទី៦÷ ភាពមិនបន្សុីគ្នានៃកម្រិតជំនាញទៅនឹងការងារបច្ចុប្បន្ន តាមអតីតភាពការងារ ភេទ និងក្រុមអាយុ**




ប្រភព÷ អង្កេតស្តីពីភាពមិនស៊ីគ្នានៃជំនាញ និងគុណវុឌ្ឍិក្នុងប្រទេសកម្ពុជាឆ្នាំ២០២១, ទីភ្នាក់ងារជាតិមុខរបរ និងការងារ

ទន្ទឹមនឹងនេះ រូបភាពទី៧ ខាងក្រោម ក៏បានបង្ហាញពីបញ្ហាភាពមិនបន្សុីគ្នានៃជំនាញ ដែលកំពុងកើតមានឡើងចំពោះអ្នកកំពុងធ្វើការ ដែលមានការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈគ្រប់កម្រិត។ ជាក់ស្តែង បញ្ហាជំនាញលើសពីតម្រូវការការងារ ត្រូវបានសង្កេតឃើញខ្ពស់ជាងគេនៅក្នុងចំណោមអ្នកដែលមានកម្រិតអប់រំខ្ពស់ចាប់ពីកម្រិតបរិញ្ញាបត្ររង ឬសញ្ញាបត្រជាន់ខ្ពស់ បច្ចេកទេស/ឯកទេសឡើងទៅ។ ខណៈបញ្ហាជំនាញទាបជាងតម្រូវការការងារត្រូវបានរកឃើញថា មានកម្រិតខ្ពស់ប្រមាណ ២៣,៨% នៅក្នុងចំណោមអ្នកដែលបញ្ចប់ការសិក្សាសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១, ២ និង៣ ដោយការងាររបស់ពួកគេត្រូវការជំនាញខ្ពស់ជាងជំនាញដែលខ្លួនមាន ដែលការណ៍នេះ ទាមទារឱ្យមានការពិនិត្យ និងរៀបចំឡើងវិញនូវគុណវុឌ្ឍិនៃការបណ្តុះបណ្តាល។

**រូបភាពទី៧÷ ភាពមិនបន្សុីគ្នានៃកម្រិតជំនាញទៅនឹងការងារបច្ចុប្បន្ន តាមកម្រិតនៃការអប់រំ និងបណ្តុះបណ្តាល**




ប្រភព÷ អង្កេតស្តីពីភាពមិនស៊ីគ្នានៃជំនាញ និងគុណវុឌ្ឍិក្នុងប្រទេសកម្ពុជាឆ្នាំ២០២១, ទីភ្នាក់ងារជាតិមុខរបរ និងការងារ

រូបភាពទី៨ បានបង្ហាញអំពីបញ្ហាភាពមិនបន្សុីគ្នានៃជំនាញដែលកំពុងកើតមាននៅតាមប្រភេទនៃមុខរបរ និងការងារ ជាពិសេសក្នុងចំណោមអ្នកធ្វើការងារគ្មានជំនាញ ប្រមាណ ២៥,០%។ ដោយឡែក ប្រមាណ ១៩,៣% និង ១៦,២% នៃអ្នកដែលធ្វើការជា អ្នកឯកទេសវិជ្ជាជីវៈកម្រិតខ្ពស់ និងមធ្យម រៀងគ្នាក៏កំពុងមានជំនាញខ្ពស់ជាងតម្រូវការក្នុងការងារបច្ចុប្បន្ន ខណៈប្រមាណចន្លោះពី ៨% ទៅ ១០% គឺមានតម្រូវការការបណ្តុះបណ្តាលបង្កើនជំនាញ។ សម្រាប់អ្នកដែលធ្វើការនៅក្នុងកម្រិតជំនាញមធ្យម(ជំនួយការរដ្ឋបាល ឬលេខា, អ្នកលក់ ឬបម្រើសេវាកម្ម, សិប្បករ ឬអ្នកជំនាញធ្វើការងារដោយកម្លាំង, និងអ្នកបញ្ជា ឬផ្គុំគ្រឿងចក្រ ឬឧបករណ៍) ប្រមាណ ១៦,៦% កំពុងប្រឈមបញ្ហាជំនាញដែលខ្លួនមានខ្ពស់ជាងតម្រូវការការងារ ខណៈប្រមាណ ៧,៧% កំពុងមានតម្រូវការការបណ្តុះបណ្តាលបង្កើនជំនាញ។

**រូបភាពទី៨÷ ភាពមិនបន្សុីគ្នានៃកម្រិតជំនាញទៅនឹងការងារបច្ចុប្បន្ន តាមប្រភេទនៃមុខរបរ**




ប្រភព÷ អង្កេតស្តីពីភាពមិនស៊ីគ្នានៃជំនាញ និងគុណវុឌ្ឍិក្នុងប្រទេសកម្ពុជាឆ្នាំ២០២១, ទីភ្នាក់ងារជាតិមុខរបរ និងការងារ

ជារួមលទ្ធផលនៃអង្កេត ដោយផ្អែកលើទស្សនៈរបស់យុវជន ដែលកំពុងធ្វើការ បង្ហាញថាយន្តការទីផ្សារការងារមិនមានប្រសិទ្ធភាពគ្រប់គ្រាន់ ក្នុងការដោះស្រាយបញ្ហាភាពមិនបន្សុីគ្នានៃជំនាញ ហើយការអប់រំ និងបណ្តុះបណ្តាលជំនាញមិនទាន់ឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការទីផ្សារការងារ ដែលទាមទារឱ្យមានការបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ និងបង្កើនជំនាញ។ បញ្ហានេះ ក៏នឹងជះផលអវិជ្ជមានមួយចំនួនក្នុងទីផ្សារការងារ ដូចជាភាពមិនពេញចិត្តលើការងារ កម្រិតនៃប្រាក់ឈ្នួលនិងលក្ខខណ្ឌការងារ ព្រមទាំងបញ្ហាផលិតភាពទាប។

កត្តានេះ ក៏បានបង្ហាញពីភាពចាំបាច់ក្នុងការជំរុញការអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម ដោយផ្តោតការយកចិត្តទុកដាក់ជាអាទិភាពលើការពង្រីកសេវាការងារសាធារណៈ និងវេទិកាការងារ, ពង្រីកសេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ និងការអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយគម្លាតរវាងការផ្គត់ផ្គង់ និងតម្រូវការនៅលើទីផ្សារការងារ និងផ្តល់ភាពងាយស្រួលឆាប់រហ័ស ក្នុងការផ្គូរផ្គងរវាងអ្នកស្វែងរកការងារ និងព័ត៌មានឱកាសការងារ និងធានាថា ប្រជាជនដែលមានជំនាញ និងបទពិសោធការងារស្រាប់នឹងមានលទ្ធភាពក្នុងការទទួលបានការងារប្រសើរជាងមុននៅតាមបណ្តាវិស័យសេដ្ឋកិច្ចដែលមានការរីកចម្រើន និងសមស្របទៅតាមជំនាញ។

### ២.១.៤. ស្ថានភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគ្រាស ត្រឹះស្ថានធុន តូច និងមធ្យម

ទោះសេដ្ឋកិច្ចក្នុងប្រព័ន្ធមានការរីកចម្រើនក្តី, សេដ្ឋកិច្ចក្រៅប្រព័ន្ធនៅតែមានការរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតការងារដោយប្រមាណ ៥១,៩% នៃចំនួនអ្នកមានការងារសរុបអាយុ ១៥-៦៤ឆ្នាំ (របាយការណ៍សេដ្ឋកិច្ច

សង្គមកិច្ចកម្ពុជាឆ្នាំ២០២១) កំពុងតែបម្រើការងារក្នុងទម្រង់ជាបុគ្គលស្វ័យនិយោជន៍ ឬអ្នកជួយការងារគ្រួសារដោយមិនទទួលបានប្រាក់កម្រៃ ដែលប្រភេទការងារទាំងអស់នេះប្រឈមទៅនឹងលក្ខខណ្ឌការងារទាប និងមិនទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម។ បើពិនិត្យលើលទ្ធផលជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២២ បានបង្ហាញថា ប្រមាណ ៨៧,៦% នៃសហគ្រាស គ្រឹះស្ថានចំនួនសរុប ៧៥៣ ៦៧០ មិនបានចុះបញ្ជីជាមួយក្រសួង ឬស្ថាប័នណាមួយ និងប្រមាណ ៩៧,៦%នៃសហគ្រាស គ្រឹះស្ថានសរុបមានកម្មករនិយោជិតតិចជាង ១០នាក់។ ហេតុនេះ ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគ្រាសធុន មីក្រូ តូចនិងមធ្យម គឺជារបៀបវារៈដ៏មានសារៈសំខាន់មួយដែលត្រូវយកចិត្តទុកដាក់ តាមរយៈការរៀបចំនូវគោលនយោបាយលើកទឹកចិត្តជាក់លាក់, ការផ្តល់ការគាំពារសង្គម, ការលើកកម្ពស់សមត្ថភាពនិងផលិតភាព ជាពិសេស ចំពោះបុគ្គលស្វ័យនិយោជន៍ និងសហគ្រិននៃសហគ្រាស គ្រឹះស្ថានធុនមីក្រូ តូច និងមធ្យម ដើម្បីរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាបន្ន និងភាពធន់ទៅនឹងវិបត្តិ។

### ២.១.៥. ស្ថានភាពប្រជាសាស្ត្រ និងនិន្នាការទេសន្តរប្រវេសន៍ការងារនៅក្នុងតំបន់

រូបភាពទី៩ ខាងក្រោមបានបង្ហាញថា និន្នាការអតុល្យភាពប្រជាសាស្ត្រនៅក្នុងតំបន់ និងការកើនឡើងនៃប្រជាពលរដ្ឋវ័យចាស់នៅក្នុងចំណោមប្រទេសអភិវឌ្ឍន៍ នឹងបន្តបង្កើតឱ្យមានតម្រូវការកម្លាំងពលកម្មពីប្រទេសកម្ពុជាកាន់តែច្រើនបន្ថែមទៀត។ កម្រិតនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចក្នុងតំបន់ផ្សេងគ្នា នឹងធ្វើឱ្យកំណើនទេសន្តរប្រវេសន៍ការងារបន្តកើនឡើង ដែលអាចបណ្តាលឱ្យមានភាពខ្វះខាតកម្លាំងពលកម្មក្នុងប្រទេស និងការកើនឡើងប្រាក់ឈ្នួលក្នុងស្រុកលឿន។

**រូបភាពទី៩÷ អនុបាតអ្នកមានអាយុ ១៥-៦៤ឆ្នាំ ធៀបនឹងអ្នកមានអាយុក្រោម ១៥ឆ្នាំ និង៦៥ឆ្នាំឡើង (ពីឆ្នាំ១៩៨០ និង២០៥០)**




ប្រភព÷ ទស្សនវិស័យប្រជាជនពិភពលោកនៃអង្គការសហប្រជាជាតិ ទាញយកថ្ងៃទី២ ខែមករា ឆ្នាំ២០២៤

ចន្លោះឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ប្រជាជនដែលបានកំពុងស្នាក់នៅ និងធ្វើការនៅបរទេស បានកើនឡើងប្រមាណពី ១,២៨លាននាក់ ដល់ប្រមាណ ១,៣៦លាននាក់ ដែលក្នុងនោះអ្នកធ្វើការនៅប្រទេសថៃចំនួន ១,២៦លាននាក់, ប្រទេសកូរ៉េ ៥,១ម៉ឺននាក់, ប្រទេសម៉ាឡេស៊ី ២,២ម៉ឺននាក់, ប្រទេសសិង្ហបុរី ៨៧១នាក់, តំបន់រដ្ឋបាលពិសេសហុងកុង (ចិន) ២១៨នាក់ និងប្រទេសអារ៉ាប់ប៊ីសាអូឌីត ៦៤នាក់។ ក្នុងចន្លោះពេលដូចគ្នានេះ ប្រាក់បញ្ញើដែលបានផ្ញើចូលក្នុងប្រទេសកម្ពុជាបានកើនឡើងប្រមាណពី ២,៥ពាន់លានដុល្លារ ដល់ ២,៩ពាន់លានដុល្លារ ដែលបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ជីវភាពគ្រួសាររបស់ប្រជាជន ព្រមទាំងចូលរួមចំណែកក្នុងការលើកកម្ពស់សុខភាព និងការអប់រំរបស់សមាជិកគ្រួសារនៃពលករទេសន្តរប្រវេសន៍កម្ពុជា។ ស្របពេលជាមួយគ្នានេះ និន្នាការជំរុញការធ្វើចល័តភាពរបបសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយ ក៏មានការកើនឡើង នៅក្នុងក្របខណ្ឌអាស៊ាន ដើម្បីលើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍ពលករទេសន្តរប្រវេសន៍ សំដៅផ្តល់លទ្ធភាពឱ្យពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍អាចទទួលបានផលប្រយោជន៍ពីរបបសន្តិសុខសង្គម។

**សម្គាល់បច្ចេកទេសទី៣÷ ប្រព័ន្ធនៃការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស**

យន្តការនៃការគ្រប់គ្រង បញ្ជូន និងទទួលពលករទេសន្តប្រវេសន៍ គឺត្រូវធ្វើឡើងទៅតាមការព្រមព្រៀងគ្នារវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលប្រទេសទទួល ប៉ុន្តែស្ថិតនៅក្រោមប្រព័ន្ធគ្រប់គ្រង បញ្ជូន និងទទួលផ្សេងៗគ្នា អាស្រ័យទៅតាមប្រទេសគោលដៅ ដែលជាទូទៅបែងចែកជា ៣ ដូចខាងក្រោម÷

- **ប្រព័ន្ធបញ្ជូនពលកររវាងរដ្ឋ និងរដ្ឋ (G2G)** គឺជាប្រព័ន្ធបញ្ជូនពលករដែលរដ្ឋាភិបាលប្រទេសទាំងពីរជាអ្នកកំណត់តម្រូវការកម្លាំងពលកម្មប្រចាំឆ្នាំ ជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករទៅធ្វើការនៅប្រទេសទទួល។ ប្រទេសទទួលដែលប្រើប្រាស់ប្រព័ន្ធរដ្ឋនិងរដ្ឋមានប្រទេសកូរ៉េ។
- **ប្រព័ន្ធបញ្ជូនពលកររវាងឯកជន និងឯកជន (B2B)** គឺជាប្រព័ន្ធបញ្ជូនពលករដែលរដ្ឋាភិបាលប្រទេសទាំងពីរ អនុញ្ញាតឱ្យវិស័យឯកជនធ្វើការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករទៅធ្វើការនៅប្រទេសទទួល។ ប្រទេសទទួលដែលប្រើប្រាស់ប្រព័ន្ធឯកជននិងឯកជន រួមមាន÷ ប្រទេសជប៉ុន តំបន់រដ្ឋបាលពិសេសហុងកុង (ចិន) ប្រទេសម៉ាឡេស៊ី ប្រទេសសិង្ហបុរី និងប្រទេសអារ៉ាប់ប៊ីសាអូឌីត។
- **ប្រព័ន្ធបញ្ជូនពលករហាយប្រ៊ីដ (Hybrid)** គឺជាប្រព័ន្ធបញ្ជូនពលករដែលរដ្ឋាភិបាលប្រទេសទាំងពីរជាអ្នកគ្រប់គ្រងតម្រូវការកម្លាំងពលកម្ម និងអនុញ្ញាតឱ្យវិស័យឯកជនធ្វើការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករទៅធ្វើការនៅប្រទេសទទួល។ ប្រទេសទទួលប្រើប្រាស់ប្រព័ន្ធបញ្ជូនពលករហាយប្រ៊ីដមានប្រទេសថៃ។

## ២.២- និន្នាការពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ

### ២.២.១. និន្នាការនយោបាយ និងសេដ្ឋកិច្ចសកល

ស្ថានភាពនយោបាយនៅក្នុងតំបន់ និងសកលលោក កំពុងបន្តស្ថិតនៅក្នុងស្ថានភាពតានតឹង និងភាពមិនប្រាកដប្រជាខ្ពស់ បើទោះបីជាមានភាពស្រាកស្រាន្តពីវិបត្តិជំងឺកូវីដ-១៩ ក្តី ដោយសារការអូសបន្លាយនៃសង្គ្រាមរុស្ស៊ីនិងអ៊ុយក្រែន សង្គ្រាមថ្មីមួយទៀត ដែលទើបនឹងកើតមានឡើងនៅតំបន់មជ្ឈិមបូព៌ា ការកើនឡើងនៃ

សម្ពាធអតិផរណា វិបត្តិថាមពល និងការបន្តកើនឡើងនៃអត្រាការប្រាក់។ កំណើនសេដ្ឋកិច្ចសកលត្រូវបានប៉ាន់ស្មានថា កើនឡើងក្នុងអត្រាយឺតប្រមាណ ៣,០ % នៅឆ្នាំ២០២៣ និង ២,៩% នៅឆ្នាំ២០២៤ ខាងមុខ ដែលទាបជាងអត្រាកំណើនជាមធ្យមប្រចាំឆ្នាំដែលធ្លាប់មានប្រមាណ ៣,៨% ចន្លោះឆ្នាំ ២០១៥-២០១៩ មុនវិបត្តិជំងឺកូវីដ-១៩ កន្លងមកនេះ។ ការណ៍នេះ បានបន្តដាក់សម្ពាធដល់បណ្តាប្រទេសអភិវឌ្ឍន៍ និងដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា ជាពិសេស សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប។ នៅក្នុងរយៈពេលមធ្យមខាងមុខ សេដ្ឋកិច្ចសកលនឹងបន្តប្រឈមនឹងហានិភ័យចម្បងៗដូចជា ការបន្តកើនឡើងនូវបំណុលសាធារណៈ, សម្ពាធក្នុងវិស័យហិរញ្ញវត្ថុនិងអតិផរណា, ភាពតានតឹងនៃភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាច, សង្គ្រាមពាណិជ្ជកម្ម និងចរន្តគាំពារនិយម, និងការកើនឡើងនៃតម្លៃឥន្ធនៈ និងថាមពល។ និន្នាការនយោបាយ និងហានិភ័យចម្បងៗនេះ នឹងធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់រំហូរពាណិជ្ជកម្មអន្តរជាតិ, ថ្លៃដឹកជញ្ជូន និងឡូជីស្ទិក, ការវិនិយោគផ្ទាល់ពីបរទេស និងខ្សែច្រវាក់ផលិតកម្ម ជាពិសេសចំពោះប្រទេសតូចៗ ដែលអនុវត្តសេដ្ឋកិច្ចបើកចំហ និងពឹងផ្អែកលើការនាំចេញ ដូចជាប្រទេសកម្ពុជា។ និន្នាការនេះ នឹងបង្កជាបច្ច័យអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច, លទ្ធភាពនៃការបង្កើតការងារជូនប្រជាជន, ព្រមទាំងការបន្តមានអត្រាអតិផរណាកម្រិតខ្ពស់ ដែលជះឥទ្ធិពលដល់ការកើនឡើងនៃចំណាយរបស់ប្រជាជន ជាពិសេសលើផ្នែកសេវាសុខាភិបាលក្នុងប្រទេសផងដែរ។

យ៉ាងនេះក្តី ការប្រែប្រួលនៃបរិបទតំបន់ និងសកលលោក ក៏នឹងអាចផ្តល់នូវកាលានុវត្តភាពដល់កម្ពុជាផងដែរ ក្នុងការជំរុញការកែទម្រង់ផ្ទៃក្នុងឱ្យកាន់តែស៊ីជម្រៅ និងមុតស្រួចបន្ថែមទៀត តាមរយៈការពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការលើកកម្ពស់ឧត្តមភាពប្រកួតប្រជែង, និងការផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងខ្សែច្រវាក់ផ្គត់ផ្គង់តំបន់និងសកលលោក ជាពិសេស តាមរយៈការចាប់យកប្រយោជន៍ពីការវិវត្តយ៉ាងឆាប់រហ័សនៃបរិវត្តកម្មឌីជីថល, ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបៃតង និងឌីជីថល, ការទាញយកផលប្រយោជន៍ពីការកើនឡើងនូវហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍ និងការពង្រីកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។

### ២.២.២. និន្នាការសេដ្ឋកិច្ច និងតម្រូវការទីផ្សារការងារ

កម្ពុជាកំពុងបន្តធ្វើបរិវត្តកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចទៅកាន់វិស័យឧស្សាហកម្ម និងវិស័យសេវាកម្មកាន់តែស៊ីជម្រៅ ដោយពឹងផ្អែកខ្លាំងលើកម្លាំងពលកម្មជំនាញ និងផលិតភាពការងារខ្ពស់ និងជំរុញការទាក់ទាញវិនិយោគផ្ទាល់ពីបរទេស ជាពិសេស ការចាប់យកឱកាសនៃខ្សែច្រវាក់តម្លៃ ដែលបង្វែរពីប្រទេសនានាក្នុងតំបន់ និងឱកាសពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលជាបច្ច័យជួយបង្កើតឱកាសការងារ ដែលទាមទារកម្លាំងពលកម្មមានជំនាញមធ្យម និងខ្ពស់កាន់តែខ្លាំង ប៉ុន្តែកាត់បន្ថយឱកាសការងារសម្រាប់អ្នកមានជំនាញទាប ឬគ្មានជំនាញ។ ទន្ទឹមនឹងនេះ រចនាសម្ព័ន្ធនៃកម្លាំងពលកម្មជំនាញ ភាគច្រើនបញ្ចប់ត្រឹមកម្រិតបឋមសិក្សា ហើយអត្រាអ្នកទទួលការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ មានកំណើនយឺត ដែលមានគម្លាតឆ្ងាយពីកម្រិតមធ្យមនៃប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ ក្នុងបរិបទនេះ តម្រូវការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈនឹងកាន់តែកើនឡើង ដើម្បីផ្តល់ជំនាញឱ្យបានគ្រប់គ្រាន់ដល់កម្លាំងពលកម្មកម្ពុជា ក្នុងការចាប់ឱកាសការងារនេះ

និងធានាថាពួកគេអាចឈានចូលទីផ្សារការងារដំបូងដោយមានជំនាញសមស្រប ឬការធ្វើអន្តរកម្មការងារពីវិស័យមួយទៅវិស័យមួយទៀតដោយងាយស្រួល សំដៅកសាងមូលដ្ឋានជំនាញរឹងមាំ និងផលិតភាពគ្រប់គ្រាន់ ដើម្បីគាំទ្រការធ្វើពិពិធកម្មសេដ្ឋកិច្ច និងប្រែក្លាយរចនាសម្ព័ន្ធសេដ្ឋកិច្ច និងទីផ្សារការងារ ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ បន្ថែមលើនេះ ការបន្តការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ច និងទីផ្សារការងារ ដែលនាំឱ្យមានការកើនឡើងចំណែកនៃកម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួល និងការកើនឡើងនៃចំនួនអ្នកធ្វើការនៅក្រៅវិស័យកសិកម្ម និងវិស័យការងារក្នុងប្រព័ន្ធផ្តល់ជាកាលានុវត្តភាពក្នុងការពង្រីកវិសាលភាពនៃរបបសន្តិសុខសង្គម និងការអភិវឌ្ឍលក្ខខណ្ឌស្តីពីការងារកាន់តែល្អប្រសើរ។

ស្របជាមួយគ្នានេះ និន្នាការនៃការកើនឡើងប្រាក់ឈ្នួល ដោយការកើនឡើងនៃអត្រាអតិផរណា និងតម្រូវការកម្រិតជីវភាពកាន់តែខ្ពស់ នឹងបន្តដាក់សម្ពាធមកលើល្បឿននៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលកន្លងមកជំរុញដោយកំណើនកម្លាំងពលកម្ម ដែលនេះត្រូវឱ្យមានការលើកកម្ពស់ផលិតភាពការងារកាន់តែខ្ពស់ ជាពិសេសតាមរយៈការរៀបចំយន្តការលើកទឹកចិត្តដល់ការអភិវឌ្ឍធនធានមនុស្ស និងការរៀបចំយុទ្ធនាការជាតិផលិតភាពការងារ សំដៅបង្កើតនូវផ្នត់គំនិតជាមូលដ្ឋានអំពីផលិតភាពការងារ ភាពចាំបាច់ និងសារៈប្រយោជន៍ក្នុងការលើកកម្ពស់ភាពប្រកួតប្រជែង ការទ្រទ្រង់កំណើនរយៈពេលវែង ការបង្កើតការងារកាន់តែល្អ និងការបន្តលទ្ធភាពដំឡើងប្រាក់ឈ្នួលកាន់តែខ្ពស់។

បន្ថែមពីលើការអភិវឌ្ឍជំនាញ និងលើកកម្ពស់ផលិតភាព ការធ្វើបរិវត្តកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ច ក៏ទាមទារឱ្យមានការផ្លាស់ប្តូរចាំបាច់មួយចំនួននៅក្នុងទីផ្សារការងាររួមមាន ការគោរពវិន័យ ឥរិយាបថការងារ ការបណ្តុះទម្លាប់និងផ្នត់គំនិតអនុលោមភាព សំដៅធានាឱ្យបាននូវទំនាក់ទំនងវិជ្ជាជីវៈដែលមានភាពសុខដុម និងរឹងមាំ។ ប៉ុន្តែទំនាក់ទំនងវិជ្ជាជីវៈស្ថិតនៅក្នុងដំណាក់កាលដំបូង និងមានភាពផុយស្រួយ ដែលនៅតែទទួលការជ្រៀតជ្រែកពីខាងក្រៅ។

### ២.២.៣. និន្នាការប្រជាសាស្ត្រ និងការផ្គត់ផ្គង់កម្លាំងពលកម្ម

និន្នាការប្រជាសាស្ត្រ បានដាក់សម្ពាធឱ្យមានការបង្កើតការងារថ្មីៗកាន់តែមានគុណភាពល្អ សម្រាប់កម្លាំងពលកម្មថ្មីដែលដល់អាយុចូលធ្វើការ ព្រមទាំងសម្រាប់អ្នកបន្តចាកចេញពីវិស័យកសិកម្ម និងសម្រាប់ទាញយកភាគលាភប្រជាសាស្ត្រជាអតិបរមា ដើម្បីឆ្លើយតបទៅនឹងក្តីប្រាថ្នាកាន់តែខ្ពស់របស់ប្រជាពលរដ្ឋក្នុងការស្វែងរកការងារដែលមានប្រាក់ចំណូលកាន់តែខ្ពស់ និងជួយលើកកម្ពស់កម្រិតជីវភាពកាន់តែប្រសើរឡើង។ ទន្ទឹមនឹងនេះ និន្នាការនៃការកើនឡើងនូវចំណែកនៃប្រជាជនស្ថិតក្នុងវ័យធ្វើការ(អាយុ១៥-៦៤ឆ្នាំ) បង្កលក្ខណៈកាន់តែប្រសើរក្នុងការពង្រីករបបសន្តិសុខសង្គម ជាពិសេស ការសន្សំសម្រាប់វិនិយោគលើការកសាងមូលធនមនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់បន្ទាប់។

និន្នាការប្រជាសាស្ត្រ ក៏នឹងដាក់សម្ពាធខ្លាំងបន្ថែមទៀតទៅលើតម្រូវការនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយកម្ពុជាកំពុងស្ថិតនៅក្នុងចំណុចអតិបរមានៃចំនួនប្រជាជន ដែលស្ថិតនៅក្នុងវ័យ

សិក្សាពីថ្នាក់បឋមសិក្សាដល់វិទ្យាល័យ (អាយុពី៦ ទៅ១៧ឆ្នាំ) ដែលមានប្រមាណជា ៣,៩លាននាក់ ជាមធ្យមក្នុង ១ឆ្នាំ សម្រាប់ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៨ ខណៈអត្រាគង់វង្សសិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិនៅមានកម្រិតទាបប្រមាណ ៤៣,១% និង ២៤,៧% រៀងគ្នា។ បន្ថែមលើនេះ ប្រជាជនអាយុពី១៥ ទៅ ២៤ឆ្នាំ ដែលស្ថិតនៅក្នុងវ័យសិក្សាបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅមានចំនួនច្រើនប្រមាណ ៣លាននាក់/ឆ្នាំ នៅចន្លោះឆ្នាំ២០២៣ ដល់២០២៨។ ការណ៍នេះបានបង្ហាញថា តម្រូវការនៃការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅតែបន្តកើនឡើង។

### ២.២.៤. ការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងនិន្នាការនៃការផ្សារភ្ជាប់គោលនយោបាយពាណិជ្ជកម្មទៅនឹងការលើកកម្ពស់លក្ខខណ្ឌការងារ

ក្នុងបរិការណ៍នៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច និងពហុប៉ូលនិយម កម្ពុជាបានបន្តនិន្នាការបុរេសកម្មក្នុងការកសាងទំនាក់ទំនងល្អជាមួយប្រទេសជាមិត្តយ៉ាងប៉ិនប្រសប់ ក្នុងការជំរុញពាណិជ្ជកម្មអន្តរជាតិ តាមរយៈការចូលជាសមាជិកនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតំបន់ និងការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាច្រើននាពេលថ្មីៗនេះ ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន, កម្ពុជា-កូរ៉េ, កម្ពុជា-អារ៉ាប់រួម និងកំពុងបន្តសិក្សា ដើម្បីចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសមួយចំនួនទៀត ដែលនេះជាឱកាសមាសសម្រាប់កម្ពុជាក្នុងការបើកចំហទីផ្សារនាំចេញបន្ថែម, ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស, និងការចូលរួមក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកល ដែលនាំឱ្យមានផលវិជ្ជមានដល់ការបង្កើតឱកាសការងារថ្មីៗបន្ថែមនៅគ្រប់សកម្មភាពសេដ្ឋកិច្ច រួមទាំងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ការណ៍នេះទាមទារឱ្យកម្ពុជាត្រូវបន្តកិច្ចខិតខំបន្ថែមក្នុងការរៀបចំ និងអនុវត្តគោលនយោបាយពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលបច្ចេកទេស ដើម្បីធានាទាញយកអត្ថប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងនោះ។

ទន្ទឹមនេះ គោលនយោបាយពាណិជ្ជកម្មអន្តរជាតិរបស់បណ្តាប្រទេសគោលដៅនាំចេញដ៏សំខាន់របស់កម្ពុជាដូចជា សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប មាននិន្នាការផ្សារភ្ជាប់ទៅនឹងការលើកកម្ពស់លក្ខខណ្ឌការងារ សិទ្ធិកម្មករនិយោជិត និងគាំពារកម្លាំងពលកម្មក្នុងយុគសម័យឌីជីថល។ ជាក់ស្តែង របៀបវារៈគោលនយោបាយពាណិជ្ជកម្មរបស់សហរដ្ឋអាម៉េរិក ដែលបានដាក់ចេញក្នុងឆ្នាំ២០២៣នេះ គឺគោលនយោបាយពាណិជ្ជកម្មដែលយកកម្មករនិយោជិតជាអាទិភាព (Worker-Centered Trade Policy) ក្នុងគោលបំណងលើកកម្ពស់សិទ្ធិការងារ ជាពិសេស គឺការប្រឆាំងនឹងពលកម្មកុមារ និងការងារដោយបង្ខំនៅគ្រប់ដំណាក់កាលនៃខ្សែច្រវាក់ផ្គត់ផ្គង់។ កាលពីខែមករា ឆ្នាំ២០២៣នេះ សហរដ្ឋអាម៉េរិក បានសហការជាមួយប្រទេសជប៉ុន បង្កើតក្រុមការងារលើកកម្ពស់សិទ្ធិមនុស្ស និងស្តង់ដាការងារអន្តរជាតិនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ទៀតផង។ ដូចគ្នានេះដែរ ការលើកកម្ពស់សិទ្ធិ និងលក្ខខណ្ឌស្តីពីការងារ គឺរបៀបវារៈមួយដ៏សំខាន់មួយរបស់សហភាពអឺរ៉ុប ដូចបានសបញ្ជាក់តាមរយៈកិច្ចសន្ទនាស្តីពីពាណិជ្ជកម្ម និងការងារ សហភាពអឺរ៉ុប និងសហរដ្ឋអាម៉េរិក កាលពីខែឧសភា ឆ្នាំ២០២៣កន្លងទៅ។

និន្នាការនេះ តម្រូវឱ្យកម្ពុជាជំរុញបន្ថែមនូវយន្តការត្រួតពិនិត្យអនុលោមភាពលក្ខខណ្ឌការងារ នៅក្នុងខ្សែច្រវាក់ផលិតកម្មរបស់សហគ្រាស គ្រឹះស្ថាន រួមទាំងការជួលផលិតបន្ត ឱ្យកាន់តែល្អប្រសើរ ស្របតាមបទដ្ឋានអន្តរជាតិខាងការងារ ដើម្បីរក្សាបាននូវភាពប្រកួតប្រជែងជាមួយបណ្តាប្រទេសនាំចេញនានានៅក្នុងច្រវាក់ផ្គត់ផ្គង់សកល។

### ២.២.៥. បច្ចេកវិទ្យាឌីជីថល និងការកើនឡើងនៃប្រភេទការងារថ្មីៗ

ការលេចឡើងនូវបដិវត្តន៍ឧស្សាហកម្ម ៤.០ បាននាំឱ្យមានតម្រូវការជំនាញកាន់តែខ្ពស់ ព្រមទាំងការជំនួសកម្លាំងពលកម្មមនុស្សដោយម៉ាស៊ីនស្វ័យប្រវត្តិកម្ម និងបញ្ញាសិប្បនិម្មិត (Artificial Intelligence) ដែលអាចនាំឱ្យបាត់បង់ការងារ ជាពិសេសក្នុងចំណោមអ្នកមានជំនាញទាប និងគ្មានជំនាញ។ បន្ថែមលើនេះ ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ សកម្មភាពសេដ្ឋកិច្ចជាច្រើនបានចាប់យកបច្ចេកវិទ្យាឌីជីថល ក្នុងការជំរុញសកម្មភាពពាណិជ្ជកម្ម និងប្រតិបត្តិការធុរកិច្ច ដែលនាំឱ្យមានការផ្លាស់ប្តូរបែបបទនៃការធ្វើការងារ ដូចជាការធ្វើការងារពីចម្ងាយ ស្របពេលមានការលេចឡើងនៃប្រភេទការងារថ្មីៗ ដែលធ្វើឡើងតាមថ្នាលឌីជីថល (Digital Platforms) ដូចជាអ្នកដឹកជញ្ជូនម្ហូបអាហារ និងអ្នកបើកបររ៉ឺម៉កកង់បី ដែលមិនទាន់មានក្របខណ្ឌគតិយុត្តគ្រប់គ្រងច្បាស់លាស់។ ការងារប្រភេទថ្មីទាំងនេះ តម្រូវឱ្យមានការសិក្សាឱ្យបានស៊ីជម្រៅបន្ថែមពាក់ព័ន្ធនឹងលក្ខខណ្ឌស្តីពីការងារ និងរបបសន្តិសុខសង្គម ដើម្បីកំណត់ក្របខណ្ឌច្បាប់សម្រាប់ការអនុវត្តឱ្យបានត្រឹមត្រូវ។ ទន្ទឹមនឹងនេះ ការធ្វើបរិវត្តកម្ម និងការចាប់យកឌីជីថលក៏ផ្តល់លទ្ធភាពនិងប្រសិទ្ធភាពកាន់តែខ្ពស់ជាងមុន ក្នុងការផ្តល់សេវាសាធារណៈ និងសេវារបបសន្តិសុខសង្គមជូនប្រជាជន។

### ២.២.៦. និន្នាការសេដ្ឋកិច្ច និងការងារបៃតង

និន្នាការផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុមានឥទ្ធិពលលើពិភពការងារនៅគ្រប់វិស័យសេដ្ឋកិច្ច ជាពិសេស វិស័យដែលពឹងផ្អែកខ្លាំងលើបរិស្ថាន និងអាកាសធាតុ ដូចជាក្នុងវិស័យកសិកម្ម ដែលអ្នកធ្វើការក្នុងវិស័យនេះ អាចបាត់បង់ការងារ កាត់បន្ថយម៉ោងការងារ ការថយចុះផលិតភាព និងបាត់បង់ប្រាក់ចំណូលដោយសារផលប៉ះពាល់ជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ ក្នុងវិស័យឧស្សាហកម្ម លក្ខខណ្ឌការងារមួយចំនួនដូចជាសុវត្ថិភាព និងសុខភាពការងារ (Occupational Safety and Health) អាចនឹងរងផលប៉ះពាល់ដោយសារព្រឹត្តិការណ៍អាកាសធាតុខ្លាំង និងការកើនឡើងសីតុណ្ហភាព ករណីមិនមានការអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារបានត្រឹមត្រូវ។ ទន្ទឹមនឹងផលប៉ះពាល់ជាអវិជ្ជមាន និន្នាការនេះក៏បង្កើតជាកាលានុវត្តភាពមួយចំនួន ដូចជាការកើតឡើងនូវការងារថ្មីៗ (Green Jobs) ក្នុងសកម្មភាពសេដ្ឋកិច្ច ដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ បន្ថែមពីលើនេះ ស្របពេលនៃការងាយទទួលបាននូវព័ត៌មាន ការកើនឡើងនូវការយល់ដឹង និងការឱ្យតម្លៃកាន់តែខ្ពស់របស់អ្នកប្រើប្រាស់ក្នុងទីផ្សារអឺរ៉ុប និងអាមេរិក អំពីប្រភពនៃផលិតផលការផ្សារភ្ជាប់ផលិតផលរបស់កម្ពុជាទៅនឹងការការពារបរិស្ថាន ការប្រើប្រាស់ធនធានប្រកបដោយចីរភាព និងទំនួលខុសត្រូវសង្គម គឺជាការចាំបាច់បំផុត។ ជាលទ្ធផល ការកើនឡើងនៃនិន្នាការផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹង



ស

ទំនួលខុសត្រូវសង្គម និងបរិស្ថាន នឹងមានផលប៉ះពាល់ដល់ការបង្កើតការងារ និងតម្រូវការជំនាញថ្មី ដែលទាមទារនូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបៃតង (Green Skills) និងជំនាញពាក់ព័ន្ធមួយចំនួនទៀត។

## ២.៣- សមិទ្ធផលនៃការអនុវត្ត ផ.យ.អ.ក.ប ២០១៩-២០២៣

នាអាណត្តិ ២០១៩-២០២៣ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមយ៉ាងសកម្ម ក្នុងការសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនជូនរាជរដ្ឋាភិបាល ទាំងផ្នែកសេដ្ឋកិច្ចនិងសង្គម បើទោះបីជាស្ថិតនៅក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ សង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន ភាពស្រុតចុះនៃទំនុកចិត្តវិនិយោគ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចអឺរ៉ុប សហរដ្ឋអាមេរិក និងចិន ព្រមទាំងការប្រឈមធំៗជាច្រើន។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុវត្ត ផ.យ.អ.ក.ប ២០១៩-២០២៣ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបាននូវលទ្ធផលការងារសំខាន់ៗ ដូចខាងក្រោម÷

### ២.៣.១. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ

- ក្រសួងបានរៀបចំកម្មវិធីសំណេះសំណាលរបស់ **សម្តេចតេជោ** ជាមួយបងប្អូនកម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធទាំងជុំទីមួយ (ចាប់តាំងពីថ្ងៃអាទិត្យ ទី២០ ខែសីហា ឆ្នាំ២០១៧ ដល់ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩) និងជុំទីពីរ (ចាប់ផ្តើមពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ខែសីហា ឆ្នាំ២០២៣) សរុបចំនួន ៩៦លើក មានកម្មករនិយោជិតសរុបប្រមាណជាង ១,៣លាននាក់ ដែលតាមរយៈកម្មវិធីសំណេះសំណាលនេះ **សម្តេចតេជោ** បានដាក់ចេញនូវអនុសាសន៍ ១០ចំណុច ក្នុងការលើកកម្ពស់លក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជាឱ្យកាន់តែប្រសើរ ដែលតាមរយៈកម្មវិធីសំណេះសំណាលជុំទីពីរនេះ **សម្តេចតេជោ** ក៏បានដាក់ចេញនូវអនុសាសន៍ថ្មីៗបន្ថែមទៀត ក្នុងនោះ កម្មការិនីដែលមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ទទួលបាន ÷

- មុនពេលសម្រាលកូន ទទួលបានប្រាក់ឧបត្ថម្ភ ចំនួន ៤លើក ទទួលបាន៨ម៉ឺនរៀល/លើក
- ពេលសម្រាលកូន ទទួលបានប្រាក់ឧបត្ថម្ភ ដោយកូន ចំនួន ១នាក់ ទទួលបានថវិកា ៨០ ម៉ឺនរៀល, កូនភ្លោះ ២នាក់ ទទួលបានថវិកា ១លាន ២សែនរៀល, និងកូនភ្លោះ ៣នាក់ ទទួលបានថវិកា ១លាន ៦សែនរៀល និងទទួលបានថវិកាឧបត្ថម្ភបន្ថែម ចំនួន ៥លានរៀល ពី **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ផ្ទាល់
- ក្រោយពេលសម្រាលកូន ទទួលបានប្រាក់ឧបត្ថម្ភ ចំនួន ១០លើក ដោយ ១លើកទទួលបាន ចំនួន ៨ម៉ឺនរៀល ក្នុងនោះ ៣លើក នៅពេលទៅទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូន និង ៧លើក នៅពេលយកកូនទៅទទួលថ្នាំបង្ការរហូតដល់អាយុ ២ឆ្នាំ។

- បានរៀបចំកម្មវិធីសំណេះសំណាលរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជាមួយបងប្អូនកម្មករនិយោជិតតាមបណ្តាសហគ្រាស គ្រឹះស្ថាន ក្នុងឋានៈជា **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចាប់ពីថ្ងៃអាទិត្យ ទី២៩ ខែសីហា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៨ ខែមករា ឆ្នាំ២០២៤ បានចំនួន ១១លើក មានកម្មករនិយោជិតចំនួន ១៨៣ ៣៤១នាក់។

- បានពង្រឹងប្រសិទ្ធភាពនៃការដោះស្រាយវិវាទការងារ ដោយយន្តការនៃការដោះស្រាយវិវាទការងារត្រូវបានលើកកម្ពស់តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការពង្រឹងសមត្ថភាពមន្ត្រីផ្សះផ្សា ភាពជាដៃគូនៃកិច្ចសន្ទនាសង្គម យន្តការត្រីភាគី និងគាំទ្រនិរន្តរភាពនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ ព្រមទាំងការកែលម្អនីតិវិធីនៃការដោះស្រាយវិវាទការងារជាប្រចាំ និងបានផ្សព្វផ្សាយអំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ

- បានធ្វើសមាហរណកម្ម និងទំនើបកម្មការធ្វើអធិការកិច្ចការងារ និងអធិការកិច្ចអន្តរក្រសួង ដោយបន្តពង្រឹងយន្តការក្រុមអធិការកិច្ចការងារ និងក្រុមអធិការកិច្ចអន្តរក្រសួងតាមវិស័យអាទិភាព មានជាអាទិ៍ វិស័យកម្មន្តសាល, ឧស្សាហកម្មទេសចរណ៍, កសិកម្ម និងវិស័យសំណង់ សំដៅកាត់បន្ថយបន្ទុករបស់ម្ចាស់សហគ្រាស គ្រឹះស្ថាន និងធានាប្រសិទ្ធភាព និងអនុលោមភាពតាមច្បាប់ ដោយផ្តោតលើចំណាត់ថ្នាក់នៃកម្រិតហានិភ័យរបស់សហគ្រាស គ្រឹះស្ថាននីមួយៗ

- បានពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយបានចុះអធិការកិច្ចការងារសរុបចំនួន ២៣ ៣៥៤លើក លើលក្ខខណ្ឌការងារ និងលក្ខខណ្ឌស្តីពីសុវត្ថិភាពនិងសុខភាពការងារដែលគិតជាមធ្យមប្រមាណចំនួន ៤ ៦៧១លើក ក្នុងមួយឆ្នាំ និងពិនិត្យឃើញថា អត្រាអនុលោមភាពរបស់សហគ្រាស គ្រឹះស្ថាន មានអត្រាជាមធ្យមប្រមាណ ៩០,២%

- បានចុះអង្កេតគ្រោះថ្នាក់ការងារចំនួន ៨៥លើក ដើម្បីដាក់ចេញជាវិធានការបង្ការគ្រោះថ្នាក់ការងារ និងវិធានការពិន័យយ៉ាងម៉ឺងម៉ាត់ចំពោះសហគ្រាស គ្រឹះស្ថានដែលមិនអនុលោមតាមលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ក្នុងនោះ សហគ្រាស គ្រឹះស្ថានចំនួន ១៧ ត្រូវបានរងការពិន័យពីអធិការការងារ

- បានដាក់ដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ តាមរយៈគេហទំព័រ https://sicms.mlvt.gov.kh/ ដែលជាប្រព័ន្ធ “ប្រឹក្សា និងបង្ការ” សំដៅបង្កើតនូវវប្បធម៌អនុលោមភាពការងារ

- បានពង្រឹង និងបន្តកិច្ចសហប្រតិបត្តិការលើការអនុវត្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (International Labour Organization-Better Factories Cambodia-ILO-BFC) ដើម្បីបន្តជំរុញការអនុវត្តគោលនយោបាយពាណិជ្ជកម្មផ្សាភ្ជាប់ជាមួយនឹងលក្ខខណ្ឌការងារ និងជាមួយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (German Agency for International Cooperation-GIZ) ប្រចាំប្រទេសកម្ពុជា ដើម្បីពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចការងារ

- បានធ្វើវិសោធនកម្មមាត្រា ១២៣ មាត្រា ១៣៨ មាត្រា ១៦២ មាត្រា ៣០០ មាត្រា ៣៤៣ មាត្រា ៣៥០ មាត្រា ៣៦៣ និងមាត្រា ៣៦៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ពាក់ព័ន្ធនឹងវេនការងាររបស់សហគ្រាស គ្រឹះស្ថាន, ការពង្រីកវិសាលភាពសេវាកម្មក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទការងារបុគ្គល, ការលុបការឈប់នៅថ្ងៃបន្ទាប់សម្រាប់ថ្ងៃឈប់សម្រាកបុណ្យចំថ្ងៃអាទិត្យ និងការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់អធិការកិច្ចការងារ

- បានកែលម្អប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសុខភាពការងារនៅកន្លែងធ្វើការជាបន្តបន្ទាប់ ព្រមទាំងជំរុញឱ្យសហគ្រាស គ្រឹះស្ថានអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការពង្រឹងលក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ

- បានពង្រឹងនិងពង្រីកយន្តការ នៃការផ្តល់សេវាពិនិត្យកាយសម្បទាដល់កម្មករនិយោជិតសរុបចំនួន ២,៩៦លានលើក

- បានអនុវត្តយុទ្ធនាការបង្ការ និងការទប់ស្កាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដល់ទីតាំងសហគ្រាស គ្រឹះស្ថាន ជាពិសេសនៅក្នុងសិប្បកម្មផលិតឥដ្ឋ និងសហគមន៍ សរុបចំនួន ៥៤៤លើក នៅទូទាំងប្រទេស ដោយបានធ្វើកិច្ចសន្យាទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមាររវាងនិយោជក និងអធិការកិច្ចការងារចំនួន ៤៨៦កិច្ចសន្យា និងរវាងអាណាព្យាបាលជាកម្មករនិយោជិត និងនិយោជកសរុបចំនួន ១ ២៦២កិច្ចសន្យា ព្រមទាំងបានអនុវត្តកិច្ចអន្តរាគមន៍ស្ទួល ដោយទប់ស្កាត់ និងគាំពារកុមារបានចំនួន ១ ៥៥០នាក់ (ស្រី ៧៦៩នាក់) ដែលស្ថិតនៅក្នុងស្ថានភាពងាយបោះបង់ការសិក្សា និងងាយធ្លាក់ចូលទៅក្នុងការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម ត្បូងឃ្មុំ ពោធិ៍សាត់ បាត់ដំបង និងសៀមរាប

- បានដំឡើងប្រាក់ឈ្នួលអប្បបរមា ក្រោមយន្តការក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ប្រកបដោយសុខដុម និងទៀងទាត់តាមកាលវិភាគ សម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូបកើនពី ១៨២ដុល្លារ/ខែ សម្រាប់ឆ្នាំ២០១៩ ដល់ ២០០ដុល្លារ/ខែ សម្រាប់ឆ្នាំ២០២៣។ បន្ថែមលើនេះ ដើម្បីកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២៤ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា បានរៀបចំកិច្ចប្រជុំពិភាក្សាចរចាផ្ទៃក្នុង ទ្វេភាគី និងត្រីភាគី សរុបចំនួន ២០លើក ដោយទទួលបានជោគជ័យ ហើយជាលទ្ធផល **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានសម្រេចបន្ថែមចំនួន ២ដុល្លារ លើតួលេខប្រាក់ឈ្នួលអប្បបរមា ២០២ដុល្លារ របស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដែលធ្វើឱ្យប្រាក់ឈ្នួលអប្បបរមាឡើងដល់ចំនួន ២០៤ដុល្លារក្នុងមួយខែ សម្រាប់ឆ្នាំ២០២៤ បើបូកបន្ថែមប្រាក់អត្ថប្រយោជន៍ជាកាតព្វកិច្ចផ្សេងៗទៀត កម្មករនិយោជិតទទួលបានប្រាក់ឈ្នួលជាមធ្យម ២២១ដុល្លារដល់ ២៣២ដុល្លារ

- បានធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីពលើមាត្រាចំនួន ១០ ក្នុងគោលបំណងលើកកម្ពស់សិទ្ធិ និងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចឱ្យកាន់តែច្បាស់លាស់ និងកែសម្រួលនីតិវិធីនៃការចុះបញ្ជីសហជីព, នីតិវិធីនៃការរក្សាបញ្ជិកា និងលក្ខខណ្ឌក្នុងការស្នើសុំទទួលស្គាល់ភាពជាតំណាងបំផុត

- បានលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនជាបន្តបន្ទាប់នៃចំនួនអង្គការវិជ្ជាជីវៈចុះបញ្ជីពី ៥ ២៥៦ នៅឆ្នាំ២០១៩ ដល់ ៦ ២៧២ នៅត្រឹមឆ្នាំ២០២៣

- បានលើកកម្ពស់យន្តការនៃការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការពង្រឹងសមត្ថភាពមន្ត្រីផ្សះផ្សា ភាពជាដៃគូនៃកិច្ចសន្ទនាសង្គម យន្តការត្រីភាគី និងគាំទ្រនិរន្តរភាពនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយបានដោះស្រាយវិវាទសរុបចំនួន ៤ ៣៨៧ករណី (សះជាចំនួន ២ ៨២៤ករណី មិនសះជាចំនួន ១ ៣១៨ករណី និងមោឃៈចំនួន ២៤៥ករណី) ដែលក្នុងនោះ÷

- វិវាទបុគ្គលសរុបចំនួន ៣ ៣១៧ករណី ដោយទទួលបានលទ្ធផលសះជាប្រមាណ ៦៤% ក្នុងនោះ សះជាក្នុងកម្រិតសហគ្រាស គ្រឹះស្ថានប្រមាណ ៤% និងសះជានៅកម្រិតមន្ត្រីផ្សះផ្សាអត្រាប្រមាណ ៦០%។ ក្នុងចំណោមវិវាទបុគ្គលសរុបខាងលើ ៤៩% ជាវិវាទអំពីសិទ្ធិ និង៥១% ជាវិវាទអំពីប្រយោជន៍
- វិវាទការងាររួមចំនួន១ ០៧០ករណី ដោយទទួលបានលទ្ធផលសះជាប្រមាណ ៦៥% ក្នុងនោះសះជាក្នុងកម្រិតសហគ្រាស គ្រឹះស្ថានប្រមាណ ៧% និងសះជានៅកម្រិតមន្ត្រីផ្សះផ្សាអត្រាប្រមាណ ៥៨% និងបានបញ្ជូនសំណុំរឿងទៅដោះស្រាយបន្តនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលចំនួន ៣០៥ករណី។ ក្នុងចំណោមវិវាទការងាររួមសរុបខាងលើ ៣៤%ជាវិវាទអំពីសិទ្ធិ និង៦៦%ជាវិវាទអំពីប្រយោជន៍
- បានរក្សាអត្រាដោះស្រាយសះជាវិវាទការងាររួម ត្រឹមកម្រិតមន្ត្រីផ្សះផ្សា និងក្រុមប្រឹក្សាអាជ្ញាកណ្តាលខ្ពស់ជាមធ្យមប្រមាណ ៨៥,៧២%

- បានពង្រឹងយន្តការដោះស្រាយកូដកម្ម បាតុកម្ម ដែលឆ្លុះបញ្ចាំងតាមរយៈ÷

- ការរក្សាឱ្យអត្រាសហគ្រាស គ្រឹះស្ថានដែលមានកូដកម្ម នៅក្រោម ១%
- ការអន្តរាគមន៍ដោះស្រាយកូដកម្ម សរុបចំនួន ៤៦០ករណី ក្នុងនោះ ៩៥% ត្រូវបានដោះស្រាយសះជា ព្រមទាំងបានធ្វើអន្តរាគមន៍ដោះស្រាយបាតុកម្ម សរុបចំនួន ៦០ករណី ក្នុងនោះ ៩០% ត្រូវបានដោះស្រាយសះជា
- ការដោះស្រាយករណីរោងចក្របិទទ្វារដោយវិបត្តិផ្សេងៗ សរុបចំនួន ១១៨ករណី មានកម្មករនិយោជិតសរុបចំនួន ៥៧ ៧៥២នាក់ ក្នុងនោះ បានសម្របសម្រួលផ្តល់ថវិកាបុរេប្រទានរបស់រាជរដ្ឋាភិបាល ចំនួន ១៥ករណី រោងចក្របិទទ្វារដោយសារថៅកែរត់ចោលដល់កម្មករនិយោជិតចំនួន ៤ ៣២៧នាក់ ដែលប្រើប្រាស់ទឹកប្រាក់សរុបចំនួនប្រមាណ ៤,០៨លានដុល្លារ ដើម្បីដោះស្រាយប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗជូនបងប្អូនកម្មករនិយោជិតជាមុន ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់ជីវភាពរបស់បងប្អូនកម្មករនិយោជិត

- បានបើកផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប និងវិស័យទេសចរណ៍ ដែលព្យួរកិច្ចសន្យាការងារដោយសាររងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ជុំទី១ គិតត្រឹមបំណាច់ឆ្នាំ២០២២ ចំនួន ៣៥៤ ២៧៦នាក់ ស្មើនឹងថវិកា ១៣៤,២៧ប៊ីលានរៀល និងឧបត្ថម្ភជុំទី២ ក្នុងឆ្នាំ២០២៣ បានចំនួន ១៦០ ៨៦៣នាក់ ស្មើនឹងថវិកា ២៧,៦៧ប៊ីលានរៀល។ បើគិតការឧបត្ថម្ភទាំងពីរជុំបានបើកផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតសរុបថវិកាចំនួន ១៦១,៩៤ប៊ីលានរៀល

- បានបន្តការពង្រីកការតបណ្តាញអគ្គិសនី និងទឹកស្អាតដោយតម្លៃទាបសមរម្យជូនកម្មករនិយោជិត សិស្សនិស្សិតនៅតាមផ្ទះជួល ការជំរុញការរៀបចំកន្លែងស្នាក់នៅ និងមធ្យោបាយធ្វើដំណើរ សម្រាប់កម្មករនិយោជិតដោយសុវត្ថិភាព និងការបន្តកែសម្រួលកម្រិតប្រាក់ឈ្នួលអប្បបរមាដែលត្រូវជាប់ពន្ធដល់ ១លាន ៥សែន និងការអនុគ្រោះពន្ធ ចំពោះប្រាក់អត្ថប្រយោជន៍បន្ថែម

- បានជំរុញការអនុវត្តការអនុញ្ញាតឱ្យកម្មការិនីបានឈប់សម្រាកចំនួន ៩០ថ្ងៃ តាមច្បាប់ស្តីពីការងារ និងទទួលបានប្រាក់ឈ្នួលសរុប ១២០% ដោយ ៥០% ទទួលបានពីនិយោជក និង ៧០% ទៀតទទួលបានពី ប.ស.ស.

- បានចូលរួមជំរុញការអនុវត្ត ការផ្តល់សេវាថែទាំសុខភាពនិងការពិនិត្យផ្ទៃពោះដល់កម្មការិនីដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យ/មណ្ឌលសុខភាពរដ្ឋ និងផ្តល់ប្រាក់ឧបត្ថម្ភពេលឈប់សម្រាកសម្រាលកូន

- បានជំរុញការអនុវត្តអនុសាសន៍ **សម្តេចតេជោ** ដែលអនុញ្ញាតឱ្យកម្មការិនីដែលមានផ្ទៃពោះ ចាប់ពី ៣ខែឡើង និងកម្មករនិយោជិត ដែលមានពិការភាពលំបាកក្នុងការធ្វើដំណើរ អាចចេញមុនម៉ោងយ៉ាងតិច ១៥នាទី ហើយចំពោះកម្មករនិយោជិតជាសាសនិកឥស្លាម ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្លៀកបំពាក់ប្រពៃណី ឬហ៊ីចាប (Hijab) នៅកន្លែងការងារបាន

- បានសម្របសម្រួល និងចូលរួមយុទ្ធនាការជាតិចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ក្រោមឆ័ត្រនៃគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងកងយោធពលខេមរភូមិន្ទ ជូនដល់ប្រជាពលរដ្ឋ និងកម្មករនិយោជិតនៅតាមសហគ្រាស គ្រឹះស្ថាន សរុបប្រមាណ ៩៩ម៉ឺននាក់ និងបានបើកផ្តល់សាច់ប្រាក់ក្រោមកម្មវិធីជំនួយសង្គមដល់កម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលរងផលប៉ះពាល់ពីការអនុវត្តវិធានការបិទខ្ទប់ចំនួន ៣៤១ ៦៤២នាក់ និងបានរៀបចំវគ្គបណ្តុះបណ្តាលពិសេស ដោយឥតគិតថ្លៃដល់កម្មករនិយោជិតដែលបាត់បង់ការងារដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩ ចំនួនប្រមាណ ៧ ៥០០នាក់ និងបានរៀបចំការបណ្តុះបណ្តាលជំនាញទន់ ដល់កម្មករនិយោជិតប្រមាណ ៦៨ ០០០នាក់។

**២.៣.២. ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

- បានអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥, ផែនការយុទ្ធសាស្ត្រសកម្មភាពការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១៩-២០២៣, ផែនការមេសម្រាប់អភិវឌ្ឍគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេល ៥ឆ្នាំ (២០២១-២០២៥) ព្រមទាំងបានពង្រឹងការអនុវត្តក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (Cambodia Qualifications Framework-CQF) និងកំពុងបន្តរៀបចំសេចក្តីព្រាងរបាយការណ៍ផ្គូផ្គងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (ASEAN Qualification Reference Framework-AQRF)

- បានពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល និងគណៈកម្មាធិការបណ្តុះបណ្តាលខេត្ត និងក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- បានរៀបចំ និងដាក់ចេញផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា ឆ្នាំ២០២៣-២០៣៥ និងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងបានរៀបចំនូវនីតិវិធីប្រតិបត្តិស្តង់ដា (Standard Operating Procedure-SOP) សម្រាប់ដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតាមគ្រឹះស្ថាន អ.ប.វ.

- បានធ្វើទំនើបកម្មពង្រឹងគុណភាព និងបង្កើនសមត្ថភាពបណ្តុះបណ្តាលវិស័យ អ.ប.វ. តាមរយៈការបន្តជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការវិភាជន៍ថវិកាប្រមាណជាង ៣០០លានដុល្លារ ដោយផ្តោតសំខាន់លើការកសាងអគារថ្មីចំនួន ២៦, រោងជាង/បន្ទប់ពិសោធន៍ចំនួន ៣៤, អន្តេវាសិកដ្ឋានចំនួន ១០, សួន អ.ប.វ. ចំនួន ៣, មជ្ឈមណ្ឌលធ្វើតេស្តវាយតម្លៃសមត្ថភាពចំនួន ៨, មជ្ឈមណ្ឌលឧត្តមភាពចំនួន ៤, មជ្ឈមណ្ឌលស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍ អ.ប.វ. ចំនួន ២, ព្រមទាំងបំពាក់ឧបករណ៍ សម្ភារ និងបរិក្ខារបណ្តុះបណ្តាល។ គិតត្រឹមឆ្នាំ២០២៣ គ្រឹះស្ថាន អ.ប.វ.សាធារណៈមានសរុបចំនួន ៣៧ មានអគារចំនួន ២២៨អគារ ដែលក្នុងនោះអគាររដ្ឋបាលមានចំនួន ២៧អគារ (២១១បន្ទប់) អគារសិក្សាមានចំនួន ១០៦អគារ (៩៩៨បន្ទប់) អគាររោងជាងមានចំនួន ៥៦អគារ (បន្ទប់រោងជាងមានចំនួន ៣៣៦បន្ទប់ និងបន្ទប់ពិសោធន៍មានចំនួន ៣៣បន្ទប់), អន្តេវាសិកដ្ឋានមានចំនួន ៣៩អគារ ព្រមទាំងបំពាក់ឧបករណ៍ សម្ភារ និងបរិក្ខារបម្រើឱ្យការបណ្តុះបណ្តាលជាច្រើនទៀត ដែលមានសមត្ថភាពបណ្តុះបណ្តាលបានចំនួនជាង ៦ម៉ឺននាក់/ឆ្នាំ។ ប្រសិនបើគម្រោងវិនិយោគកែលម្អ និងទំនើបកម្មគ្រឹះស្ថាន អ.ប.វ. ត្រូវបានបញ្ចប់តាមការគ្រោងទុកក្នុងឆ្នាំ២០២៦ នោះ សមត្ថភាពនៃការបណ្តុះបណ្តាលនឹងកើនឡើងដល់ប្រមាណជាង ១០ម៉ឺននាក់/ឆ្នាំ

- គណៈវិស្វករកម្ពុជាបានត្រួតពិនិត្យវាយតម្លៃដោយបានចុះបញ្ជីវិស្វករសរុបចំនួន ៥ ៤៧១នាក់ (ស្រី ២២២នាក់) ក្នុងនោះវិស្វករជាតិចំនួន ៥ ៣៧៧នាក់ (ស្រី ២២០នាក់) និងវិស្វករបរទេសចំនួន ៩៤នាក់ (ស្រី ២នាក់)។ បើគិតត្រឹមឆ្នាំ២០២៣ នេះ បានចុះបញ្ជីវិស្វករសរុបចំនួន ៧ ៩០៤នាក់ (ស្រី ៣១៦នាក់) ក្នុងនោះ វិស្វករជាតិចំនួន ៧ ៧៨៩នាក់ (ស្រី ៣១៤នាក់) និងវិស្វករបរទេសចំនួន ១១៥នាក់ (ស្រី ២នាក់) និងបានរៀបចំវគ្គបណ្តុះបណ្តាលជូនវិស្វករចុះបញ្ជីនៅគណៈវិស្វករកម្ពុជាសរុបចំនួន ៧៣លើក មានវិស្វករចូលរួមសរុបចំនួន ៥ ០៥៧នាក់ (ស្រី ៤៧៧នាក់)

- បានបង្កើនការផ្តល់កម្មវិធីបណ្តុះបណ្តាលជំនាញចំនួន ២៧២ ៤៥០នាក់ (ស្រី ១១៣ ៩៣៩នាក់) ក្នុងនោះ កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១, ២, ៣ ចំនួន ៥៦ ៦០២នាក់ (ស្រី ២០ ៧២០ នាក់), សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេសចំនួន ២៦ ៦៧២នាក់ (ស្រី ៧ ៣៣០នាក់) និងបរិញ្ញាបត្របច្ចេកទេសចំនួន ៣០ ៩៩១នាក់ (ស្រី ១០ ៨០៥នាក់) និងវិញ្ញាបនបត្រវិជ្ជាជីវៈចំនួន ១៥៨ ១៨៥នាក់ (ស្រី ៧៥ ០៨៤នាក់) លើមុខជំនាញសំខាន់ៗ នៅក្នុងវិស័យអាទិភាព

- បានបន្តជំរុញការអភិវឌ្ឍសមត្ថភាពកម្លាំងពលកម្មដែលនៅក្នុងទីផ្សារការងារ និងត្រៀមចូលទីផ្សារការងារ តាមរយៈការអនុវត្តការហ្វឹកហ្វឺនកូនជាងចំនួន ១២៨ ៥២៧នាក់ (ស្រី ៩២ ៨១២នាក់), បានបញ្ជូនសិស្សទៅចុះកម្មសិក្សា និងទស្សនកិច្ចសិក្សានៅតាមសហគ្រាស គ្រឹះស្ថានចំនួន ២២ ៣៧៩នាក់ (ស្រី ៥ ៥៩១នាក់), បានបណ្តុះបណ្តាលវិធីសាស្ត្រវាយតម្លៃសមត្ថភាពដល់អ្នកវាយតម្លៃសមត្ថភាពចំនួន ៤០៨នាក់ (ស្រី ៩៥នាក់) និងបានធ្វើតេស្តទទួលស្គាល់ការសិក្សាដែលមានពីមុន (RPL) ចំនួន ២ ៤២៩នាក់ (ស្រី ២៨៨នាក់)

- បានជ្រើសរើស និងបញ្ចូលក្របខណ្ឌគ្រូបច្ចេកទេសបន្ថែមចំនួន ២៩៥នាក់(ស្រី ៤៩នាក់) ដែលធ្វើឱ្យចំនួនគ្រូបច្ចេកទេសក្របខណ្ឌសរុបកើនដល់ ២ ១៥៤នាក់ (ស្រី ៥១៥នាក់) កំពុងបម្រើការងារនៅតាមគ្រឹះស្ថាន អ.ប.វ.

- បានលើកកម្ពស់សមត្ថភាពគ្រូបច្ចេកទេសសរុបចំនួន ២ ៥៣៥ដង/នាក់ (ស្រី ៣៧៣ដង/នាក់) ដែលនៅក្នុងនោះផ្នែកជំនាញបច្ចេកទេសថ្មីសរុបចំនួន ៨៤៤ដង/នាក់ (ស្រី ៦២ដង/នាក់) និងវិធីសាស្ត្របណ្តុះបណ្តាលថ្មីផ្អែកលើសមត្ថភាព (Competency-Based Training-CBT) ចំនួន ១ ០៤៩ដង/នាក់ (ស្រី ២០១ដង/នាក់), កម្មវិធីត្រឡប់ទៅឧស្សាហកម្មវិញ (Return to Industry Scheme-RIS) ចំនួន ៨៥១ដង/នាក់ (ស្រី ៩៥ដង/នាក់) និងការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ១៩១ដង/នាក់ (ស្រី ១៥ដង/នាក់)

- បានរៀបចំកម្មវិធីផ្សព្វផ្សាយទិវាជាតិ អ.ប.វ. តាមគ្រប់រូបភាព ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរៀងរាល់ឆ្នាំ នៅតាមបណ្តារាជធានី ខេត្ត ដែលមានអ្នកចូលរួមសរុប ៣២៤ ៨៨៧នាក់ (ស្រី ១១៩ ៦៥២នាក់) និងបានចុះផ្សព្វផ្សាយ និងតម្រង់ទិសវិជ្ជាជីវៈពីសារៈសំខាន់នៃការសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យក្នុងប្រព័ន្ធអប់រំចំណេះទូទៅសរុប ១ ៧៨២សាលា ចំនួនអ្នកចូលរួមសរុប ៣២១ ០៥៥នាក់ (ស្រី ១៦៤ ១៥៣នាក់)

- បានពង្រឹងអភិបាលកិច្ចប្រព័ន្ធ អ.ប.វ. ដោយបណ្តុះបណ្តាលសមត្ថភាពគណៈគ្រប់គ្រង និងមន្ត្រីរាជការ, បន្តជំរុញការត្រួតពិនិត្យ និងវាយតម្លៃ គុណភាពគ្រឹះស្ថាន អ.ប.វ. ជាប្រចាំ, ជំរុញឱ្យគ្រឹះស្ថាន អ.ប.វ. ចំនួន ៣៤/៣៧ បានទទួលវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងគុណភាពស្តង់ដាអន្តរជាតិ ISO 9001:2015, បានធ្វើបច្ចុប្បន្នភាព និងពង្រីកមុខងារប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ. (Technical Vocational Education and Training Management Information System-TVETMIS)

- បានអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលបន្ថែមចំនួន ៧០គុណវុឌ្ឍិ លើ៤២មុខជំនាញនៃវិស័យសំណង់, មេកានិក, អគ្គិសនីនិងថាមពល, អេឡិចត្រូនិក, កម្មន្តសាល, បរិក្ខារត្រជាក់និងកម្តៅ, សេវាកម្មធុរកិច្ចនិងព័ត៌មានវិទ្យា, សក់និងសម្រស់, និងវាយនភណ្ឌ ដែលធ្វើឱ្យកញ្ចប់គុណវុឌ្ឍិសរុបមានចំនួន ១៨៨ គុណវុឌ្ឍិ លើ ៧៦មុខជំនាញ (ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាពីកម្រិត ១ ដល់កម្រិត ៥) ត្រឹមឆ្នាំ២០២៣

- បានរៀបចំឱ្យមានការប្រកួតប្រជែងជំនាញថ្នាក់ជាតិចំនួន ២ដង, និងបញ្ជូនបេក្ខជនទៅចូលរួមការប្រកួតប្រជែងជំនាញអន្តរជាតិចំនួន ២ដង ដោយទទួលបានមេដាយប្រាក់ចំនួន ២នាក់

- បានពង្រឹងតួនាទីវិស័យឯកជនក្នុងការអភិវឌ្ឍវិស័យ អ.ប.វ. ដោយបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យចំនួន ៤ និងរៀបចំអនុស្សរណៈនៃការយោគយល់គ្នារវាងគ្រឹះស្ថាន អ.ប.វ. ជាមួយសហគ្រាស គ្រឹះស្ថានសរុបចំនួន ៣២៦

- បានបើកដំណើរការគ្រឹះស្ថាន អ.ប.វ. នៅក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩, និងបានអភិវឌ្ឍនិងដាក់ឱ្យដំណើរការប្រព័ន្ធជាតិ អ.ប.វ. ពីចម្ងាយ ឬតាមអនឡាញ (National TVET E-Learning Platform)

- បានផ្តល់កម្មវិធីបណ្តុះបណ្តាលជំនាញ និងកម្មវិធីបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញដល់កម្មករនិយោជិត និងយុវជនដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ក្រោមវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលសរុបចំនួន ២១ ៥០០នាក់ (ស្រី ៩ ៨៤៥នាក់) បានដាក់ឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣។ តាមរយៈកម្មវិធីនេះ ក្រសួងបានរៀបចំផែនការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេសដោយមិនបង់ថ្លៃសិក្សា និងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ។ កម្មវិធីបណ្តុះបណ្តាលជំហានដំបូងមានចំនួន ៣៨មុខជំនាញ នៅក្នុងវិស័យអាទិភាពចំនួន ១០វិស័យ រួមមាន សំណង់, អគ្គិសនីនិងថាមពល, អេឡិចត្រូនិក, បរិក្ខារត្រជាក់និងកម្តៅ, កម្មន្តសាល, មេកានិកទូទៅ/មេកានិករថយន្ត, ទេសចរណ៍, សេវាកម្ម, កសិកម្ម និងកសិ-ឧស្សាហកម្ម និងធុរកិច្ចនិងព័ត៌មានវិទ្យា។ គិតចាប់ពីថ្ងៃទី១៤ ខែវិច្ឆិកា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានអ្នកចុះឈ្មោះចូលរៀនសរុបចំនួន ១៩ ២៩៩នាក់ (ស្រី ៦ ៥៩៨នាក់)។ បន្ថែមលើនេះ ក្រសួងបានអភិវឌ្ឍប្រព័ន្ធឌីជីថលសម្រាប់ចុះឈ្មោះចូលរៀន (www.tvet.gov.kh), កម្មវិធីតាមទូរស័ព្ទដៃ TVET 1.5M និងបានផលិតវីដេអូស្តីពីកម្មវិធី អ.ប.វ. និងវីដេអូខ្លីៗសម្រាប់ធ្វើការផ្សព្វផ្សាយតាមបណ្តាញសង្គមនានា និងបានផលិតនិងបោះពុម្ពខិត្តប័ណ្ណ ព្រមទាំងបានចុះផ្សព្វផ្សាយតាមឃុំ សង្កាត់ និងតាមខ្នងផ្ទះនៃគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដើម្បីជំរុញការចុះឈ្មោះចូលរៀន។ ក្រសួងក៏បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយសភាពាណិជ្ជកម្មកម្ពុជា និងសមាគមនិយោជកសរុបចំនួន១៨ ដើម្បីគាំទ្រដល់កម្មវិធី អ.ប.វ. ជាពិសេស ការផ្តល់ឱកាសចុះកម្មសិក្សា/ហាត់ការ និងឱកាសការងារក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល។

### ២.៣.៣. ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុង និងក្រៅប្រទេស

- បានរក្សាលំនឹងស្ថានភាពការងារ និងបានបន្តចូលរួមចំណែកក្នុងការបង្កើតការងារ ឆ្លុះបញ្ចាំងតាមរយៈកំណើនសហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធបានកើនពី ១៤ ០៦០ កម្មករនិយោជិត ១ ៤៣៣ ៩៣៥នាក់ នៅឆ្នាំ២០១៩ មកដល់ ៤០ ៩៧៥ (កើនឡើង ១៩១,៤៣%) និងកម្មករសរុបចំនួន ១ ៧១៥ ០២៩នាក់ នៅឆ្នាំ២០២៣ (កើនឡើង ១៩,៦០%) ក្នុងនោះ សហគ្រាស គ្រឹះស្ថានវិស័យកាត់ដេរបានកើនពី ១ ២០៩ នៅឆ្នាំ២០១៩ ដល់ ១ ៤៩៩ នៅឆ្នាំ២០២៣ (កើនឡើង ២៣,៩៩%) មានកម្មករនិយោជិត ចំនួន ៨៨៦ ៣៥៥នាក់ (ស្រី ៦៧៣ ៧៣៦នាក់) សហគ្រាស គ្រឹះស្ថានវិស័យក្រៅពីកាត់ដេរបានកើនពី ១២ ៨៥១ ឆ្នាំ២០១៩ ដល់ ៣៩ ៤៧៦ ឆ្នាំ២០២៣ (កើនឡើង ២០៧,១៨%) មានកម្មករនិយោជិត ចំនួន ៨២៨ ៦៧៤នាក់ (ស្រី ៣៦៥ ៩៦៣នាក់)

- បានពង្រឹងយន្តការវិសាលភាព និងប្រសិទ្ធភាពការផ្តល់សេវាមុខរបរ និងការងារ ដោយបាន÷
  - បង្កើនមជ្ឈមណ្ឌលការងារ ដល់ចំនួន ១៤ និងមជ្ឈមណ្ឌលការងារចល័តចំនួន ៥ ព្រមទាំងបានពង្រីកថ្នាលឌីជីថលសេវាការងារ ដោយទទួលបានលទ្ធផល ÷
    - បានចុះឈ្មោះស្វែងរកការងារមានចំនួន ៨៩ ៨៥៥នាក់ (ស្រី ៥២ ៨២៨នាក់) ក្នុងនោះ បញ្ចប់សញ្ញាបត្រទុតិយភូមិ មានចំនួន ៧% រៀនត្រឹមថ្នាក់ទី១២ ចំនួន ៧២% និងកម្រិតបរិញ្ញាបត្រឡើងមានចំនួន ២១%
    - បង្កើនការប្រមូលផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មានទីផ្សារការងារ មានចំនួន ៦៤៨ ៧៣៦កន្លែង ក្នុងនោះតម្រូវការកម្លាំងពលកម្មជំនាញកម្រិតខ្ពស់ ដែលមានប្រភេទមុខរបរ ចាប់ពីអ្នកបញ្ជា និងអ្នកដំឡើងគ្រឿងចក្រ និងម៉ាស៊ីន រហូតដល់អ្នកគ្រប់គ្រង មានប្រមាណ ៨៤% និងជំនាញកម្រិតទាប សំដៅលើប្រភេទមុខរបរតូចតាច ប្រមាណ ១៦%។ ជាមួយគ្នានេះដែរ វិស័យដែលមានតម្រូវការកម្លាំងពលកម្ម និងបានប្រមូលផ្សព្វផ្សាយច្រើនជាងគេ គឺវិស័យកម្មន្តសាល ដែលមានតម្រូវការប្រមាណ ៤៦% និងវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង ប្រមាណចំនួន ១៧% ក្រៅពីនេះស្ថិតក្នុងវិស័យផ្សេងៗ
    - រៀបចំវេទិកាការងារ និងពិព័រណ៍ការងារថ្នាក់ជាតិ ខេត្ត សរុបចំនួន ១ ៤០៤ដង ដែលមានអ្នកចូលរួមសរុបចំនួន ៨៧៧ ១៤៩នាក់ ដោយមជ្ឈមណ្ឌលការងាររាជធានី ខេត្ត និងមជ្ឈមណ្ឌលការងារចល័ត
    - ចំនួនអ្នកទទួលបានសេវាប្រឹក្សាយោបល់អាជីពការងារ និងវិជ្ជាជីវៈ ចំនួន ១១៤ ១៩២នាក់
    - បានផ្គូផ្គងអ្នកស្វែងរកឱកាសការងារចំនួន ១១៨ ៩៥៥ដង/នាក់ (ស្រី ៦៨ ៧០០ដង/នាក់)
    - បានជួយអ្នកស្វែងរកការងារធ្វើ ឱ្យទទួលបានការងារដោយផ្ទាល់ ចំនួន ២៣ ៦៦០នាក់ (ស្រី ១៣ ៥៣០នាក់)

- បានផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ សរុបចំនួន ១ ៤២៧ ១១៨នាក់ (ស្រី ៩២៦ ៧០៩នាក់)

- បានផ្តល់និងពន្យារសុពលភាពលើបណ្ណការងារ/សៀវភៅការងារជនបរទេសតាមបណ្តាឆ្នាំ ដោយឆ្នាំ ២០១៩ ចំនួន ២០៧ ៨៨៧ នាក់, ឆ្នាំ២០២០ ចំនួន ១០០ ៩៣៤ នាក់, ឆ្នាំ២០២១ ចំនួន ១០០ ៦៩៨នាក់, ឆ្នាំ ២០២២ ចំនួន ១៨៨ ៦៥៣ នាក់, និងឆ្នាំ២០២៣ ចំនួន ២៧៤ ៨២០នាក់

- បានចេញលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មជនបរទេស (កូតា) មានចំនួន ២២ ១១៣សំណើ

- បានធ្វើអធិការកិច្ចហត្ថពលកម្មបរទេសនៅតាមសហគ្រាស គ្រឹះស្ថាន សរុបបានចំនួន ១៩ ៣៣៩ សហគ្រាស ដោយពិនិត្យឃើញជនបរទេស ចំនួន ១៦៨ ៩៣៦នាក់ ក្នុងនោះ ពិនិត្យឃើញអ្នកមានបណ្ណ/សៀវភៅការងារមានចំនួន ១៦១ ២២០នាក់ ស្មើនឹងប្រមាណ ៩៥,៤៣% និងអ្នកគ្មានបណ្ណ/សៀវភៅការងារមានចំនួន ៧៧ ១៦៣នាក់ ឬស្មើនឹង ៤,៥៧%

- បានចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេសចំនួន ១៧៩ ១៦១កិច្ចសន្យា និងប្រមូលចំណូលពីកម្រៃសេវាសាធារណៈ សរុបចំនួន ៥ ៧៧២,៥៣លានរៀល

- បានបង្កើតឱកាសការងារនៅក្រៅប្រទេស សរុបចំនួន ១៨៨ ៣៧៥នាក់ (ស្រី ៧៦ ៩៥៤នាក់) គិតចាប់ពីឆ្នាំ២០១៩-២០២៣ ហើយបើគិតមកទល់បច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជាកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេស សរុបចំនួន ១ ៣៥៦ ៦១៦នាក់ (ស្រី ៥៥២ ៨៥១នាក់) និងបានបញ្ជូនប្រាក់បញ្ញើមកក្នុងប្រទេសវិញក្នុងមួយឆ្នាំប្រមាណ ២,៩ប៊ីលានដុល្លារអាមេរិក ដោយបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាព និងសេដ្ឋកិច្ចគ្រួសាររបស់ពលករឱ្យកាន់តែប្រសើរឡើង

- បានដាក់ចេញនូវគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ២០១៩-២០២៣ និងកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ២០១៩-២០២៣ និងបានរៀបចំបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីការពារសិទ្ធិពលករទេសន្តរប្រវេសន៍ និងបន្តជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥

- បានបន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងថ្នាក់តំបន់ ដើម្បីគាំពារសិទ្ធិ ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ និងបានបញ្ជូនអនុព័ន្ធការងារ ដើម្បីជួយគាំពារពលករនៅតាមប្រទេស ដែលមានពលករកម្ពុជាស្នាក់នៅ និងធ្វើការលើសពី ៣ពាន់នាក់ មាននៅសាធារណរដ្ឋកូរ៉េ ២នាក់ ប្រទេសថៃ ៣នាក់ ប្រទេសម៉ាឡេស៊ី ២នាក់ និងប្រទេសជប៉ុន ១នាក់ ដោយបានជួយអន្តរាគមន៍ និងដោះស្រាយបញ្ហាទូទៅរបស់ពលករជួបការលំបាក សរុបចំនួន ២០ ៦៩១ករណី

- បានរៀបចំគណៈកម្មការដើម្បីសហការជាមួយភាគីថៃ ផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាប្រមាណជាង ៤៣ម៉ឺននាក់ ដែលធ្វើឱ្យពលករស្ទើរ ១០០% ក្លាយជាពលករស្របច្បាប់ និងបានផ្តល់លិខិតធ្វើដំណើរ (Travel Document-TD) សម្រាប់ពលករធ្វើការនៅក្រៅប្រទេសដោយឥតគិតថ្លៃ

- បានសហការជាមួយប្រទេសដៃគូ ដើម្បីធានាសុខភាព សុវត្ថិភាព និងជីវភាពរបស់ពលករ ក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដ-១៩ និងបានជួយសម្រួលឱ្យពលករបានវិលត្រឡប់មកពីប្រទេសថៃជាង ៣០ម៉ឺននាក់ នៅតាមបណ្តោយព្រំដែនថៃ-កម្ពុជា ដោយរៀបចំមជ្ឈមណ្ឌលចត្តាឡីស័ក, ធ្វើតេស្ត, ធ្វើចត្តាឡីស័ក, ព្យាបាល, ផ្តល់ម្ហូបអាហារ និងដឹកជញ្ជូនដោយឥតគិតថ្លៃ។

**២.៣.៤. ការអភិវឌ្ឍរបបសន្តិសុខសង្គម**

- បានរៀបចំច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មី ដើម្បីពង្រីកវិសាលភាពឱ្យកាន់តែទូលំទូលាយ ដោយគ្របដណ្តប់ដល់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ បុគ្គលធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ និងបុគ្គលស្វ័យនិយោជន៍ដែលរួមមានអាជីវករ អ្នករត់ម៉ូតូឌុប រត់កង់បី និងអ្នករកចំណូលផ្ទាល់ខ្លួនគ្រប់ប្រភេទ

- បានដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតី**

កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ និងបានរៀបចំយុទ្ធនាការផ្សព្វផ្សាយអំពីការអនុវត្ត និងអត្ថប្រយោជន៍នៃកម្មវិធីថ្មីនេះ បានចំនួន ៤ ៥៩៩លើក ដល់ប្រជាជនប្រមាណ ១,៤លាននាក់។ ជាលទ្ធផលគិតត្រឹមឆ្នាំ២០២៣ នេះ ប.ស.ស. បានចុះបញ្ជីសមាជិកសរុបចំនួន ៦៨ ៩១៧នាក់ ក្នុងនោះ បុគ្គលស្វ័យនិយោជន៍ ៦៨ ០៣៤នាក់ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. មានចំនួន ៨៨៣នាក់ ដោយសមាជិកបានទៅប្រើប្រាស់សេវាចំនួន ៤ ៧៥៣ករណី និងចំណាយតាវកាលិកអស់ទឹកប្រាក់ប្រមាណ ៤៨២,១១លានរៀល។ តាមរយៈការអនុវត្តរបបនេះសមាជិកម្នាក់ៗគ្រាន់តែបង់ភាគទានត្រឹមតែ ១៥ ៦០០រៀល គឺអាចទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រគ្រប់មូលដ្ឋានសុខាភិបាលដៃគូ ប.ស.ស. ទាំងសាធារណៈ និងឯកជន ដែលតាមការប៉ាន់ស្មានរបបនេះបានជួយឱ្យសមាជិក ប.ស.ស. អាចសន្សំសំចៃថវិកាផ្ទាល់ខ្លួនបានប្រមាណជា ១៥ ទៅ ២០ដុល្លារ ក្នុងមួយខែលើការថែទាំសុខភាពនេះ

- បានពង្រឹង និងពង្រីករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ចដល់កម្មករនិយោជិត និងមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយបានបង្កើនចំនួនសមាជិកពី ១,៥លាននាក់ នៅឆ្នាំ២០១៩ មកដល់ ២លាននាក់ នៅឆ្នាំ២០២៣ ហើយតម្រូវឱ្យនិយោជកបង់ភាគទានជំនួសកម្មករនិយោជិត ១០០%។ ដោយគិតត្រឹមឆ្នាំ២០២៣ នេះ សមាជិកទៅប្រើប្រាស់សេវាថែទាំសុខភាព សរុបមានចំនួន ១៦ ៩៤៤ ០៨០ករណី និងចំណាយតាវកាលិកចំនួន ១ ៩៤០,២២ប៊ីលានរៀល

- បានពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់កម្មករនិយោជិត និងសម្រាប់មន្ត្រីសាធារណៈ ដោយបានបង្កើនចំនួនសមាជិកពី ១,២លាននាក់ នៅឆ្នាំ២០១៩ មកដល់ ១,៨លាននាក់ នៅឆ្នាំ២០២៣ និងបានចំណាយតាវកាលិកចំនួន ១០៣,៨៦ប៊ីលានរៀល

- បានផ្តល់សេវាស្តារនីតិសម្បទាដល់សមាជិកបានចំនួន ៥០៥ករណី ក្នុងនោះសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រចំនួន ៣៤៧ករណី ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ៣៩ករណី (រួមមានជំនាញ÷ កាត់ដេរសម្លាង/កាត់សក់ អាហារនិងភេសជ្ជៈ អេឡិចត្រូនិក បច្ចេកវិទ្យាកុំព្យូទ័រ គ្រប់គ្រងគេហទំព័រ ជាងម៉ាស៊ីន និងកសិកម្ម) ផ្នែកសេវាសង្គមចំនួន ១១៧ករណី និងបានសម្របសម្រួលសេវារកការងារឡើងវិញបានចំនួន ២ករណី

- បានបើកផ្តល់ប្រាក់បំណាច់មាតុភាពដល់សមាជិក ប.ស.ស. ជាស្ត្រី គិតត្រឹមឆ្នាំ២០២៣ សរុបចំនួន ៣៥៥ ២៩១នាក់ ដែលគិតជាទឹកប្រាក់អស់ចំនួន ៧៣៩,៦២ប៊ីលានរៀល ដើម្បីលើកកម្ពស់លក្ខខណ្ឌការងារ និងសិទ្ធិស្ត្រី ព្រមទាំងចូលរួមអនុវត្តគោលនយោបាយយេនឌ័រ

- បានដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច និងស្ម័គ្រចិត្ត ចាប់ពីខែកក្កដា ឆ្នាំ២០២២។ ដោយគិតចាប់ពីថ្ងៃទី១ ខែតុលា ដល់ត្រឹមឆ្នាំ២០២៣ បានចុះបញ្ជីសមាជិកសរុបចំនួន ១,៥លាននាក់

- បានចុះអធិការកិច្ចបញ្ជិកា និងភាគទានសហគ្រាស គ្រឹះស្ថាន ចំនួន ៩ ៨៣៤ ក្នុងនោះបានចាត់វិធានការពិន័យអន្តរការណ៍ចំនួន ១២៦ សហគ្រាស គ្រឹះស្ថាន លើករណី÷ ការមិនអនុវត្តកាតព្វកិច្ចបង់ភាគទាន មិន

ចុះបញ្ជីសហគ្រាសនិងកម្មករនិយោជិត និងការប្រកាសចំនួនកម្មករនិយោជិត និងប្រាក់ឈ្នួលជាប់ភាគទានមិនត្រឹមត្រូវ ដើម្បីពង្រឹងការអនុវត្តកាតព្វកិច្ចរបស់និយោជក សំដៅពង្រីកការគ្របដណ្តប់នៃរបបសន្តិសុខសង្គម និងការពារអត្ថប្រយោជន៍របស់កម្មករនិយោជិត

- បានចុះត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងនៅមូលដ្ឋានសុខាភិបាលដៃគូសរុបចំនួន ៧៤៣ ក្នុងនោះបានធ្វើកំណត់ហេតុ និងកិច្ចសន្យាចំនួន ៥៨៧ បានចាត់វិធានការចេញលិខិតព្រមានចំនួន ១០ និងបញ្ចប់កិច្ចព្រមព្រៀងចំនួន ៥ សំដៅពង្រឹងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព

- បានចូលរួមគាំទ្រការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការចុះបញ្ជី និងផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល បានចំនួនប្រមាណ ៩,៩ម៉ឺននាក់ ដើម្បីផ្តល់ការគាំពារសុខភាពដល់ប្រជាពលរដ្ឋជាក្រុមគោលដៅអាចប្រើប្រាស់សេវាសុខភាពដោយឥតបង់ថ្លៃនៅមូលដ្ឋានសុខាភិបាលសាធារណៈ ដែលរាជរដ្ឋាភិបាលជាអ្នកទទួលបន្ទុកបង់ជំនួស

- បានចូលរួមបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលដល់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដោយគិតត្រឹមឆ្នាំ២០២៣ នេះ មានស្ត្រីសម្រាលកូនសរុបប្រមាណចំនួន ៤០,១ម៉ឺននាក់ មានកូនសរុបប្រមាណចំនួន ៤០,៤ម៉ឺននាក់ ស្មើនឹងថវិកាសរុបប្រមាណ ១៨០,៩ប៊ីលានរៀល (ប្រមាណ ៤៤,១ លានដុល្លារ) សំដៅលើកកម្ពស់សុខុមាលភាពមាតានិងទារក ក្នុងការរួមចំណែកដោះស្រាយកង្វះអាហារូបត្ថម្ភ ព្រមទាំងជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី

- បានអនុគ្រោះការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពដល់សហគ្រាស គ្រឹះស្ថាន ក្នុងវិស័យកាត់ដេរ និងទេសចរណ៍ដែលរងប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩ ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការអន្តរាគមន៍ក្នុងវិបត្តិជំងឺកូវីដ-១៩ សំដៅសម្រាលបន្ទុករបស់និយោជក និងបន្តផ្តល់សេវាថែទាំសុខភាពដល់កម្មករនិយោជិតដោយឥតគិតថ្លៃ

- បានដឹកនាំចុះផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសុវត្ថិភាពក្នុងការធ្វើដំណើរដល់អ្នកបើកបរយានយន្តដឹកកម្មករនិយោជិត និងកម្មករនិយោជិតបានចំនួន ១ ០៩៩លើក ដោយសម្រេចបានកម្រិតទាបនៃស្ថានភាពគ្រោះថ្នាក់ការងារក្នុងពេលធ្វើដំណើរ នៅអត្រាត្រឹមតែ ០,១៥% នៅឆ្នាំ២០២៣។

### ២.៣.៥. ការពង្រឹងសេវាគាំទ្រទូទៅ

- បានរៀបចំការផ្តល់សេវាសាធារណៈរបស់ក្រសួងតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីឆ្លើយតបនឹងសំណូមពររបស់វិស័យឯកជន ចំណេញពេលវេលា និងកាត់ចោលចំណាយផ្សេងៗ ដែលមិនចាំបាច់របស់អ្នកមកទទួលសេវា និងអ្នកប្រើប្រាស់សេវា

- បានពង្រឹងការគ្រប់គ្រងមន្ត្រីរាជការតាមអង្គភាពក្រោមឱវាទក្រសួង ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា

- បានចូលរួមអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីបង្កើនប្រសិទ្ធភាពការងារ

- បានបញ្ជូនមន្ត្រីទៅចូលរួមបណ្តុះបណ្តាល និងទស្សនកិច្ចទាំងក្នុង និងក្រៅប្រទេស សរុបចំនួន ២៣ ០៦៦ដង/នាក់ (ស្រី ៥ ៦៧០ដង/នាក់) ក្នុងនោះ បណ្តុះបណ្តាលក្នុងប្រទេស មានចំនួន ២១ ៣៣១ដង/នាក់ (ស្រី ៥ ៣៣០ដង/នាក់) (សាលាភូមិន្ទរដ្ឋបាល ចំនួន ៣៤៣ដង/នាក់) ទស្សនកិច្ចសិក្សាក្នុងប្រទេស ចំនួន ៧៣៩ដង/នាក់ (ស្រី ១២៤ដង/នាក់) បណ្តុះបណ្តាលក្រៅប្រទេស មានចំនួន ៨៥២ដង/នាក់ (ស្រី ១៩៣ដង/នាក់) និងទស្សនកិច្ចសិក្សាក្រៅប្រទេស ចំនួន ១៤៤ដង/នាក់ (ស្រី ២៣ដង/នាក់)

- បានធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចការងារ អង្គការវិជ្ជាជីវៈនិយោជក អង្គការវិជ្ជាជីវៈកម្មករនិយោជិត សិស្ស និស្សិត និងអ្នកពាក់ព័ន្ធដទៃទៀត ជាពិសេស បណ្តុះបណ្តាលមន្ត្រីរាជការក្នុងវិស័យការងារឱ្យក្លាយជាអធិការការងារ អធិការពេទ្យការងារ អភិបាលការងារ និងមន្ត្រីផ្សះផ្សាវិវាទការងារ ព្រមទាំងសិក្សាស្រាវជ្រាវអំពីលក្ខខណ្ឌទូទៅនៃវិស័យការងារ ទំនាក់ទំនងវិជ្ជាជីវៈ ផលិតភាពការងារ សុវត្ថិភាពនិងសុខភាពការងារ របបសន្តិសុខសង្គម និងទេសន្តរប្រវេសន៍ការងារបានចំនួនសរុប ២៨វគ្គ មានមន្ត្រីចូលរួមសរុប ៣ ៨៨៤នាក់ (ស្រី ៧១៦នាក់)

- បានយកចិត្តទុកដាក់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយពាក់ព័ន្ធ តាមរយៈការពង្រឹងយន្តការប្រមូលគ្រប់គ្រងចំណូល និងអនុវត្តចំណាយឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព

- បានពង្រឹងកិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិ កម្រិតទ្វេភាគី និងពហុភាគីជាមួយបណ្តាប្រទេស និងដៃគូពាក់ព័ន្ធនានា និងរៀបចំយន្តការច្រកចេញ-ចូលតែមួយសម្រាប់សម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងផ្សេងៗទៀត

- បានចូលរួមលើកកម្ពស់សមភាពយេនឌ័រ ដោយខិតខំអនុវត្តយ៉ាងខ្ជាប់ខ្ជួនអនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាំង ១២ចំណុច របស់ **សម្តេចតេជោ** និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាំង ៦ចំណុច របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និងផែនការយុទ្ធសាស្ត្រនារីរតនៈ និងបានផ្សព្វផ្សាយអនុសញ្ញា ស៊ី-ដ (Convention on the Elimination of All Forms of Discrimination Against Women-CEDAW) បានចំនួន ១ ៤៨៤នាក់ (ស្រី ៦៣៦នាក់)

- បានពង្រឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងគោលនយោបាយនានាពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយបានរៀបចំរបាយការណ៍វាយតម្លៃវឌ្ឍនភាពប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ និងពាក់កណ្តាលអាណត្តិរបស់ក្រសួងជាប្រចាំ ឱ្យមានសង្គតិភាពស្របតាមផែនការដើម្បីធានាដល់ប្រសិទ្ធភាពការងារកាន់តែប្រសើរ

- បានចុះអប់រំផ្សព្វផ្សាយស្តីពីការបង្ការ និងទប់ស្កាត់ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងគ្រឿងញៀនដល់សិស្ស និស្សិត កម្មករនិយោជិត និងពលករខ្មែរដែលត្រៀមចេញទៅធ្វើការនៅបរទេសបានចំនួន ២២១ ៤៨០នាក់ (ស្រី ១៦៤ ៩៩០នាក់)

- បានចុះតាមដាន និងជំរុញអនុវត្តប្រកាសលេខ ០៨៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ ប្រកាសលេខ ១៩៤ ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្មឡានដ្ឋ និងសេចក្តីណែនាំលេខ ០០៨ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមសហគ្រាស គ្រឹះស្ថាន ចំនួន ២៤

- បានចុះធ្វើអធិការកិច្ច ចំនួនសរុប ២១៦លើក តាមបណ្តាអង្គភាពរងអធិការកិច្ច

- បានធ្វើសវនកម្ម ចំនួនសរុប ២៥៨លើក តាមបណ្តាសវនដ្ឋាន។

## ២.៤- បញ្ហាប្រឈម

### ២.៤.១. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ

- លក្ខខណ្ឌការងារមិនទាន់ត្រូវបានអនុវត្តពេញលេញ និងគ្របដណ្តប់គ្រប់សកម្មភាពសេដ្ឋកិច្ច និងសហគ្រាស គ្រឹះស្ថាន ជាពិសេស ក្នុងវិស័យកសិកម្ម សេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគ្រាសធុនមីក្រូ តូច និងមធ្យម

- ការផ្លាស់ប្តូរបែបបទនៃការធ្វើការងារតាមរយៈការធ្វើការងារពីចម្ងាយ ការលេចឡើងនៃប្រភេទការងារថ្មីៗ ដូចជាការងារដោយប្រើថ្នាលឌីជីថលពុំទាន់ត្រូវបានសិក្សាឱ្យបានស៊ីជម្រៅ ដើម្បីកំណត់ក្របខណ្ឌច្បាប់អនុវត្តឱ្យបានត្រឹមត្រូវ

- ប្រព័ន្ធអធិការកិច្ចការងារ និងដំណើរការមិនទាន់មានភាពស៊ីសង្វាក់គ្នានៅក្នុងប្រព័ន្ធឯកភាពតែមួយ និងវិធីសាស្ត្រ និងឧបករណ៍ណែនាំសម្រាប់ការធ្វើអធិការកិច្ចមិនទាន់ត្រូវបានរៀបចំឱ្យស្របតាមវិធាននៃការគ្រប់គ្រងហានិភ័យ

- ជំនាញ និងសមត្ថភាពរបស់មន្ត្រីអធិការកិច្ចមិនទាន់បានបណ្តុះបណ្តាលទៅតាមចំណាត់ថ្នាក់ស្តង់ដាសមត្ថភាពនៃមន្ត្រីអធិការកិច្ចឱ្យបានពេញលេញ ខណៈការអប់រំ និងការគាំទ្រដល់អាជីវកម្មក្នុងការអនុវត្តស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅមានកម្រិត

- កង្វះវិធានការគ្រប់គ្រង ការទទួលបានព័ត៌មាន ការផ្តល់ឯកសារ និងភស្តុតាងឱ្យទាន់ពេលវេលា ចំពោះសហគ្រាស គ្រឹះស្ថាន នៅពេលបិទទ្វារ ផ្អាកអាជីវកម្ម ប្តូរអាសយដ្ឋាន ប្តូរថៅកែថ្មី ឬប្តូរស្លាកយីហោថ្មី

- សុវត្ថិភាពនិងសុខភាពការងាររបស់កម្មករនិយោជិតមិនទាន់ត្រូវបានធានាឱ្យបានពេញលេញ ទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយខ្វះយន្តការបញ្ជ្រាបការយល់ដឹង ការគ្រប់គ្រង តាមដាន វាយតម្លៃហានិភ័យការងារដែលមានលក្ខណៈជាប្រព័ន្ធ ខ្វះគោលនយោបាយជាក់លាក់ និងច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារ

- ពុំទាន់មានការសិក្សាស្រាវជ្រាវរៀបចំបញ្ជីជំងឺវិជ្ជាជីវៈ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ អ្នកបច្ចេកទេស និងគ្រូពេទ្យបច្ចេកទេស ព្រមទាំងបំពាក់សម្ភារ បរិក្ខារវេជ្ជសាស្ត្រ និងមន្ទីរពិសោធន៍ ដែលបម្រើដល់ការស្រាវជ្រាវ



ណ

- ទំនាក់ទំនងវិជ្ជាជីវៈនៅមិនទាន់មានភាពល្អប្រសើរគ្រប់គ្រាន់ ដោយតួអង្គប្រតិបត្តិករមួយចំនួននៅពុំទាន់យល់ដឹងត្រឹមត្រូវអំពីព្រំដែននៃការអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួន និងអង្គការវិជ្ជាជីវៈមួយចំនួនអនុវត្តមិនត្រឹមត្រូវតាមតួនាទី និងភារកិច្ច ដែលបានកំណត់នៅក្នុងច្បាប់ និងលក្ខន្តិកៈរបស់ខ្លួន ខណៈយន្តការដោះស្រាយវិវាទការងារមិនទាន់ឆ្លើយតបបានពេញលេញតាមតម្រូវការរបស់ភាគីវិវាទ

- ខ្វះការតាមដាន ត្រួតពិនិត្យនិងសិក្សាជាប្រព័ន្ធ ជាប្រចាំ និងទាន់ពេលវេលា និងការបកស្រាយមិនមានសង្គតិភាពគ្នានូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលបង្កឬមានហានិភ័យខ្ពស់ក្នុងការបង្កវិវាទ

- កង្វះទិន្នន័យសម្រាប់ប្រើប្រាស់ក្នុងការវិភាគ និងតាមដានលើនិន្នាការប្រាក់ឈ្នួលអប្បបរមានៅតាមវិស័យ,មិនទាន់មានម៉ូឌែល និងទិន្នន័យគ្រប់គ្រាន់ក្នុងការសិក្សាវិភាគលើបច្ច័យផលនៃប្រាក់ឈ្នួលអប្បបរមាលើការចំណាយ និងស្ថានភាពមានការងារ, លក្ខខណ្ឌវិនិច្ឆ័យនៃការកំណត់ប្រាក់ឈ្នួលអប្បបរមាមួយចំនួនមិនមាន ការកំណត់ ឬវាស់វែងជាក់លាក់ ដែលទាមទារឱ្យមានការរៀបចំបង្កើតជាសន្ទស្សន៍ ដើម្បីធ្វើការវាស់វែងព្រមទាំងមានភាពចាំបាច់ក្នុងការពង្រីកវិសាលភាពនៃការគ្របដណ្តប់ប្រាក់ឈ្នួលអប្បបរមា ទៅកាន់វិស័យផ្សេង។

**២.៤.២. ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

- ការបំពេញបេសកកម្មរបស់គ្រឹះស្ថាន អ.ប.វ. នៅមិនទាន់ឆ្លើយតបទៅនឹងអាណត្តិដែលរាជរដ្ឋាភិបាលបានកំណត់ និងប្រព័ន្ធអភិបាលកិច្ច អ.ប.វ. នៅមិនទាន់ដំណើរការបានពេញលេញនៅឡើយ ដែលទាមទារឱ្យមានការរៀបចំ និងជំរុញការអនុវត្តលិខិតបទដ្ឋានពាក់ព័ន្ធ អ.ប.វ. គោលការណ៍ណែនាំ និងលក្ខណវិនិច្ឆ័យគណៈគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ. និងនីតិវិធីប្រតិបត្តិស្តង់ដា និងជំរុញការអនុវត្តឱ្យបានពេញលេញនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ.

- គ្រឹះស្ថាន អ.ប.វ. ធំៗប្រមូលផ្តុំនៅរាជធានីភ្នំពេញ និងស្ថិតនៅទីរួមខេត្ត ខណៈក្រុមគោលដៅស្ថិតនៅឆ្ងាយ និងកំពុងធ្វើការនៅតាមសហគ្រាស គ្រឹះស្ថាន ដែលទាមទារឱ្យមានការសាងសង់អន្តេវាសិកដ្ឋានបន្ថែម និងការរៀបចំវគ្គបណ្តុះបណ្តាលចល័ត

- ការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញមិនទាន់មានភាពបត់បែន និងគ្របដណ្តប់គ្រប់ទិដ្ឋភាព និងធានាភាពធន់នៃកម្លាំងពលកម្មនៅមិនទាន់ឆ្លើយតបបានល្អជាមួយនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង

- ការផ្សារភ្ជាប់រវាងកម្មវិធីសិក្សាចំណេះទូទៅ និងកម្មវិធីសិក្សា អ.ប.វ. នៅមានកម្រិត ខណៈសេវាណែនាំប្រឹក្សាអំពីអាជីព មុខរបរ និងជំនាញវិជ្ជាជីវៈ ពុំទាន់បានទូលំទូលាយ

- ចំនួនសិក្ខាកាម សិស្ស និស្សិត ដែលទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅមានចំនួនតិចនៅឡើយ

- ការផ្តល់តម្លៃលើការសិក្សារៀនសូត្រ ការស្រាវជ្រាវ និងនវានុវត្តន៍វិស័យ អ.ប.វ. នៅមិនទាន់ផុសផុលសម្រាប់ជំរុញទឹកចិត្តយុវជនឱ្យមានក្តីស្រមៃ និងមានមោទនភាពក្នុងការសិក្សាវិស័យនេះ និងការសហការពីវិស័យឯកជនក្នុងការគាំទ្រលើគម្រោងស្រាវជ្រាវ និងនវានុវត្តន៍នៅមានកម្រិត

- កង្វះការលើកទឹកចិត្តទាំងធនធានហិរញ្ញវត្ថុ និងសម្ភារដល់សិក្ខាកាម សិស្ស និស្សិត ជាពិសេសអ្នកដែលចេញពីគ្រួសារក្រីក្រ ព្រមទាំងយន្តការក្នុងការផ្តល់កម្ចីសិក្សាដល់សិក្ខាកាម សិស្ស និស្សិត ឱ្យមានលទ្ធភាពចាប់យកជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសជំនាញអាទិភាព

- កម្មវិធី និងគុណភាព អ.ប.វ. នៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារដោយសារកង្វះខាតគ្រូបច្ចេកទេស និងសមត្ថភាពគ្រូនៅមានកម្រិត ឬខុសជំនាញ, គុណភាពកញ្ចប់ស្តង់ដាបណ្តុះបណ្តាលពុំទាន់បានល្អប្រសើរ និងការបណ្តុះបណ្តាលផ្អែកលើសមត្ថភាពមិនទាន់បានអនុវត្តពេញលេញ និងតម្រូវឱ្យបន្ថែមម៉ូឌុលបច្ចេកវិទ្យាឌីជីថល កុំព្យូទ័រមូលដ្ឋាន និងភាសាបរទេសជាដើម

- ផ្អែកតាមការធ្វើអង្កេត និងការស្ទង់មតិកន្លងទៅ ដើម្បីដំណើរការវគ្គបណ្តុះបណ្តាលដោយផ្អែកលើស្តង់ដាសមត្ថភាពលើវិស័យអាទិភាព និងមុខជំនាញសំខាន់ៗ កម្ពុជាត្រូវរៀបចំឱ្យមានកញ្ចប់ស្តង់ដាបណ្តុះបណ្តាលយ៉ាងតិចចំនួន ៧៥០គុណវុឌ្ឍិ។ ក្នុងអាណត្តិកន្លងទៅ ក្រសួងបានអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលចំនួន ១៨៨គុណវុឌ្ឍិ។ ជាទិសដៅក្នុងអាណត្តិនេះ ក្រសួងនឹងបន្តអភិវឌ្ឍឱ្យបានចំនួន ៣០០គុណវុឌ្ឍិបន្ថែមទៀត ដែលនឹងកើនឡើងដល់ចំនួន ៤៨៨គុណវុឌ្ឍិត្រឹមឆ្នាំ២០២៨ ហើយក្រសួងនឹងបញ្ចប់ការអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលដែលនៅសល់ចំនួន ២៦២គុណវុឌ្ឍិនៅអាណត្តិក្រោយឆ្នាំ២០២៩-២០៣៣

- ចំនួននិស្សិតទទួលបានការបណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេសមានប្រមាណ ២,៧ ម៉ឺននាក់ រយៈពេល ៥ឆ្នាំ កន្លងមកនេះ ដែលមិនទាន់ឆ្លើយតបទៅនឹងកំណើនយ៉ាងលឿននៃតម្រូវការទីផ្សារការងារសម្រាប់បម្រើការមុខងារជាអ្នកគ្រប់គ្រង/អ្នកបច្ចេកទេស។ ក្នុងអាណត្តិនេះ ក្រសួងនឹងធ្វើការបណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស (Higher Technical Diploma) និងសញ្ញាបត្រជាន់ខ្ពស់ផ្អែកលើសមត្ថភាព (Competency Diploma) តាមរយៈការសិក្សានៅតាមគ្រឹះស្ថាន អ.ប.វ., កម្មវិធីសិក្សាផ្អែកលើការងារ (Work -Based Learning-WBL) និងការធ្វើតេស្តវាយតម្លៃទទួលស្គាល់សមត្ថភាពជំនាញឱ្យបានយ៉ាងតិច ២០០ ០០០នាក់ ត្រឹមឆ្នាំ២០២៨

- កម្មករនិយោជិត និងពលករទេសន្តរប្រវេសន៍កម្ពុជាធ្វើមាតុភូមិនិវត្តន៍ តែងតែទទួលបានជំនាញ និងបទពិសោធការងារ ប៉ុន្តែការធ្វើតេស្តវាយតម្លៃទទួលស្គាល់សមត្ថភាពជំនាញនៅមានចំនួនតិចនៅឡើយ ដែលតម្រូវឱ្យក្រសួងត្រូវពង្រីកកម្មវិធីធ្វើតេស្តវាយតម្លៃទទួលស្គាល់ការសិក្សាដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្ន (RPL/RCC), កង្វះយន្តការលើកទឹកចិត្ត និងជំរុញការចូលរួមពីវិស័យឯកជន ដើម្បីគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យ អ.ប.វ. រួមមាន អគារសិក្សា រោងជាង/បន្ទប់ពិសោធន៍ អន្តេវាសិកដ្ឋាន ឧបករណ៍ និងបរិក្ខារបច្ចេកទេស នៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការនៃការបណ្តុះបណ្តាលនៅតាមវិស័យ និងជំនាញអាទិភាព។



ញ

### ២.៤.៣. ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុង និងក្រៅប្រទេស

- ការប្រើប្រាស់ប្រព័ន្ធផ្តល់សេវាការងារសាធារណៈពីសំណាក់អ្នកស្វែងរកការងារ សិស្ស និស្សិត និង និយោជក មិនទាន់បានប្រើប្រាស់ និងយល់ពីប្រព័ន្ធគ្រប់ជ្រុងជ្រោយ

- តម្រូវការនៃការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់សេវាការងារសាធារណៈមានការវិវត្តឆាប់រហ័ស

- លទ្ធភាព និងភាពជាដៃគូជាមួយវិស័យឯកជន និងគ្រឹះស្ថានសិក្សានៃការប្រមូល ផ្សព្វផ្សាយព័ត៌មាន ឱកាសការងារ និងការនាំយកសេវាទៅដល់អ្នកប្រើប្រាស់នៅមិនទាន់មានកិច្ចសហការទូលំទូលាយ និងគ្របដណ្តប់ពេញលេញ

- អ្នកស្វែងរកការងារដែលចុះឈ្មោះជាមួយអង្គភាពផ្តល់សេវាការងារសាធារណៈ មានជំនាញកម្រិតទាប ឬគ្មាន និងសមត្ថភាពមានកម្រិត ជាបញ្ហាប្រឈមក្នុងការបញ្ជូន និងផ្គូផ្គងទៅនិយោជក

- តម្រូវការកម្លាំងពលកម្មជំនាញរបស់និយោជកមានការវិវត្តឆាប់រហ័ស ក្នុងសម័យកាលបដិវត្តន៍ឧស្សាហកម្ម ៤.០

- ផែនការផ្តល់សេវាមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ មិនទាន់គ្របដណ្តប់ទូទាំងប្រទេស ជាពិសេសសិស្សនៅកម្រិតបឋមភូមិ និងទុតិយភូមិ

- ការគ្រប់គ្រងទិន្នន័យកម្មករនិយោជិកខ្មែរតាមរយៈប្រព័ន្ធឌីជីថលមិនទាន់បានពេញលេញ ដោយកម្មករនិយោជិកខ្មែរមួយចំនួនបាននិងកំពុងប្រើប្រាស់សៀវភៅការងារ និងបណ្ណសម្គាល់ការងារកម្មករនិយោជិតខ្មែរទម្រង់ចាស់

- ការគ្រប់គ្រងទិន្នន័យហត្ថពលកម្មបរទេស ដោយបែងចែកតាមវិស័យ និងជំនាញ នៅមានកម្រិត

- ការយល់ដឹងរបស់ជនបរទេសមានបំណងមកធ្វើការនៅប្រទេសកម្ពុជាអំពីនីតិវិធី និងតម្រូវការឯកសារធ្វើការងារដោយស្របច្បាប់នៅមិនទាន់បានទូលំទូលាយ

- ពលរដ្ឋខ្មែរដែលមានបំណងទៅធ្វើការនៅបរទេសមិនទាន់យល់ច្បាស់អំពីនីតិវិធី និងរយៈពេលដំណើរការឯកសារទៅធ្វើការនៅបរទេស

- ការទទួលបានព័ត៌មានអំពីឱកាសការងារ និងការបណ្តុះបណ្តាលជំនាញ និងការយល់ដឹងអំពីការធ្វើតេស្តសមត្ថភាពទទួលស្គាល់ជំនាញរបស់ពលករដែលធ្វើមាតុភូមិនិវត្តន៍ នៅមានកម្រិត។

### ២.៤.៤. ការអភិវឌ្ឍរបបសន្តិសុខសង្គម

- វិស័យក្រៅប្រព័ន្ធ និងសហគ្រាសធុនមីក្រូ តូច និងមធ្យម នៅមានអត្រាខ្ពស់ ដែលនាំឱ្យការពង្រីកវិសាលភាពគ្របដណ្តប់ពេញលេញនៃរបបសន្តិសុខសង្គមដែលឈរលើការបង់ភាគទានជាកាតព្វកិច្ចនៅមានកម្រិត

- ការយល់ដឹងនៅមានកម្រិតអំពីសារៈសំខាន់នៃរបបសន្តិសុខសង្គម ក្នុងការធានាការពារដល់សន្តិសុខ និងស្ថិរភាពប្រាក់ចំណូល ចំពោះហានិភ័យសំខាន់ៗពីសំណាក់កម្មករនិយោជិត ក៏ដូចជាអំពីតួនាទីរបបសន្តិសុខសង្គមក្នុងការចូលរួមចំណែកលើកកម្ពស់ផលិតភាពពីសំណាក់និយោជក

- ប្រព័ន្ធគ្រប់គ្រងទិន្នន័យ កម្មករនិយោជិត និងសហគ្រាស គ្រឹះស្ថាន នៅមិនទាន់តភ្ជាប់ជាមួយមូលដ្ឋានទិន្នន័យក្នុងប្រព័ន្ធរួមតែមួយរបស់ក្រសួង ដែលផ្តល់ភាពងាយស្រួល និងប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងតាមដានការចុះបញ្ជិកា និងបង់ភាគទានព្រមទាំងការបើកផ្តល់តាវកាលិក និងអត្ថប្រយោជន៍

- អត្រាប្រាក់ឈ្នួលមធ្យមរបស់កម្មករនិយោជិតភាគច្រើន នៅមានកម្រិត ដែលនាំឱ្យលទ្ធភាពនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់សមាជិកគ្រួសារ នៅមានកម្រិត

- ពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ អាចប្រឈមនឹងការបាត់បង់អត្ថប្រយោជន៍ពីរបបសន្តិសុខសង្គមដែលខ្លួនបានបង់ភាគទាននៅប្រទេសដែលខ្លួនបានទៅធ្វើការ ដោយសារមិនទាន់មានក្របខណ្ឌផ្លូវការនៃការធ្វើចល័តភាពរបបសន្តិសុខសង្គម។

### ២.៤.៥. ការពង្រឹងសេវាគាំទ្រទូទៅ

- ការផ្តល់សេវាសាធារណៈរបស់ក្រសួង នៅមិនទាន់ឆ្លើយតបបានទាំងស្រុងទៅនឹងសំណូមពររបស់វិស័យឯកជន និងអ្នកប្រើប្រាស់សេវា

- ប្រព័ន្ធស្វ័យប្រវត្តិកម្មសេវាសាធារណៈរបស់ក្រសួងនៅមិនទាន់ប្រមូលផ្តុំ និងមិនទាន់មានភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់នៅឡើយ (User Friendly)

- ចំនួនមន្ត្រី ថវិកា និងសមត្ថភាពជំនាញមួយចំនួននៅមានការខ្វះខាត ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព

- ការប្រមូល ចងក្រង និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តនៅមិនទាន់អនុវត្តបានពេញលេញ

- ការអនុវត្តយន្តការច្រកចេញ- ចូលតែមួយសម្រាប់ការសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគ្រប់គ្រងអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងផ្សេងៗទៀតនៅមានកម្រិត

- យន្តការនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ច្បាប់ជាតិ និងអន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅមិនទាន់អនុវត្តបានពេញលេញ

- ការបែងចែកភារកិច្ច និងរបៀបរបបបំពេញការងាររវាងអគ្គាធិការដ្ឋាន និងនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅមិនទាន់ច្បាស់លាស់។

# ជំពូកទី ៣
# ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ នឹងឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាដែលនៅសេសសល់ពីការអនុវត្តកន្លងមក និងកំណត់នូវយុទ្ធសាស្ត្រគន្លឹះច្បាស់លាស់មួយ ដែលមានភាពប្រទាក់ក្រឡា និងបំពេញគ្នាទៅវិញទៅមក ដើម្បីធានាប្រសិទ្ធភាព និងភាពជោគជ័យនៃគោលនយោបាយរបស់វិស័យទាំងមូល។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រនេះមានមុខព្រួញលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សប្រកបដោយសមធម៌ ទាំងបរិមាណ និងគុណភាព អាចឆ្លើយតបតាមតម្រូវការនៃការវិវត្តយ៉ាងឆាប់រហ័សនៃមូលដ្ឋានសេដ្ឋកិច្ច ឧស្សាហកម្ម បច្ចេកវិទ្យាឌីជីថល ការការពារបរិស្ថានប្រកបដោយចីរភាព និងភាពងាយទទួលបានការងារសមរម្យ ដែលធានាបានការប្រកួតប្រជែងក្នុងប្រទេសក៏ដូចជាចូលរួមចំណែកក្នុងការសម្រេចជោគជ័យនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រនេះបានកំណត់សកម្មភាពសម្រាប់អនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាំង ១០ចំណុច របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាំង ១០ចំណុចបន្ថែម របស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

ក្នុងន័យនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញនូវយុទ្ធសាស្ត្របច្ចេកទេសចំនួន ៥ និងយុទ្ធសាស្ត្រគាំទ្រទូទៅចំនួន ១ ដូចខាងក្រោម÷

- **យុទ្ធសាស្ត្រទី១** ÷ ការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម
- **យុទ្ធសាស្ត្រទី២** ÷ ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង
- **យុទ្ធសាស្ត្រទី៣** ÷ ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាពនិងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ស្របតាមការវិវត្តនៃពិភពការងារ
- **យុទ្ធសាស្ត្រទី៤** ÷ ការពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព
- **យុទ្ធសាស្ត្រទី៥** ÷ ការអភិវឌ្ឍរបបសន្តិសុខសង្គមស្របតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច
- **យុទ្ធសាស្ត្រទី៦** ÷ ការធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈនិងសេវាគាំទ្រទូទៅតាមបច្ចេកវិទ្យាឌីជីថល

## ៣.១- ការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម

រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា បានកំណត់ការអភិវឌ្ឍទីផ្សារការងារ តាមរយៈការបង្កើត ការរក្សា និងការបង្កើនការងារជូនកម្មករនិយោជិត ទាំងក្នុង ទាំងក្រៅប្រព័ន្ធ ជាកត្តាមួយចាំបាច់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនាពេលបច្ចុប្បន្ន និងសម្រាប់រយៈពេល ២៥ឆ្នាំខាងមុខ ដូចដែលបានរំលេចនៅក្នុង **មុំទី១ ÷ ការអភិវឌ្ឍទីផ្សារការងារនៃបញ្ចកោណទី៣ស្តីពីការអភិវឌ្ឍវិស័យឯកជន និងការងារ ក្នុង "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"**។ ប៉ុន្តែ ការបង្កើតទីផ្សារការងារមួយដែលមានភាពរឹងមាំ និងជវភាព ទាមទារជំនះឱ្យបាននូវកត្តាប្រឈមចម្បងៗមួយចំនួនដូចជា ការតម្រង់ទិសគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដោយផ្តោតលើការបង្កើតការងារដែលមានផលិតភាពខ្ពស់ ការពង្រឹងគុណភាព និងពង្រីកភាពទទួលបានសេវាការងារសាធារណៈ ការតម្រង់ទិសការបណ្តុះបណ្តាលជំនាញឱ្យស្របទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃឧស្សាហកម្ម បច្ចេកវិទ្យា បរិស្ថាន ចីរភាព និងគោលនយោបាយអភិវឌ្ឍន៍វិស័យរបស់រាជរដ្ឋាភិបាល ប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងស្រុក ព្រមទាំងការលើកទឹកចិត្តដល់វិស័យឯកជន និងអ្នកពាក់ព័ន្ធឱ្យចូលរួមក្នុងយុទ្ធនាការលើកកម្ពស់ផលិតភាពការងារ។ ឈរលើការគិតគូរក្នុងអាណត្តិថ្មីនេះ ក្រសួងនឹងដាក់ចេញនូវយុទ្ធសាស្ត្រទី ១ នៃ ផ.យ.អ.-ក.ស.ប ២០២៤-២០២៨ ដោយផ្តោតលើការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម ឱ្យកាន់តែមុតស្រួច ស៊ីជម្រៅ និងប្រទាក់ក្រឡាគ្នាជាមួយការកំណត់សូចនាករសមិទ្ធកម្ម ឬបច្ច័យផលទីផ្សារការងារជាក់លាក់ ដែលអាចវាស់វែង តាមដាន និងត្រួតពិនិត្យបានជាប្រចាំ សំដៅម្ខាងដើម្បីជំរុញកំណើនឱកាសការងារដែលមានផលិតភាពខ្ពស់ និងម្ខាងទៀតដើម្បីធានាបានថាប្រជាជនដែលមានជំនាញ និងបទពិសោធការងារនឹងមានលទ្ធភាពទទួលបានការងារប្រសើរជាងមុន នៅតាមបណ្តាវិស័យសេដ្ឋកិច្ចដែលមានការរីកចម្រើន។

សូចនាករកម្រិតយុទ្ធសាស្ត្រ ត្រូវសម្រេចឱ្យបានក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ មាន ៥ ដូចខាងក្រោម÷

៣.១.ក. កំណើនចំនួនការងារនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ

៣.១.ខ. កំណើនចំណែកនៃចំនួនការងារនៅក្នុងវិស័យកម្មន្តសាលក្រៅពីកាត់ដេរ ធៀបនឹងចំនួនការងារសរុបនៅក្នុងវិស័យកម្មន្តសាលនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ

៣.១.គ. កំណើនចំណែកនៃចំនួនការងារដែលបង្កើតដោយសហគ្រាសធុនតូច និងមធ្យម ដែលនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ធៀបនឹងចំនួនការងារក្នុង សហគ្រាសធុនតូច និងមធ្យមសរុប និងធៀបនឹងចំនួនការងារសរុបនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ

៣.១.ឃ. កំណើនចំណែកនៃចំនួនការងារបង្កើតដោយសហគ្រាស គ្រឹះស្ថាន ដែលមានសញ្ជាតិខ្មែរ ធៀបនឹងចំនួនការងារសរុបនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ

៣.១.ង. អត្រានៃចំនួនសហគ្រាស គ្រឹះស្ថាន ដែលរាយការណ៍ពីស្ថានភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម និងអត្រានៃយុវជន សិស្ស និស្សិត ដែលជ្រើសរើសជំនាញ និងមុខរបរស្របតាមទីផ្សារការងារ មានភាពប្រសើរ

ដើម្បីសម្រេចបាននូវសូចនាករកម្រិតយុទ្ធសាស្ត្រខាងលើនេះ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

### ៣.១.១. ការពង្រឹងការអនុវត្តគោលនយោបាយ និងសិក្សាស្រាវជ្រាវ ដោយឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.១.១.ក. ឯកសារគោលនយោបាយជាតិ និងកម្មវិធីរបស់អង្គការអន្តរជាតិពាក់ព័ន្ធ ត្រូវបានសិក្សាវាយតម្លៃ សហការរៀបចំ និង/ឬធ្វើបច្ចុប្បន្នភាពទៅតាមក្របខណ្ឌពេលវេលា

៣.១.១.ខ. របាយការណ៍អង្កេតព័ត៌មានទីផ្សារការងារ ត្រូវបានផលិត និងផ្សព្វផ្សាយ

៣.១.១.គ. អត្រាអង្គភាពប្រតិបត្តិ ដែលរៀបចំ និងអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដា ប្រកបដោយប្រសិទ្ធភាព ដើម្បីធានាសម្រេចឱ្យបាននូវកម្មវិធី ចង្កោមសកម្មភាព សកម្មភាពដែលបានដាក់ចេញ

៣.១.១.ឃ. ទស្សនវិស័យមុខរបរនិងការងារ ២ដង/ឆ្នាំ ត្រូវបានបោះពុម្ពផ្សាយជាទៀងទាត់ និងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ទាំងសម្រាប់សិស្ស និស្សិត សហគ្រាស គ្រឹះស្ថាន និងរាជរដ្ឋាភិបាល

៣.១.១.ង. សន្និសីទថ្នាក់ជាតិស្តីពីគោលនយោបាយទីផ្សារការងារ ត្រូវបានរៀបចំឡើងជាប្រចាំឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.១.១.១ រៀបចំបង្កើត និងពង្រឹងយន្តការអង្គភាពទទួលបន្ទុករៀបចំ សម្របសម្រួលការអនុវត្ត សិក្សាវាយតម្លៃ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយទីផ្សារការងារសកម្ម ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- យន្តការអង្គភាពស្នូលទទួលបន្ទុករៀបចំ សម្របសម្រួលការអនុវត្ត សិក្សាវាយតម្លៃ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយទីផ្សារការងារសកម្ម ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការពេញលេញ
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តការងារ ត្រូវបានរៀបចំ
- ចំនួនសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលសមត្ថភាព ត្រូវបានរៀបចំប្រចាំត្រីមាស

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំសេចក្តីសម្រេច ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីដាក់ឱ្យដំណើរការយន្តការអង្គភាពទទួលបន្ទុករៀបចំ សម្របសម្រួលការអនុវត្ត សិក្សាវាយតម្លៃ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយទីផ្សារការងារសកម្ម ដោយកំណត់នូវយន្តការដឹកនាំសម្របសម្រួល សមាសភាព និងរចនាសម្ព័ន្ធលេខាធិការដ្ឋាន
- រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាព លើការអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម ដល់សមាជិក និងមន្ត្រីលេខាធិការដ្ឋានរបស់តួអង្គទទួលបន្ទុកព្រមទាំងដៃគូពាក់ព័ន្ធ
- រៀបចំ និងផ្សព្វផ្សាយ យន្តការ និងនីតិវិធីក្នុងការរៀបចំបូកសរុប តាមដាន និងវាយតម្លៃគោលនយោបាយទីផ្សារការងារសកម្ម និងកម្មវិធីនានា
- ធ្វើទស្សនកិច្ចសិក្សា និងចូលរួមការបណ្តុះបណ្តាលនៅក្រៅប្រទេស
- រៀបចំកិច្ចប្រជុំតាមដាន និងបូកសរុបរបាយការណ៍នៃការអនុវត្តការងារជាប្រចាំខែ

៣.១.១.២ ជំរុញការសិក្សាស្រាវជ្រាវ ពិនិត្យ រៀបចំឡើងវិញ ធ្វើបច្ចុប្បន្នភាព និងផ្តួចផ្តើមរៀបចំគោលនយោបាយ និងកម្មវិធីនានាពាក់ព័ន្ធវិស័យការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ឯកសារស្រាវជ្រាវពាក់ព័ន្ធនឹងគោលនយោបាយ និងកម្មវិធីនានាពាក់ព័ន្ធវិស័យការងារត្រូវបានផលិត បោះពុម្ព និងផ្សព្វផ្សាយ
- គោលនយោបាយ និងកម្មវិធីនានាពាក់ព័ន្ធទីផ្សារការងារសកម្ម ត្រូវបានផ្តួចផ្តើមធ្វើបច្ចុប្បន្នភាព/រៀបចំឡើងវិញ ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវខាងលើ
- ចំនួនសិក្ខាសាលាពិគ្រោះយោបល់ និងសិក្ខាសាលាផ្សព្វផ្សាយ ត្រូវបានរៀបចំយ៉ាងតិច៤ដង/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- សិក្សាវាយតម្លៃអំពីតម្រូវការសម្រាប់ការពិនិត្យឡើងវិញ និងការរៀបចំគោលនយោបាយទីផ្សារការងារសកម្ម ទៅតាមក្របខណ្ឌពេលវេលា ដើម្បីធានាសង្គតិភាព ភាពគ្រប់ជ្រុងជ្រោយ និងភាពពាក់ព័ន្ធ នៃការដាក់ចេញគោលនយោបាយ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងវិស័យការងារ
- ដឹកនាំសម្របសម្រួលក្នុងការពិនិត្យ និងសហការរៀបចំឡើងវិញនូវគោលនយោបាយទីផ្សារការងារសកម្ម ព្រមទាំងផ្តួចផ្តើមរៀបចំគោលនយោបាយថ្មីបន្ថែម

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ក្នុងការប្រមូលធាតុចូលពីភាគីពាក់ព័ន្ធលើការផ្តួចផ្តើមការធ្វើបច្ចុប្បន្នភាព និងរៀបចំគោលនយោបាយ
- រៀបចំ និងអនុម័តកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា និងកម្មវិធីនានាពាក់ព័ន្ធទីផ្សារការងារសកម្ម
- សិក្សាស្រាវជ្រាវ ផលិត បោះពុម្ពគោលនយោបាយ និងកម្មវិធីនានាពាក់ព័ន្ធនឹងវិស័យការងារ

៣.១.១.៣ ជំរុញការផ្សព្វផ្សាយ និងអនុវត្ត ព្រមទាំងពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងកម្មវិធីនានា ឱ្យកាន់តែមានប្រសិទ្ធភាពទាំងនៅកម្រិតថ្នាក់ជាតិ និងរាជធានី ខេត្ត ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- កិច្ចសន្ទនាពាក់ព័ន្ធនឹងវឌ្ឍនភាព និងបញ្ហាប្រឈម នៃការអនុវត្តគោលនយោបាយ ដោយផ្អែកទៅលើទិន្នន័យច្បាស់លាស់ ត្រូវបានរៀបចំ យ៉ាងតិច ១ដង/ឆ្នាំ
- កិច្ចប្រជុំបូកសរុបវឌ្ឍនភាព តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ និងកម្មវិធី យ៉ាងតិច ១លើក/ឆ្នាំ/គោលនយោបាយ
- ឯកសារគោលនយោបាយ ត្រូវបោះពុម្ព និងផ្សព្វផ្សាយ យ៉ាងតិច ៥ ០០០ច្បាប់/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំផែនការសកម្មភាពក្នុងការអនុវត្តគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធ និងកំណត់និយមន័យ វិធីសាស្ត្រ រយៈពេល និងប្រភពនៃការវាស់វែងសូចនាករលទ្ធផលការងារពាក់ព័ន្ធគោលនយោបាយទីផ្សារការងារសកម្ម ព្រមទាំងរៀបចំនីតិវិធីក្នុងការប្រមូល និងរក្សាទុកទិន្នន័យនៅមួយកន្លែង និងងាយស្រួល ក្នុងការទាញយកមកប្រើប្រាស់នៅគ្រប់កម្រិតទាំងថ្នាក់ជាតិ និងរាជធានី ខេត្ត
- រៀបចំកិច្ចប្រជុំពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តសកម្មភាព និងកម្មវិធីនានា ដើម្បីធានាសង្គតិភាព ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ព្រមទាំងអនុម័តរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ
- រៀបចំវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពពាក់ព័ន្ធនឹងការរៀបចំផែនការសកម្មភាព និងការអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម ព្រមទាំងជំរុញការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង និងវឌ្ឍនភាពអំពីគោលនយោបាយ ដល់ដៃគូពាក់ព័ន្ធ ជាពិសេសតាមរយៈការបោះពុម្ពផ្សព្វផ្សាយ និងការរៀបចំកិច្ចសន្ទនា



ហ

- តាមដាន និងត្រួតពិនិត្យសូចនាករសមិទ្ធកម្ម និងបច្ច័យផលទៅតាមកម្មវិធីនៃគោលនយោបាយ ព្រមទាំង សិក្សា អង្កេត និងវាយតម្លៃការអនុវត្តគោលនយោបាយ និងកម្មវិធី
- ធ្វើការបូកសរុបរបាយការណ៍វឌ្ឍនភាពស្ដីពីការអនុវត្តគោលនយោបាយ និងកម្មវិធីដាក់ជូនរាជរដ្ឋាភិបាល ឱ្យទាន់ពេលវេលា តាមក្របខណ្ឌពេលវេលាដែលបានកំណត់

៣.១.១.៤ រៀបចំបង្កើត និងពង្រឹងយន្តការអង្គភាពទទួលបន្ទុក ដើម្បីដឹកនាំអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន និងស្ថិតិទីផ្សារការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- យន្តការអង្គភាពស្នូលទទួលបន្ទុកដឹកនាំអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មាន និងស្ថិតិទីផ្សារការងារ ត្រូវបានរៀបចំ និងដំណើរការពេញលេញ
- របាយការណ៍វឌ្ឍនភាពការងារ ត្រូវបានរៀបចំ
- ចំនួនសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលសមត្ថភាព ត្រូវបានរៀបចំប្រចាំត្រីមាស

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីឱ្យយន្តការអង្គភាពស្នូលទទួលបន្ទុកមានសមត្ថកិច្ចដឹកនាំអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានគ្រប់គ្រងស្ថិតិការងារ
- រៀបចំវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពមន្ត្រី លើប្រព័ន្ធព័ត៌មានគ្រប់គ្រងស្ថិតិការងារ រៀងរាល់ត្រីមាស
- ជំរុញការជ្រើសរើសមន្ត្រីជំនាញ និងពង្រឹងសមត្ថភាពមន្ត្រីដែលមានស្រាប់ សម្រាប់ផ្នែកប្រមូល អង្កេត វិភាគ ប៉ាន់ស្មាន និងព្យាករ
- ជំរុញការធ្វើទស្សនកិច្ចសិក្សា និងបណ្តុះបណ្តាលនៅក្រៅប្រទេសដើម្បីរៀនសូត្រ និងផ្លាស់ប្តូរបទពិសោធ
- រៀបចំកិច្ចប្រជុំតាមដាន និងបូកសរុបវឌ្ឍនភាពនៃការអនុវត្តការងារជាប្រចាំខែ

៣.១.១.៥ ជំរុញការអង្កេត វិភាគស្រាវជ្រាវ ប៉ាន់ស្មាន ព្យាករ រៀបចំ និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានទីផ្សារការងារឱ្យបានទៀងទាត់ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍អង្កេតស្ដីអំពីស្ថានភាពកម្លាំងពលកម្ម និងការងារនៅកម្ពុជា ត្រូវបានរៀបចំប្រចាំឆ្នាំ
- របាយការណ៍អង្កេតនិយោជកស្ដីពីតម្រូវការជំនាញ ត្រូវបានរៀបចំ ប្រចាំឆមាស

- ម៉ូឌែលសេដ្ឋកិច្ច និងទីផ្សារការងារសម្រាប់ព្យាករតម្រូវការ និងការផ្គត់ផ្គង់ជំនាញ និងកម្លាំងពលកម្ម ត្រូវបានអភិវឌ្ឍ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំអង្កេត ប្រមូល និងធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ វិភាគ ប៉ាន់ស្មាន និងព្យាករ
- ជំរុញការងារអង្កេតស្តីអំពីស្ថានភាពកម្លាំងពលម្ម និងការងារនៅកម្ពុជា ប្រចាំឆ្នាំ, អង្កេតនិយោជកស្តីពីតម្រូវការជំនាញប្រចាំឆមាស, អង្កេតស្តីពី "ភាពមិនស៊ីគ្នានៃជំនាញ" និងគុណវុឌ្ឍិក្នុងប្រទេសកម្ពុជាប្រចាំឆ្នាំ និងអង្កេតពាក់ព័ន្ធនឹងសេដ្ឋកិច្ចទីផ្សារការងារផ្សេងទៀត ដើម្បីផលិត បោះពុម្ព និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានទីផ្សារការងារ ឱ្យបានទូលំទូលាយ ដល់សិស្ស និស្សិត សហគ្រាស គ្រឹះស្ថាន និងរាជរដ្ឋាភិបាល ប្រចាំឆមាស
- សហការជាមួយអ្នកជំនាញជាតិ និងអន្តរជាតិ ដើម្បីកំណត់ជាម៉ូឌែលសេដ្ឋកិច្ច និងទីផ្សារការងារសម្រាប់ប៉ាន់ស្មាន និងព្យាករតម្រូវការ និងការផ្គត់ផ្គង់ជំនាញ និងកម្លាំងពលកម្ម ព្រមទាំងរៀបចំសន្និសីទថ្នាក់ជាតិស្តីពីគោលនយោបាយទីផ្សារការងារ
- ជំរុញការផលិតឯកសារអត្ថបទសិក្សាស្រាវជ្រាវ និងការពង្រីកបណ្តាញនៃការសិក្សាស្រាវជ្រាវតាមរយៈការចុះអនុស្សរណៈយោគយល់គ្នាជាមួយសាកលវិទ្យាល័យ ឬស្ថាប័នស្រាវជ្រាវ
- ស្រាវជ្រាវ វាយតម្លៃ និងផ្សព្វផ្សាយអំពីឥទ្ធិពលនៃការប្រែក្លាយសកម្មភាពធុរកិច្ចនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលកើតមានចំពោះការបង្កើតការងារ ប្រាក់ចំណូល និងផលិតភាព

### ៣.១.២. ការពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាស្វែងរកការងារ និងវេទិកាការងារ

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.១.២.ក. ចំនួនព័ត៌មានឱកាសការងារ (Job Vacancy) ត្រូវបានប្រមូលកាន់តែគ្រប់ជ្រុងជ្រោយ និងផ្សព្វផ្សាយកាន់តែទូលំទូលាយ

៣.១.២.ខ. ចំនួនអ្នកចុះឈ្មោះស្វែងរកការងារធ្វើ រួមទាំងសិស្ស និស្សិត និងអ្នកមានជំនាញខ្ពស់ កើនឡើង

៣.១.២.គ. ចំនួនគ្រឹះស្ថានសិក្សា រួមទាំងទិន្នន័យសិស្ស និស្សិតនៃគ្រឹះស្ថាននីមួយៗ ត្រូវបានចងក្រង និងផ្លាស់ប្តូរព័ត៌មានក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកស្វែងរកការងារធ្វើ កើនឡើង

៣.១.២.ឃ. អត្រាអ្នកទទួលបានការងារធ្វើតាមរយៈសេវាការងារសាធារណៈ កើនឡើង

៣.១.២.ង. ចំនួនអ្នកប្រើប្រាស់សេវាការងារសាធារណៈ តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.១.២.១ លើកកម្ពស់យន្តការផ្សព្វផ្សាយឱ្យមានគុណភាព និងប្រសិទ្ធភាព និងជំរុញការប្រើប្រាស់សេវាការងារ និងព័ត៌មានទីផ្សារការងារឱ្យកាន់តែទូលំទូលាយ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនមាតិកាស្តីពីសេវាការងារ និងព័ត៌មានទីផ្សារការងារ ត្រូវបានរៀបចំ ផលិត និងផ្សព្វផ្សាយតាមគ្រប់មធ្យោបាយ និងបណ្តាញផ្សព្វផ្សាយ កើនឡើង
- ចំនួនអ្នកដាក់ពាក្យស្នើសុំការងារ តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន សម្រាប់ផ្តល់សេវាការងារសាធារណៈ កើនឡើងដល់ចំនួន ១៥ ០០០នាក់/ឆ្នាំ នៅត្រឹមឆ្នាំ ២០២៨
- អត្រានៃការស្គាល់សេវាការងារសាធារណៈក្នុងចំណោមយុវជន និងកម្មករនិយោជិត កើនឡើងដល់ ៨០% នៅត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ជំរុញការអភិវឌ្ឍ និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធផ្តល់សេវាការងារសាធារណៈតាមថ្នាលឌីជីថល ជាពិសេស គេហទំព័រការងារ និងកម្មវិធីការងារលើទូរស័ព្ទដៃវៃឆ្លាត
- រៀបចំ និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រផ្សព្វផ្សាយ ស្តីពីសេវាការងារ និងព័ត៌មានទីផ្សារការងារ ដើម្បីបង្កើនប្រសិទ្ធភាពឆ្លើយតបទាន់ពេលវេលា និងជំរុញការទាញយកកម្មវិធីការងារលើទូរស័ព្ទដៃវៃឆ្លាត តាមរយៈការផលិត ពង្រីកមាតិកា និងផ្សព្វផ្សាយកម្មវិធីនាទីទីផ្សារការងារនិងមុខរបរ,ស្ពតសំឡេង, និងវីដេអូ ព្រមទាំងសម្ភារៈផ្សព្វផ្សាយនៅលើបណ្តាញសង្គម ថែមទាំងជំរុញឱ្យមានជាចលនាចូលរួមរបស់យុវជន អ្នកមានប្រជាប្រិយភាព និងដៃគូពាក់ព័ន្ធ
- ថែទាំ និងការពារសុវត្ថិភាពប្រព័ន្ធបណ្តាញកុំព្យូទ័រផ្នែករឹង និងសុវត្ថិភាពទិន្នន័យជាប្រចាំ
- សិក្សាលទ្ធភាពក្នុងការដាក់ឱ្យដំណើរការបញ្ជរសេវាការងារ នៅតាមផ្សារទំនើបធំៗ គ្រឹះស្ថានសិក្សា សាលាស្រុក ឬទីប្រជុំជន និងការិយាល័យអាជីពនិងការងារ នៅតាមបណ្តាស្នាក់ការសហភាពសហព័ន្ធយុវជនកម្ពុជា រាជធានី ខេត្ត និងតាមបណ្តាគ្រឹះស្ថានសិក្សា
- ធ្វើអង្កេតស្តីពី កម្រិតពេញចិត្ត និងការស្គាល់សេវាការងារសាធារណៈ ក្នុងចំណោមយុវជន និងកម្មករនិយោជិត

៣.១.២.២ ពង្រីកយន្តការវេទិកាការងារទាំងនៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងតាមមូលដ្ឋាន ដោយផ្ទាល់ ឬតាមប្រព័ន្ធអនឡាញ/ឌីជីថល ឬតាមប្រព័ន្ធចម្រុះ ឱ្យបានទូទាំងប្រទេស ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម៖

- ចំនួនការរៀបចំវេទិកាការងារកើនឡើង ៣៥០ដង/ឆ្នាំ នៅត្រឹមឆ្នាំ២០២៨
- ចំនួនពិព័រណ៍ការងារ និងផលិតភាពជាតិ រាជធានី ខេត្ត រៀបចំយ៉ាងតិច ២ដង/ឆ្នាំ
- ចំនួនសិក្ខាសាលាផ្សព្វផ្សាយ និងប្រមូលអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋាន រៀបចំយ៉ាងតិច ៣៥ដង/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម៖

- បង្កើនការរៀបចំវេទិកាការងារស្តីពីឱកាសការងារ និងឱកាសកម្មសិក្សាការងារ និងការរៀបចំកិច្ចសម្ភាសន៍
- បង្កើនការរៀបចំពិព័រណ៍ចល័ត តាមរយៈយន្តការមជ្ឈមណ្ឌលការងារមានស្រាប់ និងមជ្ឈមណ្ឌលការងារចល័ត និងតាមមូលដ្ឋាន
- ពង្រីកសក្តានុពលនៃការរៀបចំពិព័រណ៍ការងារ និងផលិតភាពជាតិ រាជធានី ខេត្ត ឱ្យកាន់តែធំទូលំទូលាយ និងតាមថ្នាលឌីជីថល
- ពង្រឹងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រមូលអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋាន
- បង្កើនការចូលរួម និងតាំងបង្ហាញសេវាការងារសាធារណៈនៅតាមកម្មវិធីនានា

៣.១.២.៣ ពង្រីកការប្រមូល និងផ្សព្វផ្សាយព័ត៌មានឱកាសការងារ ឱកាសវគ្គអប់រំបណ្តុះបណ្តាល ឱកាសកម្មសិក្សាការងារ និងឱកាសទទួលបានអាហារូបករណ៍ពីគ្រប់ប្រភព ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម៖

- ចំនួនព័ត៌មានឱកាសការងារ ដែលមានសុពលភាព ត្រូវបានប្រមូល និងផ្សព្វផ្សាយ យ៉ាងតិច ៣០ ០០០កន្លែង រៀងរាល់ថ្ងៃ
- ចំនួននិយោជកដែលចុះឈ្មោះប្រើប្រាស់សេវាការងារសាធារណៈ កើនឡើងយ៉ាងតិច ៤០០នាក់/ឆ្នាំ
- ចំនួនសកម្មភាពចុះជួបផ្ទាល់ជាមួយនិយោជកតាមសហគ្រាស គ្រឹះស្ថាន យ៉ាងតិច ៨០០ដង/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម៖

- បង្កើនសកម្មភាពចុះជួបផ្ទាល់ជាមួយនិយោជកថ្មី និងពង្រឹងកិច្ចសហការជាមួយនិយោជកដែលជាដៃគូ ដើម្បីពង្រីកសក្តានុពលនៃការប្រមូល និងផ្សព្វផ្សាយព័ត៌មានឱកាសការងារ
- ពង្រីកសកម្មភាពនៃការចុះប្រមូលព័ត៌មានឱកាសការងារ នៅតាមទីតាំងដែលមានការប្រមូលផ្តុំរោងចក្រ ព័ត៌មានឱកាសការងារពីគេហទំព័រការងារផ្សេងៗ និងជំរុញការប្រមូលព័ត៌មានឱកាសវគ្គអប់រំបណ្តុះបណ្តាល ឱកាសកម្មសិក្សាការងារ និងឱកាសអាហារូបករណ៍ពីគ្រប់ប្រភព
- ជំរុញកិច្ចសហការជាមួយដៃគូ និងសមាគមនិយោជក ដើម្បីជំរុញការផ្សព្វផ្សាយ និងប្រមូលព័ត៌មានឱកាសការងារ ឱកាសកម្មសិក្សាការងារ តាមរយៈការជួបប្រជុំប្រចាំត្រីមាស
- ជំរុញកិច្ចសហការជាមួយទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងការរៀបចំឱ្យមានជាលំហូរនៃការផ្សព្វផ្សាយព័ត៌មានឱកាសការងារ និងពង្រីកការផ្គូផ្គងអ្នកស្វែងរកការងារទៅនឹងឱកាសការងារ
- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីទទួលបានព័ត៌មានអំពីតម្រូវការកម្លាំងពលកម្មតាមដំណាក់កាលវឌ្ឍនភាពនីមួយៗ ពីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (Qualified Investment Projects-QIPs)

៣.១.២.៤ ពង្រឹងគុណភាពនិងប្រសិទ្ធភាព និងពង្រីកវិសាលភាព នៃការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារ តាមរយៈការពង្រឹងមជ្ឈមណ្ឌលការងារដែលមានស្រាប់ មជ្ឈមណ្ឌលការងារចល័ត និងការបង្កើនកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន គ្រឹះស្ថានសិក្សា និងដៃគូពាក់ព័ន្ធនានា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- សេវាការងារ និងព័ត៌មានទីផ្សារការងារ ត្រូវបានគ្របដណ្តប់គ្រប់រាជធានី ខេត្ត តាមរយៈមជ្ឈមណ្ឌលការងារដែលមានស្រាប់ និងមជ្ឈមណ្ឌលការងារចល័តកើនឡើង
- ចំនួនកិច្ចសហការ ឬគម្រោងជាមួយអាជ្ញាធរមូលដ្ឋាន គ្រឹះស្ថានសិក្សា និងដៃគូពាក់ព័ន្ធកើនឡើង
- លទ្ធផលការងារដែលផ្អែកលើសមិទ្ធកម្មរបស់មជ្ឈមណ្ឌលការងារ កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- បង្កើនការចុះឈ្មោះអ្នកស្វែងរកការងារ ការផ្គូផ្គងនិងបញ្ជូនទៅនិយោជក និងការទទួលបានការងារ តាមរយៈមជ្ឈមណ្ឌលការងារដែលមានស្រាប់ និងមជ្ឈមណ្ឌលការងារចល័ត
- ពង្រីកវិសាលភាពសេវាការងារតាមរយៈមជ្ឈមណ្ឌលការងារចល័ត នៅតាមគ្រឹះស្ថានសិក្សា និងតាមមូលដ្ឋាន/ទីប្រជុំជន ដែលមានតម្រូវការការងារ យ៉ាងតិច ៦០ដង/ខែ



ញ

- បង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ និងផ្នែកឯកជន ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ បច្ចេកទេស និងការគាំទ្រផ្សេងទៀតដើម្បីពង្រីកលទ្ធភាពក្នុងការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារ
- បង្កើនកិច្ចសហការជាមួយគ្រឹះស្ថានសិក្សា អាជ្ញាធរមូលដ្ឋាន និងដៃគូពាក់ព័ន្ធនានា ដើម្បីជំរុញការចុះឈ្មោះ និងពង្រីកសក្តានុពលនៃការផ្តល់សេវាការងារសាធារណៈ
- ពង្រឹងគុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវា និងលទ្ធផលការងារ ដែលផ្អែកលើសមិទ្ធកម្ម

៣.១.២.៥ ជំរុញការអនុវត្តកម្មវិធីទីផ្សារការងារសម្រាប់អ្នកស្វែងរកការងារ ជាស្ត្រី អ្នកដែលមានពិការភាព ជនជាតិភាគតិច និងជនងាយរងគ្រោះផ្សេងទៀត ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គ្រប់សហគ្រាស គ្រឹះស្ថាន ដែលបម្រើឱ្យការនាំចេញ មានហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ជនមានពិការភាព មុនដំណាច់ឆ្នាំ២០២៦
- ជនមានពិការភាពយ៉ាងតិច ១% ត្រូវបានទទួលឱ្យធ្វើការក្នុងវិស័យឯកជន
- កម្មវិធីលើកទឹកចិត្តដល់សហគ្រាស គ្រឹះស្ថាន ដែលទទួលអ្នកស្វែងរកការងារ ជាស្ត្រី អ្នកដែលមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងទៀតឱ្យធ្វើការងារត្រូវបានរៀបចំ និងអនុវត្ត

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងអនុវត្តយន្តការ ដើម្បីឱ្យមានការរៀបចំ និងកែសម្រួលហេដ្ឋារចនាសម្ព័ន្ធគាំទ្រសម្រាប់ជនមានពិការភាព នៅគ្រប់រោងចក្រសហគ្រាស គ្រឹះស្ថាននាំចេញ
- ពង្រឹងកិច្ចសហការជាមួយដៃគូពាក់ព័ន្ធ ដើម្បីទទួលបានឱកាសកម្មសិក្សាការងារ និងឱកាសការងារ សម្រាប់អ្នកស្វែងរកការងារ ជាស្ត្រី អ្នកដែលមានពិការភាព ជនជាតិភាគតិច និងជនងាយរងគ្រោះផ្សេងទៀត
- ផ្តល់ការប្រឹក្សាយោបល់ និងណែនាំអំពីកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- រៀបចំទស្សនកិច្ចសិក្សាសម្រាប់អ្នកស្វែងរកការងារ ជាស្ត្រី អ្នកដែលមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងទៀត ទៅកាន់ក្រុមហ៊ុនសក្តានុពល
- ផ្តល់មធ្យោបាយធ្វើដំណើរ ដល់អ្នកស្វែងរកការងារដែលមានពិការភាព ជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងទៀត សម្រាប់ទៅបំពេញកម្មសិក្សាការងារ

### ៣.១.៣. ការពង្រឹង និងពង្រីកសេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.១.៣.ក. សៀវភៅណែនាំ និងសៀវភៅកម្រងសំណួរសម្រាប់ផែនការអាជីពនិងការសិក្សា ត្រូវបានផលិត ប្រើប្រាស់ និងបច្ចុប្បន្នភាពជាប្រចាំ ព្រមទាំងដាក់ឱ្យប្រើប្រាស់តាមបែបឌីជីថល

៣.១.៣.ខ. សៀវភៅណែនាំអំពីជណ្តើរអាជីព សម្រាប់សេវាប្រឹក្សាយោបល់មគ្គុទេសក៍អាជីពការងារ និងវិជ្ជាជីវៈ ត្រូវបានផលិត និងផ្សព្វផ្សាយ

៣.១.៣.គ. ចំនួនអ្នកប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ កើនឡើង

៣.១.៣.ឃ. ចំនួនជនបង្គោលផ្នែកអាជីព នៅតាមគ្រឹះស្ថានសិក្សា កើនឡើង

៣.១.៣.ង. ចំនួនអ្នកទទួលបានសេវាប្រឹក្សាយោបល់អាជីព ការងារ និងវិជ្ជាជីវៈ កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.១.៣.១ រៀបចំសៀវភៅណែនាំ និងសៀវភៅកម្រងសំណួរសម្រាប់ផែនការអាជីពនិងការសិក្សា និងកម្មវិធីសម្រាប់អភិវឌ្ឍន៍សមត្ថភាព និងបណ្តុះបណ្តាលជនបង្គោលផ្នែកណែនាំអាជីព និងអ្នកប្រឹក្សាយោបល់និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- សៀវភៅណែនាំ និងសៀវភៅកម្រងសំណួរសម្រាប់ផែនការអាជីព និងការសិក្សា សម្រាប់អ្នកប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ ត្រូវបានរៀបចំ និងបច្ចុប្បន្នភាព
- សៀវភៅណែនាំ និងសៀវភៅកម្រងសំណួរសម្រាប់ផែនការអាជីព និងការសិក្សា និងកម្មវិធីសម្រាប់បណ្តុះបណ្តាលជនបង្គោលផ្នែកណែនាំអាជីព ត្រូវបានរៀបចំ និងបច្ចុប្បន្នភាព
- អ្នកប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ និងជនបង្គោលផ្នែកអាជីព ត្រូវបានបណ្តុះបណ្តាល

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- សិក្សារៀបចំ ប្រមូលចងក្រង និងដាក់ឱ្យប្រើប្រាស់ សៀវភៅណែនាំ និងសៀវភៅកម្រងសំណួរសម្រាប់ផែនការអាជីព និងការសិក្សា សម្រាប់អភិវឌ្ឍន៍សមត្ថភាពជនបង្គោលផ្នែកអាជីព អ្នកប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ
- រៀបចំកម្មវិធីបណ្តុះបណ្តាល សម្រាប់ពង្រឹងសមត្ថភាពជនបង្គោលផ្នែកអាជីព និងអ្នកប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ នៅតាមគ្រឹះស្ថានសិក្សា សហគ្រាស គ្រឹះស្ថាន និងស្ថាប័នពាក់ព័ន្ធនានា

- រៀបចំយន្តការជ្រើសរើសបណ្តុះបណ្តាល បន្តអភិវឌ្ឍសមត្ថភាព និងលើកទឹកចិត្តជនបង្គោលផ្នែកអាជីព
- ជ្រើសរើស និងបណ្តុះបណ្តាលអ្នកប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ
- ជំរុញ និងលើកទឹកចិត្តគ្រឹះស្ថានសិក្សា ឱ្យមានជនបង្គោលផ្នែកអាជីព

៣.១.៣.២ ស្រាវជ្រាវ រៀបចំ ចងក្រង និងបច្ចុប្បន្នកម្ម កម្រងឯកសារព័ត៌មានអំពីអាជីព ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ឯកសារពិពណ៌នាអំពីតួនាទី គុណវុឌ្ឍិ ស្ថានភាពតម្រូវការក្នុងទីផ្សារការងារ និងកម្រិតប្រាក់ឈ្នួលតាមប្រភេទមុខរបរ ត្រូវបានស្រាវជ្រាវ ផលិតផ្សព្វផ្សាយ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ
- ចំនួនវិស័យដែលត្រូវបានចងក្រង រៀបចំ និងផ្សព្វផ្សាយនៅក្នុងសៀវភៅណែនាំអំពីជណ្តើរអាជីព ១វិស័យ/ឆ្នាំ
- ឯកសារតម្រូវការមុខរបរខ្ពស់ជាងគេចំនួន ២០ ត្រូវបានសិក្សា ផលិត និងផ្សព្វផ្សាយ ប្រចាំឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- សិក្សារៀបចំ ចងក្រង ផលិតឯកសារការពិពណ៌នាអំពីតួនាទី គុណវុឌ្ឍិ ស្ថានភាពតម្រូវការក្នុងទីផ្សារការងារ និងកម្រិតប្រាក់ឈ្នួល តាមប្រភេទមុខរបរ
- ប្រមូលចងក្រង ផលិត និងផ្សព្វផ្សាយ សៀវភៅណែនាំអំពីជណ្តើរអាជីព
- សិក្សា ផលិត និងផ្សព្វផ្សាយឯកសារតម្រូវការមុខរបរខ្ពស់ជាងគេ ២០ ប្រចាំឆ្នាំ
- សិក្សាការផលិតជាវីដេអូបង្ហាញអំពីសកម្មភាពការងារជាក់ស្តែងតាមប្រភេទមុខរបរ
- បន្តពង្រីកវិសាលភាពសេវាបណ្ណាល័យការងារនៅតាមមជ្ឈមណ្ឌលការងារ ដើម្បីធ្វើការតាំងបង្ហាញអំពីប្រភេទការងារ និងឯកសារ ដែលបម្រើដល់ការស្វែងយល់អំពីអាជីព និងមុខរបរឱ្យបានទូលំទូលាយ

៣.១.៣.៣ ពង្រីកការផ្តល់សេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ តម្រង់ទិសមុនចូលទីផ្សារការងារ ដល់សិស្ស និស្សិត អ្នកស្វែងរកការងារ និងកម្មករនិយោជិត ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនអ្នកស្វែងរកការងារធ្វើទទួលសេវាប្រឹក្សាយោបល់អំពីអាជីព ការងារ និងវិជ្ជាជីវៈ កើនឡើងដល់ ៣០ ០០០នាក់/ឆ្នាំ នៅត្រឹមឆ្នាំ២០២៨
- ចំនួនសិស្សមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ចូលរួមសិក្ខាសាលាស្តីពីផែនការអាជីព និងជ្រើសរើសជំនាញ កើនឡើងដល់ ១៧ ៥០០នាក់/ឆ្នាំ នៅត្រឹមឆ្នាំ២០២៦

- ចំនួនសិក្ខាសាលាស្តីពីការណែនាំអំពីអាជីព និងវគ្គបណ្តុះបណ្តាលស្តីពីការត្រៀមលក្ខណសម្បត្តិក្នុងការស្វែងរកការងារ កើនឡើងដល់ ៦០ដង/ឆ្នាំ នៅត្រឹមឆ្នាំ២០២៧

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ពង្រីកការផ្តល់សេវាប្រឹក្សាយោបល់អំពីអាជីព ការងារ និងវិជ្ជាជីវៈដល់អ្នកស្វែងរកការងារធ្វើ ជាពិសេសអ្នកដែលស្វែងរកការងារលើកដំបូង
- រៀបចំសិក្ខាសាលាស្តីពីផែនការអាជីព និងជ្រើសរើសជំនាញសិក្សា សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំសិក្ខាសាលាស្តីពីការណែនាំអាជីព ការងារ និងវិជ្ជាជីវៈ សម្រាប់សិស្ស និស្សិតនៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសាកលវិទ្យាល័យ
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការត្រៀមលក្ខណសម្បត្តិក្នុងការស្វែងរកការងារ
- ពង្រីកការផ្តល់សេវាប្រឹក្សាយោបល់អំពីអាជីព ការងារ និងវិជ្ជាជីវៈ តាមរយៈការិយាល័យអាជីព និងការងាររបស់ភាគីពាក់ព័ន្ធ

៣.១.៣.៤ អភិវឌ្ឍប្រព័ន្ធឌីជីថលក្នុងការផ្តល់ប្រឹក្សាយោបល់ មគ្គទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- រាល់ឯកសារប្រឹក្សាយោបល់ មគ្គទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ ត្រូវបានប្រមូល ចងក្រង ផលិត និងដាក់ឱ្យប្រើប្រាស់តាមបែបឌីជីថល
- ប្រព័ន្ធផ្តល់សេវាប្រឹក្សាយោបល់ មគ្គទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ ត្រូវបានដាក់ឱ្យដំណើរការតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល
- អត្រាអ្នកប្រើប្រាស់សេវាប្រឹក្សាយោបល់តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលកើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ធ្វើឌីជីថលនីយកម្មរាល់ឯកសារប្រឹក្សាយោបល់ មគ្គទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ
- អភិវឌ្ឍ និងដាក់ឱ្យដំណើរការប្រព័ន្ធផ្តល់ប្រឹក្សាយោបល់ មគ្គទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល
- ផ្សព្វផ្សាយ និងណែនាំពីរបៀបប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ក្នុងការផ្តល់ប្រឹក្សាយោបល់ មគ្គទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ
- ធ្វើការគ្រប់គ្រង និងរក្សាទុករាល់លទ្ធផលនៃការផ្តល់ប្រឹក្សាយោបល់ មគ្គទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ



ហ

- តាមដាន វាយតម្លៃ និងកែលម្អ ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងការផ្តល់ប្រឹក្សាយោបល់មគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ ទៅតាមកម្រិតពេញចិត្តរបស់អ្នកប្រើប្រាស់សេវា

៣.១.៣.៥ ពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន គ្រឹះស្ថានសិក្សា និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីពង្រឹងគុណភាពការផ្តល់សេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនគ្រឹះស្ថានសិក្សាដែលបានពង្រីកកិច្ចសហប្រតិបត្តិការកើនឡើង
- ចំនួនកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីពង្រឹងគុណភាពផ្តល់ និងទទួលសេវាប្រឹក្សាយោបល់កើនឡើង
- ចំនួនសហគ្រាស គ្រឹះស្ថាន ដែលទទួលបានសេវាប្រឹក្សាយោបល់លើផែនការជ្រើសរើសកម្លាំងពលកម្មកើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ពង្រឹងទំនាក់ទំនងជាមួយវិស័យឯកជន ដើម្បីទទួលព័ត៌មានពីផែនការជ្រើសរើសកម្លាំងពលកម្មជាទៀងទាត់ តាមប្រភេទជំនាញ និងមុខរបរ
- ផ្តល់ការប្រឹក្សាយោបល់អំពីវិធីសាស្ត្រជ្រើសរើសកម្លាំងពលកម្ម ដល់វិស័យឯកជន
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សា ក្នុងការរៀបចំជ្រើសរើសឱ្យមានជនបង្គោលអាជីព ក្នុងការផ្តល់សេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីកៀរគរធនធានហិរញ្ញវត្ថុ និងការគាំទ្រផ្នែកបច្ចេកទេស
- តាមដាន វាយតម្លៃ និងកែលម្អសេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ ទៅតាមកម្រិតពេញចិត្តរបស់វិស័យឯកជន គ្រឹះស្ថានសិក្សា និងដៃគូអភិវឌ្ឍន៍

### ៣.១.៤.ការពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេសតាមរយៈបច្ចេកវិទ្យាឌីជីថល

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.១.៤.ក. សង្គតិភាពនៃប្រព័ន្ធទិន្នន័យសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត ត្រូវបានធានា និងធ្វើបច្ចុប្បន្នភាពជាមួយប្រព័ន្ធទិន្នន័យអធិការកិច្ចការងារ និងប្រព័ន្ធទិន្នន័យបេឡាជាតិសន្តិសុខសង្គម

៣.១.៤.ខ. គ្រប់កម្មករនិយោជិតមានសៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ ដើម្បីជាមូលដ្ឋានទទួលបានអត្ថប្រយោជន៍ផ្សេងៗ ដែលមានចែងក្នុងច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីរបបសន្តិសុខសង្គម

៣.១.៤.គ. ចំណាត់ថ្នាក់ស្តង់ដាវិស័យសេដ្ឋកិច្ចកម្ពុជា និងចំណាត់ថ្នាក់ស្តង់ដាមុខរបរ ដែលស្របតាមចំណាត់ថ្នាក់ស្តង់ដាអន្តរជាតិសកម្មភាពសេដ្ឋកិច្ច (International Standard Industrial Classification of All Economic Activities-ISIC) និងស្តង់ដាអន្តរជាតិមុខរបរ (International Standard Classification Of Occupations-ISCO) របស់អង្គការអន្តរជាតិខាងការងារ (International Labour Organization-ILO) ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ធ្វើកំណត់ត្រាស្ថិតិការងារ, មុខរបរ និងមុខជំនាញ ស្របតាមការកំណត់របស់វិទ្យាស្ថានជាតិស្ថិតិ

៣.១.៤.ឃ. ចំនួនទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក ដែលបានចុះបញ្ជីនៅក្រសួងកើនឡើង

៣.១.៤.ង. ផ្ទាំងតាមដានតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ស្តីពីស្ថិតិការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានផ្សព្វផ្សាយដល់គ្រប់ផ្នែកពាក់ព័ន្ធ

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពចំនួន ៥ ដូចខាងក្រោម÷

៣.១.៤.១. បន្តពង្រឹងការចុះបញ្ជីតាមប្រព័ន្ធ និងយន្តការនៃការកសាង គ្រប់គ្រងមូលដ្ឋានទិន្នន័យស្ថិតិសហគ្រាស គ្រឹះស្ថាន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ទិន្នន័យ និងព័ត៌មានរបស់សហគ្រាស គ្រឹះស្ថាន ត្រូវបានធ្វើបច្ចុប្បន្នភាព ២ដង/ឆ្នាំ
- របាយការណ៍ផ្ទៀងផ្ទាត់ស្ថិតិសហគ្រាស គ្រឹះស្ថាន ជាមួយស្ថាប័នដទៃទៀត ត្រូវបានរៀបចំតាមចំណាត់ថ្នាក់ស្តង់ដាវិស័យសេដ្ឋកិច្ចកម្ពុជា និងចំណាត់ថ្នាក់ស្តង់ដាមុខរបរ ដែលស្របតាមចំណាត់ថ្នាក់ស្តង់ដារបស់អង្គការអន្តរជាតិខាងការងារ (ILO)
- កម្រិតពេញចិត្តរបស់អ្នកប្រើប្រាស់សេវា ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធនឹងវិស័យការងារ (Labour Centralized Management System-LACMS) កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ការពង្រឹងការអនុវត្តច្បាប់ស្តីពីការងាររបស់សហគ្រាស គ្រឹះស្ថាន តាមរយៈយន្តការអធិការកិច្ចការងារ និងការផ្លាស់ប្តូរទិន្នន័យអន្តរស្ថាប័នជាទៀងទាត់

- ជំរុញការចុះឈ្មោះក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមិនទាន់មានឈ្មោះក្នុងប្រព័ន្ធ
- ធ្វើបច្ចុប្បន្នភាពព័ត៌មានអត្តសញ្ញាណ សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតដែលមាននៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) តាមចំណាត់ថ្នាក់ស្តង់ដាវិស័យសេដ្ឋកិច្ចកម្ពុជា និងចំណាត់ថ្នាក់ស្តង់ដាមុខរបរ ដែលស្របតាមចំណាត់ថ្នាក់ស្តង់ដារបស់អង្គការអន្តរជាតិខាងការងារ (ILO)
- សិក្សាលទ្ធភាពក្នុងការពិនិត្យ និងកែសម្រួលនីតិវិធីនៃការចុះបញ្ជីឱ្យកាន់តែមានភាពងាយស្រួល និងចំណាយពេលវេលាតិច ជាពិសេសដល់សហគ្រាស គ្រឹះស្ថាន មីក្រូ តូច និងមធ្យម
- បន្តធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ឱ្យមានភាពទាក់ទាញ និងងាយស្រួលដល់អ្នកប្រើប្រាស់សេវា

៣.១.៤.២ ពង្រឹងការផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ព្រមទាំងលើកកម្ពស់ការគ្រប់គ្រងលើចលនាបុគ្គលិក ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនកម្មករនិយោជិតខ្មែរដែលប្រើប្រាស់សៀវភៅការងារតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលកើនឡើង
- ១០០% នៃករណីស្នើសុំសៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ត្រូវបានអនុម័តមិនឱ្យលើសរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការ
- សហគ្រាស គ្រឹះស្ថាន ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ត្រូវបានធ្វើស្វ័យប្រកាសសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ប្រចាំត្រីមាស

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ចងក្រង ផលិត និងផ្សព្វផ្សាយនីតិវិធី និងឯកសារតម្រូវ ក្នុងការស្នើសុំសៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ និងចលនាបុគ្គលិក ឱ្យបានទូលំទូលាយ
- លើកកម្ពស់ការយល់ដឹងអំពីសារប្រយោជន៍ និងភាពចាំបាច់នៃការប្រើប្រាស់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលឱ្យបានទូលំទូលាយ
- សិក្សាលទ្ធភាពក្នុងការពិនិត្យ និងកែសម្រួលនីតិវិធីនៃការផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ និងការស្នើសុំចុះបញ្ជិកាសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកឱ្យកាន់តែមានភាពងាយស្រួល និងចំណាយពេលវេលាតិច

- ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកប្រព័ន្ធស្វ័យប្រវត្តិកម្មជាប្រចាំ
- បណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ដល់ម្ចាស់ ឬនាយក ឬតំណាងសហគ្រាស គ្រឹះស្ថាន

៣.១.៤.៣ ពង្រឹង និងពង្រីកការគ្រប់គ្រងទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក ត្រូវបានធ្វើបច្ចុប្បន្នភាព
- ចំនួនចុះបញ្ជីទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក កើនឡើង
- បញ្ជីឈ្មោះទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក ត្រូវបានធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក
- ចងក្រង ផលិត ផ្សព្វផ្សាយ និងជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ជំរុញការផ្លាស់ប្តូរទិន្នន័យរវាងសេវាស្វែងរកការងារឱ្យធ្វើឯកជន និងសាធារណៈ ដើម្បីពង្រឹងប្រសិទ្ធភាពនៃលំហូរព័ត៌មាននៅក្នុងទីផ្សារការងារ
- ជំរុញការចុះបញ្ជី និងត្រួតពិនិត្យទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក ឱ្យស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- បង្កើតយន្តការសហការជាមួយនឹងអង្គភាពផ្តល់សេវាការងារសាធារណៈ ពាក់ព័ន្ធនឹងអ្នកស្វែងរកការងារធ្វើ

៣.១.៤.៤ ជំរុញការផ្សព្វផ្សាយព័ត៌មានឱកាសការងារ សម្រាប់កម្មករនិយោជិតខ្មែរមុននឹងស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស ចាប់ពីឆ្នាំ២០២៦ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ប្រកាស ដើម្បីតម្រូវឱ្យសហគ្រាស គ្រឹះស្ថាន ធ្វើការផ្សព្វផ្សាយជាសាធារណៈ អំពីព័ត៌មានឱកាសការងារសម្រាប់កម្មករនិយោជិតខ្មែរ មុននឹងស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស ស្របតាមច្បាប់ស្តីពីការងារ ត្រូវបានរៀបចំ
- ចំនួនឯកសារបញ្ជាក់ភាពលំបាកអំពីការជ្រើសរើសកម្មករនិយោជិតខ្មែរ ត្រូវបានផ្តល់ទាន់ពេលវេលា

- ១០០% នៃករណីស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស ត្រូវមានឯកសារបញ្ជាក់ភាពលំបាកអំពីការជ្រើសរើសកម្មករនិយោជិតខ្មែរ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំប្រកាស ដើម្បីតម្រូវឱ្យសហគ្រាស គ្រឹះស្ថាន ធ្វើការផ្សព្វផ្សាយជាសាធារណៈ អំពីព័ត៌មានឱកាសការងារសម្រាប់កម្មករនិយោជិតខ្មែរ មុននឹងស្នើសុំការប្រើប្រាស់ហត្ថពលកម្មបរទេសស្របតាមច្បាប់ស្តីពីការងារ
- រៀបចំនីតិវិធីនៃការជ្រើសរើសកម្លាំងពលកម្មកម្មករនិយោជិតខ្មែរជាមុន មុនពេលប្រើប្រាស់ហត្ថពលកម្មបរទេសនៅតាមសហគ្រាស គ្រឹះស្ថាន ឱ្យបានទូលំទូលាយ
- ជំរុញការផ្សព្វផ្សាយព័ត៌មានឱកាសការងារសម្រាប់កម្មករនិយោជិតខ្មែរជាមុន តាមរយៈអង្គភាពផ្តល់សេវាការងារសាធារណៈ មុនពេលប្រើប្រាស់ហត្ថពលកម្មបរទេសនៅតាមសហគ្រាស គ្រឹះស្ថាន
- រៀបចំនីតិវិធី និងពង្រឹងការចេញឯកសារបញ្ជាក់ភាពលំបាកអំពីការជ្រើសរើសកម្មករនិយោជិតខ្មែរ
- រៀបចំរបាយការណ៍ស្តីពីការចេញឯកសារបញ្ជាក់ភាពលំបាកអំពីការជ្រើសរើសកម្មករនិយោជិតខ្មែរ

៣.១.៤.៥ ធ្វើសមាហរណកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្ម ដែលប្រើប្រាស់ក្នុងសហគ្រាស គ្រឹះស្ថាន ក្នុងប្រទេស (Data Centralization) ដោយឈរលើប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- ប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ទិន្នន័យបេឡាជាតិសន្តិសុខសង្គម ទិន្នន័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងទិន្នន័យអ្នកស្វែងរកការងារធ្វើ ត្រូវបានធ្វើសមាហរណកម្ម និងផ្លាស់ប្តូរទិន្នន័យ
- ផ្ទាំងតាមដានបង្ហាញអំពីការវិវត្តនៃទិន្នន័យកម្លាំងពលកម្ម និងសហគ្រាស គ្រឹះស្ថាន នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ទិន្នន័យបេឡាជាតិសន្តិសុខសង្គម ទិន្នន័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងទិន្នន័យអ្នកស្វែងរកការងារធ្វើ ត្រូវបានបង្កើត និងធ្វើបច្ចុប្បន្នភាពទិន្នន័យភ្លាមៗ
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តការធ្វើសមាហរណកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យ ប្រចាំខែ ត្រូវបានផលិត និងផ្សព្វផ្សាយ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំកិច្ចប្រជុំជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូល និងរៀបចំបង្កើតឱ្យមានយន្តការក្នុងការធ្វើសមាហរណកម្មប្រព័ន្ធ
- ពង្រឹងការអនុវត្តការប្រើប្រាស់ លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ក្នុងសៀវភៅការងារតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលធ្វើជាលេខសម្គាល់របស់កម្មករនិយោជិត និងកំណត់លេខចុះបញ្ជីសហគ្រាស គ្រឹះស្ថានតែមួយ ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសមាហរណកម្មទិន្នន័យក្រោមប្រព័ន្ធរួមតែមួយរបស់ក្រសួង
- បន្តពង្រឹងសុខដុមនីយកម្មនៃការបញ្ចូល និងគ្រប់គ្រងទិន្នន័យ ដោយធ្វើការបន្ស៊ីគ្នានូវព័ត៌មាន និងទិន្នន័យរបស់កម្មករនិយោជិត និងសហគ្រាស គ្រឹះស្ថាន
- ពិនិត្យតាមដាន និងប្រៀបធៀបការវិវត្តនៃទិន្នន័យកម្លាំងពលកម្មរវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ទិន្នន័យបេឡាជាតិសន្តិសុខសង្គម ទិន្នន័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងទិន្នន័យអ្នកស្វែងរកការងារធ្វើ
- ដាក់ចេញនូវសកម្មភាព ឬវិធានការជាក់ស្តែងសំដៅពន្លឿននៃការធ្វើសមាហរណកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS) ទិន្នន័យបេឡាជាតិសន្តិសុខសង្គមទិន្នន័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងទិន្នន័យអ្នកស្វែងរកការងារធ្វើ

### ៣.១.៥. ការពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងកម្មវិធីជំរុញការលើកកម្ពស់ផលិតភាពការងារ

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.១.៥.ក. របាយការណ៍វាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥ ត្រូវបានរៀបចំ និងដាក់ជូនរាជរដ្ឋាភិបាលតាមក្របខណ្ឌពេលវេលា

៣.១.៥.ខ. សេចក្តីព្រាងគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០២៦-២០៣៥ ត្រូវបានរៀបចំ និងអនុម័ត

៣.១.៥.គ. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០២៦-២០៣៥ត្រូវបានអនុវត្ត

៣.១.៥.ឃ. អត្រានៃសហគ្រាស គ្រឹះស្ថាន ដែលមានកម្មវិធីជំរុញ និងលើកកម្ពស់ផលិតភាពការងារ កើនឡើង

៣.១.៥.ង. អត្រានៃការយល់ដឹងអំពីផលិតភាពការងារក្នុងចំណោមយុវជន កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.១.៥.១ ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- សមត្ថភាពសមាជិកគណៈកម្មការអន្តរក្រសួង និងគណៈកម្មការរាជធានី ខេត្ត សម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ត្រូវបានពង្រឹង
- សមត្ថភាពសមាជិកលេខាធិការដ្ឋានសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ត្រូវបានពង្រឹង
- សមត្ថភាពសមាជិកអនុគណៈកម្មការអន្តរក្រសួងសម្រាប់អនុវត្ត គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ត្រូវបានពង្រឹង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពដល់សមាជិក គណៈកម្មការអន្តរក្រសួង និងគណៈកម្មការរាជធានី ខេត្ត សម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តតម្លៃគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ
- រៀបចំវគ្គបណ្តុះបណ្តាលពង្រឹសមត្ថភាពដល់ សមាជិកលេខាធិការដ្ឋានសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ
- រៀបចំវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពស្តីពីការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ដល់សមាជិកលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត
- រៀបចំផែនការសកម្មភាព សម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ
- ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការកៀរគរធនធាន បច្ចេកទេស និងថវិកា ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ

៣.១.៥.២ តាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ក្របខណ្ឌតាមដាន និងវាយតម្លៃត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព

- កិច្ចប្រជុំរបស់លេខាធិការដ្ឋានត្រូវបានរៀបចំប្រចាំខែ ដើម្បីពង្រឹងយន្តការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ
- កិច្ចប្រជុំគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ត្រូវបានរៀបចំឱ្យបានទៀងទាត់

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងដាក់ឱ្យអនុវត្ត ក្របខណ្ឌតាមដាន និងវាយតម្លៃគោលនយោបាយ
- ជំរុញ និងសម្របសម្រួលជាមួយអនុគណៈកម្មការអន្តរក្រសួង ក្នុងការរៀបចំផែនការសកម្មភាព និងរបាយការណ៍ឱ្យបានទៀងទាត់ ព្រមទាំងជំរុញ និងសម្របសម្រួលជាមួយគណៈកម្មការរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ
- ប្រមូល និងចងក្រងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ
- រៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ
- អនុម័ត និងផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពស្តីពីលទ្ធផលនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ

៣.១.៥.៣ រៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០២៦-២០៣៥ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០២៦-២០៣៥ ឱ្យស្របទៅតាមការវិវឌ្ឍយ៉ាងឆាប់រហ័សនៃឧស្សាហកម្ម បច្ចេកវិទ្យា បរិស្ថាន ចីរភាព និងគោលនយោបាយអភិវឌ្ឍន៍វិស័យផ្សេងទៀតរបស់រាជរដ្ឋាភិបាល ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅឆ្នាំ ២០២៦
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ត្រូវបានធ្វើបច្ចុប្បន្នភាព
- យន្តការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារត្រូវបានពង្រឹង

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- អង្កេត សិក្សា និងវាយតម្លៃអំពីតម្រូវការការងារអាទិភាពសម្រាប់យុវជនខ្មែរ ដោយសហការជាមួយបណ្តាញយុវជនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹង សម្រាប់ជាមូលដ្ឋានក្នុងការធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ
- រៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០២៦-២០៣៥
- ធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ
- ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ពង្រឹងយន្តការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ

៣.១.៥.៤ ពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ដើម្បីជំរុញកម្មវិធីលើកកម្ពស់ និងផ្សព្វផ្សាយផលិតភាពការងារ សំដៅបង្កើនចំណេះដឹង និងបង្កើតឡើងនូវផ្នត់គំនិតជាមូលដ្ឋាន ស្តីពីសារៈសំខាន់នៃផលិតភាពការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គោលការណ៍ណែនាំដល់សហគ្រាស គ្រឹះស្ថាន ដើម្បីលើកកម្ពស់ការចូលរួមយុទ្ធនាការផលិតភាពការងារ ត្រូវបានរៀបចំ
- ចំនួនសហគ្រាស គ្រឹះស្ថានដែលទទួលបានពានរង្វាន់ផលិតភាពជាតិប្រចាំឆ្នាំ
- មជ្ឈមណ្ឌលធ្វើតេស្តផលិតភាពការងារ ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការដោយមានការសហការពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំយុទ្ធនាការលើកកម្ពស់ផលិតភាពការងារ តាមរយៈប្រមូលផ្តុំ កៀរគរធនធាន និងប្រើប្រាស់មធ្យោបាយផ្សព្វផ្សាយគ្រប់ទម្រង់ ក្នុងការជំរុញការលើកកម្ពស់អំពីអត្ថប្រយោជន៍នៃផលិតភាពការងារ
- ដាក់ចេញនូវកម្មវិធីប្រកួតប្រជែង សម្រាប់ពានរង្វាន់ផលិតភាពជាតិប្រចាំឆ្នាំ
- សិក្សា រៀបចំគោលការណ៍ណែនាំដល់សហគ្រាស គ្រឹះស្ថាន ដើម្បីលើកកម្ពស់ការចូលរួមយុទ្ធនាការផលិតភាពការងារ

- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការបញ្ជូនកម្មករនិយោជិត តាមវិស័យឱ្យចូលរួមវគ្គបណ្តុះបណ្តាលអំពីជំនាញទន់
- សិក្សាលទ្ធភាពបង្កើតមជ្ឈមណ្ឌលធ្វើតេស្តផលិតភាពការងារ ត្រឹមឆ្នាំ២០២៦

៣.១.៥.៥ ជំរុញការសិក្សាស្រាវជ្រាវ និងនវានុវត្តន៍ ព្រមទាំងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ដើម្បីចូលរួមលើកកម្ពស់ផលិតភាពការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍ស្តីពីផលិតភាពការងារកម្ពុជា
- របាយការណ៍ស្តីពីផលត្រលប់នៃការវិនិយោគ (Return on Investment) នៃកម្មវិធីបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ និងបង្កើនជំនាញ
- ចំនួនវេទិកាជជែកពិភាក្សាស្តីពីផ្នត់គំនិតជាមូលដ្ឋាន នៃសារៈសំខាន់ផលិតភាពការងារ ដោយចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- កសាងសមត្ថភាពអង្គភាពទទួលបន្ទុកសិក្សាស្រាវជ្រាវ និងអង្កេតពាក់ព័ន្ធផលិតភាពការងារ
- សិក្សា អង្កេត ចងក្រងរបាយការណ៍អំពីផលិតភាពការងារកម្ពុជា
- អង្កេត សិក្សា និងរៀបចំរបាយការណ៍អំពីផលត្រលប់នៃការវិនិយោគ (Return on Investment) នៃកម្មវិធីបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ និងការបង្កើនជំនាញ
- ផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងអង្កេតពាក់ព័ន្ធផលិតភាពការងារ
- រៀបចំ និងចូលរួម វេទិកា និងកិច្ចសន្ទនាពាក់ព័ន្ធនឹងផលិតភាពការងារ តាមរយៈវេទិកាអន្តរក្រសួង ដៃគូអភិវឌ្ឍន៍ ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាលជំនាញទន់ក្នុងគោលបំណងចូលរួមបណ្តុះគំនិតផលិតភាពការងារ

ដើម្បីសម្រេចបានជោគជ័យលើការអនុវត្តនូវយុទ្ធសាស្ត្រអាទិភាពខាងលើ, អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវរៀបចំការពិនិត្យតាមដានលទ្ធផលនៃការអនុវត្តការងារជារៀងរាល់ខែ ត្រីមាស ឆមាស ប្រាំបួនខែ ជាពិសេស ការពិនិត្យវាយតម្លៃប្រចាំឆ្នាំ ដើម្បីវាយតម្លៃអំពីសមិទ្ធកម្មការងារសម្រេចបាន បញ្ហាប្រឈមដែលត្រូវកែលម្អ វិធានការអន្តរាគមន៍នានាដែលត្រូវដាក់ចេញសំដៅធានាឱ្យបាននូវការចូលរួមអនុវត្តពីគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ ការទទួលខុសត្រូវ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពជោគជ័យខ្ពស់។ យុទ្ធសាស្ត្រអាទិភាពនេះ ត្រូវបានចាត់ទុកថាជាឯកសាររស់រវើក ដែលសូចនាករកម្រិតយុទ្ធសាស្ត្រ សូចនាករកម្រិតកម្មវិធី ចង្កោមសកម្មភាព សូចនាករចង្កោមសកម្មភាព និងសកម្មភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ អាចនឹងត្រូវកែសម្រួល និងបច្ចុប្បន្នភាពជាយថាហេតុ ដើម្បីឱ្យស្របនឹង

បរិការណ៍ជាក់ស្តែង និងការវិវត្តនៃវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ, វិធានការណ៍ និងស្ថានការណ៍ជាក់ស្តែងនានាដែលរាជរដ្ឋាភិបាល នឹងបន្តដាក់ចេញទៅតាមក្របខណ្ឌពេលវេលា ព្រមទាំងស្របទៅតាមការវិវត្តនៃសង្គម-សេដ្ឋកិច្ច ទាំងនៅក្នុងតំបន់ និងសកលលោក។

## ៣.២-ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង

រាជរដ្ឋាភិបាលក្នុង នីតិកាលទី៧ នៃរដ្ឋសភាតាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដោយបានកំណត់ **ការអភិវឌ្ឍមូលធនមនុស្ស** គឺជាបញ្ចកោណសំខាន់ទី១ ដោយរាជរដ្ឋាភិបាលបានមើលឃើញពីភាពចាំបាច់ និងសារៈសំខាន់នៃការអភិវឌ្ឍមូលធនមនុស្សក្នុងការជំរុញការធ្វើពិពិធកម្ម ពង្រឹងភាពប្រកួតប្រជែង ធ្វើទំនើបកម្មសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ភាពធន់ និងបរិយាបន្ន។ យុទ្ធសាស្ត្របញ្ចកោណ បានបន្តកំណត់យក "មនុស្ស" ជាអាទិភាពគន្លឹះទី១ ហើយ "ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា" គឺជាអាទិភាពបន្តបន្ទាប់តាមលំដាប់។ នៅក្នុងនោះ មុំទី២ "ការបណ្តុះបណ្តាលជំនាញបច្ចេកទេស" នៃបញ្ចកោណទី១ គឺជារបៀបវារៈ និងជាគោលដៅចម្បងបំផុតមួយក្នុងការជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញ ដើម្បីចូលរួមចំណែកសម្រេចឱ្យបាននូវចក្ខុវិស័យរបស់កម្ពុជាក្នុងការប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។ បន្ថែមលើមុំទី២ នៃបញ្ចកោណទី១ខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញ **កម្មវិធីគោលនយោបាយអាទិភាពក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនដែលជាគោលដៅមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ដែលមានចំនួនប្រមាណ ១,៥លាននាក់** ក្នុងកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ដោយមិនបង់ថ្លៃសិក្សា និងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ ដែលបានចាប់ផ្តើមអនុវត្តភ្លាមនៅក្នុងឆ្នាំ២០២៣។

ឈរលើមូលដ្ឋាននេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ ដោយក្នុងនោះបានកំណត់នូវយុទ្ធសាស្ត្រទី២ "ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង" សំដៅផលិតមូលធនមនុស្ស និងអភិវឌ្ឍកម្លាំងពលកម្មឱ្យមានជំនាញ ចំណេះដឹង សមត្ថភាព គុណធម៌ សីលធម៌ ចរិយាមារយាទ មនសិការវិជ្ជាជីវៈ ស្មារតីទទួលខុសត្រូវ សហគ្រិនភាព មានផលិតភាព ការប្រកួតប្រជែងខ្ពស់ មានភាពធន់ បត់បែន អាចឆ្លើយតបតាមតម្រូវការនៃការវិវត្តយ៉ាងឆាប់រហ័សនៃមូលដ្ឋានសេដ្ឋកិច្ច ឧស្សាហកម្ម បច្ចេកវិទ្យាឌីជីថល និងការការពារបាននូវបរិស្ថានប្រកបដោយចីរភាព ស្របតាមការតម្រង់ទិសគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ដោយធានាថា **"ពលរដ្ឋម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"** និងអនុវត្តតាមអភិក្រមរបស់ **សម្តេចធិបតី** គឺសិស្សត្រូវរៀន

**"ឱ្យចប់ ឱ្យចេះ ឱ្យមានការងារ"**។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីរួមគ្នាអភិវឌ្ឍមូលធនមនុស្សឱ្យមានភាពប្រទាក់ក្រឡាគ្នាឆ្លើយតបបានតាមតម្រូវការសេដ្ឋកិច្ច និងសង្គម។

សូចនាករកម្រិតយុទ្ធសាស្ត្រ ត្រូវសម្រេចឱ្យបានក្នុងការអនុវត្តយុទ្ធសាស្ត្រនេះមាន ៥ ដូចខាងក្រោម÷

៣.២.ក. លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យ អ.ប.វ. ត្រូវបានធ្វើបច្ចុប្បន្នភាពឱ្យស្របតាមការវិវត្តសង្គម-សេដ្ឋកិច្ច, ឧស្សាហកម្ម, បច្ចេកវិទ្យា និងតម្រូវការអភិវឌ្ឍវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល

៣.២.ខ. កញ្ចប់ស្តង់ដាបណ្តុះបណ្តាល (ស្តង់ដាសមត្ថភាព, កម្មវិធីសិក្សា, និងកញ្ចប់វាយតម្លៃ) ចំនួន ២៣០/៧៥០គុណវុឌ្ឍិ, កញ្ចប់សិក្សា (ម៉ូឌុលសិក្សា) ចំនួន ១ ៣៥០ម៉ូឌុល ត្រូវបានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់នៅគ្រប់គ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/សមាគម

៣.២.គ. ការគ្រប់គ្រងគ្រឹះស្ថាន និងទិន្នន័យក្នុងវិស័យ អ.ប.វ. (សិក្ខាកាម, សិស្ស, និស្សិត, កញ្ចប់ស្តង់ដាបណ្តុះបណ្តាល, មុខជំនាញ, ឯកសារ និងវីដេអូបង្រៀន, វិញ្ញាបនបត្រ, សញ្ញាបត្រ, ការតាមដាន និងវាយតម្លៃ) ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ. តាមបច្ចេកវិទ្យាឌីជីថល

៣.២.ឃ. ចំនួនសិក្ខាកាម សិស្ស និស្សិត ដែលបានបញ្ចប់ការបណ្តុះបណ្តាលគ្រប់កម្រិតប្រកបដោយគុណភាព និងស្របតាមវិស័យអាទិភាពកើនឡើង និងមានការងារសមរម្យ និងមុខរបរដែលមានចំណូលខ្ពស់ជាងមុនក្រោយពេលបញ្ចប់ការបណ្តុះបណ្តាលរយៈពេល ៣ខែ

៣.២.ង. អត្រានៃការពេញចិត្ត (Satisfaction Rate) របស់និយោជកចំពោះសិក្ខាកាម សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថាន អ.ប.វ. កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករកម្រិតយុទ្ធសាស្ត្រខាងលើនេះ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាពចំនួន ៥ ដូចខាងក្រោម÷

**៣.២.១. ការពង្រឹងប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមបច្ចេកវិទ្យាឌីជីថល**

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.២.១.ក. គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានបន្តធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យអនុវត្ត

៣.២.១.ខ. ច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២៦

៣.២.១.គ. ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ. តាមបច្ចេកវិទ្យាឌីជីថល បានដំណើរការពេញលេញ

៣.២.១.ឃ. អត្រាអនុលោមភាពនៃគ្រឹះស្ថាន អ.ប.វ. សាធារណៈតាមគោលការណ៍ណែនាំ និងលក្ខណវិនិច្ឆ័យគណៈគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ. ពេញលេញចាប់ពីឆ្នាំ២០២៥

៣.២.១.ង. អត្រានីតិវិធីប្រតិបត្តិស្តង់ដា (SOP) នៅតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន និងការិយាល័យ ត្រូវបានរៀបចំធ្វើបច្ចុប្បន្នភាព និងអនុវត្ត

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.២.១.១ ធ្វើបច្ចុប្បន្នភាព និងពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ, ពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា និងគោលនយោបាយ ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ផែនការសកម្មភាព អ.ប.វ. ឆ្លើយតបទៅនឹងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា និងគោលនយោបាយ ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធ ត្រូវបានបន្តរៀបចំ និងអនុវត្ត
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពី ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានរៀបចំជាប្រចាំឆ្នាំ
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផែនការសកម្មភាព អ.ប.វ. ត្រូវបានរៀបចំជាប្រចាំឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករនៃចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- សិក្សាស្រាវជ្រាវគោលនយោបាយ ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យ អ.ប.វ. ទាំងក្នុង និងក្រៅប្រទេស និងបំប៉នសមត្ថភាពមន្ត្រីទទួលបន្ទុក
- រៀបចំបង្កើត និងពង្រឹងគណៈកម្មការអន្តរស្ថាប័ន ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យ អ.ប.វ.
- ពិនិត្យ វាយតម្លៃ និងបន្តធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- បន្តរៀបចំ និងអនុវត្តផែនការសកម្មភាព អ.ប.វ. ឆ្លើយតបទៅនឹងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រ

អភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជា និងគោលនយោបាយ ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធ

- តាមដានការអនុវត្ត និងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព អ.ប.វ.

៣.២.១.២ បន្តរៀបចំ និងអនុវត្តច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គណៈកម្មការរៀបចំច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានធ្វើបច្ចុប្បន្នភាព
- លិខិតបទដ្ឋានគតិយុត្តគាំទ្រក្នុងការអនុវត្តច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានរៀបចំ និងផ្សព្វផ្សាយ
- របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានរៀបចំជាប្រចាំឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករនៃចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ធ្វើបច្ចុប្បន្នភាពគណៈកម្មការរៀបចំច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- បន្តរៀបចំសេចក្តីព្រាង និងស្នើសុំការអនុម័តច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- រៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រការអនុវត្តច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ផ្សព្វផ្សាយ និងជំរុញការអនុវត្តច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៣.២.១.៣ បន្តពង្រឹងប្រសិទ្ធភាពការអនុវត្តប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ. និងរៀបចំប្រព័ន្ធគ្រប់គ្រងសញ្ញាបត្រតាមបច្ចេកវិទ្យាឌីជីថល ដោយភ្ជាប់នឹងថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh របស់រាជរដ្ឋាភិបាល (https://www.verify.gov.kh) ដែលអភិវឌ្ឍដោយក្រសួងប្រៃសណីយ៍

និងទូរគមនាគមន៍ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍សិក្សាវាយតម្លៃគុណភាពទិន្នន័យ និងព័ត៌មានស្តីពី អ.ប.វ. ត្រូវបានរៀបចំ
- ទិន្នន័យសិក្ខាកាម, សិស្ស, និស្សិត, កញ្ចប់ស្តង់ដាបណ្តុះបណ្តាល, មុខជំនាញ, ឯកសារ និងវីដេអូបង្រៀន, និងវិញ្ញាបនបត្រ សញ្ញាបត្រ ត្រូវបានបញ្ចូល និងទាញយកមកប្រើប្រាស់ពីប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ.
- មន្ត្រីទទួលបន្ទុកនៅតាមគ្រឹះស្ថាន អ.ប.វ. ត្រូវបានបំប៉នសមត្ថភាពឱ្យចេះប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ. រៀងរាល់ត្រីមាស

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- សិក្សាវាយតម្លៃគុណភាពទិន្នន័យ និងព័ត៌មានស្តីពី អ.ប.វ., ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ., ធ្វើសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រជាមួយប្រព័ន្ធគ្រប់គ្រងព័ត៌មានទីផ្សារការងារ និងប្រព័ន្ធគ្រប់គ្រងបេឡាជាតិសន្តិសុខសង្គម ព្រមទាំងរៀបចំប្រព័ន្ធគ្រប់គ្រងសញ្ញាបត្រតាមបច្ចេកវិទ្យាឌីជីថល ដោយភ្ជាប់នឹងថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh របស់រាជរដ្ឋាភិបាល (https://www.verify.gov.kh) ដែលអភិវឌ្ឍដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- កៀរគរថវិកាគាំទ្រ និងបំពាក់ឧបករណ៍ សម្ភារ គាំទ្រដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ. នៅអគ្គនាយកដ្ឋាន និងគ្រឹះស្ថាន អ.ប.វ.
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ.
- រៀបចំផលិត និងកែសម្រួលឯកសារ វីដេអូ សម្ភារបង្រៀន និងរៀនតាមបច្ចេកវិទ្យាឌីជីថលបន្ថែមតាមមុខជំនាញអាទិភាព និងដាក់បញ្ចូលទៅក្នុងប្រព័ន្ធជាតិ អ.ប.វ. ពីចម្ងាយ ឬតាមអនឡាញ (National TVET E-Learning Platform)
- គ្រប់គ្រង និងថែទាំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ.

៣.២.១.៤ ធ្វើសាមញ្ញកម្មនីតិវិធីនៃការចុះបញ្ជិកាគ្រឹះស្ថាន អ.ប.វ. ឯកជន និងអង្គការ/សមាគម តាមរយៈការកែសម្រួលគោលការណ៍ និងស្តង់ដា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ប្រកាសស្តីពីការចុះបញ្ជិកាគ្រឹះស្ថាន អ.ប.វ. ត្រូវបានពិនិត្យ និងកែសម្រួល

- ចំនួនគ្រឹះស្ថានសិក្សាដែលផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដែលពុំទាន់បានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផ្សព្វផ្សាយ និងជំរុញលើកទឹកចិត្តឱ្យចុះបញ្ជិកា
- ចំនួនគ្រឹះស្ថាន អ.ប.វ. ឯកជន និងអង្គការ/សមាគម ត្រូវបានចុះបញ្ជិកា កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំកែសម្រួលប្រកាសស្តីពីការចុះបញ្ជិកាគ្រឹះស្ថាន អ.ប.វ. ឱ្យមានភាពសាមញ្ញ និងភាពងាយស្រួល ដើម្បីទាក់ទាញគ្រឹះស្ថាន អ.ប.វ. ឯកជន និងអង្គការ/សមាគម ឱ្យមកចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ផ្សព្វផ្សាយអំពីនីតិវិធីនៃការចុះបញ្ជិកា ដល់គ្រឹះស្ថាន អ.ប.វ. ឯកជន និងអង្គការ/សមាគម ដែលពុំទាន់បានចុះបញ្ជិកា ក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គភាពពាក់ព័ន្ធនានា
- សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញគ្រឹះស្ថាន អ.ប.វ. ឯកជន និងអង្គការ/សមាគម ដែលពុំទាន់បានចុះបញ្ជិកា ក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មកចុះបញ្ជិកា
- ត្រួតពិនិត្យ វាយតម្លៃលើការស្នើសុំចុះបញ្ជិកាគ្រឹះស្ថាន អ.ប.វ. ឯកជន និងអង្គការ/សមាគម
- ផ្តល់ការគាំទ្រដល់គ្រឹះស្ថាន អ.ប.វ. ឯកជន និងអង្គការ/សមាគម ដែលបានចុះបញ្ជិកា ឱ្យដំណើរការស្របតាមគោលការណ៍ណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៣.២.១.៥ ពង្រឹងសមត្ថភាព និងប្រសិទ្ធភាពនៃការអនុវត្តការងារ របស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន នាយកដ្ឋាន គណៈគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ. មន្ត្រីរាជការ និងបុគ្គលិក ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ. រួមទាំងលក្ខណវិនិច្ឆ័យគណៈគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ. ត្រូវបានរៀបចំ និងអនុវត្តចាប់ពីឆ្នាំ២០២៤
- ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង មន្ត្រីរាជការ និងបុគ្គលិកនៃអគ្គនាយកដ្ឋាន នាយកដ្ឋានជំនាញ និងគ្រឹះស្ថាន អ.ប.វ. ត្រូវបានពង្រឹងសមត្ថភាព រៀងរាល់ត្រីមាស
- របាយការណ៍ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ., លក្ខណវិនិច្ឆ័យគណៈគ្រប់គ្រង ដល់គ្រឹះស្ថាន អ.ប.វ. និងនីតិវិធីប្រតិបត្តិស្តង់ដា (SOP) ត្រូវបានរៀបចំជាប្រចាំឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- បន្តរៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ. រួមទាំងលក្ខណវិនិច្ឆ័យគណៈគ្រប់គ្រង ដល់គ្រឹះស្ថាន អ.ប.វ.
- សិក្សាពីតម្រូវការ រៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាលពង្រឹងសមត្ថភាពថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន នាយកដ្ឋាន គណៈគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ. មន្ត្រីរាជការ និងបុគ្គលិក
- បន្តរៀបចំវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពថ្នាក់ដឹកនាំ គណៈគ្រប់គ្រង លើផ្នែកគ្រប់គ្រងភាពជាអ្នកដឹកនាំ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ និងមន្ត្រីរាជការ លើផ្នែកផែនការយុទ្ធសាស្ត្រថវិកា (Budget Strategy Plan-BSP) ផែនការប្រតិបត្តិប្រចាំឆ្នាំ (Annual Operation Plan-AOP) និងផែនការថវិកាតាមកម្មវិធី (Program Budgeting-PB) និងជំនាញឌីជីថល ទាំងក្នុង និងក្រៅប្រទេស
- រៀបចំ កែសម្រួល និងអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដា (SOP) នៅតាមអគ្គនាយកដ្ឋាន នាយកដ្ឋាន និងការិយាល័យ ជាប្រចាំឆ្នាំ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ., លក្ខណវិនិច្ឆ័យគណៈគ្រប់គ្រង ដល់គ្រឹះស្ថាន អ.ប.វ. និងនីតិវិធីប្រតិបត្តិស្តង់ដា (SOP)

**៣.២.២. ការពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយរួមបញ្ចូលនូវជំនាញសម្បទាការងារ, ជំនាញសម្បទាបត់បែន, ជំនាញបច្ចេកវិទ្យាឌីជីថល និងជំនាញបៃតង**

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.២.២.ក. ចំណាត់ថ្នាក់មុខជំនាញខ្ទង់ទី៥ នៃចំណាត់ថ្នាក់ស្តង់ដាមុខរបរកម្ពុជារបស់ក្រសួងផែនការដែលស្របតាមចំណាត់ថ្នាក់ស្តង់ដាមុខរបរអន្តរជាតិ (ISCO) ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តត្រឹមឆ្នាំ២០២៦

៣.២.២.ខ. អត្រានៃគ្រូបច្ចេកទេសត្រូវបានធ្វើវិក្រឹតការផ្នែកគរុកោសល្យ និងជំនាញបច្ចេកទេសស្របតាមការរីកចម្រើននៃបដិវត្តន៍ឧស្សាហកម្ម ៤.០ ជំនាញបច្ចេកវិទ្យាឌីជីថល និងជំនាញបៃតង ត្រូវបានធានាយ៉ាងតិច ៥០ភាគរយ នៃចំនួនគ្រូបច្ចេកទេសសរុប រៀងរាល់ឆ្នាំ

៣.២.២.គ. ចំនួនគ្រឹះស្ថាន អ.ប.វ. សាធារណៈ បានធ្វើឯកទេសកម្មតាមវិស័យ ស្របតាមគោលនយោបាយរាជរដ្ឋាភិបាល និងតម្រូវការនៅក្នុងតំបន់ ឱ្យបានយ៉ាងតិច ៨ ត្រឹមឆ្នាំ២០២៨

៣.២.២.ឃ. ចំនួនគ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/សមាគម ទទួលបានចំណាត់ថ្នាក់នៃការវាយតម្លៃគុណភាព "ល្អប្រសើរ" កើនឡើង

៣.២.២.ង. គ្រប់គ្រឹះស្ថាន អ.ប.វ. សាធារណៈ ទទួលបានវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងស្តង់ដាអន្តរជាតិ ISO 9001:2015 ត្រឹមឆ្នាំ២០២៦, គ្រឹះស្ថាន អ.ប.វ. ឯកជន និងអង្គការ/សមាគម ទទួលបានវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងស្តង់ដាអន្តរជាតិ ISO 9001:2015 យ៉ាងតិច ១០ ត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.២.២.១ ពង្រឹងយន្តការអភិវឌ្ឍ និងអនុវត្តកញ្ចប់ស្តង់ដាបណ្តុះបណ្តាលតាមមុខជំនាញ នៅក្នុងវិស័យអាទិភាព ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ១-៥ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គណៈកម្មការរៀបចំចំណាត់ថ្នាក់មុខជំនាញខ្ទង់ទី៥ នៃចំណាត់ថ្នាក់ស្តង់ដាមុខរបរកម្ពុជារបស់ក្រសួងផែនការ ដែលស្របតាមចំណាត់ថ្នាក់ស្តង់ដាមុខរបរអន្តរជាតិ (ISCO) ត្រូវបានបង្កើត
- គណៈកម្មការអភិវឌ្ឍន៍កញ្ចប់ស្តង់ដាបណ្តុះបណ្តាល និងកញ្ចប់សិក្សាផ្អែកលើសមត្ថភាព ត្រូវបានបង្កើត
- តម្រូវការមុខជំនាញសម្រាប់អភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាល ត្រូវបានកំណត់

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំលិខិតបទដ្ឋានបង្កើតគណៈកម្មការចំណាត់ថ្នាក់មុខជំនាញខ្ទង់ទី ៥ នៃចំណាត់ថ្នាក់ស្តង់ដាមុខរបរកម្ពុជារបស់ក្រសួងផែនការ ដែលស្របតាមចំណាត់ថ្នាក់ស្តង់ដាមុខរបរអន្តរជាតិ (ISCO) និងគណៈកម្មការអភិវឌ្ឍន៍កញ្ចប់ស្តង់ដាបណ្តុះបណ្តាល និងកញ្ចប់សិក្សាផ្អែកលើសមត្ថភាព
- កៀរគរធនធាន និងដៃគូអភិវឌ្ឍន៍គាំទ្រការរៀបចំចំណាត់ថ្នាក់មុខជំនាញខ្ទង់ទី៥ និងការអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាល និងកញ្ចប់សិក្សាផ្អែកលើសមត្ថភាព
- រៀបចំចំណាត់ថ្នាក់មុខជំនាញខ្ទង់ទី៥ នៃចំណាត់ថ្នាក់ស្តង់ដាមុខរបរកម្ពុជារបស់ក្រសួងផែនការដែលស្របតាមចំណាត់ថ្នាក់ស្តង់ដាមុខរបរអន្តរជាតិ (ISCO)
- រៀបចំកំណត់តម្រូវការមុខជំនាញសម្រាប់អភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាល

- រៀបចំអភិវឌ្ឍ និងដាក់ឱ្យអនុវត្តនូវកញ្ចប់ស្តង់ដាបណ្តុះបណ្តាល និងកញ្ចប់សិក្សាផ្អែកលើសមត្ថភាព នៅតាមគ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/សមាគម

៣.២.២.២ បន្តបង្កើន និងពង្រឹងសមត្ថភាពគ្រូបច្ចេកទេសទៅតាមតម្រូវការជំនាញនៅតាមគ្រឹះស្ថាន អ.ប.វ. ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គ្រូបច្ចេកទេសក្របខណ្ឌថ្មីត្រូវបានជ្រើសរើស ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈចំនួន ១ ៥០០នាក់ ត្រឹមឆ្នាំ២០២៨
- គ្រូកិច្ចសន្យា និងគ្រូជួល ត្រូវបានជ្រើសរើស ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈចំនួន ៨៨០នាក់ ត្រឹមឆ្នាំ២០២៨
- គ្រូបច្ចេកទេស ត្រូវបានធ្វើអធិការកិច្ច និងវាយតម្លៃនៅតាមគ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/សមាគម យ៉ាងតិច ៥០% ត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំផែនការ និងជ្រើសរើសគ្រូបច្ចេកទេសក្របខណ្ឌថ្មី គ្រូកិច្ចសន្យា និងគ្រូជួល ដើម្បីគាំទ្រកម្មវិធីបណ្តុះបណ្តាលគ្រប់កម្រិត
- ធ្វើវិក្រឹតការគ្រូបច្ចេកទេសទាំងផ្នែកគរុកោសល្យ និងផ្នែកបច្ចេកទេស
- ពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចគ្រូបច្ចេកទេស
- ចុះធ្វើអធិការកិច្ច និងវាយតម្លៃគ្រូបច្ចេកទេសនៅតាមគ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/សមាគម
- រៀបចំយន្តការជ្រើសរើសគ្រូបច្ចេកទេសឆ្នើមក្នុងវិស័យ អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/សមាគម

៣.២.២.៣ ពង្រឹងការត្រួតពិនិត្យវាយតម្លៃគុណភាព អ.ប.វ. ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- លិខិតបទដ្ឋានគតិយុត្ត និងលក្ខណវិនិច្ឆ័យនៃការធានាគុណភាពគ្រឹះស្ថាន អ.ប.វ. ត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នភាព
- មន្ត្រីវាយតម្លៃគុណភាពគ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/សមាគម ត្រូវបានបណ្តុះបណ្តាល
- គ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/សមាគម ត្រូវបានធានាគុណភាពជាប្រចាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- កែសម្រួល និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្ត និងលក្ខណវិនិច្ឆ័យនៃការធានាគុណភាពគ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/ សមាគម
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងលក្ខណវិនិច្ឆ័យនៃការធានាគុណភាពគ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/ សមាគម
- បណ្តុះបណ្តាលសមត្ថភាពមន្ត្រីវាយតម្លៃគុណភាពគ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/ សមាគម
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាពគ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/ សមាគម
- បន្តអនុវត្ត និងជំរុញប្រព័ន្ធគ្រប់គ្រងគុណភាពស្តង់ដាអន្តរជាតិ នៅតាមគ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/ សមាគម

៣.២.២.៤ ធ្វើទំនើបកម្ម និងជំរុញការធ្វើឯកទេសកម្ម និងបង្កើនចំនួនមជ្ឈមណ្ឌលឧត្តមភាព (Centre of Excellence-COE) នៅតាមគ្រឹះស្ថាន អ.ប.វ. ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ហេដ្ឋារចនាសម្ព័ន្ធនានា អគារសិក្សា អន្តេវាសិកដ្ឋាន និងរោងជាង/បន្ទប់ពិសោធន៍ ឧបករណ៍ សម្ភារ បរិក្ខារ ត្រូវបានសាងសង់ និងវិនិយោគបន្ថែម
- យន្តការវាយតម្លៃគ្រឹះស្ថាន អ.ប.វ. ដែលត្រូវធ្វើឯកទេសកម្ម និងមជ្ឈមណ្ឌលឧត្តមភាពត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាព
- មជ្ឈមណ្ឌលឧត្តមភាព (COE) ត្រូវបានបង្កើនដល់ចំនួន ៨ ត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ធ្វើបច្ចុប្បន្នភាពផែនការមេអភិវឌ្ឍន៍គ្រឹះស្ថាន អ.ប.វ. និងកៀរគរធនធានពីគ្រប់ប្រភពដើម្បីកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធនានា អគារសិក្សា អន្តេវាសិកដ្ឋាន និងបំពាក់ឧបករណ៍ សម្ភារ បរិក្ខារ នៅតាមរោងជាង/បន្ទប់ពិសោធន៍
- រៀបចំ និងធ្វើបច្ចុប្បន្នភាពយន្តការវាយតម្លៃគ្រឹះស្ថាន អ.ប.វ. ដែលត្រូវធ្វើឯកទេសកម្ម និងមជ្ឈមណ្ឌលឧត្តមភាព (COE)
- បង្កើតក្រុមវាយតម្លៃធ្វើឯកទេសកម្មគ្រឹះស្ថាន អ.ប.វ. និងមជ្ឈមណ្ឌលឧត្តមភាព (COE) ដែលមានសមាសភាពមកពីស្ថាប័នរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍

- សិក្សា វាយតម្លៃ ដើម្បីកំណត់ឯកទេសកម្មរបស់គ្រឹះស្ថាន អ.ប.វ. និងបន្តតាមដានគុណវុឌ្ឍិជាគ្រឹះស្ថានឯកទេស
- សិក្សា វាយតម្លៃ និងបង្កើតមជ្ឈមណ្ឌលឧត្តមភាព (COE) និងបន្តតាមដានគុណវុឌ្ឍិជាមជ្ឈមណ្ឌលឧត្តមភាព (COE)

៣.២.២.៥ ពង្រឹងប្រសិទ្ធភាព និងតួនាទីរបស់គណៈវិស្វករកម្ពុជាក្នុងការគ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពវិស្វករចុះបញ្ជី ព្រមទាំងចូលរួមពង្រឹងគុណភាព អ.ប.វ. ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនវិស្វករជាតិ និងបរទេស ត្រូវបានចុះបញ្ជីបន្ថែមចំនួន ៦ ៤០០នាក់ រយៈពេល ៥ឆ្នាំ (២០២៤-២០២៨)
- ចំនួនវិស្វករចុះបញ្ជី ត្រូវបានបណ្តុះបណ្តាលលើការប្រតិបត្តិជំនាញវិជ្ជាជីវៈចំនួន ៨ ៥០០នាក់ រយៈពេល ៥ឆ្នាំ (២០២៤-២០២៨)
- ចំនួនវិស្វករអាជីពដែលគណៈវិស្វករកម្ពុជាបានបញ្ជូនឱ្យចូលរួមធ្វើបទបង្ហាញ/បាឋកថា ដើម្បីចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធ នៅតាមគ្រឹះស្ថាន អ.ប.វ.

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេស ស្របតាមគោលការណ៍អាស៊ានចំនួន ២០លិខិតបទដ្ឋាន ព្រមទាំងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេស ពាក់ព័ន្ធវិស័យវិស្វកម្ម តាមរយៈប្រព័ន្ធផ្សព្វផ្សាយ (Website, Social Media) និងសិក្ខាសាលាដែលមានអ្នកចូលរួមប្រមាណ ៣ ៦០០នាក់ រយៈពេល ៥ឆ្នាំ (២០២៤-២០២៨)
- បណ្តុះបណ្តាលបង្កើនសមត្ថភាពប្រតិបត្តិជំនាញវិជ្ជាជីវៈដល់វិស្វករចុះបញ្ជីនៅគណៈវិស្វករកម្ពុជា និងពិនិត្យតាមដានវិស្វករដែលកំពុងប្រកបវិជ្ជាជីវៈវិស្វកម្មនៅតាមការដ្ឋានសហគ្រាស គ្រឹះស្ថានតាមបណ្តារាជធានី ខេត្ត ចំនួន ៦០លើក រយៈពេល ៥ឆ្នាំ
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យវិស្វកម្ម ដោយការចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលវិស្វករអាជីពឆ្នើមអាស៊ាន (ASEAN Chartered Professional Engineer Coordinating Committee-ACPECC) ចំនួន ១៥លើក, កិច្ចប្រជុំអង្គការសហព័ន្ធវិស្វកម្មអាស៊ាន (ASEAN Federation of Engineering Organizations-AFEO) ចំនួន ១០លើក និងកិច្ចប្រជុំអង្គការសហព័ន្ធវិស្វកម្មអាស៊ី និងប៉ាស៊ីហ្វិក (The Federation of Engineering Institutions of Asia and the Pacific-FEIAP) ចំនួន ៥លើក រយៈពេល ៥ឆ្នាំ

- ពង្រឹងតួនាទីគណៈកម្មាធិការវាយតម្លៃសម្បទាវិជ្ជាជីវៈវិស្វកម្ម ដោយត្រូវវាយតម្លៃវិស្វករអាជីពចំនួន ៤៥០នាក់ វិស្វករអាស៊ានចំនួន ២២៥នាក់ និងវិស្វករអាជីពឆ្មើមអាស៊ានចំនួន ៨៥នាក់ រយៈពេល ៥ឆ្នាំ
- សហការរវាងគណៈវិស្វករកម្ពុជា និងគ្រឹះស្ថាន អ.ប.វ. ដើម្បីផ្សព្វផ្សាយ និងចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធ នៅតាមគ្រឹះស្ថាន អ.ប.វ. ស្របតាមតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច ដែលមានការវិវត្តយ៉ាងឆាប់រហ័សនៃមូលដ្ឋានសេដ្ឋកិច្ច ឧស្សាហកម្ម បច្ចេកវិទ្យា និងការការពារបាននូវបរិស្ថានប្រកបដោយចីរភាព

**៣.២.៣. ការពង្រីង និងពង្រីកការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញ ដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម**

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.២.៣.ក. ចំនួនសិស្សបញ្ចប់ការសិក្សាក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនគោលដៅមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល

៣.២.៣.ខ. ចំនួនសិស្សដែលបញ្ចប់ការសិក្សាតាមវិស័យអាទិភាព កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២, ៣ ចំនួន ៤៥ ០០០នាក់ ត្រឹមឆ្នាំ២០២៨

៣.២.៣.គ. ចំនួននិស្សិតដែលបញ្ចប់ការសិក្សាតាមវិស័យអាទិភាព កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស (Higher Technical Diploma) និងសញ្ញាបត្រជាន់ខ្ពស់ផ្អែកលើសមត្ថភាព (Competency Diploma) តាមរយៈការសិក្សានៅតាមគ្រឹះស្ថាន អ.ប.វ., កម្មវិធីសិក្សាផ្អែកលើការងារ (WBL) និងការធ្វើតេស្តវាយតម្លៃទទួលស្គាល់សមត្ថភាពជំនាញយ៉ាងតិច ២០០ ០០០នាក់ ត្រឹមឆ្នាំ២០២៨

៣.២.៣.ឃ. ចំនួននិស្សិតដែលបញ្ចប់ការសិក្សាតាមវិស័យអាទិភាព កម្រិតបរិញ្ញាបត្របច្ចេកទេសយ៉ាងតិច ៤៧ ៥០០នាក់ ត្រឹមឆ្នាំ២០២៨

៣.២.៣.ង. ចំនួនបេក្ខជនទទួលបានការធ្វើតេស្តវាយតម្លៃទទួលស្គាល់ការសិក្សា ដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្នសរុប ៥៧ ៥០០នាក់ ត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពចំនួន ៥ ដូចខាងក្រោម÷

៣.២.៣.១ បង្កើនលទ្ធភាពក្នុងការទទួលបានសេវា អ.ប.វ. ជាពិសេសផ្តល់ឱកាសដល់យុវជនមកពីគ្រួសារក្រីក្រ, គ្រួសារងាយរងហានិភ័យ, ជនងាយរងគ្រោះ, ស្ត្រី, ជនមានពិការភាព, ជនជាតិដើមភាគតិច, សិស្សដែលបោះបង់ការសិក្សា, កម្មករនិយោជិតដែលត្រូវបានព្យួរការងារ, និយោជក និងកម្មករនិយោជិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងពលករទេសន្តរប្រវេសន៍កម្ពុជា

ដែលធ្វើមាតុភូមិនិវត្តន៍ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ផែនការមេសម្រាប់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅតាមគ្រឹះស្ថាន អ.ប.វ. ឱ្យឆ្លើយតបនឹងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងតម្រូវការតាមតំបន់ ត្រូវបានរៀបចំ
- ចំនួនយុវជនក្រុមគោលដៅ ១,៥លាននាក់ ដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនគោលដៅមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យរបស់រាជរដ្ឋាភិបាល កើនឡើង
- ចំនួនសិក្ខាកាម សិស្ស និស្សិត ដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធី អ.ប.វ. គ្រប់កម្រិតកើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការមេសម្រាប់ការបណ្តុះបណ្តាលជំនាញនៅតាមគ្រឹះស្ថាន អ.ប.វ. ឱ្យឆ្លើយតបនឹងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងតម្រូវការតាមតំបន់
- បន្តផ្សព្វផ្សាយជ្រើសរើសយុវជនគោលដៅប្រមាណ ១,៥លាននាក់ ឱ្យចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ និងកម្មវិធី អ.ប.វ. ទូទៅ នៅតាមគ្រឹះស្ថាន អ.ប.វ.
- បន្តផ្តល់ការបណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២, ៣ តាមវិស័យអាទិភាព
- បន្តផ្តល់ការបណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស (Higher Technical Diploma) និងសញ្ញាបត្រជាន់ខ្ពស់ផ្អែកលើសមត្ថភាព (Competency Diploma) តាមរយៈការសិក្សានៅតាមគ្រឹះស្ថាន អ.ប.វ., កម្មវិធីសិក្សាផ្អែកលើការងារ (WBL) និងការធ្វើតេស្តវាយតម្លៃទទួលស្គាល់សមត្ថភាពជំនាញ
- បន្តផ្តល់ការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្របច្ចេកទេសនៅតាមគ្រឹះស្ថាន អ.ប.វ. តាមវិស័យអាទិភាព

៣.២.៣.២ ពង្រឹង និងពង្រីកកម្មវិធីស្ពានចម្លងបន្តជំនាញ កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប) កម្មវិធីហ្វឹកហ្វឺនកូនជាង កម្មវិធីបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ កម្មវិធីបណ្តុះបណ្តាលបង្កើនជំនាញ និងកម្មវិធីសិក្សាផ្អែកលើការងារ (WBL) និងកម្មវិធីបណ្តុះបណ្តាលតាមបច្ចេកវិទ្យាឌីជីថល ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- សិស្សបានទទួលការបណ្តុះបណ្តាលក្នុងកម្មវិធីស្ពានចម្លងបន្តជំនាញ និងកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប) ចំនួន ៥ ០០០នាក់ ត្រឹមឆ្នាំ២០២៨
- កម្មករនិយោជិត ត្រូវបានអភិវឌ្ឍជំនាញ និងបង្កើនផលិតភាព តាមរយៈកម្មវិធីហ្វឹកហ្វឺនកូនជាង យ៉ាងតិច ១៨៤ ០០០នាក់
- កម្មករនិយោជិត ត្រូវបានអភិវឌ្ឍជំនាញ និងបង្កើនផលិតភាព តាមរយៈកម្មវិធីបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ កម្មវិធីបណ្តុះបណ្តាលបង្កើនជំនាញ និងកម្មវិធីសិក្សាផ្អែកលើការងារ (WBL) យ៉ាងតិច ៨៣ ៥០០នាក់

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តកម្មវិធីស្ពានចម្លងបន្តជំនាញ កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប) កម្មវិធីហ្វឹកហ្វឺនកូនជាង កម្មវិធីបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ កម្មវិធីបណ្តុះបណ្តាលបង្កើនជំនាញ និងកម្មវិធីសិក្សាផ្អែកលើការងារ (WBL)
- ផ្សព្វផ្សាយ និងជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តកម្មវិធីស្ពានចម្លងបន្តជំនាញ កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប) កម្មវិធីហ្វឹកហ្វឺនកូនជាង កម្មវិធីបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ កម្មវិធីបណ្តុះបណ្តាលបង្កើនជំនាញ និងកម្មវិធីសិក្សាផ្អែកលើការងារ (WBL)
- បន្តអនុវត្ត និងពង្រីកកម្មវិធីស្ពានចម្លងបន្តជំនាញ និងកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប)
- បន្តអនុវត្ត និងពង្រីកកម្មវិធីហ្វឹកហ្វឺនកូនជាង
- បន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ កម្មវិធីបណ្តុះបណ្តាលបង្កើនជំនាញ និងកម្មវិធីសិក្សាផ្អែកលើការងារ (WBL) សម្រាប់កម្មករនិយោជិត

៣.២.៣.៣ ពង្រឹង និងពង្រីកការធ្វើតេស្តវាយតម្លៃសមត្ថភាពទទួលស្គាល់ការសិក្សាដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្ន, ជំរុញការផ្ទឹមផ្ទងរវាងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) ជាមួយនឹងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF), និងជំរុញការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមកក្នុងតំបន់អាស៊ាន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷



ŊJ

- មជ្ឈមណ្ឌលធ្វើតេស្តវាយតម្លៃសមត្ថភាពទទួលស្គាល់ការសិក្សាដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្នត្រូវបានបង្កើត យ៉ាងតិច ២៥ ត្រឹមឆ្នាំ២០២៨
- ការផ្ទឹមផ្ទង់រវាងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) ជាមួយនឹងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF) ត្រូវបានបញ្ចប់ត្រឹមឆ្នាំ២០២៧
- ការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមកក្នុងតំបន់អាស៊ាន ដែលក្នុងនោះនឹងត្រូវបានអនុវត្តជាមួយប្រទេសថៃ ចាប់ពីឆ្នាំ២០២៥

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- បន្តផ្សព្វផ្សាយ និងជំរុញដល់គ្រឹះស្ថាន អ.ប.វ. និងវិស័យឯកជន បង្កើតមជ្ឈមណ្ឌលធ្វើតេស្តវាយតម្លៃសមត្ថភាពទទួលស្គាល់ការសិក្សាដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្ន
- បន្តជ្រើសរើស និងផ្តល់ការបណ្តុះបណ្តាលដល់អ្នកវាយតម្លៃសមត្ថភាពទទួលស្គាល់ការសិក្សាដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្ន
- បន្តអនុវត្តការធ្វើតេស្តវាយតម្លៃទទួលស្គាល់ការសិក្សាដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្ន
- បន្តរៀបចំរបាយការណ៍ និងបញ្ចប់ការផ្ទឹមផ្ទង់រវាងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) ជាមួយនឹងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF)
- បន្តរៀបចំយន្តការ និងអនុវត្តការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក (Mutual Recognition of Skills-MRS) ជាមួយប្រទេសថៃ និងបណ្តាប្រទេសជាសមាជិកអាស៊ានដទៃទៀត

៣.២.៣.៤ ពង្រឹង និងបង្កើនការផ្សព្វផ្សាយវិស័យ អ.ប.វ. ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ទិវាជាតិ អ.ប.វ. (TVET DAY) និងវេទិកាផ្សព្វផ្សាយ អ.ប.វ. តាមភូមិភាគ ត្រូវបានរៀបចំ រៀងរាល់ឆ្នាំ
- កម្មវិធីតម្រង់ទិសវិជ្ជាជីវៈនៅតាមសាលាចំណេះទូទៅ និងកម្មវិធីផ្សព្វផ្សាយ អ.ប.វ. នៅតាមសហគមន៍ សហគ្រាស គ្រឹះស្ថាន ត្រូវបានរៀបចំចំនួន ១ ៨៥០ដង ត្រឹមឆ្នាំ២០២៨
- អត្រានៃអ្នកទទួលបានព័ត៌មានពីវិស័យ អ.ប.វ. កើនឡើង ២០% រៀងរាល់ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- បន្តកៀរគរធនធានពីគ្រប់ប្រភព ដើម្បីរៀបចំទិវាជាតិ អ.ប.វ. (TVET DAY) និងវេទិកាផ្សព្វផ្សាយ អ.ប.វ. តាមភូមិភាគ



ហ

- បន្តសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា សាលាចំណេះទូទៅ សហគ្រាស គ្រឹះស្ថាន និងផ្នែកពាក់ព័ន្ធក្នុងការចុះតម្រង់ទិសវិជ្ជាជីវៈ និងការលើកកម្ពស់កិត្តិនាម អ.ប.វ. (TVET Branding) និងរៀបចំជ្រើសរើសទូតសុឆន្ទៈ អ.ប.វ. (TVET Ambassador) ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងនៅតាមសាលាចំណេះទូទៅ
- បន្តជំរុញគ្រឹះស្ថាន អ.ប.វ. អនុវត្តការប្រឹក្សាយោបល់មុនពេល ក្នុងអំឡុងពេលសិក្សា និងក្រោយពេលបញ្ចប់ការសិក្សា
- បន្តរៀបចំ ចងក្រង និងផលិតវីដេអូ ឯកសារ សម្ភារ ខិត្តប័ណ្ណ ពាក្យស្លោក អ.ប.វ. និងជំរុញការផ្សព្វផ្សាយវិស័យ អ.ប.វ. តាមគ្រប់រូបភាពទាំងផ្ទាល់ និងតាមបណ្តាញសង្គម
- បន្តសិក្សាវាយតម្លៃផលប៉ះពាល់កម្មវិធីផ្សព្វផ្សាយ អ.ប.វ.

៣.២.៣.៥ បន្តរៀបចំបង្កើនច្រកសិក្សាឱ្យមានលក្ខណៈទន់ភ្លន់ងាយស្រួលអនុវត្តក្នុងកម្មវិធី អ.ប.វ. និងអនុវត្តសកម្មភាព គោរពទង់ជាតិ អប់រំកាយនិងកីឡា សុខភាពសិក្សា បរិស្ថាន សិល្បៈ វប្បធម៌ សីលធម៌ និងមនសិការស្នេហាជាតិ នៅតាមគ្រឹះស្ថាន អ.ប.វ. ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម៖

- ច្រកសិក្សាសម្រាប់សិស្សថ្នាក់ទី១០, ថ្នាក់ទី១១ ចូលមកសិក្សាកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២, ៣ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ចាប់ពីឆ្នាំ២០២៤
- កម្មវិធីបណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់ផ្អែកលើសមត្ថភាព (Competency Diploma) តាមរយៈការសិក្សានៅតាមគ្រឹះស្ថាន អ.ប.វ., កម្មវិធីសិក្សាផ្អែកលើការងារ (WBL) និងការធ្វើតេស្តវាយតម្លៃទទួលស្គាល់សមត្ថភាពជំនាញ ត្រូវបានបន្តរៀបចំ និងអនុវត្ត ចាប់ពីឆ្នាំ២០២៤
- សកម្មភាពគោរពទង់ជាតិ អប់រំកាយនិងកីឡា សុខភាពសិក្សា បរិស្ថាន សិល្បៈ វប្បធម៌ សីលធម៌ និងមនសិការស្នេហាជាតិ នៅតាមគ្រឹះស្ថាន អ.ប.វ. ត្រូវបានបន្តអនុវត្តជាប្រចាំ

ដើម្បីសម្រេចបាននូវសូចនាករនៃចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងដាក់ឱ្យអនុវត្តច្រកសិក្សាសម្រាប់សិស្សថ្នាក់ទី១០ ថ្នាក់ទី១១ ចូលមកសិក្សាកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២, ៣ និងកម្មវិធីបណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់ផ្អែកលើសមត្ថភាព (Competency Diploma) តាមរយៈការសិក្សានៅតាមគ្រឹះស្ថាន អ.ប.វ., កម្មវិធីសិក្សាផ្អែកលើការងារ (WBL) និងការធ្វើតេស្តវាយតម្លៃទទួលស្គាល់សមត្ថភាពជំនាញ

- ផ្សព្វផ្សាយ និងអនុវត្តច្រកសិក្សាសម្រាប់សិស្សថ្នាក់ទី១០ ថ្នាក់ទី១១ ចូលមកសិក្សាកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២, ៣
- បន្តផ្សព្វផ្សាយ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់ផ្អែកលើសមត្ថភាព (Competency Diploma) តាមរយៈការសិក្សានៅតាមគ្រឹះស្ថាន អ.ប.វ., កម្មវិធីសិក្សាផ្អែកលើការងារ (WBL) និងការធ្វើតេស្តវាយតម្លៃទទួលស្គាល់សមត្ថភាពជំនាញ
- បន្តផ្សព្វផ្សាយ និងជំរុញការអនុវត្តក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជានៅតាមគ្រឹះស្ថាន អ.ប.វ.
- បន្តរៀបចំដាក់បញ្ចូលកម្មវិធីគោរពទង់ជាតិ អប់រំកាយនិងកីឡា សុខភាពសិក្សា បរិស្ថាន សិល្បៈ វប្បធម៌ សីលធម៌ និងមនសិការស្នេហាជាតិ និងបំពាក់ឧបករណ៍ សម្ភារ បម្រើឱ្យសកម្មភាពទាំងនេះ នៅតាមគ្រឹះស្ថាន អ.ប.វ.

### ៣.២.៤. ការពង្រឹងភាពជាដៃគូរវាងរដ្ឋ ឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីធានានិរន្តរភាពនៃកម្មវិធីបណ្តុះបណ្តាល

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.២.៤.ក. ចំនួនកិច្ចព្រមព្រៀងដៃគូសហការរវាងគ្រឹះស្ថាន អ.ប.វ. សាធារណៈជាមួយសហគ្រាស គ្រឹះស្ថាន ក្នុង និងក្រៅប្រទេស ដើម្បីពង្រឹងកម្មវិធី អ.ប.វ. ត្រូវបានរៀបចំ យ៉ាងតិច ១0/គ្រឹះស្ថាន/ឆ្នាំ

៣.២.៤.ខ. ចំនួនសិស្ស និស្សិត ទទួលអាហារូបករណ៍សិក្សាពីវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងប្រទេសជាដៃគូ យ៉ាងតិច ២១៥នាក់/ឆ្នាំ

៣.២.៤.គ. អត្រានៃសហគ្រាស គ្រឹះស្ថាន ចុះបញ្ជិកាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធនឹងវិស័យការងារ (LACMS) បានអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ១០% នៃកម្មករនិយោជិតស្របតាមច្បាប់ស្តីពីការងារ តាមរយៈកម្មវិធីហាត់ការ កម្មសិក្សា និង/ឬការបញ្ជូនអ្នកជំនាញរបស់ខ្លួនមកចូលរួមធ្វើបទបង្ហាញ តាមគ្រឹះស្ថាន អ.ប.វ. ដែលជាជម្រើសមានភាពបត់បែនសម្រាប់សហគ្រាស គ្រឹះស្ថាន ងាយស្រួលអនុវត្ត

៣.២.៤.ឃ. ចំនួនអ្នកបច្ចេកទេស/វិស្វករមកពីឧស្សាហកម្ម និងគណៈវិស្វករកម្ពុជា/ស្ថាប័ន ជំនាញចូលរួមផ្តល់ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថាន អ.ប.វ. កើនឡើង

៣.២.៤.ង. ចំនួនក្រុមប្រឹក្សាជំនាញតាមវិស័យ ត្រូវបានបង្កើនដល់ ១០ក្រុមប្រឹក្សា ត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.២.៤.១ បន្តរៀបចំ និងជំរុញការអនុវត្តកម្មវិធីភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងការអភិវឌ្ឍវិស័យ អ.ប.វ. និងផ្តល់ឱកាសដល់សិស្ស និស្សិតគ្រឹះស្ថាន អ.ប.វ. ចុះកម្មសិក្សា ទស្សនកិច្ចសិក្សា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនសហគ្រាស គ្រឹះស្ថាន ដែលត្រូវបានទាក់ទង និងជំរុញឱ្យធ្វើកិច្ចសហប្រតិបត្តិការ ៣៧០សហគ្រាស គ្រឹះស្ថាន/ឆ្នាំ
- ចំនួនសហគ្រាស គ្រឹះស្ថាន បានសហការជាមួយគ្រឹះស្ថាន អ.ប.វ. ក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលភាពជាដៃគូរវាងរដ្ឋ និងឯកជន យ៉ាងតិច ៧៤សហគ្រាស គ្រឹះស្ថាន/ឆ្នាំ
- អត្រានៃសិស្ស និស្សិតគ្រឹះស្ថាន អ.ប.វ. ចុះកម្មសិក្សា នៅតាមសហគ្រាស គ្រឹះស្ថាន កើនឡើង យ៉ាងតិច ៨០% ត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- បន្តរៀបចំយន្តការអនុវត្តកម្មវិធីភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងការអភិវឌ្ឍវិស័យ អ.ប.វ.
- បន្តផ្សព្វផ្សាយ និងលើកទឹកចិត្តដល់គ្រឹះស្ថាន អ.ប.វ. និងសហគ្រាស គ្រឹះស្ថាន ចូលរួមអនុវត្តកម្មវិធីបណ្តុះបណ្តាលភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បន្តរៀបចំចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងគ្រឹះស្ថាន អ.ប.វ. និងសហគ្រាស គ្រឹះស្ថាន
- បន្តជំរុញគ្រឹះស្ថាន អ.ប.វ. អនុវត្តកម្មវិធីបណ្តុះបណ្តាលភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បន្តជំរុញ និងលើកទឹកចិត្តសហគ្រាស គ្រឹះស្ថាន អនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ១០% នៃកម្មករ និយោជិត ស្របតាមច្បាប់ស្តីពីការងារ ឬជ្រើសរើសយកការផ្តល់កម្មវិធីហាត់ការកម្មសិក្សា របស់សិក្ខាកាម សិស្ស និស្សិត និង/ឬការបញ្ជូនអ្នកជំនាញរបស់ខ្លួនមកចូលរួមធ្វើបទបង្ហាញ តាមគ្រឹះស្ថាន អ.ប.វ. ដោយមានជម្រើស និងភាពបត់បែនសម្រាប់សហគ្រាស គ្រឹះស្ថានផងដែរ

៣.២.៤.២ បន្តបង្កើនកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងឯកជន ក្នុងការគាំទ្រការអភិវឌ្ឍ និងធានានិរន្តរភាពវិស័យ អ.ប.វ. ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- កិច្ចសន្ទនារវាងរដ្ឋ និងឯកជនក្នុងការគាំទ្រកម្មវិធី អ.ប.វ. ត្រូវបានរៀបចំយ៉ាងតិច ២ដង/ឆ្នាំ
- តំបន់សេដ្ឋកិច្ចពិសេស និងសួនឧស្សាហកម្ម ចូលរួមបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ យ៉ាងតិច ១ ត្រឹមឆ្នាំ២០២៨
- តំបន់សេដ្ឋកិច្ចពិសេស, សួនឧស្សាហកម្ម, សហគ្រាស គ្រឹះស្ថាន ផ្តល់ថ្នាក់រៀន/រោងជាង/បន្ទប់ពិសោធន៍/កន្លែងស្នាក់នៅសម្រាប់គាំទ្រការអនុវត្តកម្មវិធី អ.ប.វ. កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមផ្សព្វផ្សាយយន្តការលើកទឹកចិត្ត ដែលទទួលបានពីការអនុវត្តកម្មវិធីភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងការគាំទ្រការអភិវឌ្ឍ វិស័យ អ.ប.វ.
- រៀបចំកិច្ចសន្ទនារវាងរដ្ឋ និងឯកជន ក្នុងការអភិវឌ្ឍវិស័យ អ.ប.វ.
- រៀបចំកម្មវិធីវេទិកានិយោជកនៅតាមគ្រឹះស្ថាន អ.ប.វ.
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងម្ចាស់តំបន់សេដ្ឋកិច្ចពិសេស ឬសួនឧស្សាហកម្ម ដើម្បីជំរុញឱ្យបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងតំបន់សេដ្ឋកិច្ចពិសេស ឬសួន ឧស្សាហកម្ម
- សហការជាមួយសហគ្រាស គ្រឹះស្ថាន ដើម្បីប្រើប្រាស់រោងជាង/បន្ទប់ពិសោធន៍/កន្លែង ស្នាក់នៅ ក្នុងការអនុវត្តកម្មវិធី អ.ប.វ.

៣.២.៤.៣ ជំរុញវិស័យឯកជនឱ្យប្រើប្រាស់កម្លាំងពលកម្មជំនាញដែលបានឆ្លងកាត់កម្មវិធី អ.ប.វ. និង រៀបចំយន្តការផ្តល់កម្ចីសិក្សាដល់សិក្ខាកាម សិស្ស និស្សិត ដើម្បីលើកទឹកចិត្តឱ្យចាប់យក ជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនសហគ្រាស គ្រឹះស្ថាន បានទទួលការផ្សព្វផ្សាយជំរុញលើកទឹកចិត្តពីការប្រើប្រាស់ កម្លាំងពលកម្មជំនាញដែលបានឆ្លងកាត់កម្មវិធី អ.ប.វ. កើនឡើង
- ចំនួនសហគ្រាស គ្រឹះស្ថាន ដែលបានទទួលយកកម្លាំងពលកម្មជំនាញដែលទើបចេញ ពីកម្មវិធី អ.ប.វ. កើនឡើងរៀងរាល់ឆ្នាំ
- យន្តការផ្តល់កម្ចីសិក្សាដល់សិក្ខាកាម សិស្ស និស្សិត ដើម្បីលើកទឹកចិត្តឱ្យចាប់យកជំនាញ បច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត យ៉ាងយូរត្រឹមឆ្នាំ២០២៥

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ផ្សព្វផ្សាយ និងជំរុញលើកទឹកចិត្តសហគ្រាស គ្រឹះស្ថាន ឱ្យប្រើប្រាស់កម្លាំងពលកម្មជំនាញ ដែលបានឆ្លងកាត់កម្មវិធី អ.ប.វ.
- រៀបចំយន្តការគាំទ្រដល់សិក្ខាកាម សិស្ស និស្សិត ចូលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន

- រៀបចំបញ្ជីឈ្មោះសហគ្រាស គ្រឹះស្ថាន ដែលប្រើប្រាស់កម្លាំងពលកម្មជំនាញបានឆ្លងកាត់កម្មវិធី អ.ប.វ.
- រៀបចំយន្តការផ្តល់កម្ចីសិក្សាដល់សិក្ខាកាម សិស្ស និស្សិត ដើម្បីលើកទឹកចិត្តចាប់យកជំនាញបច្ចេកទេស និងវិជ្ជាជីវៈ
- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តយន្តការផ្តល់កម្ចីសិក្សាដល់សិក្ខាកាម សិស្ស និស្សិត ដើម្បីលើកទឹកចិត្តចាប់យកជំនាញបច្ចេកទេស និងវិជ្ជាជីវៈ

៣.២.៤.៤ រៀបចំយន្តការក្នុងការប្រើប្រាស់អ្នកបច្ចេកទេស/វិស្វករមកពីឧស្សាហកម្ម គណៈវិស្វករកម្ពុជា/ស្ថាប័នជំនាញសម្រាប់ផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅតាមគ្រឹះស្ថាន អ.ប.វ. ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- យន្តការទាក់ទាញអ្នកបច្ចេកទេស/វិស្វករ សម្រាប់ផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅតាមគ្រឹះស្ថាន អ.ប.វ. ត្រូវបានរៀបចំ និងអនុវត្ត ចាប់ពីឆ្នាំ២០២៤
- ផែនការតម្រូវការអ្នកបច្ចេកទេស/វិស្វករមកពីឧស្សាហកម្ម គណៈវិស្វករកម្ពុជា/ស្ថាប័នជំនាញត្រូវបានរៀបចំជាប្រចាំឆ្នាំ
- ចំនួនសហគ្រាស គ្រឹះស្ថាន និងគណៈវិស្វករកម្ពុជា/ស្ថាប័នជំនាញដែលបានទទួលការផ្សព្វផ្សាយឱ្យមកចូលរួមផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈនៅតាមគ្រឹះស្ថាន អ.ប.វ.

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំយន្តការដើម្បីទាក់ទាញអ្នកបច្ចេកទេស/វិស្វករចូលរួមផ្តល់ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថាន អ.ប.វ.
- រៀបចំផែនការតម្រូវការអ្នកបច្ចេកទេស/វិស្វករមកពីឧស្សាហកម្ម គណៈវិស្វករកម្ពុជា/ស្ថាប័នជំនាញ ដើម្បីផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅតាមគ្រឹះស្ថាន អ.ប.វ.
- ទាក់ទង និងផ្សព្វផ្សាយជាមួយវិស័យឯកជន និងគណៈវិស្វករកម្ពុជា/ស្ថាប័នជំនាញ ឱ្យមកចូលរួមផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅតាមគ្រឹះស្ថាន អ.ប.វ.
- លើកទឹកចិត្តវិស័យឯកជន និងគណៈវិស្វករកម្ពុជា/ស្ថាប័នជំនាញ ដែលបានចូលរួមផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ នៅតាមគ្រឹះស្ថាន អ.ប.វ.

- ប្រមូលយោបល់ត្រឡប់មកវិញពាក់ព័ន្ធនឹងការចូលរួមកម្មវិធី អ.ប.វ. ពីសិស្ស និស្សិត និងអ្នកបច្ចេកទេស/វិស្វករមកពីឧស្សាហកម្ម គណៈវិស្វករកម្ពុជា/ ស្ថាប័នជំនាញ

៣.២.៤.៥ បង្កើនចំនួន និងពង្រឹងតួនាទីក្រុមប្រឹក្សាជំនាញតាមវិស័យស្របតាមតម្រូវការជាក់ស្តែង ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍សិក្សាក្នុងការបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យ សម្រាប់គាំទ្រវិស័យ អ.ប.វ. ត្រូវបានរៀបចំ
- សមាសភាពក្រុមប្រឹក្សាជំនាញតាមវិស័យ ត្រូវបានបន្តធ្វើបច្ចុប្បន្នភាពរៀងរាល់ ២ឆ្នាំ
- តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជំនាញតាមវិស័យ ត្រូវបានបន្តពង្រឹងជាប្រចាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- សិក្សាបង្កើត និងធ្វើបច្ចុប្បន្នភាពក្រុមប្រឹក្សាជំនាញតាមវិស័យ សម្រាប់គាំទ្រវិស័យ អ.ប.វ.
- បន្តរៀបចំផែនការ និងកៀរគរធនធានពីគ្រប់ប្រភពសម្រាប់គាំទ្រដំណើរការការងារក្រុមប្រឹក្សាជំនាញតាមវិស័យ
- បន្តពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជំនាញតាមវិស័យ
- បន្តពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាជំនាញតាមវិស័យ
- រៀបចំបូកសរុបលទ្ធផលវាយតម្លៃការអនុវត្តការងាររបស់ក្រុមប្រឹក្សាជំនាញតាមវិស័យ ក្នុងការអភិវឌ្ឍវិស័យ អ.ប.វ.

### ៣.២.៥. ការជំរុញការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.២.៥.ក. ចំនួនមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការបន្ថែមចំនួន ២ ត្រឹមឆ្នាំ២០២៦

៣.២.៥.ខ. ចំនួនស្នាដៃផលិត Robot ឬការសិក្សាស្រាវជ្រាវ ដែលត្រូវប្រើប្រាស់នៅក្នុងឧស្សាហកម្ម ឬធ្វើពាណិជ្ជូបនីយកម្ម យ៉ាងតិច ៣/ឆ្នាំ

៣.២.៥.គ. អត្រានៃនិស្សិតដែលមានគម្រោងស្រាវជ្រាវពេលបញ្ចប់ការសិក្សា ឱ្យបាន ៥០% ត្រឹមឆ្នាំ២០២៨

៣.២.៥.ឃ. ចំនួនស្នាដៃ ឬគម្រោងដែលបានដាក់តាំងបង្ហាញជាសាធារណៈ យ៉ាងតិច ១០/ឆ្នាំ

៣.២.៥.ង. ចំនួនបេក្ខជនជ័យលាភី ក្នុងការប្រកួតប្រជែងជំនាញ ថ្នាក់ភូមិភាគ ថ្នាក់ជាតិ ថ្នាក់អាស៊ាន និងថ្នាក់អន្តរជាតិ ដែលបានទទួលការលើកទឹកចិត្តយ៉ាងតិច ២៥/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.២.៥.១ បង្កើនចំនួនមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- សមិទ្ធិលទ្ធភាពសិក្សាសម្រាប់ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ ត្រូវបានរៀបចំ
- យន្តការកៀរគរធនធានពីគ្រប់ប្រភពគាំទ្រមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ ត្រូវបានរៀបចំ
- មូលនិធិស្ម័គ្រចិត្តពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ ត្រូវបានបង្កើន

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- បង្កើតក្រុមការងាររៀបចំសមិទ្ធិលទ្ធភាពសិក្សាសម្រាប់ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍
- រៀបចំផែនការថវិកាសម្រាប់បង្កើត និងដំណើរការមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍
- កៀរគរមូលនិធិស្ម័គ្រចិត្តពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍
- រៀបចំបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត
- បំពាក់ឧបករណ៍ សម្ភារ បរិក្ខារ ស្របតាមបច្ចេកវិទ្យាថ្មីៗ នៅតាមមជ្ឈមណ្ឌលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍

៣.២.៥.២ ជំរុញការសិក្សាស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត ដែលអាចយកទៅប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម ឬធ្វើពាណិជ្ជូបនីយកម្ម ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំស្តីពីការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ត្រូវបានរៀបចំ

- គណៈកម្មការស្រាវជ្រាវ ដើម្បីកំណត់គម្រោងស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត ត្រូវបានរៀបចំ
- គម្រោងស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត ត្រូវបានសិក្សា និងកំណត់ ជាប្រចាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំស្តីពីការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍
- បង្កើតគណៈកម្មការស្រាវជ្រាវ ដើម្បីកំណត់គម្រោងស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត
- រៀបចំកំណត់គម្រោងស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត
- ផ្សព្វផ្សាយ និងកៀរគរធនធានពីគ្រប់ប្រភពសម្រាប់គាំទ្រគម្រោងស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត
- អនុវត្តគម្រោងស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត

៣.២.៥.៣ ជំរុញនិងលើកទឹកចិត្តដល់សិស្ស និស្សិត ឱ្យរៀបចំគម្រោងសិក្សាស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍សម្រាប់បញ្ចប់ការសិក្សានៅតាមគ្រឹះស្ថាន អ.ប.វ. ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គោលការណ៍ណែនាំស្តីពីគម្រោងស្រាវជ្រាវបញ្ចប់ការសិក្សារបស់សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ. ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត
- ចំនួនគ្រឹះស្ថាន អ.ប.វ. បានទទួលការផ្សព្វផ្សាយ ជំរុញ និងលើកទឹកចិត្តឱ្យអនុវត្តគម្រោងស្រាវជ្រាវរបស់សិស្ស និស្សិត ជាប្រចាំឆ្នាំ
- របាយការណ៍វាយតម្លៃគម្រោងស្រាវជ្រាវស្នាដៃបញ្ចប់ការសិក្សា នៅតាមគ្រឹះស្ថាន អ.ប.វ. ត្រូវបានរៀបចំជាប្រចាំឆ្នាំ និងលើកទឹកចិត្តសម្រាប់ស្នាដៃឆ្នើម

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីគម្រោងស្រាវជ្រាវបញ្ចប់ការសិក្សា នៅតាមគ្រឹះស្ថាន អ.ប.វ.
- ជំរុញ និងលើកទឹកចិត្តអនុវត្តគម្រោងស្រាវជ្រាវបញ្ចប់ការសិក្សា របស់សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ.
- កៀរគរធនធានពីគ្រប់ប្រភពសម្រាប់គាំទ្រគម្រោងស្រាវជ្រាវបញ្ចប់ការសិក្សា របស់សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ.
- ជ្រើសរើស និងលើកទឹកចិត្តចំពោះស្នាដៃឆ្នើមរបស់សិស្ស និស្សិត ដែលបានផលិត
- រៀបចំប្រមូលចងក្រង ផ្សព្វផ្សាយ និងរក្សាទុកស្នាដៃស្រាវជ្រាវ

៣.២.៥.៤ រៀបចំពិព័រណ៍តាំងបង្ហាញសមិទ្ធផលគម្រោងស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- សមិទ្ធផលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ឆ្នើមសម្រាប់តាំងបង្ហាញ ត្រូវបានកំណត់ និងជ្រើសរើស
- ពិព័រណ៍តាំងបង្ហាញសមិទ្ធផលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ ត្រូវបានរៀបចំរៀងរាល់ឆ្នាំ
- សមិទ្ធផលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ ត្រូវបានចងក្រងជាឯកសារ និងរក្សាទុក

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- កំណត់ និងជ្រើសរើសសមិទ្ធផលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ឆ្នើមសម្រាប់តាំងបង្ហាញ
- រៀបចំពិព័រណ៍តាំងបង្ហាញសមិទ្ធផលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍
- កៀរគរធនធានពីគ្រប់ប្រភពសម្រាប់គាំទ្រកម្មវិធីតាំងបង្ហាញសមិទ្ធផលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍
- ជ្រើសរើសសមិទ្ធផលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ ដែលអាចយកទៅប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម ឬធ្វើពាណិជ្ជូបនីយកម្ម
- រៀបចំចងក្រងជាឯកសារ និងផ្សព្វផ្សាយសមិទ្ធផលស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍

៣.២.៥.៥ បន្តជំរុញការរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ភូមិភាគ ថ្នាក់ជាតិ និងបង្កើនការចូលរួមការប្រកួតប្រជែងជំនាញថ្នាក់អាស៊ាន និងថ្នាក់អន្តរជាតិ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម៖

- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការប្រកួតប្រជែងជំនាញថ្នាក់ភូមិភាគ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ត្រូវបានបន្តរៀបចំ ត្រឹមឆ្នាំ២០២៤
- ការប្រកួតប្រជែងជំនាញថ្នាក់ភូមិភាគ ឬថ្នាក់ជាតិ ត្រូវបានរៀបចំរៀងរាល់ឆ្នាំ
- ការប្រកួតប្រជែងជំនាញថ្នាក់អាស៊ាន ឬថ្នាក់អន្តរជាតិ ត្រូវបានចូលរួមរៀងរាល់ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម៖

- បន្តធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធទៅនឹងការប្រកួតប្រជែងជំនាញថ្នាក់ភូមិភាគ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ
- បន្តផ្សព្វផ្សាយការប្រកួតប្រជែងជំនាញថ្នាក់ភូមិភាគ ថ្នាក់ជាតិ ថ្នាក់អាស៊ាន និងថ្នាក់អន្តរជាតិ
- បន្តរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ភូមិភាគ និងថ្នាក់ជាតិ
- បន្តចូលរួមការប្រកួតប្រជែងជំនាញថ្នាក់អាស៊ាន និងថ្នាក់អន្តរជាតិ
- បន្តជ្រើសរើស និងផ្តល់ការលើកទឹកចិត្តដល់បេក្ខជនជ័យលាភី ក្នុងការប្រកួតប្រជែងជំនាញថ្នាក់ភូមិភាគ ថ្នាក់ជាតិ ថ្នាក់អាស៊ាន និងថ្នាក់អន្តរជាតិ

ដើម្បីសម្រេចបានជោគជ័យលើការអនុវត្តនូវយុទ្ធសាស្ត្រអាទិភាពខាងលើ, អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវរៀបចំការពិនិត្យតាមដានលទ្ធផលនៃការអនុវត្តការងារជារៀងរាល់ខែ ត្រីមាស ឆមាស ប្រាំបួនខែ ជាពិសេស ការពិនិត្យវាយតម្លៃប្រចាំឆ្នាំ ដើម្បីវាយតម្លៃអំពីសមិទ្ធកម្មការងារសម្រេចបាន បញ្ហាប្រឈមដែលត្រូវកែលម្អ វិធានការអន្តរាគមន៍នានាដែលត្រូវដាក់ចេញ សំដៅធានាឱ្យបាននូវការចូលរួមអនុវត្តពីគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ ការទទួលខុសត្រូវ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពជោគជ័យខ្ពស់។ យុទ្ធសាស្ត្រអាទិភាពនេះ ត្រូវបានចាត់ទុកថាជាឯកសាររស់រវើក ដែលសូចនាករកម្រិតយុទ្ធសាស្ត្រ សូចនាករកម្រិតកម្មវិធី ចង្កោមសកម្មភាព សូចនាករចង្កោមសកម្មភាព និងសកម្មភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ អាចនឹងត្រូវកែសម្រួល និងបច្ចុប្បន្នភាពជាយថាហេតុ ដើម្បីឱ្យស្របនឹងបរិការណ៍ជាក់ស្តែង និងការវិវត្តនៃវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ, វិធានការណ៍ និងសូចនាករគន្លឹះជាក់ស្តែងនានាដែលរាជរដ្ឋាភិបាល នឹងបន្តដាក់ចេញទៅតាមក្របខណ្ឌពេលវេលា ព្រមទាំងស្របទៅតាមការវិវត្តនៃសង្គម-សេដ្ឋកិច្ច ទាំងនៅក្នុងតំបន់ និងសកលលោក។

### ៣.៣- ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាពនិងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ស្របតាមការវិវត្តនៃពិភពការងារ

ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាពនិងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ គឺជាកិច្ចការអាទិភាពមួយយ៉ាងសំខាន់ ដែលរាជរដ្ឋាភិបាលបន្តយកចិត្តទុកដាក់ពង្រឹងការអនុវត្ត ដូចដែលបានរំលេចនៅក្នុង**មុំទី១ ការអភិវឌ្ឍទីផ្សារការងារ នៃបញ្ចកោណទី៣ស្តីពីការអភិវឌ្ឍវិស័យឯកជន និងការងារ ក្នុង "យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១"**។ នៅក្នុងអាណត្តិថ្មីនេះ ក្រសួងនឹងបន្តយកចិត្តទុកដាក់លើការពង្រឹងការអនុវត្តច្បាប់ និងអភិវឌ្ឍក្របខណ្ឌគតិយុត្តស្របតាមការប្រែប្រួលនៃលក្ខខណ្ឌការងារ និងការលេចឡើងនៃប្រភេទការងារថ្មីៗ ស្របតាមការវិវត្តនៃពិភពការងារ, បន្តពង្រឹងយន្តការអធិការកិច្ចការងារ តាមរយៈការចាត់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះសហគ្រាស គ្រឹះស្ថានដែលអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យការងារ, ការលើកកម្ពស់លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ ព្រមទាំងធានាថាលក្ខខណ្ឌការងារនៅកម្ពុជាត្រូវបានអនុវត្តដោយអនុលោមតាមបទដ្ឋានការងារអន្តរជាតិ និងគោលនយោបាយពាណិជ្ជកម្មផ្សារភ្ជាប់នឹងលក្ខខណ្ឌការងារ។ ដូចគ្នានេះ ក្រសួងនឹងបន្តប្តេជ្ញាចិត្តក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ, ការពង្រឹងយន្តការស្ថាប័ន និងតួអង្គពាក់ព័ន្ធ ក្នុងការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត ដោយផ្អែកលើលក្ខណវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ច, ការលើកកម្ពស់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការអនុវត្តសិទ្ធិ និងតួនាទីរបស់អង្គការវិជ្ជាជីវៈ ប្រកបដោយភាពស្មោះត្រង់ សុចរិត ស្អាតស្អំ និងក្រមសីលធម៌វិជ្ជាជីវៈ និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទការងារ ដើម្បីប្រែក្លាយសហគ្រាសមួយ ជាសហគមន៍សុខសាន្តមួយ។

សូចនាករកម្រិតយុទ្ធសាស្ត្រ ត្រូវសម្រេចឱ្យបានក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ មាន ៥ ដូចខាងក្រោម÷

៣.៣.ក. អត្រានៃសហគ្រាស គ្រឹះស្ថានដែលអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ កើនឡើង ដើម្បីប្រែក្លាយ "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ" និងធានាបាននូវអាជីវកម្មប្រកបដោយទំនួលខុសត្រូវ និងការប្រើប្រាស់ពលកម្មស្អាតស្អំ

៣.៣.ខ. រាល់ករណីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានអន្តរាគមន៍ និងចាត់វិធានការតាមច្បាប់យ៉ាងម៉ឺងម៉ាត់ដោយមិនមានការលើកលែង ក្នុងរយៈពេល ២៤ម៉ោង

៣.៣.គ. ចំនួនកម្មករនិយោជិតទទួលរងគ្រោះថ្នាក់ការងារក្នុងចំណោមកម្មករនិយោជិត ១០០ ០០០នាក់ មានការថយចុះ យ៉ាងតិច ១០% ក្នុងមួយឆ្នាំ

៣.៣.ឃ. អត្រាវិវាទការងារ ឬការស្រាយបំភ្លឺច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលប្តឹង ឬស្នើសុំមកក្រសួងជាស្ថាប័នដំបូង កើនឡើង ដើម្បីទទួលបានការជឿទុកចិត្តរបស់កម្មករនិយោជិត និយោជក និងភាគីពាក់ព័ន្ធ

៣.៣.ង. អត្រានៃសំណើ ឬបណ្តឹងពាក់ព័ន្ធនឹងអនុសញ្ញាអន្តរជាតិខាងការងារ ត្រូវបានដោះស្រាយទាន់ពេលវេលា កើនឡើង ដើម្បីរក្សាកេរ្តិ៍ឈ្មោះកម្ពុជា ជាប្រទេសដែលគោរពបទដ្ឋានអន្តរជាតិខាងការងារក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកល

ដើម្បីសម្រេចបាននូវសូចនាករកម្រិតយុទ្ធសាស្ត្រខាងលើនេះ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

**៣.៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច និងយន្តការអធិការកិច្ចការងារ ដើម្បីលើកកម្ពស់ វប្បធម៌អនុលោមភាពនៃច្បាប់ពាក់ព័ន្ធវិស័យការងារ**

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៣.១.ក. អត្រានៃសហគ្រាស គ្រឹះស្ថាន ដែលអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារតាម ប្រព័ន្ធស្វ័យប្រវត្តិកម្ម (Self-Inspection Cetrailized Mangement System-SICMS) កើនឡើង

៣.៣.១.ខ. អត្រានៃសហគ្រាស គ្រឹះស្ថាន ដែលមិនបានអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិស័យការងារ ត្រូវបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់តាមច្បាប់ក្នុងការផាក ពិន័យ និងវិធានការដទៃទៀត ដោយមិនមានការលើកលែង

៣.៣.១.គ. ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងការធ្វើអធិការកិច្ចលើសហគ្រាស គ្រឹះស្ថាន ត្រូវបាន បញ្ចូល ទៅក្នុងក្រុមអធិការកិច្ចអន្តរក្រសួង នៅក្នុងឆ្នាំ២០២៥ ស្របតាមលទ្ធផលនៃ វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣

៣.៣.១.ឃ. ចំនួនមន្ត្រីអធិការកិច្ចការងារសរុប ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ កើនឡើងដល់ ៣៦០នាក់ នៅឆ្នាំ២០២៨

៣.៣.១.ង. ក្របខណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងការងារពីចម្ងាយ និងប្រភេទការងារថ្មីៗ ក្នុង បរិបទការងារលើថ្នាលឌីជីថល និងការងារបៃតង ត្រូវបានរៀបចំ និងអនុវត្តនៅឆ្នាំ ២០២៨ ព្រមទាំងរាល់គោលនយោបាយ ក្របខណ្ឌគតិយុត្ត និងនីតិវិធីប្រតិបត្តិស្តង់ដា របស់អង្គភាពដែលអនុវត្តកម្មវិធីនេះ ត្រូវបានពិនិត្យឡើងវិញ រៀបចំថ្មី និងធ្វើ បច្ចុប្បន្នភាព

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៣.១.១ បន្តកែលម្អ និងពង្រឹងយន្តការគ្រប់គ្រងប្រព័ន្ធស្វ័យប្រកាសអធិការកិច្ចការងារ ដើម្បីកំណត់ គោលដៅធ្វើអធិការកិច្ចតាមកម្រិតហានិភ័យរបស់សហគ្រាស គ្រឹះស្ថាន និងរៀបចំប្រព័ន្ធ ជូនដំណឹងដោយស្វ័យប្រវត្តិ អំពីភាពមិនប្រក្រតីនៃដំណើររបស់សហគ្រាស គ្រឹះស្ថាន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- អត្រានៃភាពងាយស្រួលក្នុងការប្រើប្រាស់ប្រព័ន្ធស្វ័យប្រកាសអធិការកិច្ចការងារ កើនឡើង

- បញ្ជីឈ្មោះសហគ្រាស គ្រឹះស្ថានតាមកម្រិតហានិភ័យ ត្រូវបានរៀបចំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងវាយតម្លៃប្រចាំត្រីមាស
- រាល់សហគ្រាស គ្រឹះស្ថានដែលមានភាពមិនប្រក្រតីនៃដំណើរការ ត្រូវបានត្រួតពិនិត្យក្នុងរយៈពេល ៤៨ម៉ោង

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ធ្វើបច្ចុប្បន្នភាព និងកែលម្អមុខងាររបស់ប្រព័ន្ធអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (SICMS) កាន់តែងាយស្រួលប្រើប្រាស់ ដោយផ្អែកលើការអង្កេត និងបទពិសោធនៃការប្រើប្រាស់ប្រព័ន្ធ
- សិក្សា និងកំណត់លក្ខណវិនិច្ឆ័យ វិធីសាស្ត្រ និងប្រភពទន្និន័យក្នុងការធ្វើចំណាត់ថ្នាក់ហានិភ័យនៃការមិនអនុលោមលក្ខខណ្ឌការងាររបស់សហគ្រាស គ្រឹះស្ថាន ដើម្បីរៀបចំប្រព័ន្ធធ្វើចំណាត់ថ្នាក់សហគ្រាស គ្រឹះស្ថាន និងផលិតជាបញ្ជីឈ្មោះសហគ្រាស គ្រឹះស្ថានតាមកម្រិតហានិភ័យ
- សិក្សា និងរៀបចំប្រព័ន្ធផ្តល់ដំណឹងមុនអំពីសហគ្រាស គ្រឹះស្ថានដែលប្រឈមនឹងការព្យួរកិច្ចសន្យាការងារ ឬមានភាពមិនប្រក្រតីនៃដំណើរការអាជីវកម្ម ដោយផ្អែកលើទិន្នន័យប្រតិបត្តិការរបស់សហគ្រាស គ្រឹះស្ថាន លើប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធនឹងវិស័យការងារ (LACMS)
- រៀបចំប្រព័ន្ធទទួលបណ្តឹងតាមប្រព័ន្ធឌីជីថលពាក់ព័ន្ធនឹងការមិនអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ ដែលត្រូវដាក់លើគេហទំព័ររបស់ក្រសួង និងផ្សព្វផ្សាយដល់សាធារណជន
- ជ្រើសរើស និងបណ្តុះបណ្តាលមន្ត្រីលើមុខជំនាញគ្រប់គ្រងស្ថិតិ វិភាគហានិភ័យ រៀបចំផែនការ និងវិធីសាស្ត្រអធិការកិច្ចការងារ

៣.៣.១.២ រៀបចំប្រព័ន្ធអភិបាលកិច្ចអធិការកិច្ចការងារ ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការធ្វើអធិការកិច្ចការងារ ព្រមទាំងធ្វើឱ្យរបាយការណ៍អធិការកិច្ចការងារត្រូវបានទទួលស្គាល់ពីគ្រប់ភាគីពាក់ព័ន្ធ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ការអនុវត្តការងាររបស់អធិការការងារអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ និងគោលការណ៍ណែនាំសម្រាប់មន្ត្រីអធិការកិច្ចការងារ កើនឡើង

- របាយការណ៍ស្តីពីលទ្ធផលក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិ បទដ្ឋានអន្តរជាតិ កិច្ចព្រមព្រៀង និងពិធីសារពាក់ព័ន្ធ ត្រូវបានរៀបចំតាមក្របខណ្ឌពេលវេលា
- របាយការណ៍អធិការកិច្ចការងារស្តីពីអនុលោមភាពការងារជាភាសាខ្មែរ និងអង់គ្លេសត្រូវបានផលិត និងផ្សព្វផ្សាយជាប្រចាំឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ និងគោលការណ៍ណែនាំសម្រាប់មន្ត្រីអធិការកិច្ចការងារ ព្រមទាំងរៀបចំផែនការសកម្មភាពអធិការកិច្ចការងារ
- រៀបចំ និងដាក់ឱ្យអនុវត្តយន្តការត្រួតពិនិត្យ និងវាយតម្លៃលើប្រព័ន្ធអធិការកិច្ចការងារ និងការបំពេញតួនាទី ភារកិច្ចរបស់អធិការការងារ អធិការពេទ្យការងារ និងអភិបាលការងារ
- ធ្វើអភិបាលកិច្ចលើភាពមិនប្រក្រតីក្នុងការអនុវត្តតួនាទី និងភារកិច្ច និងការរំលោភបំពានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារដោយអធិការងារ អធិការពេទ្យការងារ និងអភិបាលការងារ
- រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យ និងចងក្រងរបាយការណ៍ឱ្យបានទៀងទាត់ និងទាន់ពេលវេលាអំពីការអនុវត្តអនុសញ្ញាអន្តរជាតិ បទដ្ឋានអន្តរជាតិ កិច្ចព្រមព្រៀង និងពិធីសារពាក់ព័ន្ធ
- រៀបចំ ផលិត ផ្សព្វផ្សាយ របាយការណ៍អធិការកិច្ចការងារស្តីពីអនុលោមភាពការងារជាភាសាខ្មែរ និងអង់គ្លេស

៣.៣.១.៣ បន្តជំរុញការអនុវត្ត "វប្បធម៌អនុលោមភាពការងារ" តាមរយៈការចុះអធិការកិច្ចការងារ និងពង្រឹងយន្តការអធិការកិច្ចអន្តរក្រសួង ព្រមទាំងពង្រឹងយន្តការគាំទ្រគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- អត្រានៃសហគ្រាស គ្រឹះស្ថាន ដែលល្មើសនឹងលក្ខខណ្ឌអាទិភាពដាច់ខាត និងចម្បង ថយចុះ
- ការចុះធ្វើអធិការកិច្ចការងារនៅតាមសហគ្រាស គ្រឹះស្ថានទូទៅ ត្រូវបានកំណត់យ៉ាងតិច ៨ ០០០ លើក/ឆ្នាំ
- ការចុះធ្វើអធិការកិច្ចការងារក្នុងវិស័យសំណង់ សិប្បកម្មឱសថ សេវាកម្សាន្ត និងកសិកម្ម ត្រូវបានកំណត់យ៉ាងតិច ៥០០លើក/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ជំរុញការអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងការចុះធ្វើអធិការកិច្ច ដោយផ្អែកលើកម្រិតហានិភ័យរបស់សហគ្រាស គ្រឹះស្ថាន និងតាមបណ្តឹង ជាពិសេសត្រួតពិនិត្យអនុលោមភាពលក្ខខណ្ឌការងារនៅក្នុងខ្សែច្រវាក់ផលិតកម្ម រួមទាំងការជួលផលិតបន្ត និងការប្រើប្រាស់ពលកម្មគាំទ្រពាក់ព័ន្ធ
- បន្តសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីដាក់ឱ្យអនុវត្តការធ្វើអធិការកិច្ចអន្តរក្រសួង ព្រមទាំងរៀបចំនីតិវិធី និងកម្មវិធីអធិការកិច្ចអន្តរក្រសួង តាមរយៈការពង្រឹងតួនាទីរបស់លេខាធិការដ្ឋានក្រុមការងាររៀបចំក្រុមអធិការកិច្ចអន្តរក្រសួង
- ពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋានបញ្ជាការឯកភាពក្រុមអធិការកិច្ចការងារតែមួយ ព្រមទាំងផ្តល់ឧបករណ៍ សម្ភារ បរិក្ខារ និងមធ្យោបាយចាំបាច់ឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមអធិការកិច្ចការងារ
- រៀបចំយន្តការវាយតម្លៃអំពីការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យការងារ និងការផ្តល់វិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ
- អនុវត្តយន្តការនៃការចុះត្រួតពិនិត្យរួមគ្នារវាងអធិការការងារ និងគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) លើសហគ្រាស គ្រឹះស្ថានក្នុងវិស័យផលិតផលិតផលធ្វើដំណើរ និងកាបូប

៣.៣.១.៤ សិក្សា និងបំភ្លឺបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារក្រោមអភិក្រមបុរេសកម្ម ព្រមទាំងជំរុញការរៀបចំក្របខណ្ឌគតិយុត្ត និងលក្ខខណ្ឌការងារស្របតាមការវិវត្តនៅក្នុងពិភពការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- ក្រុមឆ្លើយតបរហ័សបំភ្លឺបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារក្រោមអភិក្រមបុរេសកម្ម ត្រូវបានបង្កើត
- សេចក្តីណែនាំ និងសេចក្តីបំភ្លឺដើម្បីពន្យល់ខ្លឹមសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ ត្រូវបានដាក់ឱ្យអនុវត្ត
- ក្រុមការងារពិគ្រោះយោបល់អំពីការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ ត្រូវបានបង្កើត

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ ចងក្រង និងធ្វើបច្ចុប្បន្នភាព សំណួរ និងសំណើរបស់វិស័យឯកជនពាក់ព័ន្ធនឹងការស្នើសុំបកស្រាយការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យការងារ ដើម្បីរៀបចំឆ្លើយតបជាប្រចាំ
- រៀបចំខ្លឹមសារ និងឯកសារពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌការងារ ការគណនាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ព្រមទាំងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ដើម្បីរៀបចំបញ្ចូលក្នុងកម្មវិធី ទូរស័ព្ទ ( Mobile Application)
- សិក្សាបង្កើត និងដាក់ឱ្យដំណើរការប្រព័ន្ធ និងក្រុមឆ្លើយតបរហ័សបំភ្លឺ បទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារក្រោមអភិក្រមបុរេសកម្ម
- សិក្សាកំណត់ និងធ្វើអាទិភាពនីយកម្មនៃប្រភេទការងារពីចម្ងាយ ការងារតាមថ្នាលឌីជីថល និងប្រភេទការងារថ្មីៗ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តឆ្លើយតបនឹងតម្រូវការលក្ខខណ្ឌការងារ និងលក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ
- រៀបចំ និងដំណើរការក្រុមការងារពិគ្រោះយោបល់ អំពីការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ

៣.៣.១.៥ ធ្វើវិជ្ជាជីវៈនីយកម្មអធិការការងារនិងបណ្តុះបណ្តាល វាយតម្លៃ ដើម្បីផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ និងផ្តល់ការបណ្តុះបណ្តាលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារដល់ភាគីពាក់ព័ន្ធ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- ចំនួនមន្ត្រីអធិការកិច្ចការងារយ៉ាងតិច ៥០០នាក់/ឆ្នាំ ត្រូវបានបណ្តុះបណ្តាលពង្រឹងសមត្ថភាព
- ចំនួនបុគ្គលិករដ្ឋបាលសហគ្រាស គ្រឹះស្ថានយ៉ាងតិច ១ ៥០០នាក់/ឆ្នាំ ត្រូវបានបណ្តុះបណ្តាលអំពីច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធវិស័យការងារ
- លក្ខន្តិកៈដោយឡែកកំណត់អំពីក្របខណ្ឌអធិការការងារ និងអធិការពេទ្យការងារ ត្រូវបានរៀបចំនៅឆ្នាំ២០២៤

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- សិក្សា និងកំណត់ក្របខណ្ឌគុណវុឌ្ឍិជាអធិការការងារ អធិការពេទ្យការងារ និងអធិការសន្តិសុខសង្គម ដើម្បីរៀបចំជាសេចក្តីព្រាងអនុក្រឹត្យ
- សហការជាមួយក្រសួងយុត្តិធម៌ ដើម្បីរៀបចំនីតិវិធីក្នុងការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់អធិការការងារ

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីសុវត្ថិភាពការងារក្នុងវិស័យសំណង់ សិប្បកម្មឡឥដ្ឋ សេវាកម្មរ៉ាន្ត និងកសិកម្មដល់ក្រុមអធិការកិច្ចការងារ
- រៀបចំកម្មវិធីសិក្សា មេរៀន ដើម្បីធ្វើការបណ្តុះបណ្តាលវិក្រឹត្យការអធិការការងារ និងអធិការពេទ្យការងារ ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូបង្គោល
- រៀបចំគុណវុឌ្ឍិ កម្មវិធីសិក្សា បណ្តុះបណ្តាល និងទទួលស្គាល់បុគ្គលិកទទួលបន្ទុកផ្នែករដ្ឋបាល និងធនធានមនុស្សប្រចាំសហគ្រាស គ្រឹះស្ថាន

### ៣.៣.២. ការលើកកម្ពស់លក្ខខណ្ឌស្តីពីសុវត្ថិភាពនិងសុខភាពការងារ

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៣.២.ក. អត្រានៃសហគ្រាស គ្រឹះស្ថាន ដែលអនុលោមតាមស្តង់ដាស្នូលសុវត្ថិភាពនិងសុខភាពការងារ កើនឡើង

៣.៣.២.ខ. គោលនយោបាយជាតិ និងច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារ ត្រូវបានអនុម័តមុនដំណាច់ឆ្នាំ២០២៥ ព្រមទាំងក្របខណ្ឌគតិយុត្ត និងនីតិវិធីប្រតិបត្តិស្តង់ដារបស់អង្គភាពដែលអនុវត្តកម្មវិធីនេះ ត្រូវបានពិនិត្យឡើងវិញ រៀបចំ និងធ្វើបច្ចុប្បន្នភាព

៣.៣.២.គ. កម្រងព័ត៌មានជាតិស្តីពីសុវត្ថិភាពនិងសុខភាពការងារ ត្រូវបានធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយជាប្រចាំឆ្នាំជាភាសាខ្មែរ និងអង់គ្លេស

៣.៣.២.ឃ. គ្រប់សហគ្រាស គ្រឹះស្ថាន ដែលបម្រើដល់ការនាំចេញ មានកន្លែងបរិភោគអាហារ និង/ ឬ អាហារដ្ឋានសមរម្យ មុនដំណាច់ឆ្នាំ២០២៥

៣.៣.២.ង. ទារកដ្ឋាននៅក្នុងតំបន់ប្រមូលផ្តុំរោងចក្រ និង/ ឬ សួនឧស្សាហកម្ម/តំបន់សេដ្ឋកិច្ចពិសេស ត្រូវបានរៀបចំ និងកែលម្អឱ្យបានយ៉ាងតិច ១២ ត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពចំនួន ៥ ដូចខាងក្រោម÷

៣.៣.២.១ សិក្សា រៀបចំ អនុម័ត និងពង្រឹងការអនុវត្តគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសុវត្ថិភាពនិងសុខភាពការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ផែនការមេស្តីពីសុវត្ថិភាពនិងសុខភាពការងារ ត្រូវបានធ្វើបច្ចុប្បន្នភាពស្របតាម គោលនយោបាយជាតិស្តីពីសុវត្ថិភាពនិងសុខភាពការងារ
- សូចនាករដែលបានដាក់ចេញក្នុងគោលនយោបាយជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារត្រូវបានអនុវត្តពេញលេញទៅតាមក្របខណ្ឌឆ្នាំនីមួយៗ

- លិខិតបទដ្ឋាន និងគោលការណ៍ណែនាំពាក់ព័ន្ធសុវត្ថិភាពនិងសុខភាពការងារ ត្រូវបានរៀបចំ និងកែសម្រួលយ៉ាងតិច ១៦

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីសុវត្ថិភាពនិងសុខភាពការងារ ដើម្បីឈានទៅអនុម័តដាក់ឱ្យប្រើប្រាស់នៅមុនដំណាច់ឆ្នាំ២០២៥ និងសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារ ដើម្បីឈានទៅអនុម័តឱ្យបានមុនដំណាច់ឆ្នាំ២០២៤
- សិក្សាស្រាវជ្រាវ ចងក្រង ធ្វើបច្ចុប្បន្នភាព និងបោះពុម្ពផ្សព្វផ្សាយ កម្រងព័ត៌មានជាតិស្តីពីសុវត្ថិភាពនិងសុខភាពការងារ ជាភាសារខ្មែរ និងអង់គ្លេស
- រៀបចំ និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសុវត្ថិភាពនិងសុខភាពការងារបន្ទាប់ពី ច្បាប់ស្តីពីសុវត្ថិភាព និងសុខភាពការងារត្រូវបានអនុម័ត
- ធ្វើបច្ចុប្បន្នភាពផែនការមេស្តីពីសុវត្ថិភាពនិងសុខភាពការងារ និងតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយជាតិ ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសុវត្ថិភាពនិងសុខភាពការងារ
- សិក្សាស្រាវជ្រាវ និងរៀបចំគោលការណ៍ណែនាំស្តីពីសុវត្ថិភាពនិងសុខភាពការងារនៅក្នុងវិស័យអាទិភាព ជាអាទិ៍វិស័យកម្មន្តសាល, កសិកម្ម, សិប្បកម្មផលិតឥដ្ឋ, សំណង់ និងឧស្សាហកម្មទេសចរណ៍

៣.៣.២.២ ជំរុញឱ្យមានការរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសុខភាពការងារ (OSH Management System) នៅកម្រិតសហគ្រាស គ្រឹះស្ថាន ឱ្យបានពេញលេញ និងពង្រឹងយន្តការអធិការកិច្ចផ្នែកសុវត្ថិភាពនិងសុខភាពការងារ ដោយរួមបញ្ចូលការពង្រឹងកិច្ចសហប្រតិបត្តការក្នុងក្របខណ្ឌអាស៊ានអូស្ហណេតនិងអន្តរជាតិ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គោលការណ៍ណែនាំស្តីពីការរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារនៅតាមសហគ្រាស គ្រឹះស្ថានត្រូវបានរៀបចំផ្សព្វផ្សាយ និងអនុវត្ត ឱ្យបានមុនដំណាច់ឆ្នាំ២០២៥
- ភាគរយនៃសហគ្រាស គ្រឹះស្ថានដែលមានប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសុខភាពការងារកើនឡើង
- មជ្ឈមណ្ឌលបណ្តុះបណ្តាលសុវត្ថិភាពនិងសុខភាពការងារ ត្រូវបានដាក់ឱ្យដំណើរការចាប់ពីឆ្នាំ២០២៤



ញ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- សិក្សាស្រាវជ្រាវ និងរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពការងារនៅតាមសហគ្រាស គ្រឹះស្ថាន
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យសុវត្ថិភាពនិងសុខភាពការងារ តាមថ្នាលប្រព័ន្ធបច្ចេកវិទ្យាពតិមាន ដើម្បីប្រមូល ចងក្រងពតិមានពាក់ព័ន្ធនឹងសុវត្ថិភាពនិងសុខភាពការងារ ព្រមទាំងសិក្សាលទ្ធភាព ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឬឧបករណ៍ឆ្លាតវៃក្នុងការផ្តល់ដំណឹងជាមុនដោយស្វ័យប្រវត្តិអំពីហានិភ័យការងារ
- ពង្រឹងយន្តការអធិការកិច្ចការងារផ្នែកសុវត្ថិភាពនិងសុខភាពការងារ, បង្កើនសមត្ថភាពមន្ត្រីអធិការកិច្ចការងារផ្នែកសុវត្ថិភាព និងសុខភាពការងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងចូលរួមសកម្មភាពនានាក្នុងក្របខណ្ឌនៃការអនុវត្តផែនការការងារ របស់អាស៊ានអូស្ហណេត (ASEAN-OSH NET Workplan) និងអន្តរជាតិ
- ជំរុញការរៀបចំ និងពង្រឹងសមត្ថភាពក្រុមការងារ ឬគណៈកម្មការសុវត្ថិភាពនិងសុខភាពការងារ ប្រចាំសហគ្រាស គ្រឹះស្ថាន
- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលសុវត្ថិភាពនិងសុខភាពការងារ

៣.៣.២.៣ សិក្សាស្រាវជ្រាវ និងកំណត់អំពីបញ្ជីឈ្មោះជំងឺវិជ្ជាជីវៈ ព្រមទាំងរៀបចំ និងផ្សព្វផ្សាយរបាយការណ៍ស្ថានភាពគ្រោះថ្នាក់ការងារនៅកម្ពុជាជាប្រចាំឆ្នាំ ព្រមទាំងសិក្សាលទ្ធភាពដាក់ឱ្យដំណើរការ មន្ទីរពិសោធន៍តុកស៊ីកូឡូជី (Toxicology) ឱ្យបានមុនដំណាច់ឆ្នាំ២០២៨ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- បញ្ជីឈ្មោះជំងឺវិជ្ជាជីវៈ ត្រូវបានសិក្សា និងកំណត់
- របាយការណ៍ស្ថានភាពគ្រោះថ្នាក់ការងារនៅកម្ពុជាប្រចាំឆ្នាំ ត្រូវបានផលិត និងផ្សព្វផ្សាយជាភាសាខ្មែរ និងអង់គ្លេស
- មន្ទីរពិសោធន៍តុកស៊ីកូឡូជី (Toxicology) ត្រូវបានបង្កើត និងដាក់ឱ្យដំណើការឱ្យបានមុនដំណាច់ឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ប្រមូលទិន្នន័យគ្រោះថ្នាក់ការងារ និងជំងឺ តាមរយៈប្រព័ន្ធទិន្នន័យសុវត្ថិភាពនិងសុខភាពការងារក្នុងថ្នាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីចងក្រងជារបាយការណ៍គ្រោះថ្នាក់ការងារ និងជំងឺ
- សិក្សាស្រាវជ្រាវ និងកំណត់បញ្ជីឈ្មោះជំងឺវិជ្ជាជីវៈស្របតាមបទដ្ឋានរបស់អង្គការអន្តរជាតិខាងការងារ
- រៀបចំ ចងក្រង ផលិត និងផ្សព្វផ្សាយរបាយការណ៍ស្ថានភាពគ្រោះថ្នាក់ការងារនៅកម្ពុជាប្រចាំឆ្នាំ ជាភាសាខ្មែរ និងអង់គ្លេស
- បណ្តុះបណ្តាលគ្រូពេទ្យឯកទេសជំងឺវិជ្ជាជីវៈ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិដើម្បីផ្លាស់ប្តូរបទពិសោធ និងស្វែងយល់អំពីការអនុវត្តល្អៗពាក់ព័ន្ធនឹងការកំណត់អំពីបញ្ជីឈ្មោះជំងឺវិជ្ជាជីវៈ
- សិក្សាស្រាវជ្រាវ រៀបចំលិខិតបទដ្ឋានគតិយុត្ត និងលក្ខណវិនិច្ឆ័យពាក់ព័ន្ធនឹងជំងឺវិជ្ជាជីវៈ និងដំណើរមន្ទីរពិសោធន៍តុកស៊ីកូឡូជី (Toxicology)

៣.៣.២.៤ ពង្រឹង និងពង្រីកការផ្តល់សេវាសាធារណៈឱ្យបានគ្របដណ្តប់ពេញលេញលើគ្រប់វិស័យ និងជំរុញយុទ្ធនាការថ្នាក់ជាតិស្តីពីការលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពនិងសុខភាពការងារ ដោយរួមបញ្ចូលការរៀបចំទិវាពិភពលោក និងសន្និសីទថ្នាក់ជាតិជាប្រចាំឆ្នាំ ព្រមទាំងរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពីសុវត្ថិភាពនិងសុខភាពការងារ សុវត្ថិភាពចំណីអាហារ ការលើកកម្ពស់សុខភាពផ្លូវចិត្ត សុខភាពបន្តពូជ អំពើហិង្សា ការប្រទូស្តកេរខ្មាស ផលប៉ះពាល់នៃគ្រឿងញៀន ការបង្ការជំងឺឆ្លង ជំងឺមិនឆ្លង និងជំងឺរាតត្បាតនានា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនកម្មករនិយោជិត ដែលទទួលសេវាពិនិត្យកាយសម្បទា និងសេវាបញ្ជាក់លើវិញ្ញាបនបត្រពិនិត្យកាយសម្បទា កើនឡើង
- ចំនួនគ្រូពេទ្យសហគ្រាសដែលទទួលបានលិខិតអនុញ្ញាតប្រកបមុខរបរ កើនឡើង
- ចំនួននិយោជក និងតំណាងកម្មករនិយោជិត ដែលទទួលបានការបណ្តុះបណ្តាលសុវត្ថិភាពនិងសុខភាពការងារ កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ត្រួតពិនិត្យ និងកែលម្អជាប្រចាំនូវលក្ខខណ្ឌ និងបែបបទនៃការផ្តល់សេវាសាធារណៈ ផ្នែកសុវត្ថិភាពនិងសុខភាពការងារ ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកផ្តល់សេវាសាធារណៈ ដើម្បីធានាប្រសិទ្ធភាពក្នុងការបំពេញការងារប្រកបដោយវិជ្ជាជីវៈ

- ចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលដៃគូ ព្រមទាំងត្រួតពិនិត្យជាប្រចាំនូវការផ្តល់សេវាពិនិត្យសុខភាពដល់កម្មករនិយោជិត ដោយមូលដ្ឋានសុខាភិបាល ដើម្បីធានាការអនុវត្តឱ្យបានពេញលេញនូវកិច្ចព្រមព្រៀងដែលបានចុះជាមួយនាយកដ្ឋានពេទ្យការងារ
- រៀបចំគុណវុឌ្ឍិ (កញ្ចប់ស្តង់ដាសមត្ថភាព កម្មវិធីសិក្សា កញ្ចប់វាយតម្លៃ និងកញ្ចប់សិក្សា) បណ្តុះបណ្តាល និងទទួលស្គាល់គ្រូបង្គោល ព្រមទាំងរៀបចំគុណវុឌ្ឍិ បណ្តុះបណ្តាល និងទទួលស្គាល់បុគ្គលិកសុខាភិបាលប្រចាំសហគ្រាស គ្រឹះស្ថាន
- រៀបចំទិវាពិភពលោកដើម្បីសុវត្ថិភាពនិងសុខភាពការងារ ២៨ មេសា និងសន្និសីទថ្នាក់ជាតិស្តីពីសុវត្ថិភាពនិងសុខភាពការងារ ជាប្រចាំឆ្នាំ ព្រមទាំងជំរុញការរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពីសុវត្ថិភាពនិងសុខភាពការងារ សុវត្ថិភាពចំណីអាហារ ការលើកកម្ពស់សុខភាពផ្លូវចិត្ត សុខភាពបន្តពូជ អំពើហិង្សា ការប្រទូស្តកេរខ្មាស ផលប៉ះពាល់នៃគ្រឿងញៀន ការបង្ការជំងឺឆ្លង ជំងឺមិនឆ្លង និងជំងឺរាតត្បាតនានា
- បណ្តុះបណ្តាលគ្រូបង្គោល និងកម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈកម្មវិធីនៃការកែលម្អរបៀបធ្វើការងារនៅតាមសហគ្រាសខ្នាតតូច (Work Improvement in Small Enterprises-WISE), ការកែលម្អរបៀបធ្វើការងារ និងអភិវឌ្ឍភូមិដ្ឋាន (Work Improvement in Neighborhood Development-WIND), ការកែលម្អរបៀបធ្វើការងារដើម្បីសុវត្ថិភាពអ្នកប្រកបការងារនៅតាមផ្ទះ (Work Improvement for Safe Home-DISH), ការកែលម្អរបៀបធ្វើការងារសម្រាប់យុវជន (Work Improvement in Neighborhood Development for Youth-WINDY), ការកែលម្អរបៀបធ្វើការងារនៅតាមការដ្ឋានសំណង់ខ្នាតតូច (Work Improvement at Small Construction Sites-WISCON) និងការកែលម្អរបៀបធ្វើការក្នុងការគ្រប់គ្រង និងប្រើប្រាស់ឡើងវិញ នូវកាកសំណល់ (Work Adjustment for Recycling and Managing Waste-WARM)

៣.៣.២.៥ ជំរុញការរៀបចំកន្លែងបរិភោគអាហារ និង/ ឬ អាហារដ្ឋានសមរម្យសម្រាប់កម្មករនិយោជិតទារកដ្ឋាននិងមត្តេយ្យសហគមន៍នៅក្នុងតំបន់ប្រមូលផ្តុំរោងចក្រ និង/ ឬ សួនឧស្សាហកម្ម/ តំបន់សេដ្ឋកិច្ចពិសេស ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គោលការណ៍ណែនាំស្តីពីការរៀបចំកន្លែងបរិភោគអាហារ និង/ឬអាហារដ្ឋានសម្រាប់កម្មករនិយោជិតត្រូវបានរៀបចំ ផ្សព្វផ្សាយ និងអនុវត្ត

- គោលការណ៍ណែនាំស្តីពីបទដ្ឋានស្តង់ដាទារកដ្ឋានសហគមន៍ ត្រូវបានរៀបចំ និងអនុវត្ត ឱ្យបានមុនដំណាច់ឆ្នាំ២០២៤
- គោលការណ៍ណែនាំស្តីពីបទដ្ឋានស្តង់ដាមត្តេយ្យសហគមន៍ ត្រូវបានរៀបចំ និងអនុវត្ត ឱ្យបានមុនដំណាច់ឆ្នាំ២០២៤

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំសេចក្តីព្រាងអនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំពាក់ព័ន្ធទារកដ្ឋានសហគមន៍ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- រៀបចំគោលការណ៍ណែនាំស្តីពីកន្លែងបរិភោគអាហារ និង/ឬអាហារដ្ឋានសមរម្យ សម្រាប់កម្មករនិយោជិត ជាពិសេសជំរុញឱ្យមានការរៀបចំនៅក្នុងចំណោមសហគ្រាស គ្រឹះស្ថានដែលបម្រើដល់ការនាំចេញ
- សិក្សាលទ្ធភាពក្នុងការលើកទឹកចិត្តដល់សហគ្រាស គ្រឹះស្ថានដែលបានរៀបចំកន្លែងបរិភោគអាហារ និង/ឬអាហារដ្ឋានសមរម្យសម្រាប់កម្មករនិយោជិត និងចូលរួមអនុវត្តគោលការណ៍ណែនាំពាក់ព័ន្ធទារកដ្ឋានសហគមន៍ និងមត្តេយ្យសហគមន៍នៅក្នុងតំបន់ប្រមូលផ្តុំរោងចក្រ និង/ ឬ សួនឧស្សាហកម្ម/តំបន់សេដ្ឋកិច្ចពិសេស
- សិក្សា និងរៀបចំឱ្យមានយន្តការក្នុងការវិនិយោគ បង្កើត គ្រប់គ្រង និងធានាឱ្យមាននិរន្តរភាពនៃដំណើរការទារកដ្ឋាន និងមត្តេយ្យសហគមន៍

### ៣.៣.៣. ការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៣.៣.ក. ផែនការសកម្មភាពជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាព

៣.៣.៣.ខ. គ្រប់និយោជក និងអាណាព្យាបាល ដែលជាកម្មករនិយោជិត ធ្វើការក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្មផ្នែក ស្ករអំពៅ ដំឡូងមី ចេក កៅស៊ូ ស្វាយចន្ទី បានចុះកិច្ចសន្យាស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារឱ្យបាន ត្រឹមចុងឆ្នាំ២០២៨

៣.៣.៣.គ. ១០០% នៃបណ្តឹងពាក់ព័ន្ធការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានចាត់វិធានការ/អន្តរាគមន៍ ក្នុងរយៈពេល ២៤ម៉ោង

៣.៣.៣.ឃ. អត្រានៃសហគ្រាស គ្រឹះស្ថាន ដែលប្រើប្រាស់កម្មករនិយោជិតវ័យក្មេងមិនបានត្រឹមត្រូវ ត្រូវបានពិន័យ និងចាត់វិធានការតាមច្បាប់យ៉ាងម៉ឺងម៉ាត់ ដោយមិនមានការលើកលែង

៣.៣.៣.ង. របាយការណ៍លទ្ធផលនៃការអនុវត្តការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានទទួលស្គាល់ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ ជាភាសាខ្មែរ និងអង់គ្លេស

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៣.៣.១ រៀបចំ និងធ្វើបច្ចុប្បន្នភាពក្របខណ្ឌគោលនយោបាយ ផែនការសកម្មភាពជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ផែនការសកម្មភាពជាតិ ស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០២៦-២០៣៥ ត្រូវបានដាក់ឱ្យអនុវត្តនៅដើមឆ្នាំ២០២៦
- ប្រកាសពាក់ព័ន្ធនឹងការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានរៀបចំ និងកែសម្រួលយ៉ាងតិច ៦ ត្រឹមដំណាច់ឆ្នាំ២០២៨
- គោលការណ៍ណែនាំស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារក្នុងវិស័យការងារប្រកបដោយគ្រោះថ្នាក់យ៉ាងតិច ១/ឆ្នាំ ត្រូវបានរៀបចំ និងផ្សព្វផ្សាយ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០២៦-២០៣៥
- រៀបចំ និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគិតិយុត្តដែលពាក់ព័ន្ធ ជាពិសេសប្រកាសស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករនិយោជិតវ័យក្មេង តាមនិយាមកំណត់អាយុយ៉ាងតិច ១៦ឆ្នាំ និងរៀបចំប្រកាសស្តីពី ការងារហាមឃាត់កម្មករនិយោជិតវ័យក្មេងអាយុក្រោម ១៨ឆ្នាំ ធ្វើការក្នុងសហគ្រាស គ្រឹះស្ថានផលិតផលិតផលនាំចេញ
- សិក្សាស្រាវជ្រាវ រៀបចំ ផ្សព្វផ្សាយ និងជំរុញការអនុវត្តគោលការណ៍ណែនាំស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារក្នុងវិស័យការងារប្រកបដោយគ្រោះថ្នាក់

- សិក្សា និងកំណត់ប្រភេទការងារ និងលក្ខខណ្ឌការងារសម្រាប់កម្មករនិយោជិតវ័យក្មេង ស្របតាមការវិវត្តថ្មីនៃពិភពការងារ
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីប្រមូលធាតុចូលពីភាគីពាក់ព័ន្ធលើការផ្តួចផ្តើម និងកែលម្អលើក្របខណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

៣.៣.៣.២ ការលើកកម្ពស់ការអប់រំ និងការផ្សព្វផ្សាយស្តីពីលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- យុទ្ធនាការជាតិ ស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃ ពលកម្មកុមារ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានរៀបចំប្រចាំឆ្នាំ
- ចំនួនវេទិកាផ្សព្វផ្សាយដល់ទីតាំងផលិតកម្ម ដើម្បីលើកកម្ពស់ការយល់ដឹងពីការហាមឃាត់ការប្រើប្រាស់ពលកម្មកុមារ ដល់និយោជក និងអាណាព្យាបាលដែលជាកម្មករនិយោជិតដែលធ្វើការក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្មត្រូវបានរៀបចំ យ៉ាងតិច ២៤០ទីតាំង/ឆ្នាំ
- វគ្គបណ្តុះបណ្តាលស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យ៉ាងតិច ១ដង/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងអនុវត្តផែនការនៃការអនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង អប់រំ និងផ្សព្វផ្សាយ ព្រមទាំងយុទ្ធនាការជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំផែនការអនុវត្តវេទិកាផ្សព្វផ្សាយដល់ទីតាំងផលិតកម្មដើម្បីលើកកម្ពស់ការយល់ដឹងពីការហាមឃាត់ការប្រើប្រាស់ពលកម្មកុមារ ដល់និយោជក និងអាណាព្យាបាលដែលជាកម្មករនិយោជិត ព្រមទាំងការចុះកិច្ចសន្យាជាមួយអធិការកិច្ចការងារក្នុងការយល់ព្រមទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ
- រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រី និងភាគីពាក់ព័ន្ធស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បង្កើតមធ្យោបាយ និងផលិតសម្ភារ និងឧបករណ៍សម្រាប់ផ្សព្វផ្សាយស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

- រៀបចំសេវាលើកកម្ពស់ការយល់ដឹងតាមរយៈ ប្រព័ន្ធជូនដំណឹងជាសាធារណៈ បណ្តាញសង្គមនានា និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដោយបញ្ជ្រាបខ្លឹមសារអប់រំ និងផ្សព្វផ្សាយដល់សហគមន៍ និងភាគីពាក់ព័ន្ធ ស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅកម្ពុជា

៣.៣.៣.៣ ការពង្រឹងការអនុវត្តច្បាប់ តាមរយៈវិធានការអធិការកិច្ចការងារ យន្តការទទួលពាក្យបណ្តឹង និងអន្តរាគមន៍ លើករណីបទល្មើសពាក់ព័ន្ធនឹងការប្រើប្រាស់ពលកម្មកុមារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ក្រុមការងារអន្តរាគមន៍ចំនួន ៦ ត្រូវបានបង្កើត
- គោលការណ៍ណែនាំស្តីពីកិច្ចអន្តរាគមន៍ អំពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានរៀបចំ និងអនុម័ត
- យន្តការទទួលពាក្យបណ្តឹងនៃការប្រើប្រាស់ពលកម្មកុមារត្រូវបានបង្កើត និងដំណើរការនៅឆ្នាំ២០២៤

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំក្រុមអន្តរាគមន៍អំពីការប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ព្រមទាំងរៀបចំគោលការណ៍ណែនាំស្តីពីកិច្ចអន្តរាគមន៍ អំពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- រៀបចំយន្តការទទួលពាក្យបណ្តឹង និងទទួលសេចក្តីរាយការណ៍ករណីសង្ស័យ ឬបទល្មើសពាក់ព័ន្ធនឹងការប្រើប្រាស់ពលកម្មកុមារ
- ចុះធ្វើអធិការកិច្ចការងារដោយមិនជូនដំណឹង ដើម្បីអង្កេត និងកសាងសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសប្រើប្រាស់ពលកម្មកុមារ
- ផាកពិន័យ ករណីសហគ្រាស គ្រឹះស្ថាន មិនអនុលោមតាមច្បាប់ស្តីពីការងារ ពិសេសករណីប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងការប្រើប្រាស់ពលកម្មកុមារ ព្រមទាំងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ចដោយគ្មានករណីលើកលែង
- តាមរយៈការវាយតម្លៃ សហគ្រាស ចូលរួមជំរុញការអនុវត្តយុទ្ធនាការប្រឡងប្រណាំង "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ" គ្រឹះស្ថាន ដែលមិនប្រើប្រាស់ពលកម្មកុមារស្របតាមការកំណត់លក្ខណវិនិច្ឆ័យ

៣.៣.៣.៤ ការអនុវត្តកិច្ចអន្តរាគមន៍ស្នូលដើម្បីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ការចុះអនុវត្តកញ្ចប់កិច្ចអន្តរាគមន៍ស្នូល យ៉ាងតិច ៦ដង/ឆ្នាំ
- ទិន្នន័យស្តីពីពលកម្មកុមារនៅក្នុងវិស័យដែលមានហានិភ័យខ្ពស់ត្រូវបានចងក្រង និងធ្វើបច្ចុប្បន្នភាពជាប្រចាំ
- កិច្ចប្រជុំវាយតម្លៃទៅលើប្រសិទ្ធភាពនៃនីតិវិធី និងការអនុវត្តកិច្ចអន្តរាគមន៍ស្នូល យ៉ាងតិច ២លើក/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ប្រមូល ចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងកុមារដែលងាយរងហានិភ័យទៅតាមវិស័យដែលមានហានិភ័យខ្ពស់
- កំណត់វិស័យអាទិភាព តំបន់អាទិភាព និងកំណត់អត្តសញ្ញាណកុមារងាយរងគ្រោះដើម្បីទទួលបានកិច្ចអន្តរាគមន៍ស្នូល
- រៀបចំយន្តការ វិធានការ និងគោលដៅ នៃការអនុវត្តកិច្ចអន្តរាគមន៍ស្នូល
- ពង្រឹងសមត្ថភាពនៃមន្ត្រីអនុវត្តកិច្ចអន្តរាគមន៍ស្នូលនៅថ្នាក់ជាតិ ក្រោមជាតិ និងនៅសហគមន៍
- ចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តកិច្ចអន្តរាគមន៍ស្នូល និងរៀបចំរបាយការណ៍

៣.៣.៣.៥ កិច្ចសហការជាមួយក្រសួង-ស្ថាប័ន និងពង្រីកភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ និងអង្គការនានា ដើម្បីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនរាជធានីខេត្តដែលបានបង្កើតគណៈកម្មការប្រឆាំងពលកម្មកុមារ និងបានរៀបចំផែនការសកម្មភាពការងារស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- ចំនួនជនបង្គោលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងជនបង្គោលតាមសហគមន៍ត្រូវបានរៀបចំនៅគ្រប់រាជធានីខេត្តត្រឹមឆ្នាំ២០២៦
- របាយការណ៍លទ្ធផលនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ពង្រឹងយន្តការ ធ្វើបច្ចុប្បន្នភាព និងពង្រីកវិសាលភាពតួនាទីនៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ (គ.ជ.ព.) គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានី ខេត្ត អនុគណៈកម្មការជំនាញតាមវិស័យ
- ពង្រឹង និងកសាងសមត្ថភាព មន្ត្រីនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ(អ.គ.ជ.ព.) គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្ត អនុគណៈកម្មការជំនាញតាមវិស័យ ជនបង្គោលតាមសហគមន៍ ដើម្បីបង្កើតផែនការសកម្មភាពរាជធានី ខេត្ត និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- លើកកម្ពស់ការផ្សព្វផ្សាយ និងជំរុញចលនាសង្គមប្រឆាំងពលកម្មកុមារ តាមរយៈការរៀបចំទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា រៀងរាល់ឆ្នាំ
- រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ កិច្ចប្រជុំដើម្បីតាមដានការអនុវត្តផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ យ៉ាងតិច ២ដង/ឆ្នាំ និងកិច្ចប្រជុំដើម្បីអនុម័តរបាយការណ៍វឌ្ឍនភាព
- រៀបចំយុទ្ធនាការផ្សព្វផ្សាយ ឬសិក្ខាសាលាផ្សព្វផ្សាយស្តីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅថ្នាក់ជាតិ និងក្រោមជាតិ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងអង្គការនានា

**៣.៣.៤. ការពង្រឹងសមត្ថភាពស្ថាប័ន និងតួអង្គពាក់ព័ន្ធក្នុងការពិភាក្សា កំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត**

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៣.៤.ក. ប្រាក់ឈ្នួលអប្បបរមាត្រូវបានពិភាក្សា និងកំណត់រៀងរាល់ឆ្នាំ ស្របតាមច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា

៣.៣.៤.ខ. អត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិត ត្រូវបានសិក្សា និងវាយតម្លៃ រៀងរាល់ឆ្នាំ

៣.៣.៤.គ. របាយការណ៍សិក្សាលទ្ធភាពពង្រីកវិសាលភាពប្រាក់ឈ្នួលអប្បបរមាទៅវិស័យផ្សេងៗ ត្រូវបានផលិត

៣.៣.៤.ឃ. របាយការណ៍តាមដានបម្រែបម្រួលលក្ខណវិនិច្ឆ័យបែបសង្គមនិងសេដ្ឋកិច្ច និងប្រាក់ឈ្នួលអប្បបរមានៅតាមបណ្តាប្រទេសនានា ត្រូវបានរៀបចំ និងផ្សព្វផ្សាយ រៀងរាល់ខែ

៣.៣.៤.ង. អត្រាអនុលោមភាពនៃការអនុវត្តប្រាក់ឈ្នួលអប្បបរមា ត្រូវបានតាមដាន និងធានា ១០០%



ហ

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៣.៤.១ សិក្សា អង្កេត ស្រាវជ្រាវ និងធ្វើបច្ចុប្បន្នភាព លក្ខណវិនិច្ឆ័យបែបសង្គមនិងសេដ្ឋកិច្ច ព្រមទាំងសិក្សាលទ្ធភាពក្នុងការបង្កើតសន្ទស្សន៍សមាសធាតុលក្ខណវិនិច្ឆ័យ (Composite Index) សម្រាប់វាស់វែងឱ្យកាន់តែងាយស្រួល ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- មូលដ្ឋានទិន្នន័យនៃបម្រែបម្រួលលក្ខណវិនិច្ឆ័យបែបសេដ្ឋកិច្ច និងសង្គម ត្រូវបានធ្វើបច្ចុប្បន្នភាពប្រចាំខែ
- របាយការណ៍លទ្ធផលអង្កេតស្តីពីស្ថានភាពចំណាយ និងជីវភាពរបស់កម្មករនិយោជិត ត្រូវបានផលិតប្រចាំឆ្នាំ
- របាយការណ៍វឌ្ឍនភាពនៃការសិក្សាលទ្ធភាព ក្នុងការបង្កើតសន្ទស្សន៍សមាសធាតុលក្ខណវិនិច្ឆ័យ (Composite Index) ត្រូវបានផលិត

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- បន្តធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ របស់លក្ខណវិនិច្ឆ័យបែបសង្គមនិងសេដ្ឋកិច្ចប្រចាំខែ
- រៀបចំធ្វើអង្កេតលើស្ថានភាពចំណាយ និងជីវភាពរបស់កម្មករនិយោជិតប្រចាំឆ្នាំ ដើម្បីជាធាតុចូលសម្រាប់ការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា
- សិក្សាលទ្ធភាពក្នុងការបង្កើតសន្ទស្សន៍សមាសធាតុលក្ខណវិនិច្ឆ័យ និងរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស
- រៀបចំកិច្ចប្រជុំបច្ចេកទេស ដើម្បីពិភាក្សាលទ្ធភាពបង្កើតសន្ទស្សន៍សមាសធាតុ និងបច្ចុប្បន្នភាព លក្ខណវិនិច្ឆ័យបែបសង្គមនិងសេដ្ឋកិច្ច
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគី អំពីការបង្កើតសន្ទស្សន៍សមាសធាតុ និងបច្ចុប្បន្នភាពលក្ខណវិនិច្ឆ័យបែបសង្គមនិងសេដ្ឋកិច្ច

៣.៣.៤.២ ពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា និងរៀបចំកិច្ចប្រជុំពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាក្នុងក្របខណ្ឌយន្តការត្រីភាគីឱ្យបានទៀងទាត់ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម ÷

- ចំនួនកិច្ចប្រជុំពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា ត្រូវបានរៀបចំយ៉ាងតិច ១៦ដង/ឆ្នាំ
- ចំនួនវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ត្រូវបានរៀបចំ

- របាយការណ៍លទ្ធផលសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីស្តីពីប្រាក់ឈ្នួលអប្បបរមា ត្រូវបានរៀបចំ យ៉ាងតិច ១ដង/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម៖

- រៀបចំប្រកាសស្តីពីសមាសភាពក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា រៀងរាល់ ២ឆ្នាំម្តង
- សិក្សាតម្រូវការបណ្តុះបណ្តាលពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា
- រៀបចំវគ្គបណ្តុះបណ្តាលគាំទ្រដល់សមាជិកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដោយសហការជាមួយដៃគូពាក់ព័ន្ធ ជាពិសេសអង្គការអន្តរជាតិខាងការងារ (ILO)
- រៀបចំសិក្ខាសាលាត្រីភាគី ស្តីពីបច្ចុប្បន្នភាពលក្ខណវិនិច្ឆ័យបែបសង្គមនិងសេដ្ឋកិច្ច ដោយមានការចូលរួមពីអ្នកជំនាញក្រសួង ស្ថាប័ន និងដៃគូជាតិ អន្តរជាតិពាក់ព័ន្ធ
- រៀបចំកិច្ចប្រជុំពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាក្រោមយន្តការត្រីភាគី យ៉ាងតិច ១៦ដង/ឆ្នាំ

៣.៣.៤.៣ សិក្សា អង្កេត ប្រមូល និងចងក្រងមូលដ្ឋានទិន្នន័យ អំពីប្រាក់ឈ្នួលតាមវិស័យនីមួយៗ ព្រមទាំងសិក្សាវិភាគលើបច្ច័យផលនៃបម្រែបម្រួលប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម៖

- មូលដ្ឋានទិន្នន័យអំពីប្រាក់ឈ្នួលតាមវិស័យនីមួយៗនៅកម្ពុជា ត្រូវបានប្រមូល និងចងក្រង
- របាយការណ៍លទ្ធផលអង្កេត ស្តីពីប្រាក់ឈ្នួលតាមវិស័យនៅកម្ពុជា ត្រូវបានផលិត
- របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីបម្រែបម្រួលលក្ខណវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ច និងប្រាក់ឈ្នួលអប្បបរមានៅតាមបណ្តាប្រទេសនានា ត្រូវបានផលិត

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម៖

- រៀបចំអង្កេត ស្រាវជ្រាវ ប្រមូល និងចងក្រងទិន្នន័យ ស្តីពីប្រាក់ឈ្នួលតាមវិស័យនីមួយៗ នៅកម្ពុជា
- រៀបចំសិក្ខាសាលាបច្ចេកទេស និងផ្សព្វផ្សាយលទ្ធផលនៃការអង្កេតប្រាក់ឈ្នួលតាមវិស័យនីមួយៗនៅកម្ពុជា
- រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស អំពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើបម្រែបម្រួល និងឥទ្ធិពលនៃប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា

- រៀបចំម៉ូឌែលសេដ្ឋកិច្ចសម្រាប់ការសិក្សា វិភាគ និងព្យាករ លើបច្ច័យផលនៃបម្រែបម្រួលប្រាក់ឈ្នួលអប្បបរមា
- ធ្វើបច្ចុប្បន្នភាពរបាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ អំពីបម្រែបម្រួលលក្ខណវិនិច្ឆ័យបែបសង្គមនិងសេដ្ឋកិច្ច និងប្រាក់ឈ្នួលអប្បបរមា

៣.៣.៤.៤ តាមដានការអនុវត្តប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ ព្រមទាំងបង្កើនការផ្សព្វផ្សាយ យល់ដឹងអំពីប្រាក់ឈ្នួលអប្បបរមាដល់សាធារណជន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនសិក្ខាសាលាផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីប្រាក់ឈ្នួលអប្បបរមាដល់សិស្ស និស្សិត កម្មករនិយោជិត និងសាធារណជន
- ចំនួនសៀវភៅទិន្នានុលេខន៍ដោយភ្ជាប់អំពីយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា និងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា
- អត្រាអនុលោមភាពនៃការអនុវត្តប្រាក់ឈ្នួលអប្បបរមា បានត្រឹមត្រូវ ១០០% ក្នុងរបាយការណ៍អធិការកិច្ចការងារ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីប្រាក់ឈ្នួលអប្បបរមា ដល់សិស្សនិស្សិត កម្មករនិយោជិត និងសាធារណជន
- រៀបចំបោះពុម្ពសៀវភៅទិន្នានុលេខន៍ ដោយភ្ជាប់អំពីយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា និងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា
- ផលិតមាតិកា និងផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងអំពីប្រាក់ឈ្នួលអប្បបរមា
- រៀបចំសៀវភៅដំណើរឆ្ពោះទៅការយល់ដឹងថ្មី ស្តីពីយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា
- តាមដាន និងធានាការអនុវត្តប្រាក់ឈ្នួលអប្បបរមា ដោយផ្អែកលើអត្រាអនុលោមភាពបើកប្រាក់ឈ្នួលក្នុងរបាយការណ៍អធិការកិច្ចការងារ

៣.៣.៤.៥ សិក្សា និងពិនិត្យលទ្ធភាពពង្រីកវិសាលភាពប្រាក់ឈ្នួលអប្បបរមាទៅវិស័យផ្សេងៗ និងសិក្សាស្រាវជ្រាវគោលនយោបាយប្រាក់ឈ្នួលអប្បបរមានៅតាមបណ្តាប្រទេសនានា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍លទ្ធផលនៃការសិក្សាលទ្ធភាព នៃវិស័យដែលអាចអនុវត្តប្រាក់ឈ្នួលអប្បបរមា និងគោលនយោបាយប្រាក់ឈ្នួលអប្បបរមា នៅបណ្តាប្រទេសនានា ត្រូវបានផលិត
- ចំនួនសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីលើលទ្ធភាព នៃការពង្រីកវិសាលភាពប្រាក់ឈ្នួលអប្បបរមា ត្រូវបានរៀបចំ
- វិស័យថ្មីដែលអាចអនុវត្តប្រាក់ឈ្នួលអប្បបរមា ត្រូវបានកំណត់ និងសិក្សាលម្អិត ដោយសហការជាមួយដៃគូពាក់ព័ន្ធ ជាពិសេសអង្គការអន្តរជាតិខាងការងារ (ILO)

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- សិក្សា និងផ្សព្វផ្សាយគោលនយោបាយប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍តាមបណ្តាប្រទេសនានា
- រៀបចំទស្សនកិច្ចសិក្សាក្រៅប្រទេសដើម្បីដកស្រង់បទពិសោធ យ៉ាងតិច ១លើក/ឆ្នាំ
- រៀបចំកិច្ចប្រជុំបច្ចេកទេស ដើម្បីពិភាក្សាអំពីការសិក្សា ស្រាវជ្រាវ និងវាយតម្លៃលទ្ធភាពនៃការពង្រីកវិសាលភាពប្រាក់ឈ្នួលអប្បបរមាទៅវិស័យផ្សេងៗ
- រៀបចំអង្កេត សិក្សា ស្រាវជ្រាវ និងវាយតម្លៃលទ្ធភាពនៃវិស័យដែលអាចអនុវត្តប្រាក់ឈ្នួលអប្បបរមា
- សហការជាមួយភាគីពាក់ព័ន្ធ ជាពិសេសអង្គការអន្តរជាតិខាងការងារ (ILO) ដើម្បីរៀបចំសិក្ខាសាលាពិគ្រោះយោបល់អំពីលទ្ធភាពនៃការពង្រីកវិសាលភាពប្រាក់ឈ្នួលអប្បបរមា

### ៣.៣.៥. ការលើកកម្ពស់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ដើម្បីប្រែក្លាយសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៣.៥.ក. ការជ្រើសរើសសហគ្រាស គ្រឹះស្ថានដើម្បីទទួលពានរង្វាន់ "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ" ត្រូវបានរៀបចំជាប្រចាំឆ្នាំ

៣.៣.៥.ខ. អត្រាវិវាទការងារដែលផ្សះផ្សាសះជាដោយមន្ត្រីផ្សះផ្សា និងដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានរក្សាក្នុងអត្រា យ៉ាងតិច ៨៥%

៣.៣.៥.គ. ពង្រឹងទំនាក់ទំនងវិជ្ជាជីវៈតាមរយៈជំនួបប្រចាំត្រីមាសជាមួយអង្គការវិជ្ជាជីវៈ និងបុគ្គលិកទទួលបន្ទុកផ្នែករដ្ឋបាលនិងធនធានមនុស្ស និងការបង្កើតមូលនិធិអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ

៣.៣.៥.ឃ. របាយការណ៍ស្តីពីសេរីភាពអង្គការវិជ្ជាជីវៈ ត្រូវបានរៀបចំ និងផ្សព្វផ្សាយប្រចាំឆ្នាំ ជាភាសាខ្មែរ និងអង់គ្លេស

៣.៣.៥.ង. រាល់ករណី កូដកម្ម និងបាតុកម្ម ត្រូវបានអន្តរាគមន៍ និងដោះស្រាយដោយសន្តិវិធី និងគណនេយ្យភាពស្របតាមច្បាប់

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៣.៥.១ ពង្រឹងយន្តការបង្ការ ទប់ស្កាត់ និងដោះស្រាយវិវាទការងារនៅគ្រប់ដំណាក់កាល ព្រមទាំងជំរុញការដាក់ឱ្យដំណើរការតុលាការការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- អត្រានៃសហគ្រាស គ្រឹះស្ថាន ដែលកើតមានវិវាទការងាររួម ត្រូវបានរក្សានៅកម្រិតទាបក្រោម ១%
- រាល់ករណីកូដកម្ម និងបាតុកម្ម ត្រូវបានទទួលព័ត៌មាន និងអន្តរាគមន៍ក្នុងរយៈពេល ២៤ម៉ោង
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដោះស្រាយវិវាទការងារ និងសេរីភាពអង្គការវិជ្ជាជីវៈ យ៉ាងតិច ៥ ត្រូវបានធ្វើបច្ចុប្បន្នភាព

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- អភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងដំណើរការដោះស្រាយវិវាទការងារ តាមប្រព័ន្ធឌីជីថល ដោយពង្រឹងមុខងារគ្រប់គ្រងទិន្នន័យអង្គការវិជ្ជាជីវៈ និងសំណុំរឿងវិវាទការងារ
- ធ្វើបច្ចុប្បន្នភាពសារាចរស្តីពីការចាត់តាំងបុគ្គលិកទំនាក់ទំនង ដោយតម្រូវឱ្យគ្រប់សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតលើសពី ១០នាក់ ត្រូវចាត់តាំងឱ្យមានបុគ្គលិកទំនាក់ទំនងសម្រាប់ដោះស្រាយវិវាទការងារ
- ពង្រឹងយន្តការដោះស្រាយកូដកម្ម បាតុកម្មនៅតាមរាជធានី ខេត្ត តាមរយៈការប្រមូលព័ត៌មាន និងដោះស្រាយកូដកម្ម បាតុកម្មនៅតាមរាជធានី ខេត្ត ឱ្យមានប្រសិទ្ធភាពខ្ពស់ និងការកំណត់វេនការងារសម្រាប់អន្តរាគមន៍ ៧ថ្ងៃ លើ ៧ថ្ងៃ
- ធ្វើបច្ចុប្បន្នភាពប្រកាសស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម និងប្រកាសស្តីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល ប្រកាសស្តីពីការចុះបញ្ជីសហជីព និងសមាគមនិយោជក ប្រកាសស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទនិងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត ព្រមទាំងសហការរៀបចំក្នុងការដាក់ឱ្យដំណើរការតុលាការការងារ
- ជំរុញ និងសហការជាមួយរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងអាជ្ញាធរពាក់ព័ន្ធក្នុងការពង្រឹងយន្តការដោះស្រាយកូដកម្ម បាតុកម្មនៅតាមរាជធានី ខេត្ត

៣.៣.៥.២ ពង្រឹងសមត្ថភាព និងធ្វើវិជ្ជាជីវៈនីយកម្មមន្ត្រីផ្សះផ្សាវិវាទការងារ អាជ្ញាកណ្តាល និងបុគ្គលទទួលបន្ទុកផ្នែករដ្ឋបាលនិងធនធានមនុស្សនៅតាមសហគ្រាស គ្រឹះស្ថាន ព្រមទាំងអភិវឌ្ឍសមត្ថភាព និងតួនាទីថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ និងតំណាងកម្មករនិយោជិត ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនមន្ត្រីផ្សះផ្សា និងអាជ្ញាកណ្តាលដែលត្រូវបានធ្វើវិជ្ជាជីវៈនីយកម្ម កើនដល់ ៣០០នាក់ ត្រឹមឆ្នាំ២០២៨
- គ្រប់មន្ត្រីផ្សះផ្សាអនុវត្តតាមគោលការណ៍ណែនាំស្តីពីវិធានការវិវាទការងារ និងក្រមសីលធម៌សម្រាប់មន្ត្រីផ្សះផ្សា
- ចំនួនវគ្គបណ្តុះបណ្តាលបុគ្គលទទួលបន្ទុកផ្នែករដ្ឋបាល និងធនធានមនុស្សនៅតាមសហគ្រាស គ្រឹះស្ថាន ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ និងតំណាងកម្មករនិយោជិត យ៉ាងតិច ២០វគ្គ/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំគុណវុឌ្ឍិ (កញ្ចប់ស្តង់ដាសមត្ថភាព កញ្ចប់សិក្សា កញ្ចប់វាយតម្លៃ និងកម្មវិធីសិក្សា) បណ្តុះបណ្តាល និងការទទួលស្គាល់ គ្រូបង្គោល និងមន្ត្រីផ្សះផ្សា
- រៀបចំគុណវុឌ្ឍិ (កញ្ចប់ស្តង់ដាសមត្ថភាព កញ្ចប់សិក្សា កញ្ចប់វាយតម្លៃ និងកម្មវិធីសិក្សា) បណ្តុះបណ្តាល និងការទទួលស្គាល់ អាជ្ញាកណ្តាល
- រៀបចំ ជំរុញការអនុវត្ត និងតាមដានការអនុវត្តគោលការណ៍ណែនាំស្តីពីវិធានការវិវាទការងារ និងក្រមសីលធម៌សម្រាប់មន្ត្រីផ្សះផ្សា
- ពង្រឹងសមត្ថភាពបុគ្គលទទួលបន្ទុកផ្នែករដ្ឋបាល និងធនធានមនុស្សនៅតាមសហគ្រាស គ្រឹះស្ថាន ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ និងតំណាងកម្មករនិយោជិត (ជាពិសេសប្រតិភូបុគ្គលិក)
- រៀបចំផលិត ឧបករណ៍ សម្ភារផ្សព្វផ្សាយ និងខិតប័ណ្ណ ដើម្បីផ្សព្វផ្សាយដល់កម្មករនិយោជិតអំពីសិទ្ធិក្នុងការចូលរួម ឬមិនចូលរួមក្នុងអង្គការវិជ្ជាជីវៈ និងតួនាទីស្របច្បាប់របស់តំណាងកម្មករនិយោជិត

៣.៣.៥.៣ សិក្សា និងរៀបចំគោលនយោបាយអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ និងបង្កើតមូលនិធិអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ ព្រមទាំងសន្និសីទទំនាក់ទំនងវិជ្ជាជីវៈ ដើម្បីលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គោលនយោបាយអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ ត្រូវបានអនុម័តឆ្នាំ២០២៤
- មូលនិធិអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ ត្រូវបានដាក់ឱ្យដំណើរការក្នុងឆ្នាំ២០២៦
- វេទិកាទិវាពលកម្មអន្តរជាតិ ១ ឧសភា និងសន្និសីទទំនាក់ទំនងវិជ្ជាជីវៈ ត្រូវបានរៀបចំជាប្រចាំឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- សិក្សា និងរៀបចំគោលនយោបាយអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ ដោយសហការជាមួយដៃគូពាក់ព័ន្ធ
- សម្របសម្រួលរៀបចំផែនការសកម្មភាពក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ ព្រមទាំងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយ
- សិក្សា និងរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងការបង្កើត និងដំណើរការមូលនិធិអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ
- រៀបចំវេទិកាទិវាពលកម្មអន្តរជាតិ ១ ឧសភា និងសន្និសីទទំនាក់ទំនងវិជ្ជាជីវៈ ជាប្រចាំឆ្នាំ
- ជំរុញការប្រើប្រាស់មូលនិធិទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការលើកកម្ពស់ការយល់ដឹងអំពីការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់អង្គការវិជ្ជាជីវៈ និងសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពផ្សេងៗ ដល់សហជីព

៣.៣.៥.៤ ពង្រឹងយន្តការត្រីភាគី និងកិច្ចសន្ទនាសង្គម ព្រមទាំងជំរុញយុទ្ធនាការថ្នាក់ជាតិស្តីពី“សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ” ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- ចំនួនសហគ្រាស គ្រឹះស្ថាន ដែលបានបំពេញលក្ខណវិនិច្ឆ័យក្នុងការទទួលបានពានរង្វាន់ និងវិញ្ញាបនបត្រ “សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ” កើនឡើង
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធយន្តការត្រីភាគី ត្រូវបានធ្វើបច្ចុប្បន្នភាព
- ជំនួបប្រចាំត្រីមាសជាមួយអង្គការវិជ្ជាជីវៈ និងបុគ្គលិកទទួលបន្ទុកផ្នែករដ្ឋបាល និងធនធានមនុស្ស

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងជំរុញឱ្យមានចូលរួមពីសហគ្រាស គ្រឹះស្ថានក្នុងការប្រឡងប្រណាំងដើម្បីទទួលពានរង្វាន់“សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ” ជាប្រចាំឆ្នាំ

- រៀបចំកម្មវិធីសំណេះសំណាលរបស់ថ្នាក់ដឹកនាំជាមួយកម្មករនិយោជិត បុគ្គលទទួលបន្ទុកផ្នែករដ្ឋបាល និងធនធានមនុស្សប្រចាំសហគ្រាស គ្រឹះស្ថាន ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពអនុក្រឹត្យស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ ព្រមទាំងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធយន្តការត្រីភាគី
- សហការសម្របសម្រួល និងរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារ ក្រុមការងារទំនាក់ទំនងវិជ្ជាជីវៈ និងយន្តការត្រីភាគីផ្សេងៗទៀត
- រៀបចំជំនួបប្រចាំត្រីមាសជាមួយអង្គការវិជ្ជាជីវៈ និងបុគ្គលិកទទួលបន្ទុកផ្នែករដ្ឋបាល និងធនធានមនុស្ស

៣.៣.៥.៥ ពង្រឹងប្រសិទ្ធភាព និងធានានិរន្តរភាពក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមរយៈបន្តគាំទ្រមូលនិធិ និងលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ការធ្វើស្ថាប័ននីយកម្មក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដំណើរការពេញលេញ ត្រឹមឆ្នាំ២០២៧
- អត្រាអនុលោមតាមសេចក្តីបង្គាប់ជាប់កាតព្វកិច្ចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានរក្សាក្នុងអត្រា ១០០%
- ថវិកាបដិភាគដោយរាជរដ្ឋាភិបាល ត្រូវបានបន្តផ្តល់ជូនតាមតម្រូវការជាក់ស្តែងរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាល និងតួនាទី ភារកិច្ច របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រមទាំងរៀបចំនីតិវិធីនៃការជ្រើសរើសអាជ្ញាកណ្តាល
- ពង្រឹងសមត្ថភាពមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល
- តាមដាន និងជំរុញការអនុវត្តសេចក្តីបង្គាប់ជាប់កាតព្វកិច្ចដោយអធិការការងារ
- តាមដាន និងសម្របសម្រួលរាល់គម្រោងសំណើថវិការបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោយលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ពិនិត្យ និងលើកសំណើថវិកាបដិភាគទៅរាជរដ្ឋាភិបាលដើម្បីបន្តការគាំទ្រទៅលើដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ដើម្បីសម្រេចបានជោគជ័យលើការអនុវត្តនូវយុទ្ធសាស្ត្រអាទិភាពខាងលើ, អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវរៀបចំការពិនិត្យតាមដានលទ្ធផលនៃការអនុវត្តការងារជារៀងរាល់ខែ ត្រីមាស ឆមាស ប្រាំបួនខែ ជាពិសេស ការពិនិត្យវាយតម្លៃប្រចាំឆ្នាំ ដើម្បីវាយតម្លៃអំពីសមិទ្ធកម្មការងារសម្រេចបាន បញ្ហាប្រឈមដែលត្រូវកែលម្អ វិធានការអន្តរាគមន៍នានាដែលត្រូវដាក់ចេញសំដៅធានាឱ្យបាននូវការចូលរួមអនុវត្តពីគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ ការទទួលខុសត្រូវ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពជោគជ័យខ្ពស់។ យុទ្ធសាស្ត្រអាទិភាពនេះ ត្រូវបានចាត់ទុកថាជាឯកសាររស់រវើក ដែលសូចនាករកម្រិតយុទ្ធសាស្ត្រ សូចនាករកម្រិតកម្មវិធី ចង្កោមសកម្មភាព សូចនាករចង្កោមសកម្មភាព និងសកម្មភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ អាចនឹងត្រូវកែសម្រួល និងបច្ចុប្បន្នភាពជាយថាហេតុ ដើម្បីឱ្យស្របនឹងបរិការណ៍ជាក់ស្តែង និងការវិវត្តនៃវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ, វិធានការណ៍ និងសូចនាករគន្លឹះជាក់ស្តែងនានាដែលរាជរដ្ឋាភិបាល នឹងបន្តដាក់ចេញទៅតាមក្របខណ្ឌពេលវេលា ព្រមទាំងស្របទៅតាមការវិវត្តនៃសង្គម-សេដ្ឋកិច្ច ទាំងនៅក្នុងតំបន់ និងសកលលោក។

## ៣.៤- ការពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព

ទេសន្តរប្រវេសន៍ការងារ គឺជាផ្នែកមួយយ៉ាងសំខាន់នៃកម្លាំងពលកម្មរបស់កម្ពុជា ដែលបានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការជំរុញកំណើន និងអភិវឌ្ឍសេដ្ឋកិច្ច។ ការកើនឡើងនៃចំនួនទេសន្តរប្រវេសន៍ការងារ ក្នុងរយៈពេល ២ទសវត្សរ៍កន្លងមកនេះ ដែលជំរុញដោយកត្តាប្រជាសាស្ត្រ និងសេដ្ឋកិច្ច បានផ្តល់មកកម្ពុជាទាំងកាលានុវត្តភាព និងបញ្ហាប្រឈម។ បញ្ហាប្រឈមដែលត្រូវដោះស្រាយនោះ គឺការធ្វើឱ្យពលករទេសន្តរប្រវេសន៍កម្ពុជាទទួលបានឱកាសការងារដែលមានលក្ខខណ្ឌការងារល្អ ដោយសុវត្ថិភាព និងស្របច្បាប់ ការការពារនិងគាំពារនៅប្រទេសទទួល និងការធ្វើសមាហរណកម្មដោយពេញលេញនៅពេលធ្វើមាតុភូមិនិវត្តន៍ ព្រមទាំងទទួលបានការគាំពារសង្គមទាំងផ្នែកអប់រំ និងសុខភាពរបស់គ្រួសារពលករនៅប្រទេសទទួល។ ស្របជាមួយគ្នានេះ ទេសន្តរប្រវេសន៍ការងារបាននាំមកនូវកាលានុវត្តភាពយ៉ាងសំខាន់ ក្នុងការជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈការនាំមកវិញនូវជំនាញ និងចំណេះដឹងថ្មីៗ ដែលកម្ពុជាកំពុងមានតម្រូវការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្មក្នុងស្រុក និងការផ្ញើរប្រាក់បញ្ញើរាប់ពាន់លានដុល្លារត្រឡប់មកវិញ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា **បានកំណត់ចំណុចអាទិភាពទី៣ និងទី៩ របស់ខ្លួន នៅក្នុងមុំទី១ ការអភិវឌ្ឍទីផ្សារការងារ នៃបញ្ចកោណទី៣ ស្តីពីការអភិវឌ្ឍវិស័យឯកជននិងការងារ ក្នុង "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"**។ ឈរលើមូលដ្ឋាននេះ ក្រសួងបន្តពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព ផ្តោតលើការពង្រីកទីផ្សារការងារជំនាញនៅប្រទេសអភិវឌ្ឍន៍ដែលមានលក្ខខណ្ឌការងារល្អ ការពង្រឹងយន្តការនៃការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូន ការការពារនិងលើកកម្ពស់សិទ្ធិ សេរីភាព និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍កម្ពុជានៅគ្រប់ដំណាក់កាលនៃវដ្តទេសន្តរប្រវេសន៍ និងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងពលករទេសន្តរ



ញ

ប្រវេសន៍កម្ពុជា ព្រមទាំងការធ្វើសមាហរណកម្មនៅពេលធ្វើមាតុភូមិនិវត្តន៍។ សម្រាប់ទេសន្តរប្រវេសន៍ការងារនៅក្នុងប្រទេស ក្រសួងបន្តពង្រឹងយន្តការគ្រប់គ្រងហត្ថពលកម្មបរទេស ដោយធ្វើឱ្យប្រសើរឡើងនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រើប្រាស់ហត្ថពលកម្មបរទេស និងប្រព័ន្ធគ្រប់គ្រងហត្ថពលកម្មបរទេស ព្រមទាំងបង្កើតឱ្យមានយន្តការផ្ទេរជំនាញពីជនបរទេសមកយុវជនខ្មែរ។

សូចនាករកម្រិតយុទ្ធសាស្ត្រ ត្រូវសម្រេចឱ្យបានក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ មាន ៥ ដូចខាងក្រោម÷

៣.៤.ក. អត្រានៃការយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរដែលមានបំណងទៅធ្វើការនៅបរទេស អំពីនីតិវិធី រយៈពេល និងថ្លៃសេវានៃការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅបរទេស កើនឡើង

៣.៤.ខ. ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាដែលមានជំនាញទៅធ្វើការនៅប្រទេសអភិវឌ្ឍន៍ កើនឡើង

៣.៤.គ. អត្រានៃការពេញចិត្តរបស់ភាគីទាំង៥ (រួមមាន ពលករឬយុវជន ក្រុមគ្រួសារពលករ ទីភ្នាក់ងារជ្រើសរើសឯកជន និយោជកនៃប្រទេសទទួល និងរាជរដ្ឋាភិបាលកម្ពុជានិងប្រទេសទទួល) ចំពោះនីតិវិធី រយៈពេល និងថ្លៃសេវានៃការបញ្ជូន និងការគាំពារពលករកម្ពុជាទៅធ្វើការនៅបរទេស កើនឡើង

៣.៤.ឃ. ប្រាក់បញ្ញើត្រឡប់មកក្នុងប្រទេសរបស់ពលករទេសន្តរប្រវេសន៍កម្ពុជា កើនឡើង

៣.៤.ង. រាល់ជនបរទេសដែលមកធ្វើការនៅកម្ពុជាបានបំពេញនីតិវិធីត្រឹមត្រូវតាមច្បាប់

ដើម្បីសម្រេចបាននូវសូចនាករកម្រិតយុទ្ធសាស្ត្រខាងលើនេះ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាពចំនួន ៥ ដូចខាងក្រោម÷

### ៣.៤.១. ការពង្រីក និងពង្រីកទីផ្សារការងារនៅបរទេសដែលមានលក្ខខណ្ឌការងារល្អ

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៤.១.ក. ចំនួនសរុបកិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសទទួល កើនឡើង

៣.៤.១.ខ. របាយការណ៍វាយតម្លៃអំពីវិស័យដែលមានឱកាសការងារនិងលក្ខខណ្ឌការងារល្អ និងវិស័យដែលមានហានិភ័យខ្ពស់នៅប្រទេសទទួល ត្រូវបានរៀបចំ និងផ្សព្វផ្សាយប្រចាំឆ្នាំ

៣.៤.១.គ. បរិមាណភាគពលករទេសន្តរប្រវេសន៍កម្ពុជាសរុបដែលមានជំនាញ ត្រូវបានបញ្ជូនទៅធ្វើការនៅប្រទេសអភិវឌ្ឍន៍ ធៀបនឹងពលករទេសន្តរប្រវេសន៍កម្ពុជាសរុប កើនឡើង

៣.៤១.ឃ. ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅបរទេស កើនឡើង

៣.៤.១.ង. គោលនយោបាយជាតិ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិស្តង់ដា (SOP) របស់អង្គភាពប្រតិបត្តិពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនេះ ត្រូវបានពិនិត្យឡើងវិញ រៀបចំ និងធ្វើបច្ចុប្បន្នភាព

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៤.១.១ ពង្រឹងការអនុវត្ត និងពិនិត្យបន្តសុពលភាពកិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសទទួល ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- កិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសទទួល ត្រូវបានបន្តតាមឆ្នាំកំណត់
- វិស័យដែលមានឱកាសនិងលក្ខខណ្ឌការងារល្អនៅប្រទេសទទួល ត្រូវបានពង្រីកបន្ថែម យ៉ាងតិច ២/ឆ្នាំ
- វិស័យដែលមានហានិភ័យខ្ពស់នៅប្រទេសទទួល ដើម្បីកាត់បន្ថយការបញ្ជូនពលករ ត្រូវបានសិក្សាវាយតម្លៃ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- បន្តសុពលភាព និងពង្រឹងការអនុវត្តកិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសទទួល
- សិក្សា និងវាយតម្លៃអំពីការពង្រីកវិស័យដែលមានឱកាស និងលក្ខខណ្ឌការងារល្អ
- ចរចា និងពង្រីកវិស័យដែលមានឱកាស និងលក្ខខណ្ឌការងារល្អនៅប្រទេសទទួល
- សិក្សាវាយតម្លៃ និងកាត់បន្ថយការបញ្ជូនលើវិស័យដែលមានហានិភ័យខ្ពស់នៅប្រទេសទទួល
- ប្រជុំទ្វេភាគីថ្នាក់មន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងថ្នាក់រដ្ឋមន្ត្រី សម្រាប់វាយតម្លៃការអនុវត្តកិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នា

៣.៤.១.២ សិក្សានីតិវិធី និងជំរុញការចុះកិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នានៃការបញ្ជូនពលករទៅធ្វើការនៅប្រទេសគោលដៅ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- កិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នានៃការបញ្ជូនពលករទៅធ្វើការនៅប្រទេសគោលដៅត្រូវបានចុះ យ៉ាងតិច ១/ឆ្នាំ
- ប្រទេសគោលដៅដែលជាប្រទេសអភិវឌ្ឍន៍សម្រាប់ការបញ្ជូនត្រូវបានសិក្សា និងវាយតម្លៃ យ៉ាងតិច ២/ឆ្នាំ
- នីតិវិធីនៃការបញ្ជូនពលករទៅធ្វើការនៅប្រទេសគោលដៅ ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- សិក្សា និងចងក្រងចំណាត់ថ្នាក់ទីផ្សារការងារដែលមានលក្ខខណ្ឌការងារល្អ នៅប្រទេសគោលដៅដែលជាប្រទេសអភិវឌ្ឍន៍
- ពិភាក្សាការងារជាមួយស្ថានតំណាងនៃបណ្តាប្រទេសគោលដៅដែលជាប្រទេសអភិវឌ្ឍន៍នៅកម្ពុជា ដើម្បីស្វែងរកឱកាសក្នុងការពង្រីកទីផ្សារការងារ
- រៀបចំផែនការសកម្មភាពក្នុងការចរចា ដើម្បីឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសគោលដៅ ដោយឈរលើអត្ថប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍កម្ពុជាជាអាទិភាព
- ចរចាជាមួយប្រទេសទទួលដែលជាប្រទេសអភិវឌ្ឍន៍ ដើម្បីបង្កើនការបញ្ជូនពលករជំនាញពីកម្ពុជា
- ប្រជុំកម្រិតបច្ចេកទេសជាមួយប្រទេសគោលដៅអំពីនីតិវិធីបញ្ជូន និងប្រជុំថ្នាក់រដ្ឋមន្ត្រីនិងមន្ត្រីបច្ចេកទេសជាន់ខ្ពស់ជាមួយប្រទេសគោលដៅអំពីការបញ្ជូនពលករកម្ពុជា

៣.៤.១.៣ បង្កើនការបញ្ជូនពលករជំនាញទៅធ្វើការនៅតាមបណ្តាប្រទេសទទួល ដែលជាប្រទេសអភិវឌ្ឍន៍ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនពលករជំនាញទៅធ្វើការនៅប្រទេសអភិវឌ្ឍន៍ប្រចាំឆ្នាំ កើនឡើង
- ចំនួនជំនួប/ទស្សនកិច្ចសិក្សារបស់ថ្នាក់ដឹកនាំនៅប្រទេសទទួល យ៉ាងតិច ១២ដង/ឆ្នាំ
- ចំនួនបេក្ខជនមានជំនាញស្របតាមតម្រូវការកម្លាំងពលកម្មនៅប្រទេសទទួល កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំចងក្រងសៀវភៅណែនាំអំពីសក្តានុពលកម្លាំងពលកម្មជំនាញកម្ពុជា
- រៀបចំជំនួបរបស់ថ្នាក់ដឹកនាំជាមួយក្រុមហ៊ុនធំៗ និងភាគីពាក់ព័ន្ធនៃប្រទេសទទួលដែលត្រូវការកម្លាំងពលកម្មជំនាញ ព្រមទាំងទស្សនកិច្ចស្វែងរកទីផ្សារការងារថ្មីដែលមានលក្ខខណ្ឌការងារល្អ
- សិក្សា និងវាយតម្លៃតម្រូវការទីផ្សារការងារនិងលក្ខខណ្ឌការងារនៅប្រទេសទទួល ដើម្បីរៀបចំជាផែនការបណ្តុះបណ្តាល និងបញ្ជូនពលករទេសន្តរប្រវេសន៍កម្ពុជាទៅតាមប្រទេសទទួល និងជំនាញ

- សហការជាមួយមជ្ឈមណ្ឌលរួមមួយសម្រាប់បណ្តុះបណ្តាលជំនាញ ក្នុងការរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលជំនាញ ដែលទទួលស្គាល់ដោយប្រទេសទទួល ដើម្បីឆ្លើយតបជាមួយតម្រូវការទីផ្សារការងារជាក់ស្តែង
- សហការជាមួយទីភ្នាក់ងារជ្រើសរើសឯកជន និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈទាំងរដ្ឋនិងឯកជន ដើម្បីជំរុញការជ្រើសរើស និងបណ្តុះបណ្តាលជំនាញឱ្យស្របតាមតម្រូវការកម្លាំងពលកម្មនៃប្រទេសទទួល

៣.៤.១.៤ ធ្វើឱ្យប្រសើរឡើងនូវលិខិតបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារ ដោយគិតទាំងអន្តោប្រវេសន៍ការងារ និងនិរប្រវេសន៍ការងារ ត្រូវបានអនុម័តនៅឆ្នាំ២០២៦
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ត្រូវបានរៀបចំ ផ្សព្វផ្សាយ និងអនុវត្ត
- គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ត្រូវបានរៀបចំជាគោលនយោបាយជាតិនៅឆ្នាំ២០២៤

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារ
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ការងារ
- រៀបចំ ជំរុញការអនុវត្ត និងតាមដានការវាយតម្លៃគោលនយោបាយជាតិស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា
- រៀបចំគោលការណ៍នីតិវិធីប្រតិបត្តិស្តង់ដា (SOP) របស់អង្គភាពប្រតិបត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ
- ផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ការងារ

៣.៤.១.៥ បង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អ្នកផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងសមាគម ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- គម្រោងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អ្នកផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងសមាគម យ៉ាងតិច ២/ឆ្នាំ ត្រូវបានអនុវត្ត
- កិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់ ដើម្បីអនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍន៍ អ្នកផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងសមាគមចំនួន ៣ដង/ឆ្នាំ ត្រូវបានរៀបចំ
- ទស្សនកិច្ចដើម្បីវាយតម្លៃការអនុវត្តគម្រោងចំនួន ២ដង/ឆ្នាំ ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ផ្តួចផ្តើម និងដឹកនាំការអនុវត្តគម្រោងដោយមានការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ សំដៅលើកកម្ពស់ភាពជាម្ចាស់
- រៀបចំផែនទីសកម្មភាពការងារ (Mapping) និងបែងចែកការងារអាទិភាពរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីជៀសវាងការអនុវត្តគម្រោងត្រួតគ្នា និងបង្កើនប្រសិទ្ធភាព
- រៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់ ដើម្បីពិនិត្យលើលទ្ធផលដែលបានអនុវត្ត និងទិសដៅបន្ត
- សហការអនុវត្តគម្រោងជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍
- ចុះពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងជាមួយដៃគូ

### ៣.៤.២. ការពង្រឹងយន្តការ តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការជ្រើសរើស ការបណ្តុះបណ្តាល និងការបញ្ជូនពលករទៅធ្វើការនៅបរទេស

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៤.២.ក. ថ្លៃសេវាបញ្ជូនពលករកម្ពុជាទៅធ្វើការនៅបរទេសត្រូវបានកំណត់ពិដានកម្រៃសេវា

៣.៤.២.ខ. អត្រាអនុលោមភាពរបស់ទីភ្នាក់ងារជ្រើសរើសឯកជនក្នុងការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករទេសន្តរប្រវេសន៍កម្ពុជា កើនឡើង

៣.៤.២.គ. គ្រប់ក្រុមហ៊ុន សាលាបណ្តុះបណ្តាល និងអង្គការសមាគមដែលមិនមានការអនុញ្ញាតបញ្ជូន និងបានផ្សព្វផ្សាយជ្រើសរើសពលករ ត្រូវបានចាត់វិធានការ

៣.៤.២.ឃ. បញ្ជីឈ្មោះទីភ្នាក់ងារបញ្ជូនពលករស្របច្បាប់ និងនីតិវិធីបញ្ជូន ត្រូវបានធ្វើបច្ចុប្បន្នភាពផ្សព្វផ្សាយ និងអាចផ្ទៀងផ្ទាត់បានតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល

៣.៤.២.ង. មជ្ឈមណ្ឌលរួមមួយសម្រាប់បណ្តុះបណ្តាលជំនាញ ធ្វើតេស្តជំនាញ និងផ្តល់វិញ្ញាបនបត្រដល់ពលករទេសន្តរប្រវេសន៍កម្ពុជា ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការក្នុងឆ្នាំ ២០២៤

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៤.២.១ ពង្រឹងការចុះត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសឯកជន យន្តការណែនាំតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅបរទេស ការទទួលនិងដោះស្រាយពាក្យបណ្តឹងរបស់ពលករទេសន្តរប្រវេសន៍កម្ពុជា និងការលើកកម្ពស់ការផ្តល់សេវាមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ (Migrant Resource Centres-MRC) ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- រាល់ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវបានធ្វើការត្រួតពិនិត្យយ៉ាងតិច ១ដង/ឆ្នាំ
- រាល់ពាក្យបណ្តឹងរបស់ពលករទេសន្តរប្រវេសន៍កម្ពុជា ត្រូវបានទទួល និងអន្តរាគមន៍ដោះស្រាយ ក្នុងរយៈពេល ៤៨ម៉ោង
- អត្រានៃការពេញចិត្តលើសេវាមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ យ៉ាងតិច ៩០%

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ចុះត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសឯកជន និងចាត់វិធានការចំពោះទីភ្នាក់ងារជ្រើសរើសឯកជន ដែលមិនអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត
- ធ្វើបច្ចុប្បន្នភាពឯកសារ និងផ្តល់ការណែនាំតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅបរទេស
- ទទួល និងដោះស្រាយពាក្យបណ្តឹងរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាឱ្យបានទាន់ពេលវេលា
- រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុកការងារទេសន្តរប្រវេសន៍នៅតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត និងមន្ត្រីអាជ្ញាធរភូមិ ឃុំ-សង្កាត់
- ពង្រឹងសេវាមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ និងស្ទាបស្ទង់មតិអ្នកទទួលសេវា និងពង្រឹងប្រសិទ្ធភាពសេវានៃទីស្នាក់ការផ្តល់លិខិតធ្វើដំណើរ និងបណ្ណពលករកម្ពុជា ទៅធ្វើការនៅបរទេសដែលមាននៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ

៣.៤.២.២ ពង្រឹងការគ្រប់គ្រង និងតាមដានលើការផ្សព្វផ្សាយជ្រើសរើសពលករកម្ពុជាទៅធ្វើការនៅបរទេសពីគ្រប់ប្រភព និងគ្រប់រូបភាព ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម៖

- ការផ្សព្វផ្សាយជ្រើសរើសពលករកម្ពុជាទៅធ្វើការនៅបរទេសពីគ្រប់ប្រភព និងគ្រប់រូបភាព ត្រូវបានត្រួតពិនិត្យ និងតាមដាន
- ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសនៃទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវបានពង្រឹង
- រាល់ទីភ្នាក់ងារជ្រើសរើសឯកជនណាដែលធ្វើការផ្សព្វផ្សាយជ្រើសរើសពលករដោយពុំមានការអនុញ្ញាតពីក្រសួង ត្រូវបានចាត់វិធានការដោយគ្មានការលើកលែង

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម៖

- ពង្រឹងការតាមដានការផ្សព្វផ្សាយជ្រើសរើសពលករកម្ពុជាទៅធ្វើការនៅបរទេសពីគ្រប់ប្រភព និងគ្រប់រូបភាព
- ពង្រឹងការគ្រប់គ្រងភ្នាក់ងារជ្រើសរើសនៃទីភ្នាក់ងារជ្រើសរើសឯកជន តាមរយៈការរៀបចំ និងការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ សម្រាប់ភ្នាក់ងារជ្រើសរើសនៃទីភ្នាក់ងារជ្រើសរើសឯកជន
- បណ្តុះបណ្តាល ផ្តល់បណ្ណសម្គាល់ខ្លួន និងលិខិតឧទ្ទេសនាម និងកំណត់ឱ្យមានឯកសណ្ឋានដល់ភ្នាក់ងារជ្រើសរើសនៃទីភ្នាក់ងារជ្រើសរើសឯកជន
- ចាត់វិធានការដល់ទីភ្នាក់ងារជ្រើសរើសឯកជនណាដែលធ្វើការផ្សព្វផ្សាយជ្រើសរើសពលករដោយពុំមានការអនុញ្ញាតពីក្រសួង
- សហការជាប្រចាំជាមួយស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការដល់បុគ្គលណាដែលធ្វើការផ្សព្វផ្សាយជ្រើសរើសពលករដោយខុសច្បាប់

៣.៤.២.៣ ចងក្រង ផលិត បោះពុម្ព និងផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន នីតិវិធី រយៈពេលដំណើរការ និងការកាត់បន្ថយថ្លៃសេវាបញ្ជូនពលករកម្ពុជាទៅធ្វើការនៅបរទេស ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម៖

- បញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវបានធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយជាប្រចាំ
- នីតិវិធីបញ្ជូន និងរយៈពេលដំណើរការឯកសារពលករកម្ពុជាទៅធ្វើការនៅបរទេស ត្រូវបានធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយជាសាធារណៈ

- លទ្ធភាពនៃការកាត់បន្ថយថ្លៃសេវា នីតិវិធី និងរយៈពេលនៃការបញ្ជូនពលករទៅធ្វើការនៅបរទេស ត្រូវបានសិក្សា

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម៖

- ធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ជាប្រចាំ
- ធ្វើបច្ចុប្បន្នភាព ផលិត និងផ្សព្វផ្សាយអំពីនីតិវិធី និងរយៈពេលដំណើរការឯកសារពលករកម្ពុជាទៅធ្វើការនៅបរទេសឱ្យដល់ពលករទេសន្តរប្រវេសន៍ និងសាធារណជន
- ជូនដំណឹងអំពីប្រព័ន្ធនៃការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅបរទេសដល់ស្ថានតំណាងប្រទេសគោលដៅ និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំកិច្ចប្រជុំពិភាក្សាជាមួយភាគីពាក់ព័ន្ធស្តីពីការកែសម្រួលប្រព័ន្ធជ្រើសរើស និងបញ្ជូនពលករតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយថ្លៃសេវានិងពេលវេលានៃការបញ្ជូនពលករទេសន្តរប្រវេសន៍កម្ពុជាទៅធ្វើការនៅបរទេស ឱ្យបានសមស្រប និងទទួលយកបានដោយភាគីទាំង៥
- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តថ្លៃសេវាបញ្ជូនពលករទេសន្តរប្រវេសន៍កម្ពុជា ទៅធ្វើការនៅបរទេស ដែលត្រូវបានកាត់បន្ថយចំនួន ១០ ភាគរយនៅឆ្នាំ២០២៤ និង ១០ ភាគរយបន្ថែមនៅឆ្នាំ២០២៦

៣.៤.២.៤ រៀបចំយន្តការគ្រប់គ្រង និងបង្កើតមជ្ឈមណ្ឌលរួមមួយសម្រាប់បណ្តុះបណ្តាលជំនាញជាក់លាក់ និងវគ្គបណ្តុះបណ្តាលណែនាំតម្រង់ទិសពលករមុនចេញដំណើរ ស្របទៅតាមតម្រូវការរបស់ប្រទេសទទួល ដើម្បីបង្កើនភាពប្រកួតប្រជែង និងឱកាសទីផ្សារការងារនៅបរទេស ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម៖

- ការបង្កើតឱ្យមានមជ្ឈមណ្ឌលរួមមួយសម្រាប់បណ្តុះបណ្តាលជំនាញ ដល់ពលករទេសន្តរប្រវេសន៍កម្ពុជាមុនចេញដំណើរ ត្រូវបានរៀបចំ ត្រឹមឆ្នាំ២០២៤
- យន្តការនៃការគ្រប់គ្រងមជ្ឈមណ្ឌលរួមមួយសម្រាប់បណ្តុះបណ្តាលជំនាញ ដល់ពលករទេសន្តរប្រវេសន៍កម្ពុជាមុនចេញដំណើរ ត្រូវបានរៀបចំ
- កម្មវិធីបណ្តុះបណ្តាលជំនាញសម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាមុនចេញដំណើរ ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម៖

- បង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលរួមមួយសម្រាប់បណ្តុះបណ្តាលជំនាញ ដល់ពលករទេសន្តរប្រវេសន៍កម្ពុជាមុនចេញដំណើរ
- រៀបចំយន្តការ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករដែលទទួលការបណ្តុះបណ្តាលជំនាញ
- ដាក់ឱ្យដំណើរការមជ្ឈមណ្ឌលរួមមួយសម្រាប់បណ្តុះបណ្តាលជំនាញ ព្រមទាំងសហការជាមួយទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងការជំរុញការចុះឈ្មោះពលករទេសន្តរប្រវេសន៍កម្ពុជាចូលរៀនវគ្គបណ្តុះបណ្តាលជំនាញ
- រៀបចំកម្មវិធីបណ្តុះបណ្តាល និងវគ្គបណ្តុះបណ្តាលជំនាញ ស្របតាមតម្រូវការរបស់ប្រទេសទទួល
- រៀបចំវគ្គបណ្តុះបណ្តាលណែនាំតម្រង់ទិសពលករមុនចេញដំណើរ ស្របតាមស្ថានភាពប្រទេសទទួល

៣.៤.២.៥ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងក្របខណ្ឌអាស៊ាន យន្តការទីក្រុងកូឡុំបូ (Colombo Process) មហាអនុតំបន់មេគង្គ (Greater Mekong Subregion-GMS) និងប្រទេសបញ្ជូន ដើម្បីការពារនិងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍លទ្ធផលស្តីពីការអនុវត្តផែនការសកម្មភាពសម្រាប់អនុវត្តឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារនិងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ត្រូវបានរៀបចំជាប្រចាំឆ្នាំ
- កិច្ចប្រជុំថ្នាក់តំបន់ក្នុងក្របខណ្ឌអាស៊ាន ដើម្បីពង្រឹងតួនាទី និងការអនុវត្តលើអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ យ៉ាងតិច ២ដង/ឆ្នាំ ត្រូវបានចូលរួម
- កិច្ចប្រជុំពាក់ព័ន្ធទេសន្តរប្រវេសន៍ការងារក្នុងចំណោមប្រទេសបញ្ជូន ក្រោមយន្តការទីក្រុងកូឡុំបូ (Colombo Process) មហាអនុតំបន់មេគង្គ (GMS) និងកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (Global Compact for Migration-GCM) ចំនួន ៤ដង/ឆ្នាំ ត្រូវបានចូលរួម

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ផ្សព្វផ្សាយ និងអនុវត្តផែនការសកម្មភាពសម្រាប់ប្រទេសកម្ពុជាក្នុងការអនុវត្តឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារនិងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍
- ចូលរួមកិច្ចប្រជុំថ្នាក់តំបន់ក្នុងក្របខណ្ឌអាស៊ាន ក្នុងចំណោមប្រទេសបញ្ជូនក្រោមយន្តការទីក្រុងកូឡុំបូ (Colombo Process) និងក្របខណ្ឌមហាអនុតំបន់មេគង្គ (GMS) ដើម្បីពង្រឹងតួនាទី និងការអនុវត្តលើអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ

- ចូលរួមកិច្ចប្រជុំពាក់ព័ន្ធទេសន្តរប្រវេសន៍ការងារនៅក្របខណ្ឌកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM)
- រៀបចំគំរូបទដ្ឋានកិច្ចសន្យាការងារសម្រាប់ពលករធ្វើការក្នុងផ្ទែកនេសាទ ក្រោមជំនួយបច្ចេកទេសរបស់អង្គការអន្តរជាតិខាងការងារ (ILO) និងដៃគូផ្សេងៗទៀត ដោយសហការជាមួយរដ្ឋាភិបាលមីយ៉ាន់ម៉ា ឡាវ និងថៃ
- រៀបចំកិច្ចប្រជុំពិភាក្សាក្នុងចំណោមប្រទេសបញ្ជូនដើម្បីចែករំលែកឧត្តមានុវត្តន៍ បទពិសោធ និងបញ្ហាប្រឈម ដើម្បីការពារនិងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍

### ៣.៤.៣. ការពង្រឹងយន្តការគ្រប់គ្រង និងសេវាគាំពារនៅតាមប្រទេសទទួលដល់ពលករទេសន្តរប្រវេសន៍កម្ពុជា

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៤.៣.ក. ប្រព័ន្ធគ្រប់គ្រងពលករទេសន្តរប្រវេសន៍កម្ពុជា ត្រូវបានកែលម្អ និងពង្រីកមុខងាររួមមានមុខងារតាមដានដំណើរការឯកសារ (Tracking System) និងមុខងារស្វែងរកឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់

៣.៤.៣.ខ. យន្តការបង្ការហានិភ័យ នីតិវិធីសម្រាប់ជូនដំណឹង ឆ្លើយតបបន្ទាន់ និងគាំពារដល់ពលករទេសន្តរប្រវេសន៍កម្ពុជានៅពេលមានអាសន្ន ត្រូវបានសិក្សារៀបចំ និងអនុវត្តពេញលេញ ត្រឹមឆ្នាំ២០២៥

៣.៤.៣.គ. របាយការណ៍ស្តីពីការវាយតម្លៃស្ថានភាពសិទ្ធិ ផលប្រយោជន៍ សេចក្តីថ្លៃថ្នូរ និងការទទួលបានឱកាសអភិវឌ្ឍខ្លួន និងគ្រួសារនៅប្រទេសទទួល ត្រូវបានផលិត និងផ្សព្វផ្សាយ ជាភាសាខ្មែរនិងភាសាអង់គ្លេស

៣.៤.៣.ឃ. អត្រានៃពលករទេសន្តរប្រវេសន៍កម្ពុជា ចេញដំណើរទៅធ្វើការនៅបរទេស ដែលមានគណនីធនាគារ កើនឡើង

៣.៤.៣.ង. អត្រានៃពាក្យបណ្តឹងរបស់ពលករ ត្រូវបានទទួល និងអន្តរាគមដោះស្រាយដោយអនុព័ន្ធការងារនៅប្រទេសទទួល ក្នុងរយៈពេល ៤៨ម៉ោង

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពចំនួន ៥ ដូចខាងក្រោម÷

៣.៤.៣.១ ធ្វើបច្ចុប្បន្នភាព និងពង្រីកមុខងារប្រព័ន្ធគ្រប់គ្រងពលករទេសន្តរប្រវេសន៍កម្ពុជា និងប្រមូលចងក្រង និងផ្សព្វផ្សាយរបាយការណ៍ស្ថិតិ ឧត្តមានុវត្តន៍ បទពិសោធ ព្រមទាំងបញ្ហាប្រឈមពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍កម្ពុជា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍ស្ថិតិពលករទេសន្តរប្រវេសន៍កម្ពុជា ត្រូវបានផលិតជាប្រចាំខែ
- មុខងារតាមដានដំណើរការឯកសារ (Tracking System) ដើម្បីឱ្យពលករតាមដានឯកសាររបស់ខ្លួនតាមទូរស័ព្ទដៃនៅកម្ពុជា និងប្រទេសទទួល ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការ
- របាយការណ៍ឧត្តមានុវត្តន៍ បទពិសោធ ព្រមទាំងបញ្ហាប្រឈមរបស់ពលករទេសន្តរប្រវេសន៍កម្ពុជា ត្រូវបានផលិត និងផ្សព្វផ្សាយប្រចាំឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- កែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករទេសន្តរប្រវេសន៍កម្ពុជា រួមទាំងការភ្ជាប់ប្រព័ន្ធទិន្នន័យពលករទេសន្តរប្រវេសន៍កម្ពុជា ជាមួយប្រព័ន្ធទិន្នន័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងប្រព័ន្ធទិន្នន័យអ្នកស្វែងរកការងារធ្វើ
- បង្កើតមុខងារតាមដានដំណើរការឯកសារ (Tracking System) ដើម្បីឱ្យពលករតាមដានឯកសាររបស់ខ្លួន
- បង្កើតមុខងារស្វែងរកឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់
- រៀបចំរបាយការណ៍ស្ថិតិពលករទេសន្តរប្រវេសន៍កម្ពុជាប្រចាំខែ ដោយបែងចែកទិន្នន័យពលករទេសន្តរប្រវេសន៍ តាមភេទ អាយុ កម្រិតអប់រំ វិស័យ និងមុខរបរ
- ប្រមូល ចងក្រង និងផ្សព្វផ្សាយឧត្តមានុវត្តន៍ បទពិសោធ និងបញ្ហាប្រឈមពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍កម្ពុជា

៣.៤.៣.២ សិក្សារៀបចំ និងគ្រប់គ្រងប្រព័ន្ធបង្ការហានិភ័យ និងឆ្លើយតបបន្ទាន់សម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជានៅពេលមានអាសន្ន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- ប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់ជូនដំណឹងដល់ពលករទេសន្តរប្រវេសន៍កម្ពុជានៅពេលមានអាសន្ន ត្រូវបានរៀបចំ និងដំណើរការពេញលេញត្រឹមឆ្នាំ២០២៤
- យន្តការបង្ការហានិភ័យ ឆ្លើយតបបន្ទាន់ និងគាំពារដល់ពលករទេសន្តរប្រវេសន៍កម្ពុជានៅពេលមានអាសន្ន ត្រូវបានរៀបចំត្រឹមឆ្នាំ២០២៤
- មូលនិធិសម្រាប់គាំទ្រដល់ពលករទេសន្តរប្រវេសន៍កម្ពុជានៅពេលមានអាសន្ន ត្រូវបានសិក្សា និងដាក់ឱ្យអនុវត្តត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ចងក្រង និងរៀបចំប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីសម្រាប់ជូនដំណឹងដល់ពលករទេសន្តរប្រវេសន៍កម្ពុជានៅពេលមានអាសន្ន
- សិក្សារៀបចំប្រព័ន្ធបង្ការហានិភ័យ ឆ្លើយតបបន្ទាន់ និងគាំពារដល់ពលករទេសន្តរប្រវេសន៍កម្ពុជានៅពេលមានអាសន្ន
- សិក្សារៀបចំមូលនិធិសម្រាប់គាំទ្រដល់ពលករទេសន្តរប្រវេសន៍កម្ពុជានៅពេលមានអាសន្ន
- រៀបចំកិច្ចប្រជុំពិភាក្សាជាមួយភាគីពាក់ព័ន្ធអំពីការរៀបចំប្រព័ន្ធបង្ការហានិភ័យឆ្លើយតបបន្ទាន់និងគាំពារ
- រៀបចំកិច្ចប្រជុំពិភាក្សាជាមួយភាគីពាក់ព័ន្ធអំពីការបង្កើតមូលនិធិគាំទ្រសម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជានៅពេលមានអាសន្ន

៣.៤.៣.៣ ការពារនិងលើកកម្ពស់សិទ្ធិ ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍កម្ពុជា និងគ្រួសារ ព្រមទាំងផ្តល់ឱកាសទទួលបានការអប់រំសមរម្យដល់កូនចៅរបស់ពលករនៅប្រទេសទទួល ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនការជួបសំណេះសំណាល និងសួរសុខទុក្ខស្វែងយល់អំពីការរស់នៅ និងលក្ខខណ្ឌការងាររបស់ពលករទេសន្តរប្រវេសន៍កម្ពុជានៅប្រទេសទទួល កើនឡើង
- ចំនួនការជួបជាមួយនិយោជកដែលប្រើប្រាស់កម្លាំងពលកម្មកម្ពុជា ឬអាជ្ញាធរមូលដ្ឋាននៃប្រទេសទទួល កើនឡើង
- ការបង្រៀនភាសាខ្មែរមូលដ្ឋានដល់កូនចៅរបស់ពលករ ដោយសហការជាមួយសហគមន៍ខ្មែរនៅប្រទេសទទួលនិងភាគីពាក់ព័ន្ធ ត្រូវបានរៀបចំ និងដំណើរការចាប់ពីឆ្នាំ២០២៥

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំកម្មវិធីសំណេះសំណាល និងសួរសុខទុក្ខពលករទេសន្តរប្រវេសន៍កម្ពុជា ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅប្រទេសទទួល ព្រមទាំងចុះស្វែងយល់អំពីការរស់នៅ និងលក្ខខណ្ឌការងាររបស់ពលករទេសន្តរប្រវេសន៍កម្ពុជានៅកន្លែងស្នាក់នៅ និងធ្វើការ
- បង្កើនការចុះជួបជាមួយនិយោជកដែលប្រើប្រាស់កម្លាំងពលកម្មកម្ពុជា ឬអាជ្ញាធរមូលដ្ឋាននៃប្រទេសទទួល
- ផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ និងលក្ខខណ្ឌការងារដល់ពលករទេសន្តរប្រវេសន៍កម្ពុជា

- ធ្វើអន្តរាគមន៍ចាំបាច់នានា ដោយសហការជាមួយតំណាងអចិន្ត្រៃយ៍របស់ទីភ្នាក់ងារបញ្ជូនពលករ តំណាងសមាគម និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធប្រទេសទទួល ក្នុងករណីមានបញ្ហាកើតឡើងជាយថាហេតុ ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព
- រៀបចំឱ្យមានការបង្រៀនភាសាខ្មែរមូលដ្ឋានដល់កូនចៅរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាដោយសហការជាមួយសហគមន៍ខ្មែរនៅប្រទេសទទួល និងភាគីពាក់ព័ន្ធ

៣.៤.៣.៤ លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធធនាគារដល់ពលករទេសន្តរប្រវេសន៍កម្ពុជា និងប្រមូលចងក្រងទិន្នន័យប្រាក់បញ្ញើរបស់ពលករទេសន្តរប្រវេសន៍កម្ពុជា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ចំនួនវគ្គបណ្តុះបណ្តាលស្តីពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធធនគារ កើនឡើង
- ប្រាក់បញ្ញើរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាតាមប្រព័ន្ធធនាគារ កើនឡើង
- របាយការណ៍អង្កេត និងវាយតម្លៃផលជះនៃប្រាក់បញ្ញើរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាលើជីវភាពគ្រួសាររបស់ពលករប្រចាំឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- លើកកម្ពស់ការយល់ដឹងរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធធនាគារ តាមរយៈវគ្គណែនាំតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅបរទេស
- សហការជាមួយធនាគារក្នុងការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធធនាគារ
- កំណត់ឱ្យពលករទេសន្តរប្រវេសន៍កម្ពុជា មានគណនីធនាគារសកម្មនៅប្រទេសកម្ពុជា និងនៅប្រទេសទទួល ដើម្បីទទួលប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ
- ប្រមូល និងចងក្រងទិន្នន័យប្រាក់បញ្ញើរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាតាមប្រព័ន្ធធនាគារ ដោយសហការជាមួយធនាគារជាតិនៃកម្ពុជា
- ធ្វើអង្កេត និងវាយតម្លៃផលជះនៃប្រាក់បញ្ញើរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាលើជីវភាពគ្រួសាររបស់ពលករ

៣.៤.៣.៥ ចាត់តាំង ឬបន្ថែមអនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល និងតំណាងអចិន្ត្រៃយ៍របស់ទីភ្នាក់ងារបញ្ជូនពលករ រួមជាមួយតំណាងសមាគមទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា និងបង្កើតមជ្ឈមណ្ឌលគាំពារពលករទេសន្តរប្រវេសន៍កម្ពុជា នៅតាមបណ្តាប្រទេសទទួលទៅតាមការចាំបាច់ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- អនុព័ន្ធការងារ តំណាងអចិន្ត្រៃយ៍របស់ទីភ្នាក់ងារបញ្ជូនពលករ និងតំណាងសមាគមទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ត្រូវបានចាត់តាំង ឬបន្ថែមតាមការចាំបាច់
- បណ្តាញពលករទេសន្តរប្រវេសន៍កម្ពុជា ដែលកំពុងធ្វើការនៅប្រទេសទទួល ត្រូវបានបង្កើត ចងក្រង និងធ្វើបច្ចុប្បន្នភាពជាប្រចាំ
- មជ្ឈមណ្ឌលគាំពារពលករទេសន្តរប្រវេសន៍កម្ពុជា នៅតាមបណ្តាប្រទេសទទួល ត្រូវបានបង្កើតយ៉ាងតិច ៥ ត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ចាត់តាំង ឬបន្ថែមអនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល តំណាងអចិន្ត្រៃយ៍របស់ទីភ្នាក់ងារបញ្ជូនពលករ រួមជាមួយតំណាងសមាគមទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជានៅតាមបណ្តាប្រទេសទទួលស្របទៅតាមការចាំបាច់
- បណ្តុះបណ្តាលអនុព័ន្ធការងារ តំណាងអចិន្ត្រៃយ៍របស់ទីភ្នាក់ងារបញ្ជូនពលករ និងតំណាងសមាគមទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា មុនចេញបំពេញភារកិច្ចនៅប្រទេសទទួល
- ចងក្រងបណ្តាញពលករទេសន្តរប្រវេសន៍កម្ពុជា ដែលកំពុងធ្វើការនៅប្រទេសទទួល
- សិក្សា និងរៀបចំមជ្ឈមណ្ឌលគាំពារពលករទេសន្តរប្រវេសន៍កម្ពុជា នៅតាមបណ្តាប្រទេសទទួល
- រៀបចំលិខិតបទដ្ឋានស្តីពីតួនាទី និងភារកិច្ចរបស់អនុព័ន្ធការងារ តំណាងអចិន្ត្រៃយ៍របស់ទីភ្នាក់ងារបញ្ជូនពលករ និងតំណាងសមាគមទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាប្រចាំនៅប្រទេសទទួល

### ៣.៤.៤. ការពង្រឹងយន្តការនៃការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៤.៤.ក. អត្ថប្រយោជន៍ដែលពលករទេសន្តរប្រវេសន៍កម្ពុជា ត្រូវទទួលបានស្របតាមការកំណត់ដោយច្បាប់នៃប្រទេសទទួលនៅពេលធ្វើមាតុភូមិនិវត្តន៍ ត្រូវបានធានាអន្តរាគមន៍ដោះស្រាយឱ្យបាន ១០០%

៣.៤.៤.ខ. អត្រានៃពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ បានទទួលព័ត៌មានអំពីឱកាសការងារ ការបណ្តុះបណ្តាលជំនាញ និងការធ្វើតេស្តសមត្ថភាពទទួលស្គាល់ជំនាញ កើនឡើង

៣.៤.៤.គ. វេទិកាការងារសម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ត្រូវបានរៀបចំយ៉ាងតិច ៦/ឆ្នាំ

៣.៤.៤.ឃ. របាយការណ៍ស្ថិតិទេសន្តរប្រវេសន៍ ត្រូវបានរៀបចំ

៣.៤.៤.ង. ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ បានធ្វើតេស្តទទួលស្គាល់ជំនាញ និងផ្តល់គុណវុឌ្ឍិ កើនឡើងដល់ ១០ ០០០នាក់/ឆ្នាំ នៅឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៤.៤.១. ពង្រឹងយន្តការគាំទ្រពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ដើម្បីធានាថាការទទួលបានប្រាក់ឈ្នួល របបសន្តិសុខសង្គម និងអត្ថប្រយោជន៍ផ្សេងៗ ស្របតាមការកំណត់ដោយច្បាប់នៃប្រទេសទទួល ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ១០០% ស្របតាមការកំណត់ដោយច្បាប់នៃប្រទេសទទួល
- ការផ្ទេរប្រាក់អត្ថប្រយោជន៍ផ្សេងៗ ដល់ពលករទេសន្តរប្រវេសន៍កម្ពុជា ឬសមាជិកគ្រួសារ ត្រូវបានអនុវត្ត
- របាយការណ៍ស្ថិតិពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ត្រូវបានរៀបចំ និងផ្សព្វផ្សាយ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ជំរុញទីភ្នាក់ងារជ្រើសរើសឯកជន សម្របសម្រួលជូនពលករឱ្យទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ មុនធ្វើមាតុភូមិនិវត្តន៍
- សម្របសម្រួល និងអន្តរាគមន៍ជាមួយភាគីពាក់ព័ន្ធក្នុងការផ្ទេរប្រាក់អត្ថប្រយោជន៍ផ្សេងៗ ដល់ពលករទេសន្តរប្រវេសន៍កម្ពុជា ឬសមាជិកគ្រួសារដែលស្ថិតនៅប្រទេសកម្ពុជា
- រៀបចំរបាយការណ៍លទ្ធផលអន្តរាគមន៍ដោះស្រាយ ទាក់ទងជាមួយនឹងអត្ថប្រយោជន៍ដែលពលករទេសន្តរប្រវេសន៍កម្ពុជាត្រូវទទួលបានស្របតាមការកំណត់ដោយច្បាប់នៃប្រទេសទទួល
- តម្រូវឱ្យទីភ្នាក់ងារជ្រើសរើសឯកជន ធ្វើរបាយការណ៍ប្រចាំខែស្តីពីការធ្វើមាតុភូមិនិវត្តន៍របស់ពលករទេសន្តរប្រវេសន៍កម្ពុជា មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំរបាយការណ៍ស្ថិតិពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ជាប្រចាំ

៣.៤.៤.២. ចរចាលើចល័តភាពរបបសន្តិសុខសង្គមដល់ពលករទេសន្តរប្រវេសន៍កម្ពុជា ឬសមាជិកគ្រួសារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គោលការណ៍ណែនាំអាស៊ានស្តីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ ត្រូវបានរៀបចំ
- ចំនួនកិច្ចប្រជុំទ្វេភាគី និងពហុភាគី ដើម្បីសិក្សាអំពីនីតិវិធីក្នុងការធ្វើចល័តភាពរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ពេលធ្វើមាតុភូមិនិវត្តន៍
- កិច្ចព្រមព្រៀងស្តីពីចល័តភាពរបបសន្តិសុខសង្គមជាមួយប្រទេសទទួល ត្រូវបានចុះហត្ថលេខាយ៉ាងតិច ១ ត្រឹមឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំកិច្ចប្រជុំពិភាក្សាស្តីពីគោលការណ៍ណែនាំអាស៊ានស្តីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ជាមួយរដ្ឋជាសមាជិកអាស៊ាន និងភាគីពាក់ព័ន្ធ
- រៀបចំអនុម័តគោលការណ៍ណែនាំអាស៊ានស្តីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ ដោយរដ្ឋមន្ត្រីការងារអាស៊ាន
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ពហុភាគីរវាងប្រទេសបញ្ជូននិងប្រទេសទទួល ដើម្បីសិក្សាអំពីនីតិវិធីក្នុងការធ្វើចល័តភាពរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ពេលធ្វើមាតុភូមិនិវត្តន៍ ក្នុងក្របខណ្ឌអាស៊ាន
- រៀបចំកិច្ចប្រជុំទ្វេភាគី ជាមួយប្រទេសទទួល ដើម្បីសិក្សាអំពីនីតិវិធីក្នុងការធ្វើចល័តភាពរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ពេលធ្វើមាតុភូមិនិវត្តន៍
- ចរចា និងចុះកិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសទទួល ដើម្បីធ្វើចល័តភាពរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសារ

៣.៤.៤.៣ ជំរុញការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ចូលទីផ្សារការងារក្នុងស្រុក ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- បញ្ជីឈ្មោះពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ត្រូវបានរៀបចំ និងចែករំលែកជាមួយអង្គភាពសេវាការងារសាធារណៈ និងទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុកជាប្រចាំ

- ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាដែលបានចូលរួមវេទិកាការងារ កើនឡើង
- អត្រានៃពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ទទួលបានការងារធៀបនឹងចំនួនពលករចូលរួមសរុប

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងចែករំលែកបញ្ជីឈ្មោះពលករទេសន្តរប្រវេសន៍កម្ពុជា ដែលធ្វើមាតុភូមិនិវត្តន៍ជាមួយអង្គភាពសេវាការងារសាធារណៈ និងទីភ្នាក់ងារឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក
- ផ្សព្វផ្សាយបណ្ណព័ត៌មានអំពីឱកាស និងតម្រូវការការងារក្នុងស្រុក ដល់ពលករដែលធ្វើមាតុភូមិនិវត្តន៍
- សហការរៀបចំវេទិកាការងារ និងសម្របសម្រួលពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ចូលរួមវេទិកាការងារ
- ធ្វើការសហការជាមួយសហគ្រាស គ្រឹះស្ថាន ដែលមានម្ចាស់ជាជនជាតិនៃប្រទេសទទួលដើម្បីរៀបចំឱ្យមានកម្មវិធីជ្រើសរើសពលករទេសន្តប្រវេសន៍កម្ពុជា ដែលធ្វើមាតុភូមិនិវត្តន៍
- រៀបចំរបាយការណ៍អំពីពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ទទួលបានការងារតាមរយៈវេទិកាការងារ

៣.៤.៤.៤ ជំរុញពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ចុះឈ្មោះវាយតម្លៃជំនាញ តេស្តសមត្ថភាព និងផ្តល់គុណវុឌ្ឍិ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- បញ្ជីឈ្មោះពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ត្រូវបានរៀបចំ និងចែករំលែកជាមួយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈរដ្ឋ និងឯកជនជាប្រចាំ
- ពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញ កើនឡើង
- ពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ បានធ្វើតេស្តទទួលស្គាល់ជំនាញ និងផ្តល់គុណវុឌ្ឍិ កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងចែករំលែកបញ្ជីឈ្មោះពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ជាមួយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈរដ្ឋ និងឯកជន

- សហការផ្សព្វផ្សាយអំពីព័ត៌មាន វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសសម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍
- សហការ និងពង្រីកវិស័យនិងជំនាញដែលត្រូវរៀបចំធ្វើតេស្តសមត្ថភាពទទួលស្គាល់ជំនាញសម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍
- ជំរុញពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ចុះឈ្មោះធ្វើតេស្តសមត្ថភាពទទួលស្គាល់ជំនាញពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍
- រៀបចំរបាយការណ៍ស្ថិតិពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ បានធ្វើតេស្តទទួលស្គាល់ជំនាញ និងផ្តល់គុណវុឌ្ឍិ

៣.៤.៤.៥ រៀបចំយន្តការទំនាក់ទំនងជាប្រចាំជាមួយគ្រួសាររបស់ពលករទេសន្តរប្រវេសន៍ ដើម្បីផ្តល់ព័ត៌មានរបស់ពលករទេសន្តរប្រវេសន៍កម្ពុជា និងអន្តរាគមន៍នៅពេលមានអាសន្ន ព្រមទាំងចងក្រងបណ្តាញ និងផ្សព្វផ្សាយបទពិសោធនៃភាពជោគជ័យរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គ្រួសាររបស់ពលករទេសន្តរប្រវេសន៍បានទទួលព័ត៌មានអំពីស្ថានភាពការងារ និងសុវត្ថិភាពរបស់ពលករទេសន្តរប្រវេសន៍កម្ពុជា
- វីដេអូស្តីពីភាពជោគជ័យរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ត្រូវបានផលិត និងផ្សព្វផ្សាយយ៉ាងតិច ២វីដេអូ/ឆ្នាំ
- ពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ចំនួន ៥០០នាក់/ឆ្នាំ ត្រូវបានចុះជួប

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ទំនាក់ទំនង និងផ្តល់ព័ត៌មានជាប្រចាំអំពីស្ថានភាពរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាដល់គ្រួសារ
- រៀបចំទិវាទេសន្តរប្រវេសន៍អន្តរជាតិ ១៨ ធ្នូ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំបណ្តាញពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសទទួល
- រៀបចំចុះជួបពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍នៅតាមមូលដ្ឋានចំនួន ៤ដង/ឆ្នាំ និងកម្មវិធីជួបជុំប្រចាំឆ្នាំចំនួន ១ដង/ឆ្នាំ
- ផលិត និងផ្សព្វផ្សាយវីដេអូអំពីបទពិសោធ នៃភាពជោគជ័យរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍

### ៣.៤.៥. ការពង្រឹងការគ្រប់គ្រងហត្ថពលកម្មបរទេសនៅកម្ពុជា

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម៖

៣.៤.៥.ក. ប្រព័ន្ធគ្រប់គ្រងហត្ថពលកម្មបរទេស ត្រូវបានពង្រីកមុខងារ និងធ្វើបច្ចុប្បន្នភាព

៣.៤.៥.ខ. ចំនួនហត្ថពលកម្មបរទេសជំនាញ ត្រូវបានអនុញ្ញាតស្របទៅតាមតម្រូវការទីផ្សារការងារក្នុងប្រទេស

៣.៤.៥.គ. អត្រាអនុលោមភាពរបស់សហគ្រាស គ្រឹះស្ថាន ដែលទទួលបានការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស កើនឡើង

៣.៤.៥.ឃ. របាយការណ៍វាយតម្លៃតម្រូវការ និងស្ថិតិនៃការប្រើប្រាស់ហត្ថពលកម្មបរទេសនៅកម្ពុជាតាមវិស័យ និងជំនាញ ត្រូវបានរៀបចំ និងផ្សព្វផ្សាយ

៣.៤.៥.ង. យន្តការផ្ទេរជំនាញពីហត្ថពលកម្មបរទេសជំនាញមកយុវជនខ្មែរ ត្រូវបានសិក្សា រៀបចំ និងអនុវត្តចាប់ពីឆ្នាំ២០២៦

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពចំនួន ៥ ដូចខាងក្រោម៖

៣.៤.៥.១ ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងហត្ថពលកម្មបរទេស និងសិក្សាលទ្ធភាពពង្រីកមុខងារប្រព័ន្ធសម្រាប់ប្រើប្រាស់ជាមួយក្រសួងពាក់ព័ន្ធ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម៖

- សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (API) ជាមួយប្រព័ន្ធពាក់ព័ន្ធនៅក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានអនុវត្តក្នុងឆ្នាំ២០២៦
- មុខងារគ្រប់គ្រងអធិការកិច្ចហត្ថពលកម្មបរទេស ត្រូវបានរៀបចំ និងដំណើរការ
- លទ្ធភាពពង្រីកមុខងារប្រព័ន្ធគ្រប់គ្រងហត្ថពលកម្មបរទេសជាមួយក្រសួងពាក់ព័ន្ធ ត្រូវបានសិក្សារៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម៖

- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងហត្ថពលកម្មបរទេស
- សិក្សាលទ្ធភាពធ្វើសន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (API) ជាមួយប្រព័ន្ធពាក់ព័ន្ធនៅក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំ និងបង្កើតមុខងារគ្រប់គ្រងអធិការកិច្ចហត្ថពលកម្មបរទេស
- រៀបចំកិច្ចប្រជុំស្តីពីការពិនិត្យលទ្ធភាពក្នុងការតភ្ជាប់រវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេសជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្លាស់ប្តូរទិន្នន័យ



ហ

- រៀបចំ និងបង្កើតមុខងារគ្រប់គ្រងហត្ថពលកម្មបរទេសជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

៣.៤.៥.២ ធ្វើឱ្យប្រសើរឡើង និងជំរុញការផ្សព្វផ្សាយការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រើប្រាស់ហត្ថពលកម្មបរទេស និងនីតិវិធីសម្រាប់ជនបរទេសមកធ្វើការនៅកម្ពុជា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ច្បាប់ស្តីពីការងារ ត្រង់ជំពូកទី១០ ផ្នែកទី២ ត្រូវបានធ្វើវិសោធនកម្ម និងអនុក្រឹត្យស្តីពីការគ្រប់គ្រងហត្ថពលកម្មបរទេស ត្រូវបានសិក្សារៀបចំ និងកែសម្រួល
- លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងហត្ថពលកម្មបរទេស និងនីតិវិធីសម្រាប់ជនបរទេសមកធ្វើការនៅកម្ពុជា ត្រូវបានធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយ
- នីតិវិធីសម្រាប់ជនបរទេសមកធ្វើការនៅកម្ពុជា ត្រូវបានផលិត និងផ្សព្វផ្សាយដល់ស្ថានតំណាងបរទេសប្រចាំនៅប្រទេសកម្ពុជា ស្ថានទូតកម្ពុជាប្រចាំប្រទេសគោលដៅ និងនៅតាមច្រកចេញ-ចូលអន្តរជាតិ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ ត្រង់ជំពូកទី១០ ផ្នែកទី២ ការប្រើប្រាស់ហត្ថពលកម្មបរទេស
- រៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងហត្ថពលកម្មបរទេស និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងហត្ថពលកម្មបរទេស
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រើប្រាស់ហត្ថពលកម្មបរទេសដល់សហគ្រាស គ្រឹះស្ថាន និងភាគីពាក់ព័ន្ធ
- រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីស្តីពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រើប្រាស់ហត្ថពលកម្មបរទេស ២ដង/ឆ្នាំ
- ផលិត និងផ្សព្វផ្សាយវីដេអូឃ្លីប និងបណ្ណផ្សព្វផ្សាយដែលបកប្រែជាភាសាបរទេសអំពីនីតិវិធីធ្វើការដោយស្របច្បាប់សម្រាប់ជនបរទេស ដល់ម្ចាស់ ឬនាយក ឬតំណាងសហគ្រាស គ្រឹះស្ថាន និងភាគីពាក់ព័ន្ធ ព្រមទាំងស្ថានតំណាងបរទេសប្រចាំនៅប្រទេសកម្ពុជា ស្ថានទូតកម្ពុជាប្រចាំប្រទេសគោលដៅ និងនៅតាមច្រកចេញ-ចូលអន្តរជាតិ

៣.៤.៥.៣ ពង្រឹងយន្តការគ្រប់គ្រង និងចុះអធិការកិច្ចហត្ថពលកម្មបរទេស ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គោលដៅចុះអធិការកិច្ចហត្ថពលកម្មបរទេសប្រចាំឆ្នាំ ត្រូវបានកំណត់

- ចំនួនសហគ្រាស គ្រឹះស្ថានដែលទទួលបានការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស ស្របតាមច្បាប់ស្តីពីការងារ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈវិស្វករកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ កើនឡើង
- ចំនួនហត្ថពលកម្មបរទេសដែលមានបណ្ណការងារ និងសៀវភៅការងារជនបរទេស កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំនីតិវិធី និងកំណត់គោលដៅចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេសប្រចាំឆ្នាំ ដោយសហការជាមួយអគ្គនាយកដ្ឋានអន្តោប្រវេសន៍
- ចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេសតាមបណ្តាសហគ្រាស គ្រឹះស្ថាន និងដាក់កំហិត និង/ឬផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ផ្តល់លិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស បញ្ជិកាកិច្ចសន្យាការងារជនបរទេស បញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកជនបរទេស (ចូល-ចេញ) បណ្ណការងារ និងសៀវភៅការងារជនបរទេស និងវិញ្ញាបនបត្រចុះបញ្ជីវិស្វករបរទេស/វិញ្ញាបនបត្រចុះបញ្ជីវិស្វករអាជីពឆ្នើមបរទេស
- រៀបចំរបាយការណ៍ស្ថិតិ និងវាយតម្លៃតម្រូវការនៃការប្រើប្រាស់ហត្ថពលកម្មបរទេសនៅកម្ពុជាតាមវិស័យនិងជំនាញ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងទិន្នន័យវិស្វករបរទេសមកធ្វើការនៅកម្ពុជា

៣.៤.៥.៤ រៀបចំយន្តការផ្តល់ការអនុញ្ញាត និងគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន ដែលផ្តល់សេវាជ្រើសរើសជនបរទេសដែលមានជំនាញ មកធ្វើការក្នុងប្រទេស ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- អនុក្រឹត្យ និងប្រកាសពាក់ព័ន្ធនឹងការអនុញ្ញាតឱ្យទីភ្នាក់ងារជ្រើសរើសឯកជនដែលផ្តល់សេវាជ្រើសរើសជនបរទេសជំនាញមកធ្វើការក្នុងប្រទេស ត្រូវបានរៀបចំ និងផ្សព្វផ្សាយ
- ចំនួនទីភ្នាក់ងារជ្រើសរើសឯកជនផ្តល់សេវាជ្រើសរើសជនបរទេសជំនាញមកធ្វើការក្នុងប្រទេស ត្រូវបានចុះបញ្ជី
- ចំនួនជនបរទេសជំនាញមកធ្វើការនៅកម្ពុជា តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារពាក់ព័ន្ធនឹងការអនុញ្ញាតឱ្យទីភ្នាក់ងារជ្រើសរើសឯកជនដែលផ្តល់សេវាជ្រើសរើសជនបរទេសជំនាញមកធ្វើការក្នុងប្រទេស
- រៀបចំអនុក្រឹត្យ និងប្រកាសពាក់ព័ន្ធនឹងការអនុញ្ញាតឱ្យទីភ្នាក់ងារជ្រើសរើសឯកជនដែលផ្តល់សេវាជ្រើសរើសជនបរទេសជំនាញមកធ្វើការក្នុងប្រទេស
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យ និងប្រកាសពាក់ព័ន្ធនឹងការអនុញ្ញាតទីភ្នាក់ងារជ្រើសរើសឯកជនដែលផ្តល់សេវាជ្រើសរើសជនបរទេសជំនាញ មកធ្វើការក្នុងប្រទេស
- រៀបចំនីតិវិធីចុះបញ្ជីទីភ្នាក់ងារជ្រើសរើសឯកជនដែលផ្តល់សេវាជ្រើសរើសជនបរទេសជំនាញ មកធ្វើការក្នុងប្រទេស
- ប្រមូលចងក្រងទិន្នន័យជនបរទេសជំនាញ ដែលមកធ្វើការនៅកម្ពុជាតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនដែលផ្តល់សេវាជ្រើសរើសជនបរទេសជំនាញ

៣.៤.៥.៥ រៀបចំយន្តការអនុវត្តការផ្ទេរជំនាញពីហត្ថពលកម្មបរទេសមកយុវជនខ្មែរក្នុងប្រទេស ជាពិសេសនៅក្នុងចំណោមអ្នកគ្រប់គ្រងថ្នាក់កណ្តាល អ្នកបច្ចេកទេស និងជំនាញផ្សេងៗ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការផ្ទេរជំនាញមកយុវជនខ្មែរ ត្រូវបានរៀបចំ និងផ្សព្វផ្សាយឱ្យបានមុនឆ្នាំ២០២៦
- វគ្គបណ្តុះបណ្តាលស្តីពីការផ្ទេរជំនាញពីជនបរទេស ត្រូវបានរៀបចំ
- ការផ្ទេរជំនាញពីជនបរទេសដល់យុវជនខ្មែរ តាមរយៈការហាត់ការនៅកន្លែងធ្វើការ ត្រូវបានជំរុញឱ្យអនុវត្ត

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងការផ្ទេរជំនាញមកយុវជនខ្មែរ
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងការផ្ទេរជំនាញមកយុវជនខ្មែរ
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការផ្ទេរជំនាញពីជនបរទេសដល់យុវជនខ្មែរ
- ជំរុញម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ឱ្យអនុវត្តការផ្ទេរជំនាញពីជនបរទេសដល់យុវជនខ្មែរតាមរយៈការហាត់ការនៅកន្លែងធ្វើការ
- ជំរុញម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ធ្វើការបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ (Reskilling) និងបង្កើនជំនាញ (Upskilling) ដល់កម្មករនិយោជិតខ្មែរមុនការផ្តល់លិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស

ដើម្បីសម្រេចបានជោគជ័យលើការអនុវត្តនូវយុទ្ធសាស្ត្រអាទិភាពខាងលើ, អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវរៀបចំការពិនិត្យតាមដានលទ្ធផលនៃការអនុវត្តការងារជារៀងរាល់ខែ ត្រីមាស ឆមាស ប្រាំបួនខែ ជាពិសេស ការពិនិត្យវាយតម្លៃប្រចាំឆ្នាំ ដើម្បីវាយតម្លៃអំពីសមិទ្ធកម្មការងារសម្រេចបាន បញ្ហាប្រឈមដែលត្រូវកែលម្អ វិធានការអន្តរាគមន៍នានាដែលត្រូវដាក់ចេញសំដៅធានាឱ្យបាននូវការចូលរួមអនុវត្តពីគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ ការទទួលខុសត្រូវ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពជោគជ័យខ្ពស់។ យុទ្ធសាស្ត្រអាទិភាពនេះ ត្រូវបានចាត់ទុកថាជាឯកសាររស់រវើក ដែលសូចនាករកម្រិតយុទ្ធសាស្ត្រ សូចនាករកម្រិតកម្មវិធី ចង្កោមសកម្មភាព សូចនាករចង្កោមសកម្មភាព និងសកម្មភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ អាចនឹងត្រូវកែសម្រួល និងបច្ចុប្បន្នភាពជាយថាហេតុ ដើម្បីឱ្យស្របនឹងបរិការណ៍ជាក់ស្តែង និងការវិវត្តនៃវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ, វិធានការណ៍ និងសូចនាករគន្លឹះជាក់ស្តែងនានាដែលរាជរដ្ឋាភិបាល នឹងបន្តដាក់ចេញទៅតាមក្របខណ្ឌពេលវេលា ព្រមទាំងស្របទៅតាមការវិវត្តនៃសង្គម-សេដ្ឋកិច្ច ទាំងនៅក្នុងតំបន់ និងសកលលោក។

## ៣.៥- ការអភិវឌ្ឍរបបសន្តិសុខសង្គមស្របតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច

ប្រព័ន្ធសន្តិសុខសង្គម គឺជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធគាំពារសង្គម ដោយឈរលើការបង់ភាគទានជាកាតព្វកិច្ច ពីសំណាក់និយោជិត និងនិយោជក ទាំងក្នុងវិស័យឯកជន និងវិស័យសាធារណៈ និងពីនិវត្តជន និងប្រជាជននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងការបង់ភាគទានជំនួសមួយភាគ ឬទាំងស្រុងពីថវិកាជាតិ ដោយរាជរដ្ឋាភិបាលសម្រាប់ប្រជាជនក្រីក្រងាយរងគ្រោះ និងក្រុមជនគោលដៅមួយចំនួន។ តាមរយៈការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន បានចូលរួមធានាឱ្យមានសមធម៌ និងសាមគ្គីធម៌សង្គម និងជួយលើកកម្ពស់សុខុមាលភាព និងជីវភាពប្រជាពលរដ្ឋបានជាទីកត់សម្គាល់។ ទន្ទឹមនឹងវឌ្ឍនភាពនេះ ការអនុវត្តរបបសន្តិសុខសង្គមក៏នូវមិនទាន់បានអនុវត្តពេញលេញទាំងវិសាលភាពគ្របដណ្តប់ និងរបប ព្រមទាំងជួបប្រទះបញ្ហាប្រឈមមួយចំនួនពី ការវិវត្តស្ថានភាពសង្គម-សេដ្ឋកិច្ច ប្រជាសាស្ត្រ ហានិភ័យវិជ្ជាជីវៈ និងហានិភ័យសរីរៈសាស្ត្រជាដើម។ ដូច្នេះក្នុងអាណត្តិថ្មីនេះ រាជរដ្ឋាភិបាលនឹងបន្តខិតខំប្រឹងប្រែងក្នុងការពង្រឹង និងពង្រីកការផ្តល់ការធានាការពារដល់សន្តិសុខ និងស្ថិរភាពប្រាក់ចំណូលរបស់កម្មករនិយោជិតទាំងក្នុងវិស័យឯកជន និងវិស័យសាធារណៈ និងនិវត្តជន ដើម្បីធានាការពារពីហានិភ័យដោយសារការឈឺថ្កាត់ មាតុភាព គ្រោះថ្នាក់ការងារ និកម្មភាព ពិការភាព ជរាភាព និងមរណភាព ដូចដែលបានរំលេចនៅត្រង់ **ចំណុចអាទិភាពទី១ ទី២ និងទី៣ នៃមុំទី៤ ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង បញ្ចកោណទី១ ការអភិវឌ្ឍមូលធនមនុស្ស នៃ "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"**។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវកម្មវិធីគោលនយោបាយអាទិភាពបន្ថែមចំនួន ២ ដែលត្រូវអនុវត្តភ្លាមៗនៅក្នុងឆ្នាំ២០២៣ ដែលរួមមាន (១) ការផ្តល់ការថែទាំសុខភាពឆ្ពោះទៅកម្មវិធីគ្របដណ្តប់សុខភាពជាសកល ដែលនឹងធ្វើឱ្យប្រជាជនប្រមាណ ៥លាននាក់

មានលទ្ធភាពទទួលបាននូវរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព។ **អនុលោមតាមទិសដៅអាទិភាពនៃ "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១" និង "កម្មវិធីនយោបាយអាទិភាព"** របស់រាជរដ្ឋាភិបាល ក្រសួងនឹងបន្តជំរុញការអភិវឌ្ឍរបបសន្តិសុខសង្គម ដល់កម្មករនិយោជិត និងមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បុគ្គលស្វ័យនិយោជន៍ អ្នកក្នុងបន្ទុក និងចូលរួមអនុវត្តគោលនយោបាយវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយក្រសួងបានដាក់ចេញនូវកម្មវិធីចំនួន ៥ រួមមាន÷ កម្មវិធីទី១ "ការពង្រឹង និងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គមស្របតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច" កម្មវិធីទី២ "ការពង្រឹង និងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម" កម្មវិធីទី៣ "ការលើកកម្ពស់ការយល់ដឹង និងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម" កម្មវិធីទី៤ "ការពង្រឹងការគ្រប់គ្រង និងចាត់ចែងមូលនិធិសន្តិសុខសង្គមដើម្បីបង្កើនប្រយោជន៍បន្ថែមដល់សមាជិក ប.ស.ស. និងវិស័យទំនាក់ទំនងវិជ្ជាជីវៈ" និងកម្មវិធីទី៥ "ការអភិវឌ្ឍសមត្ថភាពបច្ចេកទេសសន្តិសុខសង្គម" សំដៅធានាបាននូវសន្តិសុខសេដ្ឋកិច្ច រួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម។

សូចនាករកម្រិតយុទ្ធសាស្ត្រ ត្រូវសម្រេចឱ្យបានក្នុងការអនុវត្តយុទ្ធសាស្ត្រនេះមាន ៥ ដូចខាងក្រោម÷

៣.៥.ក. គ្រប់កម្មករនិយោជិតដែលធ្វើការនៅតាមសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីនៅ ប.ស.ស. ត្រូវបានធានាការគ្របដណ្តប់ដោយរបបសន្តិសុខសង្គម

៣.៥.ខ. ការទូទាត់តាវកាលិកសន្តិសុខសង្គម បានទាន់ពេលវេលា

៣.៥.គ. ការបង្កើនភាពពេញចិត្ត និងទំនុកចិត្តចំពោះការប្រើប្រាស់សេវាសន្តិសុខសង្គម តាមរយៈការកាត់បន្ថយអត្រានៃពាក្យបណ្តឹងក្រោម០,១%

៣.៥.ឃ. មូលនិធិសន្តិសុខសង្គម ត្រូវបានធានានិរន្តរភាព និងអនុលោមតាមគោលការណ៍ប្រុងប្រយ័ត្ន

៣.៥.ង. បរិវត្តកម្មបច្ចេកវិទ្យាទាំងស្រុង និងគ្រប់ជ្រុងជ្រោយនៃប្រតិបត្តិការប្រចាំថ្ងៃរបស់ ប.ស.ស.

ដើម្បីសម្រេចបាននូវសូចនាករកម្រិតយុទ្ធសាស្ត្រខាងលើនេះ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាពចំនួន ៥ ដូចខាងក្រោម÷

**៣.៥.១. ការពង្រឹង និងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម ស្របតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច**

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៥.១.ក. ចំនួនសមាជិក ប.ស.ស. កើនឡើង

៣.៥.១.ខ. ចំនួនសហគ្រាស កើនឡើងយ៉ាងតិច ៥ ០០០សហគ្រាស/ឆ្នាំ

៣.៥.១.គ. ចល័តភាពរបបសន្តិសុខសង្គម ត្រូវបានចុះកិច្ចព្រមព្រៀងយ៉ាងតិច ១ នៅឆ្នាំ២០២៨

៣.៥.១.ឃ. រាល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាលដែលស្នើសុំ និងគ្រប់លក្ខខណ្ឌ ត្រូវបានផ្តល់ជូនទាន់ពេលវេលា

៣.៥.១.ង. របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ ត្រូវបានសិក្សាបញ្ចប់

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៥.១.១. ពង្រឹង និងបង្កើនការចុះបញ្ជីស្ថាប័ន សហគ្រាស គ្រឹះស្ថានសំដៅធ្វើការពង្រីកការគ្របដណ្តប់ដល់ជនគោលដៅដទៃផ្សេងទៀតតាមរយៈយន្តការក្រសួងសាមី និងអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធ ឬអាជ្ញាធរមូលដ្ឋានទៅក្នុងរបបសន្តិសុខសង្គមជារបបភាគទានកាតព្វកិច្ច ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- សហគ្រាស គ្រឹះស្ថានថ្មី យ៉ាងតិច ៥ ០០០សហគ្រាស/ឆ្នាំ និងកម្មករនិយោជិតយ៉ាងតិច ៦០ ០០០នាក់/ឆ្នាំ ត្រូវបានចុះបញ្ជី
- ស្ថាប័ន និងបុគ្គលក្នុងវិស័យសាធារណៈដែលជាសមាជិក ប.ស.ស. ផ្នែកថែទាំសុខភាព ត្រូវបានធ្វើបច្ចុប្បន្នភាពជាប់ជាប្រចាំ
- អត្រានៃសហគ្រាស គ្រឹះស្ថាន មិនអនុវត្តកាតព្វកិច្ចចុះបញ្ជី ចំនួន ១០០% ត្រូវបានចាត់វិធានការជាពិសេសការផាកពិន័យយ៉ាងម៉ឺងម៉ាត់

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ចុះស្រាវជ្រាវ សហគ្រាស គ្រឹះស្ថានថ្មី
- ចុះអធិការកិច្ចបញ្ជិកា
- រៀបចំរបាយការណ៍បច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន និងសមាជិក ប.ស.ស.
- រៀបចំរបាយការណ៍បច្ចុប្បន្នភាពស្ថាប័ន និងបុគ្គលក្នុងវិស័យសាធារណៈដែលជាសមាជិក ប.ស.ស. ផ្នែកថែទាំសុខភាព
- រៀបចំឯកសារពិន័យអន្តរការណ៍លើការមិនអនុវត្តកាតព្វកិច្ចចុះបញ្ជី

៣.៥.១.២. ពង្រឹង និងបង្កើនការចុះបញ្ជីសមាជិក ប.ស.ស. ក្នុងរបបភាគទានដោយស្ម័គ្រចិត្តព្រមទាំងចូលរួមក្នុងការពង្រឹងការអនុវត្តមូលនិធិសមធមិសុខាភិបាល ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- សមាជិក ប.ស.ស. ក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់អ្នកនៅក្នុងបន្ទុក កើនឡើង
- សមាជិក ប.ស.ស. ក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ កើនឡើង

- សមាជិក ប.ស.ស. ក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវបានធ្វើបច្ចុប្បន្នភាពជាប់ជាប្រចាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ចុះផ្សព្វផ្សាយគ្រប់រូបភាព និងគ្រប់ទម្រង់ស្តីពីរបបសន្តិសុខសង្គមតាមរបបភាគទានដោយស្ម័គ្រចិត្ត
- រៀបចំយន្តការចុះបញ្ជិកាសមាជិកចល័តតាមទីប្រជុំជន
- ធ្វើបច្ចុប្បន្នភាពសមាជិក ប.ស.ស. នៃរបបភាគទានដោយស្ម័គ្រចិត្ត
- ពង្រឹងយន្តការនៃការបើកផ្តល់ប័ណ្ណមូលនិធិសមធមិសុខាភិបាល
- ធ្វើបច្ចុប្បន្នភាពប័ណ្ណមូលនិធិសមធមិសុខាភិបាល

៣.៥.១.៣ សហការពិនិត្យនិងកែសម្រួលលិខិតបទដ្ឋានគតិយុត្តសម្រាប់ការចុះបញ្ជី និងបន្តពង្រឹងសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជីក្រោមប្រព័ន្ធរួមតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅលើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange-CamDX) ដោយអនុវត្តគោលការណ៍តែមួយលើក ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- កិច្ចប្រជុំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការចុះបញ្ជី ត្រូវបានចូលរួមយ៉ាងតិច ២លើក/ឆ្នាំ
- ការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន ក្នុងប្រព័ន្ធ ប.ស.ស. តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ត្រូវបានពង្រឹង និងអភិវឌ្ឍន៍
- ប្រព័ន្ធចុះបញ្ជីក្រោមប្រព័ន្ធរួមតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានពង្រឹង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ចូលរួមកិច្ចប្រជុំរៀបចំលិខិតបទដ្ឋានជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការចុះបញ្ជី
- ធ្វើទំនើបកម្មប្រព័ន្ធចុះបញ្ជីសហគ្រាស គ្រឹះស្ថានរបស់ ប.ស.ស. ឱ្យស្របទៅនឹងថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)
- ចូលរួមកិច្ចប្រជុំរៀបចំប្រព័ន្ធចុះបញ្ជីក្រោមប្រព័ន្ធរួមតែមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ធ្វើសុខដុមនីយកម្មទិន្នន័យរវាងប្រព័ន្ធ ប.ស.ស. និងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (LACMS)
- ធ្វើបច្ចុប្បន្នភាពសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីក្នុងថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) មុនពេលធ្វើសុខដុមនីយកម្មជាមួយប្រព័ន្ធ ប.ស.ស.

៣.៥.១.៤ រៀបចំ ពិនិត្យ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តសម្រាប់អភិវឌ្ឍន៍របបសន្តិសុខសង្គម និងជំរុញកិច្ចប្រជុំពិភាក្សាជាមួយបណ្តាប្រទេសនានា សំដៅអនុវត្តនូវចល័តភាពរបបសន្តិសុខសង្គម ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- លិខិតបទដ្ឋានស្តីពីតាវកាលិករបបសន្តិសុខសង្គម ត្រូវបានរៀបចំ អនុវត្ត និងកែសម្រួល
- របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ ត្រូវបានសិក្សាបញ្ចប់
- របាយការណ៍ស្តីពីកិច្ចប្រជុំពិភាក្សាពីចល័តភាពរបបសន្តិសុខសង្គម ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូលដើម្បីកំណត់ប្រភេទជំងឺវិជ្ជាជីវៈ
- រៀបចំកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូល ដើម្បីពិនិត្យកែសម្រួលតាវកាលិករបបសន្តិសុខសង្គម និងពង្រីករបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់មន្ត្រីសាធារណៈ
- សិក្សាសមិទ្ធិលទ្ធភាពនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត
- ចូលរួមរៀបចំគោលការណ៍ណែនាំអាស៊ានស្តីពីចល័តភាពរបបសន្តិសុខសង្គម
- រៀបចំកិច្ចប្រជុំពិភាក្សាពីលទ្ធភាពចុះកិច្ចព្រមព្រៀងក្នុងការអនុវត្តចល័តភាពរបបសន្តិសុខសង្គម

៣.៥.១.៥ សិក្សាសមិទ្ធិលទ្ធភាពរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ ដោយសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ការិយាល័យនិកម្មភាពការងារ ត្រូវបានបង្កើត
- របាយការណ៍សិក្សាស៊ីជម្រៅលើបច្ចេកទេស និងហានិភ័យហិរញ្ញវត្ថុនៃរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ ត្រូវបានរៀបចំ
- សេចក្តីព្រាងលិខិតបទដ្ឋានពាក់ព័ន្ធនឹងផ្នែកនិកម្មភាពការងារ ត្រូវបានសិក្សា និងរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ប.ស.ស. ដើម្បីរៀបចំបង្កើតការិយាល័យនិកម្មភាពការងារ
- ចូលរួមទស្សនកិច្ចសិក្សាពីការអនុវត្តផ្នែកនិកម្មភាពការងារនៅបណ្តាប្រទេសពាក់ព័ន្ធ
- សហការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកការគាំទ្រផ្នែកបច្ចេកទេស
- រៀបចំវិភាគស្ថានភាពហានិភ័យហិរញ្ញវត្ថុផ្នែកនិកម្មភាពការងារ
- រៀបចំកិច្ចប្រជុំ សិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូល និងសិក្សាស៊ីជម្រៅលើបច្ចេកទេស ដើម្បីកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការត្រៀមដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ

### ៣.៥.២. ការពង្រឹង និងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៥.២.ក. អត្រានៃមូលដ្ឋានសុខាភិបាលសាធារណៈ ចំនួន ១០០% ត្រូវបានចុះកិច្ចព្រមព្រៀង

៣.៥.២.ខ. អត្រានៃមូលដ្ឋានសុខាភិបាលដៃគូដែលអនុវត្តត្រឹមត្រូវតាមកិច្ចព្រមព្រៀង យ៉ាងតិច ៩៥%

៣.៥.២.គ. ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ ត្រូវបានបើកផ្តល់ស្របតាមគោលការណ៍ទាន់ពេលវេលា

៣.៥.២.ឃ. ការទាមទារតាវកាលិក (រួមទាំងការបើកផ្តល់ប្រាក់ឧបត្ថម្ភនានា) ត្រូវបានទូទាត់ត្រឹមត្រូវ និងទាន់ពេលវេលា

៣.៥.២.ង. អត្រានៃសមាជិកទទួលរងពិការភាពដោយហានិភ័យការងារដែលបានស្នើសុំសេវារកការងារឡើងវិញ ត្រូវបានធ្វើសមាហរណកម្មជោគជ័យចូលទីផ្សារការងារ

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៥.២.១ ពង្រឹង និងបង្កើនគុណភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលរបស់មូលដ្ឋានសុខាភិបាលជាដៃគូ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- យន្តការត្រួតពិនិត្យមូលដ្ឋានសុខាភិបាលដែលស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ត្រូវបានពង្រឹង

- អត្រានៃមូលដ្ឋានសុខាភិបាល ដែលស្ថិតក្នុងគោលដៅត្រួតពិនិត្យផ្អែកលើកម្រិតចំណាត់ថ្នាក់ហានិភ័យ ចំនួន ១០០% ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀង
- អត្រានៃមូលដ្ឋានសុខាភិបាលដៃគូ ដែលរកឃើញអនុវត្តមិនត្រឹមត្រូវតាមកិច្ចព្រមព្រៀង ចំនួន ១០០% ត្រូវបានចាត់វិធានការជាពិសេសបញ្ចប់កិច្ចព្រមព្រៀង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ពង្រឹងការងារក្រុមប្រឹក្សាវេជ្ជសាស្ត្រលើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លក្ខខណ្ឌមូលដ្ឋានសុខាភិបាល
- ធ្វើបច្ចុប្បន្នភាពបញ្ជីត្រួតពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិមូលដ្ឋានសុខាភិបាល
- ត្រួតពិនិត្យសំណុំឯកសារ និងចុះពិនិត្យលក្ខខណ្ឌមូលដ្ឋានសុខាភិបាលដែលស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងឡើងវិញ
- ចាត់វិធានការចំពោះមូលដ្ឋានសុខាភិបាលដៃគូដែលមិនអនុវត្តតាមកិច្ចព្រមព្រៀង

៣.៥.២.២ សិក្សាវាយតម្លៃ និងពិនិត្យលទ្ធភាពនៃការកែសម្រួលលើឯកតាចំណាយនៃកញ្ចប់ព្យាបាលជំងឺឱ្យស្របតាមស្ថានភាពនៃទីផ្សារសុខភាព ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាល ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ទិន្នន័យជាមូលដ្ឋានព្យាករផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារ ត្រូវបានចងក្រង
- កញ្ចប់សេវាព្យាបាលផ្នែកថែទាំសុខភាព ត្រូវបានសិក្សា និងកែសម្រួល
- យន្តការទូទាត់ថ្លៃសេវាជាមួយមូលដ្ឋានសុខាភិបាល ត្រូវបានសិក្សា និងកែសម្រួល

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ត្រួតពិនិត្យ និងចងក្រងទិន្នន័យក្នុងផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារ
- រៀបចំសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រសម្រាប់ធ្វើរោគវិនិច្ឆ័យ និងការព្យាបាលផ្ដុំជាប្រភេទករណី
- រៀបចំនិយមន័យប្រភេទករណី និងសិក្សាថ្លៃសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ
- សិក្សា រៀបចំ និងកំណត់រោគវិនិច្ឆ័យ និងផ្ដុំរោគវិនិច្ឆ័យ
- រៀបចំបញ្ជីរោគវិនិច្ឆ័យ

៣.៥.២.៣ សិក្សា ចងក្រង កំណត់សេវាបង្ការសុខភាព និងប្រភេទជំងឺវិជ្ជាជីវៈ ដើម្បីធានានិរន្តរភាពមូលនិធិសន្តិសុខសង្គម តាមរយៈការលើកកម្ពស់សុខុមាលភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាជូនសមាជិក ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍ស្តីពីបញ្ហាសុខភាព ត្រូវបានសិក្សា និងចងក្រង
- របាយការណ៍ស្តីពីប្រភេទសេវាបង្ការសុខភាព ត្រូវបានសិក្សា និងរៀបចំ
- បញ្ជីប្រភេទជំងឺវិជ្ជាជីវៈ ត្រូវបានរៀបចំយ៉ាងយូរឆ្នាំ២០២៨

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំវិភាគទិន្នន័យប្រើប្រាស់សេវារបស់សមាជិក ប.ស.ស.
- ចុះស្រាវជ្រាវបញ្ហាសុខភាពជាមួយសមាជិក ប.ស.ស.
- កំណត់តម្រូវការសេវាបង្ការសុខភាព
- សិក្សាស្រាវជ្រាវពីជំងឺវិជ្ជាជីវៈដែលកើតលើសមាជិក ប.ស.ស. តាមវិស័យ
- រៀបចំសៀវភៅបញ្ជីបញ្ហាសុខភាព និងវិធានការបង្ការ

៣.៥.២.៤ ពង្រឹងសេវាទូទាត់ និងបើកផ្តល់តាវកាលិករបបសន្តិសុខសង្គម ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- អត្រានៃការទាមទារតាវកាលិករបស់សមាជិក ចំនួន ១០០% ត្រូវបានទូទាត់ទាន់ពេលវេលាក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ
- កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ដែលជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ ត្រូវបានបើកផ្តល់ទាន់ពេលវេលា
- អត្រានៃសំណើសុំទាមទាររបស់មូលដ្ឋានសុខាភិបាលដៃគូ ចំនួន ៩៥% ត្រូវបានទូទាត់ទាន់ពេលវេលាក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ត្រួតពិនិត្យ និងចេញសេចក្តីសម្រេចផ្តល់តាវកាលិកជូនសមាជិក ប.ស.ស.
- ត្រួតពិនិត្យ និងផ្តល់ប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ



ញ

- ត្រួតពិនិត្យ និងផ្តល់ប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ ជាមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យា
- ត្រួតពិនិត្យ និងផ្តល់ប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាលសម្រាប់កម្មករនិយោជិតជាស្ត្រីនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ត្រួតពិនិត្យ និងទូទាត់ថ្លៃសេវាជូនមូលដ្ឋានសុខាភិបាលដៃគូ

៣.៥.២.៥ ពង្រឹងសេវាស្តារនីតិសម្បទា និងសិក្សាលទ្ធភាពសហការជាមួយដៃគូផ្តល់សេវាបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ (TVET) អង្គភាពផ្តល់សេវាការងារសាធារណៈ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- មជ្ឈមណ្ឌលផ្តល់សេវាស្តារនីតិសម្បទា ត្រូវបានសិក្សាបង្កើត
- អត្រានៃសមាជិកដែលមានតម្រូវការសេវាស្តារនីតិសម្បទា ចំនួន ១០០% ទទួលសេវាបានទាន់ពេលវេលាមិនលើសពី ១៥ថ្ងៃ
- កិច្ចព្រមព្រៀងស្តីពីការសហការជាមួយដៃគូផ្តល់សេវាបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ អង្គភាពផ្តល់សេវាការងារសាធារណៈ និងអង្គភាពពាក់ព័ន្ធ ដើម្បីផ្តល់សេវាបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងសេវាការងារជូនសមាជិក ប.ស.ស. ដែលមានតម្រូវការ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ប.ស.ស.
- ពង្រឹងការផ្តល់សេវាស្តារនីតិសម្បទា
- ចុះកិច្ចព្រមព្រៀងជាមួយដៃគូផ្តល់សេវា
- សហការជាមួយអង្គភាពសុខុមាលភាព និងសំណងគ្រោះថ្នាក់ការងារនៃសាធារណរដ្ឋកូរ៉េ លើការបង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទា
- រៀបចំចងក្រងតម្រូវការជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាការងារ

### ៣.៥.៣. ការលើកកម្ពស់ការយល់ដឹង និងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៥.៣.ក. រាល់បញ្ហាបណ្តឹងផ្សេងៗ ត្រូវបានអន្តរាគមន៍យ៉ាងយូរ ២៤ម៉ោង

៣.៥.៣.ខ. សមាជិក ប.ស.ស. មានទំនុកចិត្តខ្ពស់លើការអនុវត្តរបបសន្តិសុខសង្គម យ៉ាងតិច ៩០%

៣.៥.៣.គ. សមាជិក ប.ស.ស. មានការយល់ដឹងពីតាវកាលិកនៃរបបសន្តិសុខសង្គម យ៉ាងតិច ៩០%

៣.៥.៣.ឃ. រថយន្តដឹកកម្មករនិយោជិតត្រូវបានកែលម្អឱ្យកាន់តែមានផាសុកភាព និងសុវត្ថិភាព យ៉ាងយូរត្រឹមឆ្នាំ២០២៧

៣.៥.៣.ង. រាល់សហគ្រាស គ្រឹះស្ថាន ដែលមិនអនុលោមតាមច្បាប់ត្រូវបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ដោយមិនមានការលើកលែង

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពចំនួន ៥ ដូចខាងក្រោម÷

៣.៥.៣.១ ពង្រឹងសេវាផ្តល់ព័ត៌មានអតិថិជន និងដោះស្រាយបណ្តឹង ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ប្រព័ន្ធផ្តល់ព័ត៌មាន ត្រូវបានអភិវឌ្ឍន៍ឱ្យកាន់តែប្រសើរឡើង
- អត្រានៃបញ្ហា ឬចម្ងល់របស់សមាជិក ចំនួន ៩៩% ត្រូវបានដោះស្រាយទាន់ពេលវេលាតាមរយៈប្រព័ន្ធផ្តល់ព័ត៌មាន
- អត្រានៃវិវាទ ឬបណ្តឹងតវ៉ា ចំនួន ៩៩% ត្រូវបានចាត់វិធានការយ៉ាងយូរ ១៥ថ្ងៃ តាមរយៈគណៈកម្មការដោះស្រាយវិវាទនៃ ប.ស.ស.

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- អភិវឌ្ឍន៍មជ្ឈមណ្ឌលព័ត៌មាន
- រៀបចំអភិវឌ្ឍន៍ប្រព័ន្ធផ្តល់ព័ត៌មាន
- ទទួលបញ្ហា ឬចម្ងល់របស់សមាជិកដើម្បីដោះស្រាយ
- ឆ្លើយតបព័ត៌មាន ទស្សនាវដ្តី និងអង្គភាពពាក់ព័ន្ធ
- ទទួលបណ្តឹងមកដោះស្រាយតាមរយៈគណៈកម្មការដោះស្រាយវិវាទនៃ ប.ស.ស.

៣.៥.៣.២ សហការបង្កើនការអប់រំ និងផ្សព្វផ្សាយអំពីរបបសន្តិសុខសង្គមដល់សមាជិក ប.ស.ស. និងសាធារណជនគ្រប់រូបភាព និងគ្រប់ទម្រង់ប្រកបដោយភាពប្រទាក់ក្រឡាគ្នា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- កម្មវិធីផ្សព្វផ្សាយអំពីអត្ថប្រយោជន៍របបសន្តិសុខសង្គមយ៉ាងតិច ២ ០២៥លើក/ឆ្នាំ និងមានអ្នកចូលរួមយ៉ាងតិច ២៦៨ ០០០នាក់/ឆ្នាំ ត្រូវបានរៀបចំ
- ការផ្សព្វផ្សាយតាមបណ្តាញសង្គម និងមធ្យោបាយផ្សព្វផ្សាយព័ត៌មានគ្រប់ប្រភេទ យ៉ាងតិច ៧០០លើក/ឆ្នាំ ត្រូវបានរៀបចំ
- លទ្ធផលអង្កេតអំពីទំនុកចិត្តលើប្រសិទ្ធភាព ស័ក្តិសិទ្ធភាពនៃការអនុវត្តរបបសន្តិសុខសង្គម ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំផ្សព្វផ្សាយអំពីអត្ថប្រយោជន៍របបសន្តិសុខសង្គមដល់សមាជិក ប.ស.ស.
- រៀបចំផ្សព្វផ្សាយបែបទំនើប និងបែបប្រពៃណី
- ចុះកិច្ចព្រមព្រៀងជាមួយគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអប់រំ និងបញ្ជ្រាបការយល់ដឹងពីសិទ្ធិជាមូលដ្ឋាននៃរបបសន្តិសុខសង្គម
- រៀបចំការអង្កេតវាយតម្លៃពីការយល់ដឹង និងភាពពេញចិត្តនៃការអនុវត្តរបបសន្តិសុខសង្គម
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើការផ្តល់សេវារបបសន្តិសុខសង្គមជាមួយភាគីពាក់ព័ន្ធ

៣.៥.៣.៣ ពង្រឹងការអប់រំ និងផ្សព្វផ្សាយលើកកម្ពស់សុខុមាលភាព ការបង្ការហានិភ័យការងារ និងការគ្រប់គ្រងហិរញ្ញវត្ថុ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ការផ្សព្វផ្សាយស្តីពីសុវត្ថិភាពចរាចរណ៍ពេលធ្វើដំណើរ និងលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ អត្ថប្រយោជន៍របបសន្តិសុខសង្គម និងការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានរៀបចំ យ៉ាងតិច ៩៦០វគ្គ/ឆ្នាំ និងមានអ្នកចូលរួម យ៉ាងតិច ១២៨ ០០០នាក់/ឆ្នាំ
- រាល់វិធានការទប់ស្កាត់ និងសង្គ្រោះបន្ទាន់ករណីទទួលរងហានិភ័យការងារ ត្រូវបានចុះអន្តរាគមន៍ភ្លាមៗ
- សេវាបង្ការសុខភាព និងលើកកម្ពស់សុខភាព ត្រូវបានផ្សព្វផ្សាយយ៉ាងតិច ៤០ ០០០នាក់/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំផ្សព្វផ្សាយស្តីពីសុវត្ថិភាពចរាចរណ៍ពេលធ្វើដំណើរ លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គមដល់អ្នកបើកបររថយន្តដឹកកម្មករ និងកម្មករនិយោជិត
- ចុះត្រួតពិនិត្យ និងចាត់វិធានការទៅដល់និយោជក ដើម្បីទប់ស្កាត់ករណីសន្លប់របស់កម្មករនិយោជិតនៅកន្លែងធ្វើការ
- ចុះសួរសុខទុក្ខសមាជិក ប.ស.ស. ដែលទទួលរងហានិភ័យការងារ
- រៀបចំផ្សព្វផ្សាយសេវាបង្ការសុខភាព និងលើកកម្ពស់សុខភាពដល់សមាជិក ប.ស.ស.
- រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយអំពីការគ្រប់គ្រងហិរញ្ញវត្ថុ ជាពិសេសការត្រៀមខ្លួនមុនចូលនិវត្តន៍

៣.៥.៣.៤ សិក្សា សហការ និងរៀបចំមធ្យោបាយធ្វើដំណើរសមរម្យសម្រាប់កម្មករនិយោជិត ដើម្បីកាត់បន្ថយអត្រានៃគ្រោះថ្នាក់ចរាចរណ៍រថយន្តដឹកកម្មករនិយោជិត សំដៅលើកកម្ពស់កម្មវិធីបង្ការហានិភ័យការងារ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- បញ្ជីអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ
- រថយន្តដឹកអ្នកដំណើរសម្រាប់ដឹកកម្មករនិយោជិតដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន ឬអង្គភាពណាមួយច្បាស់លាស់ ត្រូវបានសិក្សា
- របាយការណ៍ស្តីពីការតាមដានរថយន្តដឹកកម្មករនិយោជិតប្រភេទដឹកទំនិញឱ្យមានការផ្លាស់ប្តូរ និងកែច្នៃកៅអីអង្គុយត្រឹមត្រូវ ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំបញ្ជីបច្ចុប្បន្នភាពអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត
- បង្កើតក្រុមការងារជំរុញការផ្លាស់ប្តូររថយន្តដឹកកម្មករនិយោជិត ដែលស្របតាមបទដ្ឋានបច្ចេកទេស និងជាសុកភាព
- រៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ដើម្បីសិក្សាជម្រើសក្នុងការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត
- រៀបចំកិច្ចប្រជុំជាមួយម្ចាស់រថយន្តបើកបរដឹកកម្មករប្រភេទដឹកទំនិញឱ្យមានការផ្លាស់ប្តូរ និងកែច្នៃកៅអីអង្គុយត្រឹមត្រូវ
- ពង្រឹងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្តដឹកម្មករនិយោជិតប្រភេទដឹកទំនិញ និងប្រភេទដឹកអ្នកដំណើរ

៣.៥.៣.៥ ពង្រឹងអនុលោមភាព ការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងចាត់វិធានការចាំបាច់ដោយការធ្វើសមាហរណកម្មនៃប្រព័ន្ធអធិការកិច្ចតែមួយ និងតាមរយៈអធិការសន្តិសុខសង្គម ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- អធិការសន្តិសុខសង្គម ត្រូវបានតែងតាំង
- គ្រប់សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីក្នុងថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងប្រព័ន្ធ ប.ស.ស. យ៉ាងយូរត្រឹមឆ្នាំ២០២៨
- របាយការណ៍ស្តីពីការចុះអធិការកិច្ចការងារតែមួយតាមសហគ្រាស គ្រឹះស្ថាន ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- បង្កើតគណៈកម្មការប្រឡងជ្រើសរើសអធិការសន្តិសុខសង្គម
- បណ្តុះបណ្តាលមន្ត្រីអធិការសន្តិសុខសង្គម
- ចុះស្រាវជ្រាវ និងជំរុញសហគ្រាសក្នុងថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ដែលមិនទាន់បានចុះបញ្ជីនៅក្នុងប្រព័ន្ធ ប.ស.ស.
- ចុះអធិការកិច្ចតែមួយតាមសហគ្រាស គ្រឹះស្ថាន
- រៀបចំលិខិតសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីសម្រួលការអនុវត្តច្បាប់ជាមួយសហគ្រាស គ្រឹះស្ថាន

**៣.៥.៤. ការពង្រឹងការគ្រប់គ្រង និងចាត់ចែងមូលនិធិសន្តិសុខសង្គម ដើម្បីបង្កើនប្រយោជន៍បន្ថែមដល់សមាជិក ប.ស.ស. និងវិស័យទំនាក់ទំនងវិជ្ជាជីវៈ**

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៥.៤.ក. គោលការណ៍ប្រុងប្រយ័ត្នគ្រប់ផ្នែកនៃរបបសន្តិសុខសង្គម ត្រូវបានអនុវត្ត និងរក្សាបានអនុលោមភាព ១០០%

៣.៥.៤.ខ. អត្រានៃចំណាយប្រតិបត្តិការតិចជាង ១០%/ឆ្នាំ នៃចំណូលភាគទាន

៣.៥.៤.គ. អត្រាភាគទាននៃរបបសន្តិសុខសង្គម ត្រូវបានធានាយ៉ាងហោចស្មើនឹងអត្រានៃចំណូលគ្រប់ចំណាយគ្រប់ (Pay As You Go-PAYG)

៣.៥.៤.ឃ. ប្រាក់ត្រៀមបម្រុង ត្រូវបានធានាស្របតាមផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម

៣.៥.៤.ង. ផលនៃការវិនិយោគទទួលបានយ៉ាងតិច ៥%/ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពចំនួន ៥ ដូចខាងក្រោម÷

៣.៥.៤.១ ពង្រឹងការបង់ភាគទានតាមរយៈការត្រួតពិនិត្យ តាមដាន និងចាត់វិធានការ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- អត្រានៃសហគ្រាស គ្រឹះស្ថានដាក់ឱ្យជាប់ភាគទាន ចំនួន ១០០% បានបង់ភាគទាន
- អត្រាបង់ភាគទានរបស់សមាជិក ប.ស.ស. ជាបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកកើនឡើង
- អត្រានៃសហគ្រាស គ្រឹះស្ថាន មិនអនុវត្តកាតព្វកិច្ចបង់ភាគទាន ចំនួន ១០០% ត្រូវបានចាត់វិធានការជាពិសេសការផាកពិន័យយ៉ាងម៉ឺងម៉ាត់

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំស្តង់ដាប្រតិបត្តិការគ្រប់ជ្រុងជ្រោយសម្រាប់តាមដាន ត្រួតពិនិត្យ និងចាត់វិធានការដើម្បីជំរុញការបង់ភាគទាន
- តាមដាន និងត្រួតពិនិត្យស្ថានភាពនៃការបង់ភាគទាន ដោយយន្តការផ្ទៃក្នុង
- តាមដាន និងត្រួតពិនិត្យស្ថានភាពនៃការបង់ភាគទានដោយយន្តការសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- ចាត់វិធានការជំរុញការបង់ភាគទាន និងផាកពិន័យ
- រៀបចំឯកសារពិន័យអន្តរការណ៍លើការមិនអនុវត្តកាតព្វកិច្ចបង់ភាគទាន

៣.៥.៤.២ ពង្រឹងការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ផែនការថវិកា ផែនការយុទ្ធសាស្ត្រថវិកា និងយន្តការតាមដាន និងវាយតម្លៃ ត្រូវបានអនុវត្តជាប់ជាប្រចាំ
- របាយការណ៍ហិរញ្ញវត្ថុ និងយន្តការតាមដាន និងវាយតម្លៃ ត្រូវបានអនុវត្តជាប់ជាប្រចាំ
- របាយការណ៍តាមដាន និងត្រួតពិនិត្យចំណូល និងចំណាយរបស់ ប.ស.ស. ត្រូវបានអនុវត្តជាប់ជាប្រចាំ

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុកថវិកា
- រៀបចំសៀវភៅផែនការយុទ្ធសាស្ត្រថវិកា
- អនុវត្តផែនការថវិកា ផែនការយុទ្ធសាស្ត្រថវិកា និងយន្តការតាមដាន និងវាយតម្លៃ
- ត្រួតពិនិត្យ និងតាមដានការងារហិរញ្ញវត្ថុ
- ត្រួតពិនិត្យ និងតាមដានចំណូល និងចំណាយរបស់ ប.ស.ស.

៣.៥.៤.៣ សិក្សា តាមដាន និងវាយតម្លៃស្ថានភាពហានិភ័យហិរញ្ញវត្ថុផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន ដើម្បីការពារអត្ថប្រយោជន៍ជូនសមាជិក ប.ស.ស. ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍ស្ថានភាពហានិភ័យហិរញ្ញវត្ថុផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ត្រូវបានរៀបចំ
- របាយការណ៍ស្ថានភាពហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធន ត្រូវបានរៀបចំ
- សៀវភៅគោលនយោបាយហិរញ្ញប្បទានសន្តិសុខសង្គម ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំវិភាគ និងវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកហានិភ័យការងារ
- រៀបចំវិភាគ និងវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកថែទាំសុខភាព
- រៀបចំវិភាគ និងវាយតម្លៃហានិភ័យហិរញ្ញវត្ថុផ្នែកប្រាក់សោធន
- រៀបចំសៀវភៅគោលនយោបាយហិរញ្ញប្បទានសន្តិសុខសង្គម
- ចូលរួមរៀបចំគោលការណ៍ប្រុងប្រយ័ត្នគ្រប់ផ្នែកនៃរបបសន្តិសុខសង្គម

៣.៥.៤.៤ ពង្រឹងការងារវិនិយោគមូលនិធិសន្តិសុខសង្គម តាមរយៈការរៀបចំផែនការវិនិយោគឱ្យស្រប តាមគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម ដើម្បីធានាបាននូវ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពរឹងមាំផ្នែកហិរញ្ញវត្ថុ ដោយត្រូវសម្រេចឱ្យបាន នូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- អត្រាការប្រាក់បញ្ញើនៅគ្រឹះស្ថានធនាគារ ហិរញ្ញវត្ថុយ៉ាងតិច ៦%/ឆ្នាំ ត្រូវបានធានា
- ផែនការយុទ្ធសាស្ត្រវិនិយោគរយៈពេលខ្លី មធ្យម និងវែង ត្រូវបានអនុវត្ត
- របាយការណ៍ស្តីពីការធ្វើពិពិធកម្ម និងវិបាឡែនស៊ីងនៃកញ្ចប់វិនិយោគ (Portfolio)

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំសេចក្តីសម្រេចស្តីពីការកំណត់លក្ខខណ្ឌ បែបបទ នីតិវិធីវាយតម្លៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សម្រាប់វិនិយោគលើប្រាក់បញ្ញើ
- ផ្តល់ការគាំទ្រដល់និរន្តរភាពក្រុមប្រឹក្សាអាជ្ញាកណ្តាល និងលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញា កណ្តាល សំដៅផ្តល់ការដោះស្រាយវិវាទការងារប្រកបដោយប្រសិទ្ធភាព ដល់ភាគីកម្មករ និយោជិត និងនិយោជក រួមចំណែកពង្រឹងសុខដុមនីកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ
- រៀបចំផែនការវិនិយោគរយៈពេលខ្លី មធ្យម និងវែង
- ត្រួតពិនិត្យកញ្ចប់វិនិយោគ (Portfolio) ជាទៀងទាត់ទៅតាមការបែងចែកកញ្ចប់វិនិយោគ
- រៀបចំបង្កើតអគារ និងហេដ្ឋារចនាសម្ព័ន្ធទារកដ្ឋាន និងមត្តេយ្យសហគមន៍

៣.៥.៤.៥ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគ្រប់គ្រងហានិភ័យនៃការវិនិយោគមូលនិធិសន្តិសុខសង្គម ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍ស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃហានិភ័យវិនិយោគតាមកញ្ចប់ វិនិយោគ (Portfolio) នីមួយៗ

- របាយការណ៍ស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃហានិភ័យគម្រោងវិនិយោគនីមួយៗ
- ប្រព័ន្ធគ្រប់គ្រងបញ្ជីគណនេយ្យ និងទូទាត់ ត្រូវបានអនុវត្ត

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំបង្កើត និងពង្រឹងការអនុវត្តការងារក្រុមប្រឹក្សាធនាភិបាល
- រៀបចំផែនការវិនិយោគ និងកញ្ចប់វិនិយោគ
- រៀបចំចងក្រងគោលការណ៍តាមដាន និងត្រួតពិនិត្យហានិភ័យវិនិយោគតាមកញ្ចប់វិនិយោគនីមួយៗ
- រៀបចំនីតិវិធីនៃការគ្រប់គ្រងហានិភ័យវិនិយោគ ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោងវិនិយោគនីមួយៗ
- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងបញ្ជីគណនេយ្យ និងទូទាត់

### ៣.៥.៥. ការអភិវឌ្ឍសមត្ថភាពបេឡាជាតិសន្តិសុខសង្គម

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៥.៥.ក. ប្រសិទ្ធភាពនៃការគ្រប់គ្រង ចាត់ចែង ត្រូវបានពង្រឹងស្របតាមគោលការណ៍

៣.៥.៥.ខ. អត្រានៃមន្ត្រី និងបុគ្គលិក នៃស្នាក់ការកណ្តាលដែលមានអាជ្ញាប័ណ្ណជំនាញវិជ្ជាជីវៈ ឬសញ្ញាបត្រឯកទេសពាក់ព័ន្ធព័ន្ធ (Professionally Certified / Licensed or Specialized Diploma) និងគាំទ្រដល់វិស័យសន្តិសុខសង្គម យ៉ាងតិច ១០% នៅឆ្នាំ២០២៨

៣.៥.៥.គ. កិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិលើគម្រោងអភិវឌ្ឍន៍របបសន្តិសុខសង្គម យ៉ាងតិច ២/ឆ្នាំ

៣.៥.៥.ឃ. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តរបបសន្តិសុខសង្គម ត្រូវបានអនុវត្ត

៣.៥.៥.ង. ប្រព័ន្ធប្រតិបត្តិការ និងសន្តិសុខបច្ចេកវិទ្យាសម្រាប់ការអនុវត្តរបបសន្តិសុខសង្គម ត្រូវបានធ្វើទំនើបកម្ម

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៥.៥.១ ពិនិត្យនិងកែសម្រួលលិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារគ្រប់គ្រងផ្ទៃក្នុង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- បទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក សេចក្តីជូនដំណឹង និងសេចក្តីណែនាំ ត្រូវបានត្រួតពិនិត្យ និងកែសម្រួល
- អគារសាខា ប.ស.ស. ខេត្តចំនួន ២៤ ត្រូវបានសាងសង់ថ្មី និងបញ្ចប់
- ការគ្រប់គ្រងបញ្ជីសារពើភណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានពង្រឹង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងកែសម្រួលបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក សេចក្តីជូនដំណឹង និងសេចក្តីណែនាំ
- សាងសង់អគារសាខា ប.ស.ស. ខេត្តចំនួន ១៤
- រៀបចំរបាយការណ៍គ្រប់គ្រងបញ្ជីសារពើភណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ
- បង្កើតប្រព័ន្ធបច្ចេកវិទ្យាឌីជីថល គ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធគ្រប់គ្រងសន្និធិ

៣.៥.៥.២ អភិវឌ្ឍន៍ធនធានមនុស្ស រៀបចំយន្តការ និងផែនការគ្រប់គ្រងចំណេះដឹង ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ផែនការតម្រូវការ ជ្រើសរើស បណ្តុះបណ្តាល និងរក្សាធនធានមនុស្ស ត្រូវបានរៀបចំ
- ផែនការតម្រូវការជំនាញ និងវគ្គបណ្តុះបណ្តាល ត្រូវបានរៀបចំ
- យន្តការគ្រប់គ្រងធនធានចំណេះដឹង ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំជ្រើសរើសមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា
- រៀបចំបណ្តុះបណ្តាល និងគ្រប់គ្រងធនធានមនុស្ស ជាពិសេសជំនាញឯកទេសសន្តិសុខសង្គម និងជំនាញពាក់ព័ន្ធ
- ស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាលផ្តល់ក្របខណ្ឌមុខងារសាធារណៈដោយមិនទទួលប្រាក់បៀវត្សជូនបុគ្គលិក ដើម្បីលើកទឹកចិត្ត និងរក្សាធនធានមនុស្ស
- រៀបចំកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ប.ស.ស.
- រៀបចំបញ្ជីចំណេះដឹង ជំនាញ និងបទពិសោធដែលធានាដល់និរន្តរភាពសម្រាប់ដំណើរការអង្គភាពនានាក្រោមឱវាទ

៣.៥.៥.៣ ចូលរួមការរៀបចំ អនុវត្ត តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីនយោបាយ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងអនុសញ្ញាអន្តរជាតិ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ទម្រង់តាមដាន និងវាយតម្លៃលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសន្តិសុខសង្គម និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ ប.ស.ស. ត្រូវបានបង្កើត និងធ្វើបច្ចុប្បន្នភាព
- របាយការណ៍វឌ្ឍនភាពនៃការចូលរួមអនុវត្តកម្មវិធីនយោបាយ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងអនុសញ្ញាអន្តរជាតិ ត្រូវបានរៀបចំទៅតាមវដ្ត
- មូលដ្ឋានទិន្នន័យវិស័យសន្តិសុខសង្គម ត្រូវបានធ្វើបច្ចុប្បន្នភាព

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំរបាយការណ៍វឌ្ឍនភាពតាមដាននៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសន្តិសុខសង្គម និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ ប.ស.ស.
- អនុវត្តកម្មវិធីនយោបាយ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ
- អនុវត្តអនុសញ្ញាអន្តរជាតិ និងកម្មវិធីនានា ជាមួយដៃគូពាក់ព័ន្ធ
- ពង្រឹងប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ និងរបាយការណ៍
- រៀបចំបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធយន្តការតាមដាន និងវាយតម្លៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម

៣.៥.៥.៤ ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិសំដៅកៀរគរធនធាន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- បច្ចុប្បន្នភាពអនុស្សរណៈនៃការយោគយល់លើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ជាពិសេសជាមួយសមាគមសន្តិសុខសង្គម
- ចំនួនគម្រោងទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីដៃគូអភិវឌ្ឍន៍ ត្រូវបានពង្រីក
- របាយការណ៍បទពិសោធដែលទទួលបានពីកិច្ចប្រជុំក្របខណ្ឌអាស៊ានពាក់ព័ន្ធនឹងវិស័យការងារ និងសន្តិសុខសង្គម ត្រូវបានរៀបចំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាមួយសមាគមសន្តិសុខសង្គម
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធស្វែងរកការគាំទ្រផ្នែកបច្ចេកទេស និងថវិកា

- ជំរុញការចូលរួមសហការរបស់សមាគម អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ជាពិសេស វិស័យឯកជនក្នុងការជំរុញអ្នកប្រកបមុខរបរ និងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ
- ចូលរួមកិច្ចប្រជុំក្របខណ្ឌអាស៊ានពាក់ព័ន្ធនឹងវិស័យការងារ និងសន្តិសុខសង្គម
- រៀបចំបញ្ជីដៃគូអភិវឌ្ឍន៍ ដៃគូអង្គភាពសន្តិសុខសង្គមពាក់ព័ន្ធ និងគម្រោង

៣.៥.៥.៥ ធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីអភិវឌ្ឍន៍សមត្ថភាពផ្តល់សេវា និងការគ្រប់គ្រងស្ថាប័ន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ការគ្រប់គ្រងរដ្ឋបាល និងធនធានមនុស្ស ត្រូវបានធ្វើទំនើបកម្ម
- ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ការផ្តល់សេវា ប.ស.ស. ត្រូវបានធ្វើទំនើបកម្មគ្រប់ជ្រុងជ្រោយ ប្រកបដោយភាពប្រទាក់ក្រឡាគ្នា
- ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ការគ្រប់គ្រងការងារអធិការកិច្ច ត្រូវបានធ្វើទំនើបកម្ម

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងធនធានមនុស្ស
- ធ្វើទំនើបកម្ម និងសុខដុមនីយកម្មប្រព័ន្ធ ប.ស.ស. រួមតែមួយ
- សិក្សាសមិទ្ធលទ្ធភាពធ្វើសុខដុមនីយកម្មរវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលនិធិសមធម៌សុខាភិបាលដែលចេញដោយ ប.ស.ស. និងប្រព័ន្ធអេឡិចត្រូនិចកត់ត្រា និងគ្រប់គ្រងអ្នកជំងឺ (Patient Management and Registration System-PMRS)
- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងការងារអធិការកិច្ច
- រៀបចំរចនាសម្ព័ន្ធបច្ចេកវិទ្យាឱ្យកាន់តែប្រសើរ និងមានសុវត្ថិភាពខ្ពស់ស្តង់ដាអន្តរជាតិ

ដើម្បីសម្រេចបានជោគជ័យលើការអនុវត្តនូវយុទ្ធសាស្ត្រអាទិភាពខាងលើ, អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវរៀបចំការពិនិត្យតាមដានលទ្ធផលនៃការអនុវត្តការងារជារៀងរាល់ខែ ត្រីមាស ឆមាស ប្រាំបួនខែ ជាពិសេស ការពិនិត្យវាយតម្លៃប្រចាំឆ្នាំ ដើម្បីវាយតម្លៃអំពីសមិទ្ធកម្មការងារសម្រេចបាន បញ្ហាប្រឈមដែលត្រូវកែលម្អ វិធានការអន្តរាគមន៍នានាដែលត្រូវដាក់ចេញសំដៅធានាឱ្យបាននូវការចូលរួមអនុវត្តពីគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ ការទទួលខុសត្រូវ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពជោគជ័យខ្ពស់។ យុទ្ធសាស្ត្រអាទិភាពនេះ ត្រូវបានចាត់ទុកថាជាឯកសាររស់រវើក ដែលសូចនាករកម្រិតយុទ្ធសាស្ត្រ សូចនាករកម្រិតកម្មវិធី ចង្កោមសកម្មភាព សូចនាករចង្កោមសកម្មភាព និងសកម្មភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ អាចនឹងត្រូវកែសម្រួល និងបច្ចុប្បន្នភាពជាយថាហេតុ ដើម្បីឱ្យស្របនឹង

បរិការណ៍ជាក់ស្តែង និងការវិវត្តនៃវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ, វិធានការណ៍ និងសូចនាករគន្លឹះជាក់ស្តែងនានាដែលរាជរដ្ឋាភិបាល នឹងបន្តដាក់ចេញទៅតាមក្របខណ្ឌពេលវេលា ព្រមទាំងស្របទៅតាមការវិវត្តនៃសង្គម-សេដ្ឋកិច្ច ទាំងនៅក្នុងតំបន់ និងសកលលោក។

## ៣.៦-ការធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈនិងសេវាគាំទ្រទូទៅតាមបច្ចេកវិទ្យាឌីជីថល

ការធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈនិងសេវាគាំទ្រទូទៅតាមបច្ចេកវិទ្យាឌីជីថល គឺជាគន្លឹះមួយដែលរួមចំណែកពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។ សម្រាប់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភានេះ ក្រសួងបន្តយកចិត្តទុកដាក់លើការពង្រឹងការងារអភិបាលកិច្ចល្អ ដោយបន្ត (១) ពង្រឹងការគ្រប់គ្រងរដ្ឋបាលនិងបុគ្គលិក គាំទ្រការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការធ្វើបរិវត្តកម្មឌីជីថល ស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច សង្គមឌីជីថល(២) ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (៣) អភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រងចំណេះដឹង គ្រប់គ្រងស្ថិតិ និងកសាងលិខិតបទដ្ឋានគតិយុត្ត (៤) ពង្រឹងភាពជាម្ចាស់ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ សមភាពយេនឌ័រ និងសេវាសង្គម (៥) ពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ដើម្បីសម្រេចបាននូវការធ្វើទំនើបកម្មស្ថាប័នក្រសួង និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន ការលើកកម្ពស់ និងការពង្រឹងភាពជាអ្នកដឹកនាំ ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ ការធានានិរន្តរភាពនៃតួនាទី និងពង្រឹងសមត្ថភាពនៃដំណើរការវិស័យសាធារណៈ ការលើកកម្ពស់គុណាធិបតេយ្យ។

សូចនាករកម្រិតយុទ្ធសាស្ត្រ ត្រូវសម្រេចឱ្យបានក្នុងការអនុវត្តយុទ្ធសាស្ត្រនេះមាន ៥ ដូចខាងក្រោម÷

៣.៦.ក. ការធ្វើឌីជីថលូបនីយកម្ម ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងកែលម្អសេវាសាធារណៈ ត្រូវបានជំរុញ ស្របតាមក្របខណ្ឌគោលនយោបាយបរិវត្តកម្មឌីជីថលរបស់រាជរដ្ឋាភិបាល និងសំណូមពរពីវិស័យឯកជន

៣.៦.ខ. ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានពង្រឹងដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៣.៦.គ. នីតិវិធីប្រតិបត្តិស្តង់ដា គំនូសបំព្រួញលំហូរការងារ ការវិភាគមុខងារ និងការកែសម្រួលឡើងវិញរចនាសម្ព័ន្ធស្ថាប័ន និងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មត្រូវបានរៀបចំ និងអនុវត្ត ឱ្យស្រប



ឃរ

តាមវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១

៣.៦.ឃ. ភាពជាម្ចាស់ និងភាពជាដៃគូ នៃកិច្ចសហប្រតិបត្តិការគ្រប់ផ្នែក និងគ្រប់ដៃគូជាតិ និងអន្តរជាតិ ត្រូវបានពង្រឹង និងពង្រីក

៣.៦.ង. ការគាំទ្រដល់អង្គភាពក្រោមឱវាទក្រសួង ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រ បេសកកម្ម និងកម្មវិធីនយោបាយនានារបស់រាជរដ្ឋាភិបាល ត្រូវបានពង្រឹង

ដើម្បីសម្រេចបាននូវសូចនាករកម្រិតយុទ្ធសាស្ត្រខាងលើនេះ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាពចំនួន ៥ ដូចខាងក្រោម÷

**៣.៦.១. ពង្រឹងការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក ស្របតាមកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា**

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៦.១.ក. ប្រសិទ្ធភាពនៃការងាររដ្ឋបាល ត្រូវបានពង្រឹងតាមរយៈការគ្រប់គ្រងវត្តមានការបែងចែកវេនបំពេញការងារ និងរបៀបរបបការងារ

៣.៦.១.ខ. ប្រសិទ្ធភាពនៃការគ្រប់គ្រងប្រើប្រាស់ធនធានមនុស្ស ត្រូវបានជំរុញស្របតាមការពិពណ៌នាមុខតំណែង និងរចនាសម្ព័ន្ធដែលបានកែសម្រួល

៣.៦.១.គ. សមិទ្ធកម្ម និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ ត្រូវបានលើកកម្ពស់កាន់តែប្រសើរតាមរយៈការលើកទឹកចិត្ត និងការអនុវត្តទណ្ឌកម្មខាងវិន័យ

៣.៦.១.ឃ. អភិបាលកិច្ច និងសេវាសាធារណៈរបស់ក្រសួង ត្រូវបានធ្វើបរិវត្តកម្មឌីជីថល ឱ្យកាន់តែមានប្រសិទ្ធភាព ឆ្លើយតបនឹងតម្រូវការការងារ និងការរីកចម្រើននៃបច្ចេកវិទ្យា

៣.៦.១.ង. មន្ត្រីមានវិន័យ ក្រមសីលធម៌ វិជ្ជាជីវៈ សមត្ថភាព បុរេសកម្មអាចឆ្លើយតបនឹង ចក្ខុវិស័យ បេសកកម្មរបស់ក្រសួង និងតម្រូវការរបស់មហាជន

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពចំនួន ៥ ដូចខាងក្រោម÷

៣.៦.១.១ ពង្រឹងការគ្រប់គ្រងឯកសាររដ្ឋបាលរបស់ក្រសួងឱ្យកាន់តែមានប្រសិទ្ធភាព និងងាយស្រួលក្នុងការគ្រប់គ្រង ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ការគ្រប់គ្រងឯកសារ ត្រូវបានដាក់ឱ្យដំណើរការ
- ការចរាចរឯកសាររដ្ឋបាល ត្រូវបានធ្វើឱ្យប្រសើរឡើង
- ការគ្រប់គ្រងកម្មវិធីការងាររបស់ថ្នាក់ដឹកនាំក្រសួង និងអង្គភាព និងឯកសារផ្សេងៗរបស់ក្រសួង ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាឌីជីថល

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងឯកសារ ចាប់ពីឆ្នាំ២០២៤ ដើម្បីពង្រឹងការគ្រប់គ្រងលំហូរឯកសាររដ្ឋបាលឱ្យកាន់តែល្អប្រសើរ
- រៀបចំសៀវភៅណែនាំស្តីពីរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឯកសារ សម្រាប់ផ្តល់ជូនគ្រប់អង្គភាព និងបណ្តុះបណ្តាលអ្នកប្រើប្រាស់មកពីអង្គភាពនានា
- រៀបចំ និងធ្វើបច្ចុប្បន្នភាពគំរូលិខិតរដ្ឋបាល ដើម្បីឱ្យមានសង្គតិភាព និងប្រសិទ្ធភាព
- បញ្ចូលឯកសារពាក់ព័ន្ធនឹងបម្រែបម្រួលស្ថានភាពមន្ត្រីរាជការ និងឯកសាររដ្ឋបាលគ្រប់ប្រភេទ ទៅក្នុងប្រព័ន្ធគ្រប់គ្រងឯកសារ
- រៀបចំប្រព័ន្ធគ្រប់គ្រងកម្មវិធីការងាររបស់ថ្នាក់ដឹកនាំក្រសួង និងអង្គភាព និងការផ្តល់របាយការណ៍ ឯកសារផ្សេងៗ ក្រោយចុះបេសកកម្ម ឬចូលរួមកម្មវិធីនានា

៣.៦.១.២ ធ្វើឱ្យកាន់តែប្រសើរនូវសេវារដ្ឋបាល និងសេវាផ្សេងៗ ព្រមទាំងសហការរៀបចំកម្មវិធីនានារបស់ក្រសួងឱ្យទទួលបានលទ្ធផលល្អតាមការរំពឹងទុក ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គុណភាពសេវារដ្ឋបាលផ្តល់ជូនមន្ត្រីរាជការ ត្រូវបានពង្រឹងឱ្យកាន់តែប្រសើរ
- កិច្ចសហការ និងសម្របសម្រួលរៀបចំកិច្ចប្រជុំ កម្មវិធីផ្សេងៗ ការងារសង្គមរបស់ក្រសួង ត្រូវបានរៀបចំដោយស្មារតីយកចិត្តទុកដាក់ខ្ពស់
- ប្រព័ន្ធសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណក្រសួង ត្រូវបានពង្រឹងឱ្យកាន់តែប្រសើរ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំបើកផ្តល់ប្រាក់បៀវត្ស ២ដង/ខែ តាមប្រព័ន្ធធនាគារ ឱ្យបានទៀងទាត់ និងប្រាក់ធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការលាឈប់ មរណភាព និងប្រាក់ឧបត្ថម្ភ ៨ខែដំបូងជូនមន្ត្រីរាជការចូលនិវត្តន៍ ឱ្យបានឆាប់រហ័ស
- សហការ រៀបចំកិច្ចប្រជុំ និងកម្មវិធីនានារបស់ថ្នាក់ដឹកនាំក្រសួង និងបណ្តាអង្គភាព ព្រមទាំងការងារសង្គមរបស់ក្រសួង
- រៀបចំ និងចូលរួមសកម្មភាពសង្គម សិល្បៈ និងកីឡា ដើម្បីបង្កើនមិត្តភាពសាមគ្គីភាពផ្ទៃក្នុង និងទំនាក់ទំនងសង្គម



ហ

- រៀបចំ ជំរុញកម្មវិធីគោរពទង់ជាតិ នៅទីស្តីការក្រសួង អង្គភាពក្រោមឱវាទក្រសួង និងនៅតាមសហគ្រាសគ្រឹះស្ថាន
- រៀបចំ ត្រួតពិនិត្យ និងថែទាំប្រព័ន្ធសុវត្ថិភាព អគ្គិភ័យ និងហេដ្ឋារចនាសម្ព័ន្ធ ក្នុងបរិវេណក្រសួង ធានាបានរបៀបរៀបរយ សន្តិសុខ សណ្តាប់ធ្នាប់ និងបរិស្ថានការងារល្អ

៣.៦.១.៣. ពង្រឹងយន្តការគ្រប់គ្រងមន្ត្រីរាជការក្រោមឱវាទក្រសួង និងគាំទ្រការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់នានា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- ក្រមសីលធម៌វិជ្ជាជីវៈ និងទណ្ឌកម្មវិន័យរដ្ឋបាល និងការតែងតាំងផ្អែកលើ គុណាធិបតេយ្យ សាមគ្គីភាពផ្ទៃក្នុង និងសមិទ្ធកម្ម ឬការប្រឡងប្រជែង ត្រូវបានពង្រឹង
- ការគ្រប់គ្រងវត្តមានតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ផ្អែកតាមបំណែងចែកវេនការងារ ត្រូវបានដាក់ឱ្យដំណើការនិងអនុវត្ត នៅទីស្តីការក្រសួង គ្រឹះស្ថាន អ.ប.វ និងមន្ទីរ ក.ប រាជធានី ខេត្ត
- រចនាសម្ព័ន្ធក្រសួង ត្រូវបានកែសម្រួលស្របតាមបេសកកម្ម និងទំហំការងារ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំសេចក្តីណែនាំ លិខិតក្រើនរំលឹក និងគោលការណ៍ផ្សេងៗ និងត្រួតពិនិត្យការអនុវត្តតួនាទីភារកិច្ចក្នុងការគ្រប់គ្រងមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៅតាមបណ្តាអង្គភាព
- អនុវត្តទណ្ឌកម្មខាងវិន័យចំពោះមន្ត្រីរាជការប្រព្រឹត្តកំហុស និងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ និងលើកទឹកចិត្តមន្ត្រីផ្អែកតាមសមិទ្ធកម្មការងារ
- បែងចែកវេនបំពេញការងាររបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាដើម្បីពង្រឹងគុណភាព និងពង្រីកលទ្ធភាពនៃការផ្តល់សេវារបស់ក្រសួង
- វិភាគមុខងារ និងកែសម្រួលឡើងវិញរចនាសម្ព័ន្ធស្ថាប័នស្របតាមវិធានការណ៍គន្លឹះក្នុងកម្មវិធីជាតិកែទម្រង់មុខងារសាធារណៈ
- កសាងផែនការសកម្មភាពរបស់ក្រសួង សម្រាប់ចូលរួមអនុវត្តកម្មវីធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់នានា

៣.៦.១.៤ រៀបចំប្រព័ន្ធការងារដើម្បីធ្វើបរិវត្តកម្មឌីជីថលការងាររបស់ក្រសួងឱ្យបានរលូន ស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ផែនទីបង្ហាញផ្លូវសម្រាប់ធ្វើសមាហរណកម្មប្រព័ន្ធ កម្មវិធី និងទិន្នន័យរបស់ក្រសួងត្រូវបានរៀបចំ
- ធនធានមនុស្សឌីជីថល គ្រប់កម្រិត កើនឡើងទាំងបរិមាណ និងគុណភាព
- ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថល និងការគ្រប់គ្រងក្នុងពេលប្រធានសក្តិត្រូវបានគ្រប់គ្រង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំបង្កើតនាយកដ្ឋានបរិវត្តកម្មឌីជីថល ដើម្បីអនុវត្ត និងគាំទ្រគោលនយោបាយពាក់ព័ន្ធបរិវត្តកម្មឌីជីថល
- រៀបចំផែនទីបង្ហាញផ្លូវ ក្នុងការធ្វើបរិវត្តកម្មឌីជីថលរួមរបស់ក្រសួង
- កសាងសមត្ថភាពផ្នែកឌីជីថល ដល់ថ្នាក់ដឹកនាំ, មន្ត្រីជំនាញ (អ្នកអភិវឌ្ឍន៍ ប្រព័ន្ធកម្មវិធី និងប្រព័ន្ធបណ្តាញ IT), និងអ្នកប្រើប្រាស់
- សិក្សាអំពីជម្រើសនៃការ ប្រើប្រាស់បច្ចេកវិទ្យាធំៗ ដើម្បីពង្រឹងការគ្រប់គ្រង និងការវិភាគទិន្នន័យ ឱ្យកាន់តែប្រសើរ
- រៀបចំផែនការសម្រាប់ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថល និងការគ្រប់គ្រងក្នុងពេលប្រធានសក្តិ

៣.៦.១.៥ ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងការងារផ្ទៃក្នុងក្រសួង និងសេវាសាធារណៈរបស់ក្រសួងតាមរយៈការធ្វើបរិវត្តកម្មឌីជីថលនៅគ្រប់ផ្នែក និងគ្រប់កម្រិត ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ប្រព័ន្ធកម្មវិធីគ្រប់គ្រងការងារផ្ទៃក្នុងក្រសួង ត្រូវបានធ្វើឌីជីថលូបនីយកម្ម
- ប្រព័ន្ធតាមដានវឌ្ឍនភាពសេវាសាធារណៈ និងកម្មវិធី App របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT Services app) ត្រូវបានដាក់ឱ្យដំណើការ
- ហេដ្ឋារចនាសម្ព័ន្ធ ម៉ាស៊ីនមេ មជ្ឈមណ្ឌលទិន្នន័យ និងប្រព័ន្ធបណ្តាញ ត្រូវបានអភិវឌ្ឍន៍ និងធ្វើទំនើបកម្ម

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំអភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពគេហទំព័រ កម្មវិធីលើទូរស័ព្ទឆ្លាតវៃ និងកុំព្យូទ័រសម្រាប់ការងារផ្ទៃក្នុងក្រសួង និងសេវាសាធារណៈឌីជីថលនៅតាមផ្សារទំនើប និងទីសាធារណៈ
- អភិវឌ្ឍ និងដំណើរការប្រព័ន្ធ កម្មវិធី App របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT Services app) ត្រូវបានដាក់ឱ្យដំណើការ
- រៀបចំ និងបង្កើតប្រព័ន្ធគោល/មូលដ្ឋានគ្រឹះ (Core Backend) សម្រាប់ផ្ទេរ/ផ្ទុក និងគ្រប់គ្រងទិន្នន័យកណ្តាលរបស់ក្រសួង (Server និង Data center, Storage) ដោយផ្តោតលើការធ្វើសមាហរណកម្ម សុវត្ថិភាព សន្តិសុខ ចែកចាយទិន្នន័យ និងរបាយការណ៍
- រៀបចំ គ្រប់គ្រងសុវត្ថិភាពប្រព័ន្ធសារអេឡិចត្រូនិកផ្លូវការ (Email) របស់ក្រសួងសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី
- រៀបចំ និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ទូរគមនាគមន៍ បច្ចេកវិទ្យាសម្រាប់ភ្ជាប់ ទំនាក់ទំនងក្រសួង អង្គភាព និងមន្ទីរ (Network, Internet) និងគាំទ្របច្ចេកទេស

**៣.៦.២. ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៦.២.ក. ប្រសិទ្ធភាពនៃការវិភាជធនធានហិរញ្ញវត្ថុដល់យុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាពអាទិភាព

៣.៦.២.ខ. ប្រសិទ្ធភាពនៃការអនុវត្តចំណាយតាមគម្រោងផែនការថវិកា

៣.៦.២.គ. ប្រសិទ្ធភាពនៃការប្រមូលចំណូលមិនមែនសារពើពន្ធពីសេវាសាធារណៈ

៣.៦.២.ឃ. ប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ

៣.៦.២.ង. ប្រសិទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពចំនួន ៥ ដូចខាងក្រោម÷

៣.៦.២.១ ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តចំណាយ និងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុតាមប្រព័ន្ធ (Financial Management Information Systems-FMIS) ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ប្រសិទ្ធភាពនៃការបែងចែកធនធានហិរញ្ញវត្ថុ
- ប្រសិទ្ធភាពនៃការអនុវត្តចំណាយតាមកម្មវិធីចំណាយប្រចាំត្រីមាស
- កិច្ចការហិរញ្ញវត្ថុ កិច្ចការលទ្ធកម្មសាធារណៈ និងធនធាន ត្រូវបានកត់ត្រាក្នុងប្រព័ន្ធ FMIS

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- វិភាជថវិកាទៅតាមប្រតិបត្តិការសកម្មភាពអាទិភាពរបស់យុទ្ធសាស្ត្រ កម្មវិធី និងអង្គភាពក្រោមឱវាទក្រសួង
- រៀបចំបញ្ជីតម្រូវការសម្ភារប្រើប្រាស់ ការជួសជុលនិងការសាងសង់ និងបែងចែកសម្ភារជូនអង្គភាពប្រើប្រាស់ស្របទៅនឹងតម្រូវការជាក់ស្តែង ដើម្បីគាំទ្រការអនុវត្តការងារ
- តាមដាន ត្រួតពិនិត្យការអនុវត្តចំណាយប្រចាំខែ និងត្រីមាស សំដៅជំរុញការអនុវត្តការងារ និងភារកិច្ចរបស់បណ្តាអង្គភាពឱ្យឆ្លើយតបជាអតិបរមាទៅនឹងផែនការសកម្មភាព
- រៀបចំកិច្ចលទ្ធកម្មសាធារណៈតាមនីតិវិធីលទ្ធកម្ម ផ្អែកលើកញ្ចប់ថវិកាដែលមានក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- បញ្ចូលប្រតិបត្តិការហិរញ្ញវត្ថុចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ផ្ទៀងផ្ទាត់ជាមួយប្រតិបត្តិការជាក់ស្តែង ដើម្បីធានាសង្គតិភាពក្នុងការទាញយករបាយការណ៍ហិរញ្ញវត្ថុ

៣.៦.២.២ ពង្រឹងការគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធពីសេវាសាធារណៈដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល (Non-Tax Revenue Management Information System-NRMIS & E-payment) ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម៖

- ប្រសិទ្ធភាពនៃការប្រមូលចំណូលស្របតាមកម្មវិធីចំណូលប្រចាំត្រីមាស
- ចំណូលដែលត្រូវបង់ចូលថវិកាជាតិប្រចាំខែ ត្រូវបានផ្ទៀងផ្ទាត់ជាមួយប្រតិបត្តិការចំណូលក្នុងប្រព័ន្ធ NRMIS
- ប្រាក់រង្វាន់លើកទឹកចិត្តពីការប្រមូលចំណូលសេវាសាធារណៈ ត្រូវបានទូទាត់ក្នុងឆ្នាំសារពើពន្ធ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម៖

- តាមដានត្រួតពិនិត្យ និងគ្រប់គ្រងការប្រមូលចំណូលពីសេវាសាធារណៈ ប្រចាំខែ និងត្រីមាស និងកត់ត្រាថវិកាជាតិឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា នៅតាមបណ្តាអង្គភាពប្រមូលចំណូល ដើម្បីដាក់ចេញនូវវិធានការជំរុញ និងបង្កើនការប្រមូលចំណូល
- បញ្ចូលទិន្នន័យប្រតិបត្តិការចំណូលក្នុងប្រព័ន្ធ NRMIS ផ្ទៀងផ្ទាត់ជាមួយប្រតិបត្តិការជាក់ស្តែង និងប្រតិបត្តិការបង្វែរកម្រៃសេវាសាធារណៈរបស់ធនាគារដៃគូ ដើម្បីឱ្យមានសង្គតិភាពទិន្នន័យ

- រៀបចំគោលការណ៍គ្រប់គ្រង និងបែងចែកប្រាក់រង្វាន់លើកទឹកចិត្តពីចំណូលសេវាសាធារណៈ ផ្អែកលើគោលការណ៍សមធម៌ សំដៅបង្កើនប្រសិទ្ធផល និងប្រសិទ្ធភាពការងារ
- រៀបចំគោលការណ៍គ្រប់គ្រង និងបែងចែកចំណូលរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈក្រោមឱវាទក្រសួង ដែលបានពីវគ្គបង់ថ្លៃ ផ្អែកលើគោលការណ៍សមធម៌ សាមគ្គីភាព និងការអភិវឌ្ឍអង្គភាពប្រកបដោយចីរភាព
- កែសម្រួលប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងឆ្លើយតបទៅតាមសំណូមពររបស់វិស័យឯកជន

៣.៦.២.៣ ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព និងគង់វង្ស តាមរយៈការចុះបញ្ជីសារពើភណ្ឌដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ប្រសិទ្ធភាពនៃការជម្រះទ្រព្យសម្បត្តិរដ្ឋ ដែលអស់គុណភាពចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- សៀវភៅបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានរៀបចំតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (State Asset Register Management Information System-SARMIS)
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់អង្គភាពក្រោមឱវាទក្រសួង ត្រូវបានរៀបចំ និងរក្សាទុក

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ជម្រះទ្រព្យសម្បត្តិរដ្ឋ ដែលអស់គុណភាពចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋផ្អែកលើគោលការណ៍ដែលបានកំណត់
- ជំរុញឱ្យគ្រប់អង្គភាពប្រើប្រាស់បញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋ ក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS)
- តាមដាននិងជំរុញឱ្យគ្រប់អង្គភាពប្រើប្រាស់រៀបចំតារាងប្រៀបធៀប កើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឱ្យទាន់ពេលវេលាកំណត់
- បិទលេខកូដសម្គាល់សម្ភារតាមអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ សម្រាប់ផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង និងវាយតម្លៃទ្រព្យសម្បត្តិរដ្ឋ
- ជំរុញការស្នើសុំវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដោយសហការជាមួយអាជ្ញាធរ និងក្រសួងមានសមត្ថកិច្ច

៣.៦.២.៤ ចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ផ្តោតលើប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាសមិទ្ធកម្ម ត្រូវបានរៀបចំទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ
- សូចនាករគន្លឹះនៃការអនុវត្តផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានសម្រេចតាមគោលដៅ
- សមត្ថភាពមន្ត្រីផ្នែកហិរញ្ញវត្ថុនៅតាមបណ្តាអង្គភាពថវិកា ត្រូវបានពង្រឹងត្រៀមលក្ខណៈក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំផែនការយុទ្ធសាស្ត្រថវិកាដែលមានភាពគ្រប់ជ្រុងជ្រោយ គ្របដណ្តប់គ្រប់ទិដ្ឋភាព និងប្រមូលបូកសរុបទិន្នន័យពីគ្រប់ប្រភព
- រៀបចំគម្រោងថវិកាសមិទ្ធកម្មតាមកម្មវិធី ដោយផ្តោតលើគោលដៅសមិទ្ធផល
- ត្រៀមលក្ខណៈក្នុងការប្រើប្រាស់មុខងារបន្ថែម ពីប្រព័ន្ធបច្ចេកវិទ្យាឌីជីថលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បញ្ជូនមន្ត្រីចូលរួម និងរៀបចំវគ្គបណ្តុះបណ្តាលហិរញ្ញវត្ថុ ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យក្លាយជាជនបង្គោល សម្រាប់ចូលរួមគាំទ្រដល់ការពង្រឹងសមត្ថភាពរបស់អង្គភាពថវិកា
- រៀបចំឱ្យមានអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ នៅតាមបណ្តាអង្គភាពថវិកាក្រោមឱវាទក្រសួង

៣.៦.២.៥ ពង្រឹងយន្តការគ្រប់គ្រង និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសមិទ្ធកម្ម ឆ្លើយតបទៅនឹងគោលដៅសូចនាករដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្ម ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍ហិរញ្ញវត្ថុពីគ្រប់ប្រភព ត្រូវបានរៀបចំកត់ត្រាគ្រប់ជ្រុងជ្រោយ
- របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាសមិទ្ធកម្ម ត្រូវបានរៀបចំចងក្រងបូកសរុបទាន់ពេលវេលា
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំតាមកាលកំណត់

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- បូកសរុបចងក្រងរបាយការណ៍ចំណូល ចំណាយថវិកា ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកា
- ប្រមូលបូកសរុបចងក្រងរបាយការណ៍ហិរញ្ញវត្ថុពីគម្រោងដៃគូអភិវឌ្ឍន៍ ប្រចាំត្រីមាស ឆមាស និងឆ្នាំ សម្រាប់ការគណនាបន្ថែមអំពីតម្រូវការថវិកា ក្នុងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ប្រមូលបូកសរុបចងក្រងរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាសមិទ្ធកម្ម ប្រចាំឆមាស និងឆ្នាំ ដើម្បីជាធាតុចូលក្នុងការវាយតម្លៃប្រសិទ្ធភាពនៃការវិភាជ និងប្រើប្រាស់ថវិកា
- រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាស និងឆ្នាំ ដើម្បីត្រួតពិនិត្យវឌ្ឍនភាពនៃការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំរបាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃថវិកាសមិទ្ធកម្ម ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីឆ្លើយតបទៅនឹងចំណុចខ្វះខាតក្នុងក្របខណ្ឌនៃការអនុវត្តថវិកាសមិទ្ធកម្ម

### ៣.៦.៣. អភិវឌ្ឍសមត្ថភាពមន្ត្រី គ្រប់គ្រងចំណេះដឹង គ្រប់គ្រងស្ថិតិ និងកសាងលិខិតបទដ្ឋានគតិយុត្ត

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៦.៣.ក. សមត្ថភាព និងទំនួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ត្រូវបានពង្រឹង និងឆ្លើយតបទៅនឹងចក្ខុវិស័យ និងបេសកកម្ម របស់ក្រសួង

៣.៦.៣.ខ. ការបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ និងការចងក្រងស្ថិតិក្រសួងកាន់តែមានគុណភាព តាមរយៈការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធរបាយការណ៍ឌីជីថល

៣.៦.៣.គ. ផ្ទាំងព័ត៌មាន និងរបាយការណ៍អំពីសមិទ្ធផលការងារ និងសូចនាករសំខាន់ៗរបស់ក្រសួង ត្រូវបានរៀបចំ និងផ្សព្វផ្សាយជាប្រចាំ

៣.៦.៣.ឃ. នីតិវិធីប្រតិបត្តិស្តង់ដារបស់អង្គភាពក្រោមឱវាទក្រសួង ត្រូវបានរៀបចំ ដើម្បីធានាសង្គតិភាព និរន្តរភាព ប្រសិទ្ធភាព នៃការអនុវត្តការងារនៅក្នុងអង្គភាព

៣.៦.៣.ង. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានកសាង និងធ្វើបច្ចុប្បន្នភាពជាប្រចាំស្របតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច និងសង្គម

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៦.៣.១ រៀបចំយន្តការអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការ សំដៅបង្កើនប្រសិទ្ធភាពក្នុងការបំពេញមុខងារ និងតួនាទីភារកិច្ច ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ផែនការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ត្រូវបានរៀបចំ
- មេរៀនតាមជំនាញពាក់ព័ន្ធនឹងប្រតិបត្តិការការងាររបស់អង្គភាពក្រោមឱវាទក្រសួង ត្រូវបានរៀបចំចងក្រង
- ការប្រឡងធ្វើតេស្តសមត្ថភាពតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ត្រូវបានរៀបចំនៅគ្រប់វគ្គបណ្តុះបណ្តាល

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- កែសម្រួលសមាសភាពគណៈកម្មការវិក្រឹតការ និងអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីរាជការ
- រៀបចំផែនការវគ្គបណ្តុះបណ្តាលផ្អែកតាមតម្រូវការរបស់អង្គភាពជំនាញនីមួយៗ
- ជ្រើសរើសគ្រូបង្គោល គ្រូឧទ្ទេស ទៅតាមជំនាញ និងផ្តល់ការលើកទឹកចិត្ត ដើម្បីបង្កើនគុណភាព នៃការបណ្តុះបណ្តាល
- រៀបចំចងក្រង និងធ្វើបច្ចុប្បន្នភាពមេរៀនសម្រាប់ការបណ្តុះបណ្តាលពង្រឹងសមត្ថភាព
- រៀបចំការប្រឡងតេស្តសមត្ថភាពសិក្ខាកាមតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ក្រោយទទួលការបណ្តុះបណ្តាល

៣.៦.៣.២ វាយតម្លៃសមត្ថភាព ចំណេះដឹងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ដើម្បីបណ្តុះបណ្តាលបង្កើនសមត្ថភាពឱ្យកាន់តែប្រសើរ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម ÷

- របាយការណ៍បណ្តុះបណ្តាលតាមបណ្តាអង្គភាព ត្រូវបានបញ្ចូលក្នុងប្រព័ន្ធឌីជីថលសម្រាប់ការគ្រប់គ្រងទិន្នន័យបណ្តុះបណ្តាល
- កម្រិតវប្បធម៌ កម្រិតបណ្តុះបណ្តាល និងជំនាញឯកទេស របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ត្រូវបានកត់ត្រា និងរក្សាទុកក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រី
- កម្រិតសមត្ថភាព និងជំនាញឯកទេសរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ត្រូវបានពិនិត្យ និងវាយតម្លៃដើម្បីជាមូលដ្ឋានសម្រាប់រៀបចំផែនការបណ្តុះបណ្តាលបន្ត

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំ និងដំណើរការប្រព័ន្ធឌីជីថល សម្រាប់ការគ្រប់គ្រងទិន្នន័យបណ្តុះបណ្តាល
- កសាងទិន្នន័យអំពីកម្រិតបណ្តុះបណ្តាល និងជំនាញឯកទេសរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ តាមប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ
- ធ្វើសម្រង់ព័ត៌មាន និងវាយតម្លៃលើកម្រិតវប្បធម៌ កម្រិតបណ្តុះបណ្តាល និងជំនាញឯកទេសរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ដើម្បីជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាលបន្ត
- រៀបចំសិក្សាពីតម្រូវការបណ្តុះបណ្តាលរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៅតាមអង្គភាពជំនាញក្រោមឱវាទក្រសួង
- រៀបចំរបាយការណ៍ស្តីពីការអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

៣.៦.៣.៣ បណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការ សំដៅឆ្លើយតបនឹងតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម÷

- វគ្គបណ្តុះបណ្តាលជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការ ត្រូវបានរៀបចំតាមផែនការបណ្តុះបណ្តាល
- ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការ ត្រូវបានបញ្ជូនទៅទស្សនកិច្ចសិក្សា ឬកម្មវិធីនានាទាំងក្នុង និងក្រៅប្រទេសដើម្បីទទួលបទពិសោធ និងចំណេះដឹងនានាសម្រាប់បម្រើឱ្យការបំពេញមុខងាររបស់ខ្លួន
- ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការ ត្រូវបញ្ជូនទៅទទួលការបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល

ដើម្បីសម្រេចបាននូវសូចនាករចង្អុលសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំវគ្គបណ្តុះបណ្តាល ជូនដល់ថ្នាក់ដឹកនាំចាប់ពីអនុប្រធាននាយកដ្ឋានឡើង និងមន្ត្រីជំនាញលើការងាររដ្ឋបាល បុគ្គលិក ផែនការ របាយការណ៍ ស្ថិតិ និងបរិវត្តកម្មឌីជីថល
- បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការ ទៅទទួលការបណ្តុះបណ្តាល និងធ្វើទស្សនកិច្ចសិក្សាទាំងក្នុង និងក្រៅប្រទេស ដើម្បីដកស្រង់បទពិសោធ និងលើកកម្ពស់សមត្ថភាព
- សហការ និងរៀបចំវគ្គបណ្តុះបណ្តាលលើជំនាញចាំបាច់នានា នៅសាលាភូមិន្ទរដ្ឋបាលជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការ

- ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការដែលទទួលបានការបណ្តុះបណ្តាល និងធ្វើទស្សនកិច្ចសិក្សា ត្រូវធ្វើរបាយការណ៍ និងឯកសារបទបង្ហាញ ដើម្បីផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងបន្ត
- រៀបចំបណ្តុះបណ្តាល ពង្រឹងសមត្ថភាព គ្រប់គ្រង ដឹកនាំដល់ប្រធានអង្គភាពដែលត្រូវបានតែងតាំងថ្មី

៣.៦.៣.៤ ពង្រឹងការគ្រប់គ្រងរបាយការណ៍ ស្ថិតិ កម្រងព័ត៌មាន និងឯកសារផ្សេងៗ បម្រើឱ្យការសិក្សាស្រាវជ្រាវ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ របស់ក្រសួងត្រូវបានបូកសរុប ចងក្រង កាន់តែមានគុណភាព និងឆ្លើយតបទៅនឹងសូចនាករសមិទ្ធកម្មគន្លឹះរបស់ក្រសួង
- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងរបាយការណ៍ ស្ថិតិ ត្រូវបានដាក់ឱ្យដំណើរការ
- ព្រឹត្តិបត្រព័ត៌មានវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានចងក្រង ផលិត និងផ្សព្វផ្សាយ

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- រៀបចំទម្រង់របាយការណ៍ឱ្យឆ្លើយតបទៅនឹងសូចនាករសមិទ្ធកម្មគន្លឹះរបស់ក្រសួង និងបូកសរុបរបាយការណ៍លទ្ធផលការងាររបស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- រៀបចំផ្ទាំងព័ត៌មាន និងរបាយការណ៍អំពីសមិទ្ធផលការងារ និងសូចនាករសំខាន់ៗរបស់ក្រសួង ត្រូវរៀបចំ និងផ្សព្វផ្សាយជាប្រចាំ
- រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងរបាយការណ៍ ស្ថិតិ ដើម្បីបង្កើនគុណភាព ប្រសិទ្ធភាព និងទាន់ពេលវេលា
- ប្រមូលចងក្រង រក្សាទុកឯកសារ សៀវភៅ ព្រឹត្តបត្រ និងឯកសារសិក្សាស្រាវជ្រាវផ្សេង សម្រាប់តម្កល់ទុកក្នុងបណ្ណាល័យ
- បង្កើតក្រុមការងារទទួលបន្ទុករៀបចំសុន្ទរកថា ឯកសារជំនួយស្មារតី និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំក្រសួង ប្រកបដោយគុណភាព និងទាន់ពេលវេលា

៣.៦.៣.៥ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានកសាង និងផ្សព្វផ្សាយ សំដៅលើកកម្ពស់ការយល់ដឹងក្នុងចំណោម ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ និងស្ថាប័ន-ភាគីពាក់ព័ន្ធ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានបោះពុម្ពផ្សព្វផ្សាយ រៀងរាល់ឆ្នាំ
- ការគ្រប់គ្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានពង្រឹង
- កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានរៀបចំតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ប្រមូលចងក្រង និងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាប្រចាំ
- សិក្សា និងបង្កើតយន្តការគ្រប់គ្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យកាន់តែប្រសើរ
- រៀបចំបង្កើតកម្មវិធីកម្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល
- រៀបចំកែសម្រួល បច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ឱ្យស្របតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច និងសង្គម
- ពិនិត្យ វាយតម្លៃតម្រូវការលិខិតបទដ្ឋានគតិយុត្តថ្មីស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងស្ថានភាពសេដ្ឋកិច្ច និងសង្គម

### ៣.៦.៤. ពង្រឹងភាពជាម្ចាស់ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ សមភាពយេនឌ័រ និងសេវាសង្គម

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៦.៤.ក. កិច្ចសហប្រតិបត្តិការជាមួយដៃគូ ដើម្បីការពារ និងទាញយកផលប្រយោជន៍សម្រាប់កម្ពុជា ពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានបង្កើនប្រសិទ្ធភាព

៣.៦.៤.ខ. របាយការណ៍ឆ្លើយតបនឹងអនុសញ្ញា និងអនុសាសន៍របស់អង្គការសហប្រជាជាតិ និងឯកសារគោលនយោបាយ គោលការណ៍ណែនាំ និងរបាយការណ៍នានាក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបានផ្តល់មតិយោបល់ ឬធាតុចូល និងឆ្លើយតបទាន់ពេលវេលា

៣.៦.៤.គ. យន្តការគ្រប់គ្រង ពិនិត្យ និងតាមដានការអនុវត្ត កិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា (MOU) ពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានពង្រឹង

៣.៦.៤.ឃ. សមាមាត្រថ្នាក់ដឹកនាំជាស្ត្រី កើនឡើង

៣.៦.៤.ង. អត្រានៃការយល់ដឹងអំពីការបង្ការនៃការចម្លងមេរោគអេដស៍ ជំងឺអេដស៍ និងការការពារអំពីផលវិបាកនិងគ្រោះថ្នាក់នៃគ្រឿងញៀន និងសេវាសង្គមផ្សេងៗ ក្នុងចំណោមកម្មករ និយោជិត ពលករខ្មែរ និងសិក្ខាកាម សិស្ស និស្សិត កើនឡើង

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៦.៤.១. ជំរុញកិច្ចសហប្រតិបត្តិការ និងការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ក្នុងក្របខណ្ឌអាស៊ាន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គោលការណ៍ណែនាំអាស៊ាន ស្តីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ ក្នុងតំបន់អាស៊ាន ត្រូវបានអនុម័ត និងអនុវត្ត
- សេចក្តីថ្លែងការណ៍ ស្តីពីការទទួលស្គាល់ជំនាញទៅវិញទៅមកក្នុងតំបន់អាស៊ាន ត្រូវបានអនុម័តដោយកិច្ចប្រជុំកំពូលអាស៊ាន
- កិច្ចប្រជុំក្នុងក្របខណ្ឌអាស៊ានជាមួយរដ្ឋសមាជិកអាស៊ាន និងដៃគូពាក់ព័ន្ធ ត្រូវបានចូលរួម និងរៀបចំ ស្របតាមគោលការណ៍ប្តូរវេនរបស់អាស៊ាន ដើម្បីបង្ហាញពីជំហរ កម្ពុជាក្នុងភាពជាដៃគូ និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- សហការជាមួយលេខាធិការដ្ឋានអាស៊ានរៀបចំកិច្ចប្រជុំ និងសិក្ខាសាលាពិគ្រោះយោបល់កម្រិតអាស៊ាន ពាក់ព័ន្ធនឹងគោលការណ៍ណែនាំអាស៊ាន ស្តីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ ក្នុងតំបន់អាស៊ាន
- សហការជាមួយលេខាធិការដ្ឋានអាស៊ាន ដើម្បីព្រាងសេចក្តីថ្លែងការណ៍ ស្តីពីការទទួលស្គាល់ជំនាញទៅវិញទៅមកក្នុងតំបន់អាស៊ាន ព្រមទាំងរៀបចំកិច្ចប្រជុំនានា និងសិក្ខាសាលាពិគ្រោះយោបល់អាស៊ាន ដើម្បីពិនិត្យសេចក្តីព្រាងនៃសេចក្តីថ្លែងការណ៍នេះ មុននឹងដាក់ឱ្យអនុម័តដោយកិច្ចប្រជុំកំពូលអាស៊ាន
- ចូលរួមកិច្ចប្រជុំក្រៅប្រទេសក្នុងក្របខណ្ឌអាស៊ាន ពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់ធាតុចូល បង្ហាញគោលជំហរកម្ពុជា និងពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការក្នុងតំបន់

- រៀបចំកិច្ចប្រជុំត្រៀម និងធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំឧត្តមមន្ត្រីការងារអាស៊ាន ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងារ ដើម្បីពង្រឹងភាពប្រកួតប្រជែងរបស់អាស៊ានលើកទី២១ (21stSLOM)
- រៀបចំកិច្ចប្រជុំបច្ចេកទេសពាក់ព័ន្ធផ្សេងៗ ក្នុងក្របខណ្ឌអាស៊ាន

៣.៦.៤.២. បង្កើនប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការក្នុងកម្រិតទ្វេភាគី ពហុភាគី អង្គការជាតិអន្តរជាតិនានា ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- កិច្ចប្រជុំទាំងក្នុង និងក្រៅប្រទេសក្នុងកម្រិតទ្វេភាគី ពហុភាគី អង្គការជាតិ-អន្តរជាតិនានា ត្រូវបានបន្តរៀបចំ និងចូលរួម ដើម្បីបង្ហាញពីជំហរកម្ពុជាក្នុងភាពជាដៃគូ និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអន្តរជាតិ
- ឯកសារឆ្លើយតបទៅនឹងអនុសញ្ញា និងអនុសាសន៍របស់អង្គការសហប្រជាជាតិ និងឯកសារគោលនយោបាយ គោលការណ៍ណែនាំ និងរបាយការណ៍នានាក្នុងក្របខណ្ឌអន្តរជាតិនានា ត្រូវបានរៀបចំ
- ឯកសារសំណើគម្រោងនានា និងសំណើសុំជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ត្រូវបានអនុម័ត

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ចូលរួមកិច្ចប្រជុំក្នុង និងក្រៅប្រទេស ដើម្បីពង្រឹងគោលជំហរកម្ពុជាក្នុងភាពជាដៃគូទាំងក្នុងកម្រិតទ្វេភាគី ពហុភាគី និងអង្គការជាតិ-អន្តរជាតិនានា ក្នុងបេសកកម្មជំរុញការអភិវឌ្ឍវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បន្តសមាជិកភាពជាមួយអង្គការអន្តរជាតិ និងយន្តការអន្តរជាតិនានា ដូចជាការបង់វិភាគទានសមាជិកភាពជាមួយអង្គការអន្តរជាតិខាងការងារ, គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) និងយន្តការទីក្រុងកូឡុំបូ (Colombo Process)
- រៀបចំកិច្ចប្រជុំ និងសិក្ខាសាលា ដែលជាយន្តការក្រុមការងារអន្តរជាតិ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិនិត្យ និងប្រមូលធាតុចូលសម្រាប់រៀបចំឯកសារឆ្លើយតបទៅនឹងអនុសញ្ញា និងអនុសាសន៍របស់អង្គការសហប្រជាជាតិ និងឯកសារគោលនយោបាយ គោលការណ៍ណែនាំ និងរបាយការណ៍នានាក្នុងក្របខណ្ឌអន្តរជាតិ
- រៀបចំឯកសារសំណើគម្រោងនានា និងសំណើសុំជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូពាក់ព័ន្ធក្នុងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំរបាយការណ៍វឌ្ឍនភាព និងឯកសារជំនួយស្មារតី សម្រាប់កិច្ចប្រជុំទ្វេភាគី ពហុភាគី

៣.៦.៤.៣ ផ្សព្វផ្សាយ និងជំរុញការអនុវត្តសេចក្តីថ្លែងការណ៍ គោលការណ៍ណែនាំ និងបទដ្ឋានអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- រាល់សេចក្តីថ្លែងការណ៍ គោលការណ៍ណែនាំ និងបទដ្ឋានអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបកប្រែជាភាសាខ្មែរ
- សេចក្តីថ្លែងការណ៍ គោលការណ៍ណែនាំ និងបទដ្ឋានអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានប្រមូល ចងក្រងជាកម្រងឯកសារភាសាខ្មែរ និងភាសាអង់គ្លេស
- សេចក្តីថ្លែងការណ៍ គោលការណ៍ណែនាំ ត្រូវបានផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ ដៃគូ និងសាធារណជន

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- បកប្រែជាភាសាខ្មែរនូវរាល់សេចក្តីថ្លែងការណ៍ គោលការណ៍ណែនាំ និងបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ប្រមូល ចងក្រងជាកម្រងជាភាសាខ្មែរ និងភាសាអង់គ្លេសនូវកម្រងសេចក្តីថ្លែងការណ៍ គោលការណ៍ណែនាំ និងបទដ្ឋានអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ផ្សព្វផ្សាយសេចក្តីថ្លែងការណ៍ និងគោលការណ៍ណែនាំ ដល់គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដៃគូពាក់ព័ន្ធ ព្រមទាំងសាធារណជន ដើម្បីជាចំណេះដឹង និងជាមូលដ្ឋានសម្រាប់ការបង្កើតច្បាប់គោលនយោបាយថ្មីៗ ពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំកិច្ចប្រជុំ/សិក្ខាសាលាផ្សព្វផ្សាយសេចក្តីថ្លែងការណ៍ និងគោលការណ៍ណែនាំដល់គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដៃគូពាក់ព័ន្ធ
- បញ្ជូនអនុសញ្ញា អនុសាសន៍ និងពិធីសាររបស់អង្គការអន្តរជាតិខាងការងារ ជូនស្ថាប័ននីតិបញ្ញត្តិ ដើម្បីស្នើសុំផ្តល់សច្ចាប័នទទួលស្គាល់ជាច្បាប់ជាតិ ឬជូនជ្រាបជាមូលដ្ឋានពិចារណាក្នុងការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

៣.៦.៤.៤ ពង្រឹងយន្តការច្រក-ចេញចូលតែមួយលើការងារសម្របសម្រួលកិច្ចសហប្រតិបត្តិការ និងគ្រប់គ្រងអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងផ្សេងៗ ដើម្បីធានាបាននូវសង្គតិភាព វឌ្ឍនភាព និងអត្ថប្រយោជន៍អតិបរមាសម្រាប់កម្ពុជា ដោយផ្អែកលើទិដ្ឋភាព

នយោបាយ សេដ្ឋកិច្ច និងច្បាប់ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម៖

- អនុស្សរណៈនៃការយោគយល់គ្នា និងឯកសារកិច្ចព្រមព្រៀងផ្សេងៗ ត្រូវបានពិនិត្យសង្គតិភាព និងប្រមូលចងក្រង
- កិច្ចប្រជុំលេខាធិការដ្ឋានក្រុមការងារអន្តរជាតិ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានរៀបចំជាទៀងទាត់ ដើម្បីតាមដាន ត្រួតពិនិត្យការអនុវត្ត អនុស្សរណៈនៃការយោគយល់គ្នា និងឯកសារកិច្ចព្រមព្រៀងផ្សេងៗ ដែលធ្វើឡើងដោយអង្គភាពក្រោមឱវាទក្រសួង ជាមួយដៃគូជាតិ-អន្តរជាតិ
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា និងឯកសារកិច្ចព្រមព្រៀងផ្សេងៗ ត្រូវបានរៀបចំ រៀងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីផ្សព្វផ្សាយក្នុងចំណោមថ្នាក់ដឹកនាំ និងអង្គភាពក្រោមឱវាទក្រសួង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម៖

- កែសម្រួលសមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារអន្តរជាតិ ដោយប្រគល់ភារកិច្ចដល់លេខាធិការដ្ឋានក្នុងការតាមដានវឌ្ឍនភាព នៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា និងឯកសារកិច្ចព្រមព្រៀងផ្សេងៗ
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំចុះ ឬបន្តអនុស្សរណៈនៃការយោគយល់គ្នា និងឯកសារកិច្ចព្រមព្រៀងផ្សេងៗ
- ពិនិត្យសង្គតិភាពនៃការរៀបចំអនុស្សរណៈនៃការយោគយល់គ្នា និងឯកសារកិច្ចព្រមព្រៀងផ្សេងៗ
- រៀបចំកិច្ចប្រជុំពង្រឹងប្រសិទ្ធភាពការងារសហប្រតិបត្តិការអន្តរជាតិ
- ប្រមូលចងក្រង រៀបចំរបាយការណ៍វឌ្ឍនភាពអនុស្សរណៈនៃការយោគយល់គ្នា និងឯកសារកិច្ចព្រមព្រៀងផ្សេងៗ និងផ្សព្វផ្សាយរៀងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ប្រជុំក្រុមការងារបច្ចេកទេសតាមដានវឌ្ឍនភាព

៣.៦.៤.៥ លើកកម្ពស់សមភាពយេនឌ័រ, ការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍និងគ្រឿងញៀន និងការយល់ដឹងអំពីសេវាសង្គមផ្សេងៗ ក្នុងចំណោមកម្មករនិយោជិត ពលករខ្មែរ និងសិក្ខាកាមសិស្សនិស្សិត រួមទាំងជនមានពិការភាព ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារចំនួន ៣ ដូចខាងក្រោម៖

- អត្រានៃការតែងតាំងថ្នាក់ដឹកនាំជាស្ត្រី តាមអង្គភាព កើនឡើង រៀងរាល់ឆ្នាំ
- អាត្រានៃកម្មករនិយោជិត ពលករខ្មែរ និងសិក្ខាកាម សិស្សនិស្សិត រួមទាំងជនមានពិការភាព ដែលបានទទួលចំណេះដឹងអំពីការបង្ការនៃការចម្លងមេរោគអេដស៍ ជំងឺអេដស៍

និងការការពារអំពីផលវិបាកនិងគ្រោះថ្នាក់នៃគ្រឿងញៀន និងសេវាសង្គមផ្សេងៗ កើនឡើងរៀងរាល់ឆ្នាំ

- អាត្រានៃសហគ្រាស គ្រឹះស្ថាន ដែលមានស្នាដៃក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន នៅកន្លែងការងារ មានបុគ្គលិកជាជនមានពិការភាព កើនឡើង រៀងរាល់ឆ្នាំ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពជនបង្គោលយេនឌ័រ ទិវាអន្តរជាតិនារី ៨មីនា និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ស្របតាមផែនការយុទ្ធសាស្ត្រនារីរតនៈ
- រៀបចំសិក្ខាសាលាពង្រឹងសមត្ថភាព ផ្សព្វផ្សាយ តាមដាន និងវាយតម្លៃ នៃការអនុវត្តការងារអំពីការបង្ការការចម្លងមេរោគអេដស៍ ផលវិបាក និងគ្រោះថ្នាក់នៃគ្រឿងញៀន
- ជំរុញ និងចូលរួមអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារ និងលើកកម្ពស់ជនមានពិការភាព និងសេវាសង្គមផ្សេងៗ
- សហការដឹកនាំអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការគាំពារកម្មករនិយោជិតក្រៅប្រព័ន្ធ
- រៀបចំឱ្យមានការធ្វើតេស្តសារធាតុញៀនពីរដងក្នុងមួយឆ្នាំ ក្នុងចំណោមមន្ត្រីក្រសួង និងយុទ្ធនាការធ្វើតេស្តសារធាតុញៀននៅតាមសហគ្រាស គ្រឹះស្ថាន

### ៣.៦.៥. ពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ

សូចនាករកម្មវិធីត្រូវសម្រេចឱ្យបានក្នុងកម្មវិធីនេះ មាន ៥ ដូចខាងក្រោម÷

៣.៦.៥.ក. លទ្ធផលការងារតាមបណ្ដាអង្គភាព ត្រូវបានវាយតម្លៃជាប្រចាំ

៣.៦.៥.ខ. ប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ សន្តិសុខសង្គម និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២០២៤-២០២៨ ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃ

៣.៦.៥.គ. ការចូលរួមអនុវត្តគោលនយោបាយពាក់ព័ន្ធ និងការផ្ដល់សេវាសាធារណៈរបស់ក្រសួងកាន់តែមានគុណភាព និងប្រសិទ្ធភាព

៣.៦.៥.ឃ. កម្រងសេវាសាធារណៈរបស់ក្រសួង ត្រូវបានកែសម្រួលតាមសំណូមពររបស់វិស័យឯកជន និងគោលការណ៍របស់រាជរដ្ឋាភិបាល នៅក្នុងវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន ឱ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០២៤

៣.៦.៥.ង. ការបំពេញតួនាទីភារកិច្ចមន្ត្រីរាជការ ត្រូវបានពង្រឹង ស្របតាមអភិក្រមទាំង៥ (ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និងវះកាត់)



ស

ដើម្បីសម្រេចបាននូវសូចនាករកម្មវិធីខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាព ចំនួន ៥ ដូចខាងក្រោម÷

៣.៦.៥.១ ពង្រឹងការរៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពតាមបណ្តាអង្គភាពក្រោមឱវាទក្រសួងជាទៀងទាត់ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ តាមបណ្តាអង្គភាពក្រោមឱវាទក្រសួង ត្រូវបានសម្រេចតាមគោលដៅ
- ចំនួនរបាយការណ៍វាយតម្លៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ នៅតាមបណ្តាអង្គភាពក្រោមឱវាទក្រសួង ត្រូវបានរៀបចំ
- ការកំណត់សូចនាករ និងការវាស់វែងវាយតម្លៃប្រចាំឆ្នាំ កាន់តែមានគុណភាព

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារ ចំនួន ៥ ដូចខាងក្រោម÷

- ជំរុញការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំតាមទម្រង់រួម ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨
- ជំរុញការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ប្រចាំឆមាស និងប្រចាំឆ្នាំ
- ពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុករៀបចំផែនការ និងជនបង្គោលទទួលបន្ទុករបាយការណ៍តាមបណ្តាអង្គភាពក្រោមឱវាទក្រសួង
- ជំរុញឱ្យមានកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំតាមបណ្តាអគ្គនាយកដ្ឋាន និងអង្គភាពនានា ដើម្បីផ្សព្វផ្សាយអំពីលទ្ធផលការងារសម្រេចបានក្នុងឆ្នាំ កំណត់បញ្ហាប្រឈម និងទិសដៅការងាររៀងៗខ្លួន
- រៀបចំសន្និបាតក្រសួង ដើម្បីពិនិត្យលើបញ្ហាប្រឈម ដាក់ចេញនូវដំណោះស្រាយ និងទិសដៅការងារក្នុងកម្រិតអន្តរវិស័យ ឬអន្តរអង្គភាព

៣.៦.៥.២ ពង្រឹងយន្តការ និងនីតិវិធីក្នុងការបូកសរុប តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីនយោបាយពាក់ព័ន្ធ ត្រូវបានតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- របាយការណ៍បូកសរុបវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធ ត្រូវបានរៀបចំទាន់ពេលវេលា

- ការអនុវត្តផែនការយុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធ ត្រូវបានវាយតម្លៃតាមកាលកំណត់ និងកាន់តែប្រសើរ
- បញ្ហាប្រឈមក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធ ត្រូវបានកំណត់ និងដោះស្រាយ

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ និងគោលនយោបាយពាក់ព័ន្ធ
- បូកសរុបវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ និងគោលនយោបាយពាក់ព័ន្ធ
- តាមដាន និងវាយតម្លៃការអនុវត្តវិធានការថ្មីៗដែលដាក់ចេញដោយរាជរដ្ឋាភិបាលពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំបង្កើត និងពង្រឹងសមត្ថភាព លេខាធិការដ្ឋាន /ក្រុមការងារទទួលបន្ទុកលើការអនុវត្តផែនការគោលនយោបាយពាក់ព័ន្ធដើម្បីបង្កើនការទទួលខុសត្រូវរបស់អង្គភាពពាក់ព័ន្ធ
- ប្រជុំត្រួតពិនិត្យវាយតម្លៃ និងរៀបចំរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ ប្រចាំឆមាស

៣.៦.៥.៣ ពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវាសាធារណៈរបស់ក្រសួង ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈរបស់ក្រសួងកាន់តែប្រសើរ
- គណនេយ្យភាព និងសុចរិតភាពនៃការផ្តល់សេវាសាធារណៈ ត្រូវបានពង្រឹង
- អ្នកទទួលសេវាពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកាន់តែពេញចិត្តតាមរយៈការធ្វើអង្កេត

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំចងក្រងនីតិវិធីនៃការផ្តល់សេវាសាធារណៈដោយផ្ទាល់ និងតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងបណ្តុះបណ្តាលដល់មន្ត្រីផ្តល់សេវា

- ចុះពិនិត្យ តាមដានដល់ទីតាំងលើការប្រមូលចំណូល ប្រតិបត្តិការ និងអត្តចរិតរបស់មន្ត្រីផ្តល់សេវាជួរមុខ
- ពិនិត្យ វាយតម្លៃលើយន្តការគ្រប់គ្រង នីតិវិធី របាយការណ៍ និងការបែងចែកប្រាក់រង្វាន់តាមបណ្តាអង្គភាពផ្តល់សេវា
- រៀបចំយន្តការផ្តល់ព័ត៌មានត្រឡប់ពីអ្នកប្រើប្រាស់តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធស្វ័យប្រវត្តិកម្មឱ្យកាន់តែមានភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់
- ជំរុញក្រុមការងារទទួលបន្ទុកសេវាសាធារណៈ កំណត់ឱ្យមានរបបប្រជុំប្រចាំខែទៀងទាត់ដើម្បីដោះស្រាយបញ្ហាប្រឈម សំណូមពរនានា និងលើកសំណើដោះស្រាយទៅថ្នាក់ដឹកនាំ

៣.៦.៥.៤ ពង្រឹងការធ្វើសវនកម្មផ្ទៃក្នុងលើប្រតិបត្តិការ ហិរញ្ញវត្ថុ ភាពអនុលោម បច្ចេកវិទ្យាព័ត៌មាន និងសមិទ្ធកម្ម ដើម្បីពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃដំណើរការគ្រប់គ្រងហានិភ័យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចល្អតាមសវនដ្ឋានក្រោមឱវាទក្រសួង ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- គុណភាពនៃការចុះសវនកម្មតាមសវនដ្ឋាន ត្រូវបានពង្រឹង
- សមត្ថភាពសវនករលើជំនាញសវនកម្មតាមបច្ចេកវិទ្យាព័ត៌មាន និងសវនកម្មសមិទ្ធកម្មត្រូវបានលើកកម្ពស់
- គុណភាពរបាយការណ៍លទ្ធផលសវនកម្មតាមសវនដ្ឋាន ត្រូវបានពង្រឹងអនុលោមតាមស្តង់ដាររបាយការណ៍សវនកម្មផ្ទៃក្នុង

ដើម្បីសម្រេចបាននូវសូចនាករចង្អោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង បីឆ្នាំរំកិល និងផែនការសវនកម្មប្រចាំឆ្នាំ ដោយផ្តោតលើការធ្វើសវនកម្មប្រតិបត្តិការ ហិរញ្ញវត្ថុ ភាពអនុលោម ការពិនិត្យការគ្រប់គ្រងផ្ទៃក្នុង សវនកម្មលើបច្ចេកវិទ្យាព័ត៌មាន និងសវនកម្មសមិទ្ធកម្ម
- ចុះធ្វើសវនកម្មតាមសវនដ្ឋានស្របតាមផែនការសវនកម្មប្រចាំឆ្នាំ និងតាមដានការកែលម្អតាមអនុសាសន៍សវនកម្មគ្រាមុន
- ពង្រឹងសមត្ថភាពសវនករផ្ទៃក្នុង ជាពិសេសជំនាញសវនកម្មបច្ចេកវិទ្យាព័ត៌មាន និងសវនកម្មសមិទ្ធកម្ម
- ពង្រីកគោលដៅសវនដ្ឋានដែលត្រូវធ្វើសវនកម្មបច្ចេកវិទ្យាព័ត៌មាន និងសវនកម្មសមិទ្ធកម្ម
- រៀបចំ និងចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលសវនកម្ម



ៗៃ

៣.៦.៥.៥ ពង្រឹងការចុះធ្វើអធិការកិច្ចផ្អែកលើអភិក្រមហានិភ័យ និងករណីសង្ស័យ និងដោះស្រាយបណ្តឹងតវ៉ា និងវិវាទរដ្ឋបាល ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាព ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករលទ្ធផលការងារ ចំនួន ៣ ដូចខាងក្រោម÷

- ប្រសិទ្ធភាពនៃការចុះធ្វើអធិការកិច្ច ត្រូវបានពង្រឹង
- កម្រិតហានិភ័យ និងករណីសង្ស័យតាមបណ្តាអង្គភាពរងអធិការកិច្ច ត្រូវបានវាយតម្លៃ
- ប្រសិទ្ធភាពនៃការដោះស្រាយពាក្យបណ្តឹងអនាមិក និងបណ្តឹងវិវាទរដ្ឋបាលនានា ត្រូវបានពង្រឹង

ដើម្បីសម្រេចបាននូវសូចនាករចង្កោមសកម្មភាពខាងលើនេះ ក្រសួងនឹងធ្វើសកម្មភាពការងារចំនួន ៥ ដូចខាងក្រោម÷

- ចុះធ្វើអធិការកិច្ចផ្អែកលើកម្រិតហានិភ័យ និងករណីសង្ស័យ ឬមានពាក្យបណ្តឹង
- ចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ចរបស់អង្គភាពក្រោមឱវាទក្រសួង
- ទទួល និងដោះស្រាយពាក្យបណ្តឹងរវាងមន្ត្រីរាជការ និងមន្ត្រីរាជការ រវាងមន្ត្រីផ្តល់សេវាសាធារណៈនិងអ្នកប្រើប្រាស់សេវាបានទាន់ពេលវេលា
- រៀបចំ និងចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍លទ្ធផលអធិការកិច្ច និងដោះស្រាយវិវាទ និងអនុសាសន៍កែលម្អ
- រៀបចំប្រព័ន្ធទទួលពាក្យបណ្តឹងអនាមិកក្នុងគេហទំព័រផ្លូវការរបស់ក្រសួង

ដើម្បីសម្រេចបានជោគជ័យលើការអនុវត្តនូវយុទ្ធសាស្ត្រអាទិភាពខាងលើ, អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវរៀបចំការពិនិត្យតាមដានលទ្ធផលនៃការអនុវត្តការងារជារៀងរាល់ខែ ត្រីមាស ឆមាស ប្រាំបួនខែ ជាពិសេស ការពិនិត្យវាយតម្លៃប្រចាំឆ្នាំ ដើម្បីវាយតម្លៃអំពីសមិទ្ធកម្មការងារសម្រេចបាន បញ្ហាប្រឈមដែលត្រូវកែលម្អ វិធានការអន្តរាគមន៍នានាដែលត្រូវដាក់ចេញ សំដៅធានាឱ្យបាននូវការចូលរួមអនុវត្តពីគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ ការទទួលខុសត្រូវ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពជោគជ័យខ្ពស់។ យុទ្ធសាស្ត្រអាទិភាពនេះ ត្រូវបានចាត់ទុកថាជាឯកសាររស់រវើក ដែលសូចនាករកម្រិតយុទ្ធសាស្ត្រ សូចនាករកម្រិតកម្មវិធី ចង្កោមសកម្មភាព សូចនាករចង្កោមសកម្មភាព និងសកម្មភាពដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនេះ អាចនឹងត្រូវកែសម្រួល និងបច្ចុប្បន្នភាពជាយថាហេតុ ដើម្បីឱ្យស្របនឹងបរិការណ៍ជាក់ស្តែង និងការវិវត្តនៃវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ, វិធានការណ៍ និងសូចនាករគន្លឹះជាក់ស្តែងនានាដែលរាជរដ្ឋាភិបាល នឹងបន្តដាក់ចេញទៅតាមក្របខណ្ឌពេលវេលា ព្រមទាំងស្របទៅតាមការវិវត្តនៃសង្គម-សេដ្ឋកិច្ច ទាំងនៅក្នុងតំបន់ និងសកលលោក។



ញ

# ជំពូកទី ៤
# ការកៀរគរប្រភពធនធានហិរញ្ញវត្ថុ

ដើម្បីអាចឱ្យសកម្មភាពដែលមានចែងក្នុង ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨ អាចអនុវត្តប្រកបដោយជោគជ័យ និងសម្រេចបានទៅតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ការផ្តល់នូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងទាន់ពេលវេលាពីស្ថាប័នជាតិ និងដៃគូអភិវឌ្ឍន៍នានាគឺជាកត្តាចាំបាច់បំផុត។

ចំពោះវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ថវិកាជាតិដែលទទួលបានពុំអាចធានាបានតាមតម្រូវការនៃការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបានទេ ព្រោះតម្រូវការនៃការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញមានការកើនឡើង។ ដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃការកសាងកម្លាំងពលកម្មជំនាញដែលប្រកបដោយចំណេះដឹង សមត្ថភាពជំនាញ ផលិតភាព និងភាពប្រកួតប្រជែងស្របតាមតម្រូវការនៃទីផ្សារការងារ គឺចាំបាច់ត្រូវមានប្រភពហិរញ្ញវត្ថុគ្រប់គ្រាន់។ ដូចនេះ ក្រៅពីថវិកាជាតិដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបានកិច្ចសហការពីដៃគូជាតិ និងអន្តរជាតិ ស្ថាប័នពាក់ព័ន្ធ សហគមន៍មាតាបិតា សមាគមវិជ្ជាជីវៈ អង្គការមិនមែនរដ្ឋាភិបាល និងជាពិសេស គឺវិស័យឯកជនទាំងឡាយ ដែលមានតម្រូវការកម្លាំងពលកម្មជំនាញ ក្នុងការផ្តល់នូវធនធានហិរញ្ញវត្ថុ ជំនួយបច្ចេកទេស និងឱកាសកម្មសិក្សាសម្រាប់សិស្សនិស្សិតនៃវិស័យ អ.ប.វ. គឺជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍវិស័យ អ.ប.វ. ដើម្បីគាំទ្រដល់ការធ្វើបរិវត្តកម្មគ្រប់វិស័យនៃសេដ្ឋកិច្ចឆ្ពោះទៅកាន់សកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់ ដោយឈរលើជំនាញ និងចំណេះដឹង, ជំរុញកំណើនផលិតភាពការងារ ព្រមទាំងផ្តល់ភាពទាក់ទាញដល់ការវិនិយោគមកក្នុងប្រទេសកម្ពុជា។

ដោយឡែកយោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម មានមកពី÷

- ការបង់ភាគទានពីរដ្ឋ និយោជក និងសមាជិក ប.ស.ស.
- ផលដែលបានមកពីការវិនិយោគ
- អំណោយ ឬអច្ច័យទាន និងប្រភពស្របច្បាប់ផ្សេងទៀត។

ដោយអនុលោមតាមព្រះរាជក្រឹត្យខាងលើនេះ បេឡាជាតិរបបសន្តិសុខសង្គមមានប្រភពធនធានហិរញ្ញវត្ថុមួយ ដ៏ច្បាស់លាស់ និងមានភាពរឹងមាំ។ តាមរយៈដំណើរការដំបូងចាប់តាំងពីឆ្នាំ២០០៨ រហូតមកដល់ពេលនេះ ប.ស.ស. បានទទួលនូវប្រភពធនធានហិរញ្ញវត្ថុមួយចំនួន រួមមានការឧបត្ថម្ភពីសំណាក់រាជរដ្ឋាភិបាលសម្រាប់កិច្ចដំណើរការដំបូង ប្រាក់ភាគទានពីសមាជិករបស់ ប.ស.ស. ប្រាក់ពិន័យពីការមិនចុះបញ្ជិកា ឬការយឺតយ៉ាវក្នុងការបង់ភាគទាន និងធនធានហិរញ្ញវត្ថុជាជំនួយបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានា។

# ជំពូកទី ៥

# ការតាមដាន និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាឧបករណ៍វាស់វែងធាតុចេញ (Outputs) លទ្ធផល (Outcomes) និងកម្មវិបាក (Impacts) ដែលសម្រេចបានពីការអនុវត្ត "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨" ដោយកំណត់ថាតើការអនុវត្តផែនការយុទ្ធសាស្ត្រនេះមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ភាពពាក់ព័ន្ធទៅនឹងគោលនយោបាយ ច្បាប់ និងអាទិភាពរបស់គោលនយោបាយថ្នាក់ជាតិ ជាពិសេសក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ និងនិរន្តរភាពនៃការអភិវឌ្ឍកម្រិតណា។ ទន្ទឹមនឹងនេះ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក៏ជាឧបករណ៍សម្រាប់តម្រង់ទិស និងកែសម្រួលការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ដើម្បីធានាថា ចក្ខុវិស័យ បេសកកម្ម គោលបំណង គោលដៅសម្រេចបានតាមការគ្រោងទុក។

នៅក្នុងក្របខណ្ឌការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ឆ្នាំ ២០២៤-២០២៨ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គឺជាដំណើរការនៃការប្រមូលទិន្នន័យព័ត៌មាន និងវិភាគទាក់ទងនឹងសូចនាករពាក់ព័ន្ធនឹងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

**ការតាមដាន ត្រួតពិនិត្យ** ជាដំណើរការប្រមូល វិភាគ និងប្រើប្រាស់ទិន្នន័យ ឬព័ត៌មានជាប្រចាំ តាមវដ្តរាយការណ៍ ឬរបាយការណ៍ដែលបានកំណត់ លើដំណើរការនៃការអនុវត្តផែនការយុទ្ធសាស្ត្រតាមអង្គភាពប្រតិបត្តិនីមួយៗ។ គោលបំណងនៃការតាមដាន ត្រួតពិនិត្យនេះ គឺដើម្បីពិនិត្យលើវឌ្ឍនភាព និងបញ្ហាប្រឈមដោយផ្អែកលើសូចនាករដែលបានកំណត់ និងសម្រេចចិត្តលើវិធានការបន្ទាន់ចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខដែលកើតមានឡើងក្នុងពេលអនុវត្ត។ ការតាមដានត្រួតពិនិត្យនេះត្រូវអនុវត្តគ្របដណ្តប់លើសកម្មភាព (Activities), ចង្កោមសកម្មភាព, ធាតុចេញ (Outputs), និងការប្រើប្រាស់ថវិកា ព្រមទាំងអាចចង្អុលបង្ហាញអំពីលទ្ធភាពនៃការសម្រេចបាននូវគោលដៅ និងគោលបំណងនៃផែនការយុទ្ធសាស្ត្រនេះ។ ការតាមដានត្រួតពិនិត្យនេះ គឺប្រើផែនការសកម្មភាព ឬផែនការប្រតិបត្តិជាគោល ដែលអនុវត្តដោយអង្គភាពទទួលខុសត្រូវ/អង្គភាពប្រតិបត្តិតាមការកំណត់នៅក្នុងម៉ាទ្រីសអនុវត្តការងារដែលនឹងបង្កើតដោយអង្គភាពទទួលខុសត្រូវ/អង្គភាពប្រតិបត្តិនីមួយៗ។

**ការវាយតម្លៃ**គឺជាដំណើរការប្រមូល វិភាគ និងប្រើប្រាស់ទិន្នន័យ ឬព័ត៌មាននៅពេលវេលាជាក់លាក់ណាមួយដែលអាចជាពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ឬ/និងនៅចុងអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ដោយផ្តោតលើលទ្ធផល (outcome) និងកម្មវិបាក (impact) ដែលសម្រេចបានពីការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ គោលបំណងចម្បងនៃការវាយតម្លៃនេះ គឺដើម្បីវាយតម្លៃការសម្រេចបាននូវគោលដៅ, គោលបំណង បេសកកម្ម និងចក្ខុវិស័យនៃផែនការយុទ្ធសាស្ត្រ តាមរយៈការវាស់វែងលទ្ធផល និងកម្មវិបាកដោយកំណត់ថាតើការអនុវត្តកម្មវិធីមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ភាពពាក់ព័ន្ធ និងនិរន្តរភាពកម្រិតណា។

## ៥.១. ការរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីសម្រេចបានជោគជ័យលើការអនុវត្ត **ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨**, អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត និងគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងទាំងអស់ ត្រូវរៀបចំការពិនិត្យតាមដានលទ្ធផលនៃការអនុវត្តការងារជារៀងរាល់ខែ ត្រីមាស ឆមាស ប្រាំបួនខែ ជាពិសេស ការពិនិត្យវាយតម្លៃប្រចាំឆ្នាំ ដើម្បីវាយតម្លៃអំពីសមិទ្ធកម្មការងារសម្រេចបាន បញ្ហាប្រឈមដែលត្រូវកែលម្អ វិធានការអន្តរាគមន៍នានាដែលត្រូវដាក់ចេញ សំដៅធានាឱ្យបាននូវការចូលរួមអនុវត្តពីគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ ការទទួលខុសត្រូវ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងភាពជោគជ័យខ្ពស់។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានចាត់ទុកថាជាឯកសាររស់រវើក ដែលយុទ្ធសាស្ត្រអាទិភាពទាំង៥ និងយុទ្ធសាស្ត្រគាំទ្រចំនួន ១, សូចនាករកម្រិតយុទ្ធសាស្ត្រ, សូចនាករកម្រិតកម្មវិធី, ចង្កោមសកម្មភាព, សូចនាករចង្កោមសកម្មភាព, និងសកម្មភាព ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រនេះ អាចនឹងត្រូវកែសម្រួល និងបច្ចុប្បន្នភាពជាយថាហេតុ ដើម្បីឱ្យស្របនឹងបរិការណ៍ជាក់ស្តែង និងការវិវត្តនៃវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ, វិធានការណ៍ និងសូចនាករគន្លឹះជាក់ស្តែងនានាដែលរាជរដ្ឋាភិបាល នឹងបន្តចេញចេញទៅតាមក្របខណ្ឌពេលវេលា ព្រមទាំងស្របទៅតាមការវិវត្តនៃសង្គម-សេដ្ឋកិច្ច ទាំងនៅក្នុងតំបន់ និងសកលលោក។ ឈរលើមូលដ្ឋាននេះ ក្រសួងនឹងរៀបចំនូវប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមួយសម្រាប់គាំទ្រដល់ការអនុវត្ត ដែលរួមមាន៖

- បង្កើតប្រព័ន្ធក្របខណ្ឌតក្កកម្ម (Logical Framework) ដោយផ្អែកលើ “ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ ”នេះ សម្រាប់ជាឯកសារណែនាំរួមក្នុងការអនុវត្ត ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃតាមយុទ្ធសាស្ត្រនីមួយៗ
- បង្កើតប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ការចងក្រងរបាយការណ៍វឌ្ឍនភាពប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ
- ធ្វើការតាមដាន និងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨ ជារៀងរាល់ឆ្នាំ ដើម្បីត្រួតពិនិត្យលើវឌ្ឍនភាព និងបញ្ហាប្រឈមផ្អែកលើសូចនាករ និងគោលដៅដែលបានកំណត់ និងធ្វើការសម្រេចចិត្តលើវិធានការបន្ទាន់ចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ ដែលកើតមានឡើងក្នុងពេលអនុវត្ត
- ធ្វើការវាយតម្លៃពាក់កណ្តាលអាណត្តិ នៅឆ្នាំ២០២៦ និងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្ត ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨ ដើម្បីពិនិត្យការសម្រេចបាននូវលទ្ធផល និងកម្មវិបាក (impact) ក្នុងរយៈពេល២ឆ្នាំកន្លះដំបូង ធៀបនឹងគោលដៅដែលបានកំណត់ ព្រមទាំងប្រមូលធាតុចូលសម្រាប់កែសម្រួលផែនការយុទ្ធសាស្ត្រ និងជាមូលដ្ឋានកែតម្រូវនិងតម្រង់ទិសដល់ការអនុវត្តបន្តក្នុងរយៈពេល២កន្លះបន្ទាប់

- ធ្វើការវាយតម្លៃចុងអាណត្តិ នៅចុងឆ្នាំ២០២៨ ឬដើមឆ្នាំ២០២៩ និងរៀបចំរបាយការណ៍លទ្ធផលវាយតម្លៃចុងអាណត្តិនៃការអនុវត្ត ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨ ដើម្បីពិនិត្យការសម្រេចបាននូវលទ្ធផល និងកម្មវិបាក (impact) ក្នុងរយៈពេល៥ឆ្នាំពេញ ធៀបនឹងគោលដៅដែលបានកំណត់ ព្រមទាំងប្រមូល និងវិភាគនូវព័ត៌មានដើម្បីតម្រង់ទិសដៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ៥ឆ្នាំបន្តទៅមុខទៀត។

**៥.២. ដំណាក់កាលការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**

ការតាមដានត្រួតពិនិត្យលើដំណើរការការអនុវត្តផែនការយុទ្ធសាស្ត្រ នឹងផ្តោតសំខាន់លើការពិនិត្យនូវធាតុចូល (ធនធានមនុស្ស ថវិកា ពេលវេលា និងសម្ភារ:) សកម្មភាព និងធាតុចេញ ឬលទ្ធផលក្នុងឆ្នាំដែលជាលទ្ធផលភ្លាមៗចេញពីការអនុវត្តផែនការយុទ្ធសាស្ត្រ។ ការតាមដានត្រួតពិនិត្យនេះនឹងធ្វើជាប្រចាំ និងរៀងរាល់ឆ្នាំ ដើម្បីត្រួតពិនិត្យលើវឌ្ឍនភាព និងបញ្ហាប្រឈមផ្អែកលើសូចនាករ និងគោលដៅដែលបានកំណត់ និងធ្វើការសម្រេចចិត្តលើវិធានការបន្ទាន់ចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខ ដែលកើតមានឡើងក្នុងពេលអនុវត្ត។ រីឯការវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រនឹងផ្តោតសំខាន់លើការពិនិត្យនូវលទ្ធផល និងកម្មវិបាក (impact) នៅពាក់កណ្តាលអាណត្តិ (ឆ្នាំ២០២៦) និងចុងអាណត្តិ (ចុងឆ្នាំ២០២៨ ឬដើមឆ្នាំ២០២៩) បន្ទាប់ពីការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ លទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ នឹងប្រើប្រាស់ជាធាតុចូលសម្រាប់កែសម្រួលផែនការយុទ្ធសាស្ត្រ និងជាមូលដ្ឋានកែតម្រូវនិងតម្រង់ទិសដល់ការអនុវត្តបន្ត។ ដូចគ្នាដែរ លទ្ធផលនៃការវាយតម្លៃចុងអាណត្តិ នឹងផ្តល់ជាព័ត៌មាន ដើម្បីតម្រង់ទិសដៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ៥ឆ្នាំបន្តទៅមុខទៀត។

ក្របខណ្ឌទស្សនទាននៃយន្តការការតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់ផែនការយុទ្ធសាស្ត្រ (M &E Conceptual Framework) មានដូចខាងក្រោម÷

**រូបភាពទី១០ ÷ ក្របខណ្ឌទស្សនទាននៃយន្តការការតាមដានត្រួតពិនិត្យ និងវាយតម្លៃ**



## ៥.៣. ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រ លទ្ធផល និងសូចនាករ

ផែនការយុទ្ធសាស្ត្របានដាក់ចេញនៅផែនការដែលបានគ្រោងនូវធាតុចូលសកម្មភាព ចង្កោមសកម្មភាព កម្មវិធីអាទិភាព យុទ្ធសាស្ត្រដើម្បីសម្រេចបាននូវគោលដៅ គោលបំណង បេសកកម្ម និងចក្ខុវិស័យដែលបានកំណត់។ តាមរយៈផែនការនេះ ផែនការយុទ្ធសាស្ត្រទាំងមូលក៏មានការរំពឹងទុកនូវលទ្ធផលភ្លាមៗ រយៈពេលមធ្យម និងរយៈពេលវែងដែលលទ្ធផលទាំងបីកម្រិតនេះក៏មានសូចនាករតាមកម្រិតនីមួយៗផងដែរ។ ខាងក្រោមនេះជាគំនូសបំព្រួញពន្យល់ពីទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រ លទ្ធផល និងសូចនាករ។

**រូបភាពទី១១ ÷ ទំនាក់ទំនងផែនការយុទ្ធសាស្ត្រ លទ្ធផល និងសូចនាករ**



ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ មានយុទ្ធសាស្ត្របច្ចេកទេសចំនួន៥ និងយុទ្ធសាស្ត្រគាំទ្រទូទៅចំនួន ១, កម្មវិធីចំនួន ៣០ និងចង្កោមសកម្មភាពចំនួន ១៥០ ដែលមានសូចនាករវាស់វែងសរុបចំនួន ៦៣០សូចនាករ ក្នុងនោះ សូចនាករកម្រិតយុទ្ធសាស្ត្រចំនួន ៣០, សូចនាករកម្រិតកម្មវិធីចំនួន ១៥០, និងសូចនាករកម្រិតចង្កោមសកម្មភាព ចំនួន ៤៥០ ព្រមទាំងមានសកម្មភាពសម្រាប់អនុវត្តចំនួន ៧៥០។

- យុទ្ធសាស្ត្រទី១÷ មានសូចនាករកម្រិតយុទ្ធសាស្ត្រចំនួន ៥, សូចនាករកម្រិតកម្មវិធីចំនួន ២៥, ចង្កោមសកម្មភាពចំនួន ២៥ ដែលមានសូចនាករ ចំនួន ៧៥ និងសកម្មភាពចំនួន ១២៥
- យុទ្ធសាស្ត្រទី២÷ មានសូចនាករកម្រិតយុទ្ធសាស្ត្រចំនួន ៥, សូចនាករកម្រិតកម្មវិធីចំនួន ២៥, ចង្កោមសកម្មភាពចំនួន ២៥ ដែលមានសូចនាករ ចំនួន ៧៥ និងសកម្មភាពចំនួន ១២៥
- យុទ្ធសាស្ត្រទី៣÷ មានសូចនាករកម្រិតយុទ្ធសាស្ត្រចំនួន ៥, សូចនាករកម្រិតកម្មវិធីចំនួន ២៥, ចង្កោមសកម្មភាពចំនួន ២៥ ដែលមានសូចនាករ ចំនួន ៧៥ និងសកម្មភាពចំនួន ១២៥
- យុទ្ធសាស្ត្រទី៤÷ មានសូចនាករកម្រិតយុទ្ធសាស្ត្រចំនួន ៥, សូចនាករកម្រិតកម្មវិធីចំនួន ២៥, ចង្កោមសកម្មភាពចំនួន ២៥ ដែលមានសូចនាករ ចំនួន ៧៥ និងសកម្មភាពចំនួន ១២៥
- យុទ្ធសាស្ត្រទី៥÷ មានសូចនាករកម្រិតយុទ្ធសាស្ត្រចំនួន ៥, សូចនាករកម្រិតកម្មវិធីចំនួន២៥, ចង្កោមសកម្មភាពចំនួន ២៥ ដែលមានសូចនាករ ចំនួន ៧៥ និងសកម្មភាពចំនួន ១២៥
- យុទ្ធសាស្ត្រទី៦÷ មានសូចនាករកម្រិតយុទ្ធសាស្ត្រចំនួន ៥, សូចនាករកម្រិតកម្មវិធីចំនួន ២៥, ចង្កោមសកម្មភាពចំនួន ២៥ ដែលមានសូចនាករ ចំនួន ៧៥ និងសកម្មភាពចំនួន ១២៥

**តារាងសង្ខេបចំនួនសូចនាករ នៃ ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨**

| | សូចនាករ យុទ្ធសាស្ត្រ | ចំនួន កម្មវិធី | សូចនាករ កម្មវិធី | ចំនួន ចង្កោមសកម្មភាព | សូចនាករ ចង្កោមសកម្មភាព | សកម្មភាព |
|---|---|---|---|---|---|---|
| យុទ្ធសាស្ត្រទី១ | ៥ | ៥ | ២៥ | ២៥ | ៧៥ | ១២៥ |
| យុទ្ធសាស្ត្រទី២ | ៥ | ៥ | ២៥ | ២៥ | ៧៥ | ១២៥ |
| យុទ្ធសាស្ត្រទី៣ | ៥ | ៥ | ២៥ | ២៥ | ៧៥ | ១២៥ |
| យុទ្ធសាស្ត្រទី៤ | ៥ | ៥ | ២៥ | ២៥ | ៧៥ | ១២៥ |
| យុទ្ធសាស្ត្រទី៥ | ៥ | ៥ | ២៥ | ២៥ | ៧៥ | ១២៥ |
| យុទ្ធសាស្ត្រទី៦ | ៥ | ៥ | ២៥ | ២៥ | ៧៥ | ១២៥ |
| **សរុប** | **៣០** | **៣០** | **១៥០** | **១៥០** | **៤៥០** | **៧៥០** |



ឍ

សរុបរួម សូចនាករសម្រាប់កម្រិតយុទ្ធសាស្ត្រ កម្រិតកម្មវិធី និងកម្រិតចង្កោមសកម្មភាពមានចំនួនសរុប ៦៣០ បូកបន្ថែម ៥សូចនាករគោលដៅកម្រិតកម្មវិបាក (Impact) ដែលបានកំណត់ក្នុងផ្នែក ១.៥ "គោលដៅ" បានសូចនាករនៅក្នុងផែនការយុទ្ធសាស្ត្រនេះទាំងមូលមានចំនួន **៦៣៥សូចនាករ។**

ទន្ទឹមនឹងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងរៀបចំដាក់បញ្ចូលបន្ថែមនូវសូចនាករថ្មីៗឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងអនុសាសន៍ណែនាំរបស់សម្តេចធិបតីនាយករដ្ឋមន្ត្រី ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រនេះក្លាយជាឯកសាររស់ មានភាពបត់បែន និងឆ្លើយតបបានគ្រប់ជ្រុងជ្រោយតាមគោលនយោបាយពាក់ព័ន្ធនានាដែលរាជរដ្ឋាភិបាលអាចនឹងដាក់ចេញជាបន្តបន្ទាប់នាពេលខាងមុខ។

តារាងម៉ាទ្រីសសូចនាករតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ផ.យ.អ.-ក.ស.ប. ឆ្នាំ ២០២៤-២០២៨ មានធាតុសំខាន់ចំនួន៧ រួមមាន÷

- ឈ្មោះយុទ្ធសាស្ត្រ និងឈ្មោះកម្មវិធី
- សូចនាករគន្លឹះ
- ការវាស់វែង និងប្រភពទិន្នន័យ
- ឯកតា
- ឆ្នាំគោល (២០២៣)
- ឆ្នាំអនុវត្ត និងតម្លៃគោលដៅ (២០២៤, ២០២៥, ២០២៦, ២០២៧ និង២០២៨)
- អង្គភាពប្រតិបត្តិ (រួមទាំងលេខកូដយោងឯកសារពាក់ព័ន្ធ), អង្គភាពដែលសរសេរនៅខាងលើគេ គឺជាអង្គភាពទទួលខុសត្រូវដឹកនាំសម្របសម្រួលអនុវត្ត និងរាយការណ៍)។

សូចនាករសមិទ្ធកម្មគន្លឹះនីមួយៗ បានកំណត់អំពីការវាស់វែង ប្រភពទិន្នន័យ បន្ទាត់មូលដ្ឋាន តម្លៃនិងឆ្នាំគោលដៅច្បាស់លាស់។ សូចនាករសមិទ្ធកម្មគន្លឹះ ភាគច្រើន បានឆ្លើយតប និង/ឬត្រូវបានបន្សុីគ្នាជាមួយនឹងសូចនាករឬសកម្មភាពដែលបានកំណត់នៅក្នុងគោលនយោបាយជាតិ និងអន្តរជាតិពាក់ព័ន្ធ ដូចជា យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, អនុសាសន៍ទាំង១០ចំណុចរបស់សម្តេចធិបតី, គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម, ស្តង់ដាឬលក្ខខណ្ឌរបស់អង្គការអន្តរជាតិខាងការងារ (ILO) ជាដើម។

### ៥.៤. ក្របខណ្ឌអនុវត្ត និងយន្តការសម្របសម្រួល ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ឆ្នាំ ២០២៤-២០២៨ គឺជាទស្សនវិស័យវែងឆ្ងាយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការចូលរួមចំណែកសម្រេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រទាំង៥ របស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដូច្នេះ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព

និងភាពជោគជ័យក្នុងការអនុវត្ត និងការសម្រេចបាននូវក្របខណ្ឌយុទ្ធសាស្ត្រនេះ ចាំបាច់ត្រូវមានការរៀបចំ និងការដាក់ចេញក្របខណ្ឌការងារ និងយន្តការ សម្របសម្រួល ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដ៏ច្បាស់លាស់មួយ។

ដើម្បីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រនេះប្រកបដោយស័ក្តិសិទ្ធិភាព ប្រសិទ្ធភាព និងទាន់ពេលវេលា, ក្រសួងនឹងបង្កើតគណៈកម្មការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ ដោយបែងចែកជាអនុគណៈកម្មការបច្ចេកទេសចំនួន ៦ ទទួលបន្ទុកទៅតាមយុទ្ធសាស្ត្រនីមួយៗ រួមមាន ១). អនុគណៈកម្មការបច្ចេកទេសតាមដាន “ការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម”, ២). អនុគណៈកម្មការបច្ចេកទេសតាមដាន “ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឱ្យឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ សេដ្ឋកិច្ចនិងសង្គមឌីជីថល និងសេដ្ឋកិច្ចបៃតង”, ៣). អនុគណៈកម្មការបច្ចេកទេស “តាមដានការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាពនិងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈស្របតាមការវិវត្ត នៃពិភពការងារ”, ៤). អនុគណៈកម្មការបច្ចេកទេសតាមដាន “ការពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព”, ៥). អនុគណៈកម្មការបច្ចេកទេសតាមដាន “ការអភិវឌ្ឍរបបសន្តិសុខសង្គមស្របតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច” និង ៦). អនុគណៈកម្មការបច្ចេកទេសតាមដាន “ការធ្វើទំនើបកម្មស្ថាប័ន និង ការផ្តល់សេវាសាធារណៈនិងសេវាគាំទ្រទូទៅ តាមប្រព័ន្ធឌីជីថល”។ អនុគណៈកម្មការបច្ចេកទេសទាំង៦នេះ ត្រូវបំពេញមុខងារដឹកនាំ និងតាមដានការអនុវត្តយុទ្ធសាស្ត្រអាទិភាពទាំង៦, រៀបចំរបាយការណ៍វឌ្ឍនភាព ព្រមទាំងសហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ ដើម្បីគាំទ្រ និងជំរុញការអនុវត្តវិធានការផែនការយុទ្ធសាស្ត្រ។ សមាសភាព រចនាសម្ព័ន្ធ និងទំនួលខុសត្រូវរបស់គណៈកម្មាធិការ និងអនុគណៈកម្មាធិការខាងលើនឹងត្រូវបានកំណត់ក្នុងប្រកាស ឬសេចក្តីសម្រេចរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។



ហ

# ជំពូកទី ៦
# សេចក្តីសន្និដ្ឋាន

ជារួម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ ជាឧបករណ៍ដ៏ចាំបាច់សម្រាប់ការអភិវឌ្ឍវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រកបដោយចីរភាព និងបរិយាបន្ន និងដើម្បីសម្រេចបាននូវអាទិភាពគោលនយោបាយនានា ដែលរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ បានរំលេចក្នុង យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ ព្រមទាំងក្របខណ្ឌគោលនយោបាយពាក់ព័ន្ធដទៃទៀត ដើម្បីចូលរួមប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចឱ្យបានចក្ខុវិស័យប្រែក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ផែនការយុទ្ធសាស្ត្រនេះ មានវិសាលភាពគ្របដណ្តប់លើទិដ្ឋភាពគ្រប់ជ្រុងជ្រោយ ដោយផ្តោតលើគ្រប់សមាសភាពពាក់ព័ន្ធ ដើម្បីធានាសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅគោលនយោបាយដែលខ្លួនបានកំណត់។ យុទ្ធសាស្ត្រអាទិភាពដែលបានដាក់ចេញ និងរួមចំណែកដល់ការរក្សាបាននូវស្ថិរភាពសង្គម ការអភិវឌ្ឍ ខណៈពេលដែលកម្ពុជាត្រូវសម្របសម្រួលខ្លួនទៅនឹងនិន្នាការប្រែប្រួលនៃសេដ្ឋកិច្ចតំបន់ និងពិភពលោក ជាពិសេស នៅក្នុងបរិការណ៍នៃសកលភាវូបនីយកម្ម បដិវត្តន៍ឧស្សាហកម្ម ៤.០ បច្ចេកវិទ្យាឌីជីថល ទំនាមការនៃនិន្នាការបៃតង និងបម្រែបម្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ច និងទីផ្សារការងារ ដែលជាការវិវឌ្ឍប្រែប្រួលនៃកត្តាផលិតកម្មទាំងក្នុង និងក្រៅប្រទេស ព្រមជាមួយគ្នានេះ ក៏ដើម្បីចាប់យកនូវកាលានុវត្តភាពនានានៃសេដ្ឋកិច្ចសកលផងដែរ។

តាមរយៈនេះ ការដាក់ចេញនូវ ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨ សំដៅផ្តល់នូវក្របខណ្ឌគោលនយោបាយ និងយន្តការមួយជាក់លាក់សម្រាប់ការចូលរួមចំណែកការជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ ការបង្កើតឱកាសការងារប្រកបដោយសមធម៌ និងការពង្រឹងមូលដ្ឋានកំណើនសេដ្ឋកិច្ចថ្មី។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានជំនឿយ៉ាងមុតមាំថា អង្គភាពក្រោមឱវាទក្រសួងទាំងអស់នឹងជំនះនូវរាល់បញ្ហាប្រឈម និងឧបសគ្គទាំងឡាយ ដើម្បីឈានទៅអនុវត្តដោយជោគជ័យ នឹងទទួលបាននូវសមិទ្ធផលគួរជាទីមោទនៈថ្មីថែមទៀត ជូនរាជរដ្ឋាភិបាល ប្រជាជាតិ និងប្រជាជនកម្ពុជា។

ការប្តេជ្ញាយ៉ាងមុតមាំក្នុងការសម្របសម្រួលនិងអនុវត្តន៍ គឺជាមូលដ្ឋាននៃជោគជ័យ ដោយគ្រប់អង្គភាពពាក់ព័ន្ធត្រូវប្រែក្លាយចង្កោមសកម្មភាពដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រនេះ ទៅរៀបចំជាផែនការសកម្មភាពលំអិតសម្រាប់ការអនុវត្តជាក់ស្តែង តាមរយៈការខិតខំបង្កើត និងប្រើប្រាស់ធនធានដែលមានស្រាប់ ព្រមទាំងខិតខំកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក៏ដូចជាត្រូវធ្វើសមាហរណកម្មគ្រប់ជ្រុងជ្រោយនូវតួអង្គពាក់ព័ន្ធសំខាន់ៗ ដើម្បីចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឱ្យសម្រេចបានសមិទ្ធផលផ្លែផ្កាជាវិជ្ជមាន និងប្រកបដោយប្រសិទ្ធភាពខ្ពស់ស្របតាមការរំពឹងទុក។

ដើម្បីធានានូវវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្ត ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨ អង្គភាពគ្រប់កម្រិតក្រោមឱវាទក្រសួងទាំងអស់ ត្រូវច្បិចយកយុទ្ធសាស្ត្រ កម្មវិធី ចង្កោមសកម្មភាព សូចនាករ និងសកម្មភាព

ដែលបានកំណត់ ទៅរៀបចំជាផែនការសកម្មភាពសម្រាប់ការអនុវត្តប្រចាំរបស់អង្គភាព ដើម្បីធានាថា ការអនុវត្តនឹងត្រូវរត់ទៅតាមទិសដៅមួយជាក់លាក់ដែលក្រសួងបានកំណត់ទុកដើម្បីសម្រេចនូវចក្ខុវិស័យ និងគោលបំណងគោលនយោបាយរបស់ក្រសួង។ ជាមួយគ្នានេះ ក្រសួងនឹងបង្កើតនូវយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើផែនការសកម្មភាព ដោយមានការរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យវឌ្ឍនភាពសម្រេចបាន បញ្ហាប្រឈម ធានាវេទយិតភាព និងដាក់ចេញនូវវិធានការអន្តរាគមន៍ដ៏រស់រវើកចាំបាច់នានាជាបន្ទាន់ ដើម្បីជាមូលដ្ឋានកែតម្រូវ និងតម្រង់ទិសសម្រាប់ការអនុវត្តជំហានបន្ទាប់។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងត្រៀមខ្លួនដើម្បីអនុវត្តនូវវិធានការគោល និងសូចនាករគន្លឹះដទៃផ្សេងទៀត ដែលរាជរដ្ឋាភិបាលដាក់ចេញ ដើម្បីធានាសង្គតិភាព និងប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យស្របតាមអាទិភាព នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

# គំនូសបំព្រួញនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍
# វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨



## ឧបសម្ព័ន្ធ ៖ តារាងម៉ាទ្រីសសូចនាករស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨

| | សូចនាករគន្លឹះ | ការវាស់វែង និងប្រភពទិន្នន័យ | ឯកតា | ឆ្នាំគោល ២០២៣ | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | |
| ១ | **ការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម** | | | | | | | | | |
| | ១.ក. កំណើនចំនួនការងារនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ | ចំនួនការងារក្នុងប្រទេសដែលចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ [ប្រភព៖ LACMS] | នាក់ | ១,៧លាន | ១,៩លាន | ២,១លាន | ២,៣លាន | ២,៥លាន | ២,៧លាន | - អង្គភាពស្នូលទទួលបន្ទុកគោលនយោបាយទីផ្សារការងារសកម្ម<br>- អគ្គ.ការងារ<br>(IDP, PS1: SO1: p.30) |
| | ១.ខ. កំណើនចំណែកនៃចំនួនការងារនៅក្នុងវិស័យកម្មន្តសាលក្រៅពីកាត់ដេរ ធៀបនឹងចំនួនការងារសរុបនៅក្នុងវិស័យកម្មន្តសាលនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ | ចំនួនការងារនៅក្នុងវិស័យកម្មន្តសាលក្រៅពីកាត់ដេរ ធៀបនឹងចំនួនការងារក្នុងវិស័យកម្មន្តសាលសរុប គុណនឹង១០០ [ប្រភព៖ LACMS] | % | ១៧,៨ | ១៨,៥ | ១៩,០ | ១៩,៥ | ២០,០ | ២០,៥ | - អង្គភាពស្នូលទទួលបន្ទុកគោលនយោបាយទីផ្សារការងារសកម្ម<br>- អគ្គ.ការងារ<br>(PS1:PG2:Side1:p.60-62)<br>(ASCC:B:ASI.L.090202.X.X) |
| | ១.គ. កំណើនចំណែកនៃចំនួនការងារដែលបង្កើតដោយសហគ្រាសធុនតូច និងមធ្យម ដែលនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ធៀបនឹងចំនួនការងារក្នុង សហគ្រាសធុនតូច និងមធ្យមសរុប និងធៀបនឹងចំនួនការងារសរុបនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ | ចំនួនការងារ ដែលបង្កើតដោយសហគ្រាសធុនតូច និងមធ្យម(កសិកម្ម និងឧស្សាហកម្ម ៥-១៩៩នាក់, សេវាកម្ម និងពាណិជ្ជកម្ម ៥-៩៩នាក់) ធៀបនឹងចំនួនការងារក្នុង SMEs សរុប (ទិន្នន័យជំរឿនសេដ្ឋកិច្ច ២០២២) គុណនឹង១០០ [ប្រភ៖ LACMS សម្រាប់ទិន្នន័យ SMEs ក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ, ជំរឿនសេដ្ឋកិច្ច សម្រាប់ទិន្នន័យ SMEs សរុប] | % | ៦៤,៦ | ៧០,០ | ៧០,៥ | ៧១,០ | ៧១,៥ | ៧២,០ | - អង្គភាពស្នូលទទួលបន្ទុកគោលនយោបាយទីផ្សារការងារសកម្ម<br>- អគ្គ.ការងារ<br>(IDP,PS1:PG3:Side2:p.72-74) |
| | | ចំនួនការងារ ដែលបង្កើតដោយសហគ្រាសធុនតូច និងមធ្យម(កសិកម្ម និងឧស្សាហកម្ម ៥-១៩៩នាក់, សេវាកម្ម និងពាណិជ្ជកម្ម ៥-៩៩នាក់) | % | ៣៥,៤ | ៣៦,០ | ៣៦,៥ | ៣៧,០ | ៣៧,៥ | ៣៨,០ | - អង្គភាពស្នូលទទួលបន្ទុកគោលនយោបាយទីផ្សារការងារសកម្ម<br>- អគ្គ.ការងារ<br>(IDP,PS1:PG3:Side2:p.72-74) |



ញ

| | សូចនាករគន្លឹះ | ការវាស់វែង និងប្រភពទិន្នន័យ | ឯកតា | ឆ្នាំគោល ២០២៣ | ឆ្នាំអនុវត្ត ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | ធៀបនឹងចំនួនការងារសរុប (LACMS)គុណនឹង១០០ [ប្រភ÷ LACMS] | | | | | | | | |
| | ១.ឃ. កំណើនចំណែកនៃចំនួនការងារដែលបង្កើតដោយសហគ្រាស គ្រឹះស្ថាន ដែលមានសញ្ជាតិខ្មែរ ធៀបនឹងចំនួនការងារសរុបនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ | ចំនួនការងារដែលបង្កើតដោយសហគ្រាស គ្រឹះស្ថាន ដែលមានសញ្ជាតិខ្មែរ ធៀបនឹងចំនួនការងារសរុប គុណនឹង ១០០ [ប្រភព÷ LACMS] | % | ៤១,៩ | ៤៣,០ | ៤៤,០ | ៤៥,០ | ៤៦,០ | ៤៧,០ | - អង្គភាពស្នូលទទួលបន្ទុកគោលនយោបាយទីផ្សារការងារសកម្ម<br>- អគ្គ.ការងារ<br>(IDP, NEP) |
| | ១.ង. អត្រានៃចំនួនសហគ្រាស គ្រឹះស្ថាន ដែលរាយការណ៍ពីស្ថានភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម និងអត្រានៃយុវជនសិស្ស និស្សិត ដែលជ្រើសរើសជំនាញ និងមុខរបរស្របតាមទីផ្សារការងារ មានភាពប្រសើរ | អត្រានៃចំនួនសហគ្រាស គ្រឹះស្ថាន បានរាយការណ៍ពីមុខរបរ ឬជំនាញ ដែលពិបាកក្នុងការជ្រើសរើស [ប្រភព÷ អង្កេតស្តីពីតម្រូវការជំនាញរបស់និយោជក] | % | ២៥,៨ | ២៥,៨ | ២៥,៥ | ២៥,០ | ២៤,៥ | ២៤,០ | - អង្គភាពស្នូលទទួលបន្ទុកគោលនយោបាយទីផ្សារការងារសកម្ម<br>- ទ.ជ.ម.ក.<br>- អគ្គ.ការងារ<br>(IDP, NEP) |
